ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា
# ឆ្នាំ២០១០


រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា


## សម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣
## ថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១០


ខែឧសភា ឆ្នាំ២០១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា
# ឆ្នាំ២០១០

**រៀបចំដោយ**

**គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

## សម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣
## ថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១០

**ខែឧសភា ឆ្នាំ២០១០**

# សេចក្ដីថ្លែងអំណរគុណ

ប្រភពព័ត៌មានសំខាន់សម្រាប់រៀបចំរបាយការណ៍ស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនេះ គឺជាព័ត៌មាននៃរបាយការណ៍ ដែលក្រុមការងារបច្ចេកទេសចម្រុះបានផ្ដល់ឱ្យគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រធានក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ មន្ត្រីបង្គោលរបស់ក្រុមការងារ និងប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ ហើយសង្ឃឹមថា របាយការណ៍នេះនឹងផ្ដល់សារៈប្រយោជន៍សម្រាប់កិច្ចការរបស់យើងទាំងអស់គ្នា នាពេលអនាគត ។

ទន្ទឹមនេះដែរ រាជរដ្ឋាភិបាលក៏ថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានបញ្ចូលទិន្នន័យស្ដីពីគម្រោងនិងកម្មវិធីរបស់ខ្លួន ទៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ។ ប្រសិនបើគ្មានការអំណត់ និងកិច្ចសហការល្អពីសំណាក់ដៃគូអភិវឌ្ឍន៍ទេនោះ រាជរដ្ឋាភិបាលនឹងជួបការលំបាកក្នុងការវិភាគព័ត៌មានស្ដីពីបរិមាណធនធានទាំងឡាយរបស់ដៃគូអភិវឌ្ឍន៍ សម្រាប់រៀបចំរបាយការណ៍ជាមិនខាន ។

របកគំហើញក្នុងរបាយការណ៍នេះបានផ្អែកលើសក្ខីកម្មជាក់ស្ដែង ដែលគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាប្រមូលបានសម្រាប់ធ្វើការវិភាគ ។ នៅក្នុងគ្រប់ករណីទាំងអស់ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានធ្វើសុពលភាពទិន្នន័យទាំងឡាយជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ មុននឹងធ្វើការវិភាគលើទិន្នន័យទាំងនេះ ។

# មាតិការឿង

*អារម្ភកថា*

***ខ្លឹមសារសង្ខេបប្រតិបត្តិ*** i-vii

***ជំពូក ១ - សេចក្តីផ្តើម*** 1

គោលដៅចំបងនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០ 1

ការពិនិត្យឡើងវិញអំពីប្រព័ន្ធលើកទឹកចិត្តសម្រាប់លើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ 2

ការពង្រឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ការសម្រេចជោគជ័យនូវកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល 3

រចនាសម្ព័ន្ធ និងរបកគំហើញគន្លឹះនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ ២០១០ 4

***ជំពូក ២ - ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ឆ្នាំ២០០៩-២០១០*** 6

សូចនាករតាមដានរួមគ្នានៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ 6

ការពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូ 7

បណ្តាញក្រុមការងារបច្ចេកទេសចម្រុះ និងយន្តការគាំទ្រ 8

គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ 9

ការតាមដានគម្រោងអាទិភាពសម្រាប់ឆ្លើយតបទៅនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ច 10

ការគ្រប់គ្រងព័ត៌មាន 11

កិច្ចដំណើរការសកលៈ ការអនុវត្តន៍ការប្តេជ្ញានានានៃ «ផែនការសកម្មភាពទីក្រុងអាក្រា» 12

ការវាយតម្លៃកម្រិតសកលនៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស 14

***ជំពូក ៣ - និន្នាការនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍*** 16

និន្នាការនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ 16

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ 17

និន្នាការនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ 20

និន្នាការតាមវិស័យនិងការវិភាជន៍ធនធាន 24

ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមបណ្តាខេត្ត 26

ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស 28

គោលការណ៍នានានៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការៈ សក្តិកម្មនៃការអនុវត្តន៍ 30

ភាពជាម្ចាស់ 30

ការតម្រឹម 34

ទម្រង់ការនានានៃហិរញ្ញប្បទានសហប្រតិបត្តិការ 37

សុខដុមនីយកម្ម 40

ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល 43

គណនេយ្យភាពទ្វេទិស 47

***ជំពូក ៤ - គណនេយ្យភាពទ្វេទិសដោយផ្ដោតលើលទ្ធផល*** 49
គោលការណ៍នៃស្ទូចនាករតាមដានរួមគ្នា 49
វឌ្ឍនភាពក្នុងការអនុវត្តន៍ 50
អាទិភាពក្នុងវិស័យសង្គមកិច្ច 51
អាទិភាពក្នុងវិស័យសេដ្ឋកិច្ច 51
អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ 51
អាទិភាពក្នុងវិស័យអភិបាលកិច្ចនិងអន្តរវិស័យ 51
ការស្វែងយល់ និងការអនុវត្តន៍ទស្សនទានស្ដីពីគណនេយ្យភាពទ្វេទិស 52
វឌ្ឍនភាពសង្ខេបក្នុងការអនុវត្តន៍ស្ទូចនាករតាមដានរួមគ្នា 53
***ជំពូក ៥ - ទិសដៅកម្រិតគោលនយោបាយក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ*** 56
ការបន្ត និងការផ្លាស់ប្តូរក្នុងគោលនយោបាយគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ 57
ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី 59
ការរៀបចំបណ្ដាញការងារ និងចំណេះដឹងផ្នែកគ្រប់គ្រង ដើម្បីពង្រឹងភាពជាម្ចាស់ សមត្ថភាព និងភាពជាដៃគូ 62
ការពង្រឹងការអនុវត្តន៍កម្រិតសកលសម្រាប់កែលំអកិច្ចប្រតិបត្តិក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ 63
ការត្រួតពិនិត្យតាមដានរួមគ្នាស្ដីពីការអនុវត្តន៍គោលនយោបាយ 63
***ជំពូក ៦ - សន្និដ្ឋាន*** 66

------------------

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ : សុក្រិត្យភាពនៃទិន្នន័យ 68-70
ឧបសម្ព័ន្ធទី ២ : តារាងទិន្នន័យបន្ថែម
២-១ ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០០៨ 71
២-២ ការប៉ាន់ស្មានការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ តាមវិស័យ ឆ្នាំ២០០៩ 72
២-៣ ការព្យាករណ៍ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០១០ 73
២-៤ ការប្រើប្រាស់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ១៩៩២-២០១៣ 74
២-៥ ការប្រើប្រាស់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ ឆ្នាំ១៩៩២-២០១៣ 75
២-៦ ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យរដ្ឋ និងមិនមែនរដ្ឋ ឆ្នាំ២០០៧-២០១០ 76
២-៧ ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមខេត្ត-រាជធានី ឆ្នាំ២០០៧-២០១០ 77-78
ឧបសម្ព័ន្ធទី ៣ : ចំណាត់ថ្នាក់តាមវិស័យ និងអនុវិស័យ 79-80
ឧបសម្ព័ន្ធទី ៤ : វឌ្ឍនភាពនៃការអនុវត្តន៍ស្ទូចនាករតាមដានរួមគ្នា 81-96
ឧបសម្ព័ន្ធទី ៥ : វាក្យស័ព្ទប្រើប្រាស់ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ 97-109

------------------

# បញ្ជីតារាង


| | | |
|---|---|---|
| តារាងទី១ : | ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គម្រោងអាទិភាព ឆ្នាំ២០០៩-១០ | 11 |
| តារាងទី២ : | តម្រូវការធនធាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦ - ២០១៣ | 19 |
| តារាងទី៣ : | ការប្រើប្រាស់និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍ ឆ្នាំ២០០៤- ២០១២ | 22 |
| តារាងទី៤ : | ភាពទស្សន៍ទាយជាមុនក្នុងការការប្រើប្រាស់និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការ | 23 |
| តារាងទី៥ : | ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមវិស័យ ឆ្នាំ២០០៤-២០១០ | 25 |
| តារាងទី៦ : | ការគាំទ្រតាមខេត្ត | 27 |
| តារាងទី៧ : | ធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាលសម្រាប់កិច្ចសហប្រតិបត្តិការ និងតាមវិស័យ ឆ្នាំ២០០៨-២០០៩ | 29 |
| តារាងទី៨ : | ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍និងតាមប្រភេទហិរញ្ញប្បទាន ២០០៧-០៩ | 39 |
| តារាងទី៩ : | សូចនាករតាមដានរួមគ្នាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ | 44 |
| តារាងទី១០ : | សង្ខេបវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា | 54 |


------------------

# បញ្ជីគំនូរ


| | | |
|---|---|---|
| គំនូរទី១: | ការប្រើប្រាស់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៤-២០១២ | 17 |
| គំនូរទី២: | Aid per Capita and Aid/GDP ratios | 17 |
| គំនូរទី៣: | ការវិវត្តន៍នៃការវិភាជន៍ធនធានសម្រាប់គាំទ្របណ្តាអាទិភាពនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ | 20 |
| គំនូរទី៤: | ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសរុប ឆ្នាំ១៩៩២-២០១០ | 21 |
| គំនូរទី៥: | ការប្រែប្រួលប្រចាំឆ្នាំក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសរុប ឆ្នាំ២០០៨-២០០៩ | 22 |
| គំនូរទី៦: | និន្នាការតាមវិស័យ | 26 |
| គំនូរទី៧: | ការគាំទ្រតាមបណ្តាខេត្ត | 27 |
| គំនូរទី ៨: | សមត្ថភាព ធាតុចូល និងលទ្ធផល | 33 |
| គំនូរទី៩: | ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១០ | 36 |
| គំនូរទី១០: | ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦ | 37 |
| គំនូរទី១១: | ការប្រើប្រាស់តាមប្រភេទហិរញ្ញប្បទាន | 38 |
| គំនូរទី១២ : | អន្តរកាលឆ្ពោះទៅរកតុល្យភាពកម្រិតខ្ពស់ស្តីពីប្រសិទ្ធភាពនិងលទ្ធផល | 57 |

# អារម្ភកថា

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.ន) បានរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០ សម្រាប់ **វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣** ។ ផ្អែកលើការវិភាគ និងអនុសាសន៍ដែលមានចែងក្នុងរបាយការណ៍លើកទី១ និងលើកទី២ ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានរៀបចំសម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នាខែមិថុនា ឆ្នាំ២០០៧ និងលើកទី២ នាខែធ្នូ ឆ្នាំ២០០៨ របាយការណ៍លើកទី៣នេះ បានធ្វើការបូកសរុបវឌ្ឍនភាព និងវិភាគនិន្នាការនៃកិច្ចសហប្រតិបត្តិការសម្រាប់អភិវឌ្ឍន៍ ព្រមទាំងលើកឡើងនូវកិច្ចប្រឹងប្រែងបន្ថែមទៀតសម្រាប់បន្តពង្រឹងភាពជាដៃគូ ។ ក្នុងស្មារតីនេះ របាយការណ៍លើកទី៣ បានផ្តល់ធាតុចូលសំខាន់ៗសម្រាប់ជម្រុញអនុវត្ត **«យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា - ដំណាក់កាលទី២»** ដែល **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសនៅក្នុងកិច្ចប្រជុំលើកទី១នៃគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨កន្លងមក ។

រយៈពេល ២ ឆ្នាំចុងក្រោយនេះ គឺជាដំណាក់កាលមួយដែលមានបញ្ហាប្រឈមជាច្រើន សម្រាប់ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ ។ ក្នុងបរិការណ៍រួមនៃវិបត្តិសេដ្ឋកិច្ចសកលលោក វេទិកាកំពូលស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ នាខែកញ្ញា ឆ្នាំ២០០៨ បានតម្រូវឱ្យមានកិច្ចប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចឱ្យបាននូវលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ ក្នុងបរិការណ៍ដែលធនធានអន្តរជាតិមានកម្រិត កិច្ចខិតខំប្រឹងប្រែងសម្រាប់បង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនឹងផ្តល់សារៈសំខាន់បន្ថែមទៀត ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ។ របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហ-ប្រតិបត្តិការលើកទី៣នេះបានកត់ត្រាកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ។

របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនេះបានបង្ហាញថា កម្ពុជាមិនទទួលរងឥទ្ធិពលពីការធ្លាក់ចុះហិរញ្ញប្បទានកម្រិតសកលនោះឡើយ ។ ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ឆ្នាំ២០០៩ មានចំនួន ៩៨៩,៥លានដុល្លាអាមេរិក ធៀបនឹង៩៥៥,៦លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៨កន្លងមក ។ នៅក្នុងឆ្នាំ២០១០ រាជរដ្ឋា-ភិបាលសង្ឃឹមថានឹងអាចទទួលហិរញ្ញប្បទានសហប្រតិបត្តិការ ប្រមាណជាង១.០០០លានដុល្លាអាមេរិក ។ ក្នុងស្មារតីនេះ ភាពជាដៃគូបានផ្តល់លទ្ធភាពសម្រាប់កែលំអការផ្តល់សេវាសាធារណៈ ក៏ដូចជាការអភិវឌ្ឍន៍សមត្ថភាពក្នុងបណ្តាការដ្ឋានកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ។ របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនេះបានប្រើប្រាស់ព័ត៌មានប្រាកដប្រជា និងសក្ខីកម្មជាច្រើន ដើម្បីឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃហិរញ្ញប្បទានសហប្រតិ-បត្តិការ សម្រាប់អនុវត្តគោលដៅនៃ «យុទ្ធសាស្ត្រចតុកោណ» ។ ទន្ទឹមនេះ ក៏បានលើកឡើងពីតម្រូវការមួយចំនួន

សម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ឱ្យបន្តអនុវត្តបណ្តាគោលការណ៍នៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីឈានទៅសម្រេចគោលដៅស្តីពីប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិនៃហិរញ្ញប្បទាន ។

របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០នេះ មានសារៈសំខាន់សម្រាប់ជម្រុញតម្លាភាពក្នុងការប្រើប្រាស់ និងធានាគុណប្រយោជន៍នៃហិរញ្ញប្បទានសហប្រតិបត្តិការផងដែរ ។ រាជរដ្ឋាភិបាលបានប្តេជ្ញាផ្សព្វផ្សាយជាសាធារណៈ នូវបណ្តាព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងគម្រោងសហប្រតិបត្តិការ តាមរយៈ «ប្រព័ន្ធព័ត៌មានកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ» ។ របាយការណ៍បានបញ្ជាក់អំពីការអនុវត្តន៍ការប្តេជ្ញារបស់រាជរដ្ឋាភិបាលស្តីពីតម្លាភាព តាមរយៈការគួបផ្សំគ្នារវាងការប្រមូលទិន្នន័យខាងបរិមាណ និងសក្ខីកម្មកម្រិតសកលជាច្រើនទៀត ដើម្បីឆ្លុះបញ្ចាំងពីការចូលរួម និងតួនាទីរបស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។ ខ្ញុំសង្ឃឹមជឿជាក់ថា របាយការណ៍នេះនឹងជម្រុញឱ្យមានការពិភាក្សា សម្រាប់ពង្រឹង និងពង្រីកភាពជាដៃគូព្រមទាំងជម្រុញលើកទឹកចិត្តបន្ថែមទៀត ដើម្បីធានាថាកិច្ចប្រឹងប្រែងរួមគ្នារបស់យើងនៅតែផ្តោតទៅលើគោលដៅរួមក្នុងការឈានទៅសម្រេចលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព និងតម្លាភាព ។

ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីសំដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការ គ.ជ.ន/ក.អ.ក និងជាអគ្គលេខាធិការនៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ព្រមទាំងសហការី ដែលបានរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការដ៏សំខាន់នេះ ។ ខ្ញុំមានជំនឿជឿជាក់យ៉ាងមាំថា របាយការណ៍នេះបានវិភាគដោយផ្អែកលើសក្ខីកម្ម និងបានផ្តល់អនុសាសន៍ជាច្រើន ហើយសង្ឃឹមថា របាយការណ៍នេះពិតជាបានផ្តល់វិភាគទានយ៉ាងថ្លៃថ្លាដល់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ និងសម្រាប់ពិភាក្សានាពេលបន្តបន្ទាប់ក្រោយៗទៀត ។

រាជធានីភ្នំពេញ ថ្ងៃទី ខែឧសភា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**ប្រធានវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣**

**គាត ឈន់**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

## សេចក្តីផ្តើម

របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនេះបានឆ្លុះបញ្ចាំងឱ្យឃើញ អំពីសមិទ្ធផលជាច្រើនដែលបានសម្រេច និងបញ្ហាប្រឈមនានាដែលបានជួបប្រទះនៅក្នុងអំឡុងពេលអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលរបស់រាជរដ្ឋាភិបាល សម្រាប់ឆ្នាំ២០០៦-២០១០ ។ គោលដៅសំខាន់ៗរបស់របាយការណ៍នេះគឺ : ទី១- ការពិនិត្យឡើងវិញអំពីបទពិសោធន៍ដែលទទួលបានក្នុងការអនុវត្តន៍កន្លងមក ពិសេស សម្រាប់ឆ្នាំ២០០៩-២០១០ និងទី២- ការកំណត់ទិសដៅក្នុងពេលអនាគតស្តីពីគោលនយោបាយគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ សក្ខីកម្មដែលបានយកមកប្រើប្រាស់នៅក្នុងរបាយការណ៍នេះបានដកស្រង់ចេញពីប្រភពជាច្រើន ទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតសកល ដែលរួមមានប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ របាយការណ៍របស់ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ និងរបាយការណ៍ស្តីពីការវាយតម្លៃ«សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស» ។

សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសបានកំណត់បញ្ហាចំនួន១១ ស្តីពីរបៀបចាត់ចែងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចុប្បន្ន ដែលបញ្ហាគន្លឹះនិងសំខាន់ជាងគេរួមមានៈ ការពង្រឹងគុណភាពនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងថវិកា ការកែលំអការតម្រឹមជាមួយនឹងបណ្តាអាទិភាពរបស់ប្រទេសនិងប្រព័ន្ធជាតិ ការពង្រឹងគណនេយ្យភាពចំពោះលទ្ធផល កំណែទម្រង់និងការធ្វើឱ្យសាមញ្ញនូវទម្រង់ការនានារបស់ដៃគូអភិវឌ្ឍន៍ និងការពង្រឹងសមត្ថភាពខាងស្ថាប័ន ។ ការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការដើម្បីសម្រេចលទ្ធផលនៃកិច្ចអភិវឌ្ឍន៍តម្រូវឱ្យដោះស្រាយបញ្ហាប្រឈមទាំងនេះ ។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថា ទំនាក់ទំនងរវាងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនិងលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ត្រូវពឹងផ្អែកលើភាពជាម្ចាស់ និងភាពដឹកនាំ ព្រមទាំងការរៀបចំប្រព័ន្ធលាភការសមស្របសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ លើសពីនេះ ក៏ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍សមត្ថភាពនិងការផ្តល់សេវា ព្រមទាំងការបង្កើតប្រព័ន្ធសម្រាប់បង្កើនគុណភាពនៃការតាមដាន និងគណនេយ្យភាពផងដែរ ។

## ***ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ក្នុងឆ្នាំ២០០៩-២០១០***

ការវិវត្តន៍ក្នុងការអនុវត្តន៍របៀបវារៈស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការតម្រូវឱ្យយកចិត្តទុកដាក់ក្នុងការកំណត់សកម្មភាពសមស្របមួយចំនួនតែប៉ុណ្ណោះ ។ អាទិភាពសំខាន់មួយដែលបានអនុវត្ត គឺការលើកកំពស់ភាពដឹកនាំសម្រាប់កសាងកុងសង់ស៊ុស និងការបញ្ចូលការងារស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការទៅក្នុងកម្មវិធីតាមវិស័យ និងកំណែទម្រង់នានា ។ ផ្អែកលើការសម្រេចដើម្បីរៀបចំនិងឯកភាពសូចនាករតាមដានរួមគ្នា ដែលត្រូវផ្សារភ្ជាប់ជាមួយនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់បានកំណត់សកម្មភាព ដែលអាចបែងចែកជា៣ផ្នែកធំៗគឺ : ១- ការពង្រឹងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនិងយុទ្ធសាស្ត្រតាមវិស័យ ។ ២- ការអភិវឌ្ឍន៍សមត្ថភាពនិងការប្រើប្រាស់ប្រព័ន្ធជាតិ និងទី៣- ការជម្រុញកិច្ចប្រតិបត្តិស្តីពីភាពជាដៃគូឱ្យបានល្អប្រសើរ ។ ដោយទទួលស្គាល់ពីភាពស្មុគ្រស្មាញនៃភាពជាដៃគូដែលមានតួអង្គជាច្រើន គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ. ជ. នា/ក. អ. ក) បានអនុវត្តគំនិតផ្តួចផ្តើមមួយស្តីពី «ការបង្កើនប្រសិទ្ធភាពនៃភាពជាដៃគូនៅកម្ពុជា» ដើម្បីសម្របសម្រួលការ

ពង្រឹងភាពជាដៃគូ ។ កិច្ចប្រជុំកម្រិតយុទ្ធសាស្ត្រមួយត្រូវបានរៀបចំនៅខេត្តសៀមរាប នាខែកញ្ញា ឆ្នាំ២០០៩ កន្លងមក ។ កិច្ចប្រជុំនេះបានផ្តល់កាលានុវត្តភាព សម្រាប់អ្នកចូលរួមទាំងអស់បង្កើនការយល់ដឹងអំពីភាពជាដៃគូ ក្នុងការគ្រប់គ្រងពិពិធកម្មនិងការបង្កើតតម្លៃ ។ បណ្តាញក្រុមការងារបច្ចេកទេសចម្រុះបន្តជួបជុំគ្នា សម្រាប់ពង្រឹងទំនាក់ទំនងរវាងគ្នានិងគ្នា ដែលកិច្ចប្រឹងប្រែងទាំងនេះបានជួយបំពេញបន្ថែមឱ្យរចនាសម្ព័ន្ធដែលបានបង្កើតជាផ្លូវការ ។ កិច្ចការនេះក៏បានយកចិត្តទុកដាក់ដល់ការអនុវត្តន៍ការប្តេជ្ញានានានៃ«ផែនការសកម្មភាពទីក្រុងអាក្រា» ដែលផ្តោតទៅលើការពង្រឹងទំនាក់ទំនងជាមួយនឹងអង្គការសង្គមស៊ីវិល ។ គំនិតផ្តួចផ្តើមផ្សេងទៀត រួមមានការបន្តជម្រុញឱ្យប្រើប្រាស់ប្រព័ន្ធជាតិ ។ លើសពីនេះ ក៏មានការសិក្សាមួយដែលរៀបចំដោយសហព័ន្ធអន្តរៈសភា កាលពីខែមិនា ឆ្នាំ២០១០ បានស្នើឱ្យបង្កើនសមត្ថភាពរបស់សភានៅក្នុងការដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចជាតិ ។

សកម្មភាពទាំងអស់នេះគឺជាមូលដ្ឋានសម្រាប់វាយតម្លៃការអនុវត្តន៍«សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស» នៅកម្ពុជា ដែលបានបញ្ជាក់អំពីការផ្លាស់ប្តូរឥរិយាបថនិងផលប្រយោជន៍ស្តីពីលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។ របកគំហើញបឋមនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល មុនពេលមាន«សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស» បានបង្ហាញអំពីការប្តេជ្ញាឥតរាថយរបស់ខ្លួន នៅខណៈដែលឥរិយាបថរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានកំណត់ដោយទម្រង់ការ និងតម្រូវការផ្ទៃក្នុងរបស់ខ្លួន ។ ប្រការនេះបានបង្ហាញអំពីទំនាក់ទំនងរវាងសមត្ថភាពនិងភាពដឹកនាំ ព្រមទាំងអំណាច និងឥទ្ធិពលដែលបានចរិកនៅក្នុងទំនាក់ទំនងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទន្ទឹមនឹងនេះ ក៏មានថាមភាពជាវិជ្ជមានជាមួយនឹងកំណែទម្រង់ស្ថូលរបស់រាជរដ្ឋាភិបាលផងដែរ ។ ប៉ុន្តែ យើងនៅមានកិច្ចការជាច្រើនដែលត្រូវប្រឹងប្រែងដោះស្រាយបន្ថែមទៀត ដើម្បីពង្រឹងប្រព័ន្ធជាតិ ពិសេសការងារថវិកាកម្ម ការតាមដាននិងវាយតម្លៃ ដើម្បីពង្រឹងទំនាក់ទំនងរវាងហិរញ្ញប្បទានសហប្រតិបត្តិការនិងលទ្ធផល ។ ក្នុងស្មារតីនេះ វាក្យស័ព្ទ«ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ» ត្រូវបានលើកមកពិភាក្សាយ៉ាងល្អិតល្អន់ រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តឱ្យបានពេញលេញ ។

## ***និន្នាការក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍***

ថវិកាសរុបដែលបានប្រើប្រាស់ក្នុងឆ្នាំ២០០៩ មានប្រមាណ៩៨៩,៥លានដុល្លាអាមេរិក ពោលគឺកើនឡើងប្រចាំឆ្នាំ ប្រមាណ៣,៥% និងស្មើប្រមាណ៩%នៃផលិតផលក្នុងស្រុកសរុប ។ ហិរញ្ញប្បទានឥតសំណងមានប្រមាណ ២/៣នៃធនធានសរុបដែលបានប្រើប្រាស់ ។ ជប៉ុននៅតែជាដៃគូដែលបានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការច្រើនជាងគេ ចំនួន១៤៨,៤លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៩ កើនឡើង១៨%ធៀបនឹងឆ្នាំមុន ។ ទន្ទឹមនឹងនេះ សាធារណៈរដ្ឋប្រជាមានិតចិន បានផ្តល់ហិរញ្ញប្បទានចំនួន១១៤,៧លានដុល្លាអាមេរិក ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ពោលគឺស្មើនឹង១៣%នៃហិរញ្ញប្បទានសហប្រតិបត្តិការសរុប ហើយបានកើនឡើង២០%ក្នុងមួយឆ្នាំ ។ ការព្យាករណ៍ធនធានហិរញ្ញប្បទានសហប្រតិបត្តិការសរុបមានភាពល្អប្រសើរ ។ ធនធានប្រមាណ៩៣% ដែលបានគ្រោងសម្រាប់ឆ្នាំ២០០៩ នៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានាខែធ្នូ ឆ្នាំ២០០៨ ត្រូវបានប្រើប្រាស់ជាក់ស្តែង ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏យើងសង្កេតឃើញមានអត្រាប្រែប្រួលគួរឱ្យកត់សំគាល់ ក្នុងការផ្តល់ហិរញ្ញប្បទានរវាងបណ្តាដៃគូអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលបានទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ដែលបានផ្តល់ព័ត៌មាន និងបានផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តគម្រោងនិងកម្មវិធីបានទាន់ពេលវេលា ។







*ការប្រើប្រាស់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (លានដុល្លាអាមេរិក)*

| | 2006 | 2007 | 2008 | 2009(ប៉ាន់ស្មាន) USD | % | 2010 (ព្យាករណ៍) |
|---|---|---|---|---|---|---|
| អង្គការសហប្រជាជាតិ (ធនធានផ្ទាល់) | 54 | 58,3 | 68,3 | 74,8 | 7,6 | 95,8 |
| ធនាគារពិភពលោក | 24,5 | 47,5 | 44 | 60,4 | 6,1 | 122,7 |
| មូលនិធិរូបិយវត្ថុអន្តរជាតិ | 83,5 | 0,9 | | | | |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 67,5 | 69,4 | 145,7 | 89,5 | 9 | 124,5 |
| មូលនិធិសកល | 21,9 | 21,1 | 38,6 | 47,9 | 4,8 | 41,2 |
| **អង្គការសហប្រជាជាតិ និងពហុភាគី** | **251,2** | **197,1** | **296,6** | **272,6** | **27,5** | **384,2** |
| បែលហ្សិក | 7,3 | 7,2 | 2,8 | 3,1 | 0,3 | 1,2 |
| ដាណឺម៉ាក | 4,1 | 9,8 | 10,1 | 14,2 | 1,4 | 16,4 |
| ហ្វាំងឡង់ | 4,5 | 5,2 | 6,6 | 6,3 | 0,6 | 1,6 |
| បារាំង | 21,8 | 21,7 | 31,3 | 25,5 | 2,6 | 26,7 |
| អាល្លឺម៉ង់ | 32,4 | 20,7 | 36,5 | 32,5 | 3,3 | 60,2 |
| ហុល្លង់ | 0,1 | 0,1 | 2,2 | 0,7 | 0,1 | 1,2 |
| អេស្ប៉ាញ | 2,8 | 3,5 | 6,5 | 16,8 | 1,7 | 22,9 |
| ស៊ុយអែត | 16 | 17,3 | 15,9 | 22,9 | 2,3 | 26,7 |
| ចក្រភពអង់គ្លេស | 20,7 | 23,7 | 29,6 | 32,5 | 3,3 | 31,6 |
| សហភាពអឺរ៉ុប | 46,5 | 44 | 47,2 | 50,3 | 5,1 | 57,8 |
| **ប្រទេសជាសមាជិកសហភាពអឺរ៉ុប** | **156,1** | **153,2** | **188,6** | **204,8** | **20,7** | **246,3** |
| អូស្ត្រាលី | 22,5 | 29,6 | 31,2 | 23,7 | 2,4 | 36,3 |
| កាណាដា | 7,9 | 12,6 | 17,2 | 13,1 | 1,3 | 7,9 |
| សាធារណរដ្ឋប្រជាមានិតចិន | 53,2 | 92,4 | 95,4 | 114,7 | 11,6 | 100,2 |
| ជប៉ុន | 103,7 | 117,2 | 126,2 | 148,4 | 15 | 104,7 |
| ណូវែលហ្សេឡង់ | 1,7 | 4,5 | 2,8 | 2,7 | 0,3 | 3,3 |
| សាធារណរដ្ឋកូរ៉េ | 13,3 | 31,3 | 33 | 46,5 | 4,7 | 26,5 |
| ស្វីស | 2,4 | 3,6 | 3,9 | 2,8 | 0,3 | 2,8 |
| សហរដ្ឋអាមេរិក | 51 | 58,1 | 55,7 | 56,9 | 5,8 | 61,2 |
| **ដៃគូអភិវឌ្ឍន៍ទ្វេភាគីដទៃទៀត** | **255,7** | **349,4** | **365,5** | **408,8** | **41,3** | **343** |
| អង្គការមិនមែនរដ្ឋាភិបាល (ធនធានផ្ទាល់) | 50,2 | 77,7 | 104,9 | 103,3 | 10,4 | 112,4 |
| **សរុប** | **713,2** | **777,5** | **955,6** | **989,5** | **100** | **1.086** |

ដៃគូអភិវឌ្ឍន៍នៅបន្តយកចិត្តទុកដាក់ផ្តល់ហិរញ្ញប្បទានជាច្រើនសម្រាប់វិស័យសង្គម ដូចជាវិស័យអប់រំ និងសុខាភិបាល ហ៊ីវ/អេដស៍ ប្រមាណជាង៣០%នៃហិរញ្ញប្បទានសរុបក្នុងឆ្នាំ២០០៩ ។ លើសពីនេះ ហិរញ្ញប្បទានសម្រាប់វិស័យដឹកជញ្ជូនក៏កើនឡើងប្រមាណ២០%ក្នុងឆ្នាំ២០០៩ ហើយវិស័យនេះបានក្លាយទៅជាវិស័យមួយដែលទទួលបានហិរញ្ញប្បទានច្រើនជាងគេ ។ រីឯវិស័យកសិកម្មក៏បានទទួលហិរញ្ញប្បទានច្រើនផងដែរ ប្រមាណ ៩១,២ លានដុល្លាអាមេរិក ពោលគឺកើនឡើងប្រមាណ៦០% ។

ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធ«អនឡាញ» សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៩ បានបង្កើនគុណភាពនៃការប្រមូលទិន្នន័យ និងការធ្វើសុពលភាពសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ផ្អែកតាមទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល **ធនធានផ្ទាល់**របស់ពួកគេមានប្រមាណ ១០៣លានដុល្លាអាមេរិកនៅឆ្នាំ២០០៩ ពោលគឺស្មើនឹង១០%នៃហិរញ្ញប្បទានសហប្រតិបត្តិការសរុប ។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថា នៅឆ្នាំ២០០៩ ហិរញ្ញប្បទានសហប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនបានផ្តល់ឱ្យខេត្ត ប្រមាណ២០%នៃហិរញ្ញប្បទានសរុបដែលបានផ្តល់ឱ្យថ្នាក់ក្រោមជាតិ ។ ហិរញ្ញប្បទានភាគច្រើនត្រូវបានប្រើប្រាស់នៅក្នុងវិស័យសង្គមកិច្ច ដោយបានផ្តោតជាសំខាន់លើវិស័យសុខាភិបាល ប្រមាណជាង៣០%នៃធនធានផ្ទាល់ខ្លួន ។ ក្នុងតួនាទីជាដៃគូអនុវត្ត អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិបានគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍បន្ថែមទៀត ប្រមាណ១០០លានដុល្លាអាមេរិកនៅឆ្នាំ២០០៩ ដែលហិរញ្ញប្បទានភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ផ្តល់សេវាសុខាភិបាល ។ លើសពីនេះ ហិរញ្ញប្បទានក៏ត្រូវបានប្រើប្រាស់សម្រាប់វិស័យអភិបាលកិច្ច ពាណិជ្ជកម្ម កសិកម្ម និងអភិវឌ្ឍន៍ជនបទផងដែរ ។

ក្នុងគោលដៅពង្រឹង«**ភាពជាម្ចាស់**» រាជរដ្ឋាភិបាលបានអនុវត្តគំនិតផ្តួចផ្តើមសំខាន់មួយក្នុងឆ្នាំ២០០៩ ។ នោះគឺការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់ឆ្នាំ២០០៩-២០១៣ ដើម្បីតម្រឹមជាមួយនឹង «យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២» និងដើម្បីធានាសង្គតិភាពនៃអាណត្តិកាលជាមួយនឹងរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ គំនិតផ្តួចផ្តើមសំខាន់មួយទៀតដែលកំពុងអនុវត្ត គឺការធ្វើសមាហរណកម្មរវាងថវិកាកម្ម កម្មវិធីវិនិយោគសាធារណៈ និងដំណើរការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់ជាមូលដ្ឋានក្នុងការពង្រឹងការរៀបចំ «ក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម» និងការរៀបចំផែនការកម្មតាមវិស័យ ។ ទន្ទឹមនឹងនេះ ក៏មានបទពិសោធន៍ជាវិជ្ជមានជាច្រើនក្នុងការអនុវត្តន៍គំនិតផ្តួចផ្តើមស្តីពីការពង្រឹងភាពដឹកនាំ និងសមត្ថភាពនៅកម្រិតវិស័យដែរ ។ នោះគឺការរៀបចំយុទ្ធសាស្ត្រតាមវិស័យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាព ដែលជាមូលដ្ឋានសម្រាប់ដៃគូអភិវឌ្ឍន៍នានាបានចូលរួម និងគាំទ្រកិច្ចខិតខំប្រឹងប្រែងដែលដឹកនាំដោយរាជរដ្ឋាភិបាល ។ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានដើរតួនាទីស្នូល ជាចំណុចប្រមូលផ្តុំក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ។ ការត្រួតពិនិត្យឯករាជ្យមួយត្រូវបានធ្វើឡើងនាពាក់កណ្តាលឆ្នាំ២០០៩ ។ របាយការណ៍ឯករាជ្យនេះបានបង្ហាញពីវឌ្ឍនភាពសំខាន់ៗជាច្រើនក្នុងការសម្រេចធាតុចេញ ប៉ុន្តែ ក៏បានបញ្ជាក់ពីឧបសគ្គជាច្រើនក្នុងការឈានទៅសម្រេចលទ្ធផលដោយសារត្រូវពឹងផ្អែកជាច្រើនទៅលើបរិការណ៍ពីខាងក្រៅ ។ ទាំងនេះបានឆ្លុះបញ្ចាំងអំពីបទពិសោធន៍នានា ក្នុងការអនុវត្តន៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ។ យើងត្រូវចងចាំថា«សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស» គឺជាកំណែទម្រង់រយៈពេលវែងរបស់ភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ធានាឱ្យមានការកែប្រែឥរិយាបថដ៏ជ្រាលជ្រៅមួយ ។

ក្របខ័ណ្ឌធនធានដែលត្រូវបានកែសម្រួលក្នុង«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម» គឺជាមូលដ្ឋានបង្អែកដ៏សំខាន់សម្រាប់ដៃគូអភិវឌ្ឍន៍ ដោយសារក្របខ័ណ្ឌនេះបានបង្ហាញពីការតម្រឹមធនធានជាមួយនឹងអាទិភាពនៃកិច្ចអភិវឌ្ឍន៍ជាតិ ។ យោងតាមការប៉ាន់ស្មានតម្រូវការធនធានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហិរញ្ញប្បទានសហប្រតិបត្តិការដែលកម្ពុជាបានទទួល មានប្រមាណ៩៨៩,៥លានដុល្លាអាមេរិក ក្នុងឆ្នាំ២០០៩

នេះ ពោលគឺលើសពីតម្រូវការធនធានដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលមានត្រឹមតែ ៨៤០លានដុល្លាអាមេរិកប៉ុណ្ណោះ ។ ការតម្រឹមជាមួយនឹងបណ្តាអាទិភាពជាតិ មានលក្ខណៈជាវិជ្ជមាន ចាប់តាំងពីការចាប់ផ្តើមអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនាឆ្នាំ២០០៦មក ។ រីឯការប្រើប្រាស់ប្រព័ន្ធជាតិវិញមានវឌ្ឍនភាពតិចតួច ហើយនេះគឺជាការលំបាកសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដើម្បីឈានទៅសម្រេចឱ្យបានតាមការប្តេជ្ញារបស់ខ្លួន ។

គោលដៅចម្បងនៃការពង្រឹង«**សុខដុមនីយកម្ម**» ក្នុងចំណោមដៃគូអភិវឌ្ឍន៍ គឺការគ្រប់គ្រង និងកាត់បន្ថយភាពបែកខ្ញែកក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ។ រាជរដ្ឋាភិបាលមិនបានប្រកាន់យកវិធានការស្តីពី «ការបែងចែកពលកម្ម» ថាជាវិធីសាស្ត្រសមស្របសម្រាប់ដោះស្រាយភាពបែកខ្ញែកឡើយ ។ ប៉ុន្តែ រាជរដ្ឋាភិបាលបានខិតខំជម្រុញ និងពង្រឹង «អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី» ព្រោះអភិក្រមនេះអាចជួយដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងភាពជាម្ចាស់ ការពង្រឹងសមត្ថភាព និងការប្រើប្រាស់ប្រព័ន្ធជាតិ ការផ្សារភ្ជាប់ជាមួយនឹងកំណែទម្រង់សំខាន់ៗ និងការជម្រុញឱ្យប្រើប្រាស់អភិក្រមដោយផ្តោតលើលទ្ធផល ។ របាយការណ៍ស្តីពីការវាយតម្លៃការអនុវត្តន៍ «សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ» នៅកម្ពុជា បានគូសបញ្ជាក់យ៉ាងច្បាស់ពីបញ្ហាប្រឈមក្នុងការអនុវត្តន៍សុខដុមនីយកម្មសម្រាប់បណ្តាដៃគូអភិវឌ្ឍន៍ ។ របាយការណ៍នេះបានបញ្ជាក់ថា ពុំមានវឌ្ឍនភាពគ្រប់គ្រាន់ក្នុងការធ្វើសុខដុមនីយកម្មប្រព័ន្ធរបាយការណ៍ និងនីតិវិធីសម្រាប់តាមដាននិងវាយតម្លៃនៅឡើយ ។ លើសពីនេះ ក្នុងការធ្វើសុខដុមនីយកម្មរបស់ដៃគូអភិវឌ្ឍន៍ របាយការណ៍នេះក៏បានផ្តល់សក្ខីកម្មបន្ថែមទៀតសម្រាប់បញ្ជាក់អំពីបញ្ហាលំបាកនានាសម្រាប់ជម្រុញឱ្យមានការផ្លាស់ប្តូរឥរិយាបថ ។

ការប្រឹងប្រែងក្នុងការអនុវត្តន៍ «**ការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល**» នៅកម្រិតវិស័យបានផ្តោតទៅលើការកំណត់សកម្មភាពមុតស្រួចមួយចំនួន ដែលការចាប់ផ្តើមអនុវត្តអាចផ្តល់នូវលទ្ធផល ។ ភាពប៉ិនប្រសប់របស់ក្រុមកាងារបច្ចេកទេសចម្រុះក្នុងការរំលេចអភិក្រមទាំងនេះទៅក្នុងការងាររបស់ក្រុមការងារ គឺជាឧទាហរណ៍ល្អប្រសើរ សម្រាប់ប្រែក្លាយការងារដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ទៅក្នុងការងារប្រចាំថ្ងៃរបស់ខ្លួន ជាជាងការយល់ថានេះគឺជាការបង្កើតការងារបន្ថែម ។ គំនិតផ្តួចផ្តើមថ្មីៗមួយចំនួននៅកម្រិតវិស័យ ដូចជាកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងការពិនិត្យឡើងវិញអំពីក្របខ័ណ្ឌការងារសម្រាប់តាមដានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្តល់កាលានុ-វត្តភាពសម្រាប់ពង្រឹងប្រព័ន្ធ និងសមត្ថភាព ក្នុងគោលបំណងផ្សារភ្ជាប់ធាតុចេញរបស់គម្រោងជាមួយនឹងលទ្ធផលនៅកម្រិតវិស័យ ។

## គណនេយ្យភាពទ្វេទិស

គំនិតផ្តួចផ្តើមស្តីពី «ការពង្រឹងភាពជាដៃគូឱ្យមានប្រសិទ្ធភាពនៅកម្ពុជា» បានចាក់ឫសយ៉ាងរឹងមាំនៅក្នុងកិច្ចប្រឹងប្រែងជម្រុញអភិក្រមស្តីពី «គណនេយ្យភាពទ្វេទិស» និងបានជម្រុញទស្សនទាននេះឱ្យអនុវត្តបាន ។ យើងទទួលស្គាល់ថា មានដៃគូអភិវឌ្ឍន៍មួយចំនួនប៉ុណ្ណោះដែលបានចូលរួមយ៉ាងពេញលេញក្នុងការអនុវត្តន៍អភិក្រមនេះ ។ ការងារនេះត្រូវអនុវត្តបន្តក្នុងឆ្នាំ២០១០ ដើម្បីបន្តដោះស្រាយទិដ្ឋភាពខាងឥរិយាបថនៃភាពដៃគូ ។ អង្គការសង្គមស៊ីវិលបានចាប់ផ្តើមអនុវត្តគំនិតផ្តួចផ្តើមជាច្រើនដោយផ្អែកលើការប្តេជ្ញានានារបស់ដៃគូអភិវឌ្ឍន៍និងប្រទេស

ដៃគូ ដែលមានចែងនៅក្នុង «ផែនការសកម្មភាពទីក្រុងអាក្រា» ដើម្បី «ពង្រឹងទំនាក់ទំនងបន្ថែមទៀតរវាងដៃគូអភិវឌ្ឍន៍និងប្រទេសដៃគូជាមួយនឹងអង្គការសង្គមស៊ីវិល»។

## គណនេយ្យភាពទ្វេទិសដោយផ្តោតលើលទ្ធផល

សូចនាករតាមដានរួមគ្នានឹងដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹង «ការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍» និង «គណនេយ្យភាពទ្វេទិស» ដែលទាំងនេះគឺជាគោលការណ៍នៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទម្រង់នៃសូចនាករតាមដានរួមគ្នាត្រូវបានកែសម្រួល ដោយផ្តោតជាសំខាន់ទៅលើលទ្ធផល ហើយដោយផ្អែកលើគោលការណ៍ស្តីពី«គណនេយ្យភាពទ្វេទិស» រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ សូចនាករទាំងនេះបានផ្តោតទៅលើទំនាក់ទំនងរវាង «សកម្មភាព- ធាតុចេញ- លទ្ធផល» ដែលត្រូវផ្សារភ្ជាប់កិច្ចដំណើរការការងារជាមួយនឹងការតាមដាន ។ ពិនិត្យជារួម ការអនុវត្តន៍សូចនាករតាមដានរួមគ្នាទាំងអស់ មានវឌ្ឍនភាពគួរជាទីគាប់ចិត្ត ។ ប៉ុន្តែ ក៏ទាមទារឱ្យរក្សាបាននូវកម្រិតប្រឹងប្រែងបច្ចុប្បន្ន ហើយក្នុងករណីខ្លះ ក៏ត្រូវបង្កើនកិច្ចប្រឹងប្រែងបន្ថែមទៀត ។ ការយល់ដឹងឱ្យបានច្បាស់អំពីការជម្រុញលើកទឹកចិត្ត ទាំងបុគ្គល និងទាំងស្ថាប័ន គឺជាប្រការចាំបាច់ ដើម្បីឈានទៅគ្រប់គ្រងផលប្រយោជន៍ផ្សេងៗពីគ្នា សម្រាប់សម្រេចបានលទ្ធផល ។

## ទិសដៅកម្រិតគោលនយោបាយក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ

អនុសាសន៍មួយចំនួននៅក្នុងរបាយការណ៍នេះបានផ្អែកលើតម្រូវការនិងការទទួលស្គាល់អំពីភាពចាំបាច់ក្នុងការអនុវត្តន៍បន្ត ដើម្បីប្រែក្លាយគោលដៅនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសឱ្យទៅជាក្របខ័ណ្ឌដែលមានលក្ខណៈស្របនឹងបរិបទកម្ពុជា ហើយត្រូវផ្តោតលើលទ្ធផល ។ ដោយទទួលស្គាល់តថភាពនៃការបែកខ្ញែកហិរញ្ញប្បទានសហប្រតិបត្តិការ និងសមត្ថភាពមានកម្រិត ការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាទំនោររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងភាពជាម្ចាស់ ការជម្រុញការអភិវឌ្ឍន៍សមត្ថភាពប្រកបដោយចីរភាព និងការធ្វើសមាហរណកម្មធនធានទាំងអស់ទៅក្នុងយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយក្នុងកម្រិតវិស័យសម្រាប់រយៈពេលមធ្យម ។ បន្ថែមលើការងារបច្ចេកទេស យើងចាំបាច់ត្រូវដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹង «ភាពដឹកនាំកម្រិតយុទ្ធសាស្រ្ត» និងភាពជាដៃគូ ព្រមទាំងការបង្កើនសមត្ថភាព ។ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ. ជ. ន/ ក. អ. ក) បានប្តេជ្ញាបន្តផ្តល់ការគាំទ្រដល់បណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ព្រមទាំងបន្តជម្រុញការអនុវត្តន៍ឱ្យបានជោគជ័យ នូវ «ការពង្រឹងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព» ។ សូចនាករតាមដានរួមគ្នា ដែលបានរៀបចំថ្មី ដូចខាងក្រោម ÷

***លទ្ធផល*** **:** សុខដុមនីយកម្មនិងការតម្រឹមក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍បានរួមចំណែកក្នុងការអនុវត្តន៍យុទ្ធសាស្រ្តចតុកោណ- ដំណាក់កាលទី២ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ តាមរយៈការស្តែងចេញជាលទ្ធផលនៅកម្រិតវិស័យ ។

***ធាតុចេញ*** **:** ការកែលំអការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ឬការបង្កើតអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីថ្មីបន្ថែមទៀត ព្រមទាំងភាពជាដៃគូ សម្រាប់អនុវត្តកម្មវិធីតាមវិស័យដោយផ្តោតលើលទ្ធផល អាចកាត់បន្ថយភាពបែកខ្ញែកក្នុងការផ្តល់ហិរញ្ញប្បទាន ព្រមទាំងបង្កើនភាពទស្សន៍ទាយទុកជាមុន ដែលរួមមាន ÷ ផែនការតាមវិស័យ ផែនការប្រតិបត្តិការប្រចាំឆ្នាំ ផែនការយុទ្ធសាស្រ្តថវិកា ការវាយតម្លៃរួមគ្នាអំពីសមត្ថភាព សកម្មភាពរួមគ្នាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការត្រួតពិនិត្យរួមគ្នាស្តីពីវឌ្ឍនភាពដោយផ្តោតលើលទ្ធផល ។

***សកម្មភាពៈ***

១- គ.ជ.នា/ក.អ.ក សម្របសម្រួលបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ (រួមទាំងការបណ្តុះបណ្តាល) ។

២- គ.ជ.នា/ក.អ.ក សម្របសម្រួលការតាមដានវាយតម្លៃស្តីពីសមត្ថភាពនៃក្រុមការងារបច្ចេកទេសចម្រុះ និង ក្រសួងនិងស្ថាប័នតាមវិស័យ ។

៣- គ.ជ.នា/ក.អ.ក ជម្រុញការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងការកសាងសមត្ថភាព ដើម្បីកាត់បន្ថយ ភាពបែកខ្ញែក និងបង្កើនភាពអាចទស្សន៍ទាយទុកជាមុននៃហិរញ្ញប្បទាន ។

៤- គ.ជ.នា/ក.អ.ក បញ្ចប់ និងបន្តតាមដានការងារស្តីពី «ការពង្រឹងភាពជាដៃគូឱ្យមានប្រសិទ្ធភាព» ។

៥- ក្រុមការងារបច្ចេកទេសចម្រុះស្តីពីសុខដុមនីយកម្មនិងភាពជាដៃគូ គឺជាវេទិកាសម្រាប់ក្រុមការងារបច្ចេកទេស ចម្រុះដទៃទៀត ផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹង ។

៦- ក្រុមការងារបច្ចេកទេសចម្រុះស្តីពីសុខដុមនីយកម្មនិងភាពជាដៃគូ ផ្តល់ការគាំទ្រដល់ការសិក្សាស្តីពីការប្រើប្រាស់ ប្រព័ន្ធជាតិ ។

៧- ដៃគូអភិវឌ្ឍន៍បញ្ជាក់ពីការប្តេជ្ញារបស់ខ្លួនក្នុងការអនុវត្តន៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។

## ***សេចក្តីសន្និដ្ឋាន***

ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់យ៉ាងណាក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវ បន្តអនុវត្ត ។ ការត្រួតពិនិត្យឡើងវិញស្តីពីការអនុវត្តន៍គំនិតផ្តួចផ្តើមនានា និងលទ្ធផលដែលបានសម្រេចកន្លងមក បានបញ្ជាក់ថា មានការផ្លាស់ប្តូរនៅកម្រិតបច្ចេកទេស ប៉ុន្តែ ការផ្លាស់ប្តូរនៅក្នុងរបៀបគ្រប់គ្រងហិរញ្ញប្បទាន នៅពុំទាន់មានភាពច្បាស់លាស់នៅឡើយ ។ លក្ខណៈពិសេសរបស់កម្ពុជានៅក្នុងហិរញ្ញប្បទានសហប្រតិបត្តិការ ដូចជាការពឹងផ្អែកលើហិរញ្ញប្បទានសហប្រតិបត្តិការរយៈពេលវែង ភាពទន់ខ្សោយខាងស្ថាប័ន ឥរិយាបថប្រកួត ប្រជែងរបស់ដៃគូអភិវឌ្ឍន៍ និងវប្បធម៌របស់កម្ពុជា ព្រមទាំងធុរៈកិច្ចហិរញ្ញប្បទានសហប្រតិបត្តិការ មិនត្រូវមើល រំលង ឬមើលស្រាលបានឡើយ ។ របកគំហើញដែលផ្តល់តាមរយៈការវិភាគនៅកម្ពុជាក៏មានលក្ខណៈស្របជាមួយ នឹងរបកគំហើញកម្រិតសកលដែរ ហើយបានគូសបញ្ជាក់ថា ការផ្លាស់ប្តូរក្នុងការផ្តល់និងការគ្រប់គ្រងហិរញ្ញ- ប្បទានសហប្រតិបត្តិការមិនមែនជាកិច្ចការងាយស្រួលឡើយ ។ វិធានការបន្ទាន់ដែលត្រូវអនុវត្តគឺ ការពង្រឹង កម្មវិធីតាមវិស័យ និងការដ្ឋានកំណែទម្រង់នានា ដែលអាចពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ដោយផ្តោត លើការអភិវឌ្ឍន៍សមត្ថភាព ។ លើសពីនេះ ក៏ត្រូវទទួលយកនូវទស្សនវិស័យរយៈពេលវែងស្តីពីការផ្លាស់ប្តូរមួយ ដែលទទួលស្គាល់អំពីភាពស្មុគ្រស្មាញ និងសាំញ៉ាំ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាបន្តធ្វើការជាមួយ នឹងដៃគូអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខទាំងនេះ ។

---------------

# ជំពូក ១
# សេចក្តីផ្តើម

យោងតាមសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០០៥ ការអនុវត្តន៍«ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល» សម្រាប់រយៈពេល៥ឆ្នាំរបស់រាជរដ្ឋាភិបាលនឹងត្រូវបញ្ចប់នាខែធ្នូ ឆ្នាំ២០១០ខាងមុខនេះ ។ របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានរៀបចំសម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ នាខែមិថុនា ឆ្នាំ២០១០ នេះ នឹងផ្តល់កាលានុវត្តភាពសម្រាប់បង្ហាញអំពីសមិទ្ធផលដែលសម្រេចបានក្នុងការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងលើកឡើងនូវបញ្ហាប្រឈមដែលនៅសេសសល់ ។ គោលបំណងនៃការឆ្លុះបញ្ចាំងនេះ គឺការដកស្រង់បទពិសោធន៍នៃការអនុវត្តន៍ដើម្បីជាមូលដ្ឋានសម្រាប់កំណែទម្រង់ការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់ជម្រុញការអនុវត្តន៍តាមអភិក្រមអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។ ផ្អែកលើការយល់ដឹងទាំងអស់នេះ បទពិសោធន៍នឹងអាចផ្តល់អនុសាសន៍ល្អៗសម្រាប់ការពិភាក្សាកម្រិតគោលនយោបាយ និងសម្រាប់កំណត់ទិសដៅនាពេលអនាគតក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ។

## ***<u>គោលដៅចំបងនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០</u>***

របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០ មានគោលដៅចំបងពីរ គឺ:

១- *ការពិនិត្យឡើងវិញនូវមេរៀននិងបទពិសោធន៍នៃការអនុវត្តន៍* : ការពិនិត្យនឹងផ្តោតជាសំខាន់លើការអនុវត្តន៍ចាប់ពីវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២នាខែធ្នូ ឆ្នាំ២០០៨មក ។ ប៉ុន្តែដើម្បីយល់ឱ្យបានកាន់តែច្បាស់លាស់ ក៏បានឆ្លុះបញ្ចាំងការអនុវត្តន៍ចាប់ពីឆ្នាំ២០០៦ នៅពេលដែលកម្ពុជាបានចាប់អនុវត្ត «ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល» និង «សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស» ។

២- *កំណត់ទិសដៅអនាគតក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ* : ដោយប្រើប្រាស់សក្ខីភាពជាក់ស្តែងនៃការវិវឌ្ឍន៍នៃកិច្ចប្រតិបត្តិការហិរញ្ញប្បទានសហប្រតិបត្តិការ និងឥទ្ធិពលនៃហិរញ្ញប្បទាននេះក្នុងកិច្ចអភិវឌ្ឍន៍ យើងអាចពិនិត្យឃើញអំពីការរួមចំណែករបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តន៍របៀបវារៈនយោបាយកម្រិតសកល និងកម្រិតជាតិ ដើម្បីសម្រេចឱ្យបាននូវអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។

ផ្អែកតាមបទពិសោធន៍ជាក់ស្តែងសំខាន់ៗ និងការប្រមើលមើលទៅអនាគតនៃការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរយៈកន្លងមក របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការលើកនេះនឹងលើកបង្ហាញអំពីបទពិសោធន៍សំខាន់ៗទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតសកល ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ នៅតែជាប្រភពទិន្នន័យចំបងនិងសំខាន់នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ លើសពីនេះ ក៏បន្ថែមដោយរបាយការណ៍ខាងគុណភាព ដែលផ្តល់ដោយក្រុមការងារ

បច្ចេកទេសចម្រុះទាំង១៩ និងរបាយការណ៍ស្តីពីការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជា និងបណ្តាសុន្ទរកថាគន្លឹះរបស់ថ្នាក់ដឹកនាំកំពូលរបស់រាជរដ្ឋាភិបាល ព្រមទាំងរបកគំហើញនៃការសិក្សាស្រាវជ្រាវមួយចំនួនដែលរៀបចំដោយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។ ទន្ទឹមនឹងការអនុវត្តន៍ «សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស» កម្រិតសកលអស់រយៈពេលជិត៥ឆ្នាំ កម្ពុជាក៏បានទទួលរបាយការណ៍និងការសិក្សាកម្រិតអន្តរជាតិជាច្រើនដែលសមស្របនឹងបរិការណ៍កម្ពុជាផងដែរ ។

មុននឹងពិនិត្យសកម្មភាពស្តីពីប្រសិទ្ធិភាពហិរញ្ញប្បទានសហប្រតិបត្តិការ យើងត្រូវពិនិត្យឡើងវិញនូវប្រព័ន្ធលើកទឹកចិត្តដំបូងសម្រាប់អនុវត្តកិច្ចការងារទាំងអស់នេះជាមុនសិន ។ ទោះបីជាសហគមន៍ដៃគូអភិវឌ្ឍន៍អន្តរជាតិបានបង្ហាញពីលទ្ធផលនៃការខំប្រឹងប្រែងរបស់ខ្លួនក្នុងទសវត្សរ៍ឆ្នាំ៩០ក៏ដោយ ក៏វេទិកាកំពូលលើកទី១ត្រូវបានប្រារព្ធឡើង នាឆ្នាំ២០០៣ ហើយបានចេញសេចក្តីថ្លែងការណ៍ទីក្រុងរ៉ូមស្តីពីសុខដុមនីយកម្ម ។ បន្ទាប់មកក៏មានសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនាឆ្នាំ២០០៥ ដែលមានទស្សនវិស័យទូលំទូលាយ ដោយរួមបញ្ចូលបណ្តាប្រទេសជាដៃគូ និងអង្គការសង្គមស៊ីវិលខ្លះៗចូលរួម និងបានពិចារណាអំពីទិដ្ឋភាពទូទៅនៃការគ្រប់គ្រងហិរញ្ញប្បទាន បន្ថែមលើការងារសុខដុមនីយកម្មរបស់ដៃគូអភិវឌ្ឍន៍ ។

## ***ការពិនិត្យឡើងវិញអំពីប្រព័ន្ធលើកទឹកចិត្តសម្រាប់លើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ***

សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស (កថាខណ្ឌទី៣និងទី៤) បានកំណត់បញ្ហាប្រឈមចំនួន១១ ក្នុងការគ្រប់គ្រងហិរញ្ញប្បទាននាពេលបច្ចុប្បន្ននេះ ។ ការឆ្លុះបញ្ចាំងបញ្ហាប្រឈមទាំងនេះបានក្លាយជាកត្តាគន្លឹះ សម្រាប់វាស់ស្ទង់ភាពជោគជ័យនៅកម្ពុជាចាប់តាំងពីឆ្នាំ២០០៥ និងឆ្លុះបញ្ចាំងបណ្តាបញ្ហាប្រឈមនានាដែលត្រូវបន្តដោះស្រាយ ហើយដែលបញ្ហាប្រឈមទាំងនេះស្ថិតនៅក្រៅក្របខ័ណ្ឌនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតសកល ។ បញ្ហាប្រឈមសំខាន់ៗដែលជម្រុញឱ្យមានការយកចិត្តទុកដាក់ពីបណ្តាប្រទេសជាដៃគូ និងភ្នាក់ងារអនុវត្ត ព្រមទាំងដៃគូអភិវឌ្ឍន៍ប្រមាណជាង១០០ ដែលជាហត្ថលេខីនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស រួមមាន ÷

១- ពង្រឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងថវិការបស់ប្រទេសជាដៃគូ

២- ពង្រឹងការតម្រឹមក្នុងការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ទៅនឹងអាទិភាពជាតិ និងការប្រើប្រាស់ប្រព័ន្ធជាតិដោយផ្តោតលើការកសាងសមត្ថភាព

៣- បង្កើនគណនេយ្យភាពក្នុងកិច្ចអភិវឌ្ឍន៍ ចំពោះប្រជាពលរដ្ឋ និងសភា

៤- លុបបំបាត់កិច្ចប្រឹងប្រែងត្រួតគ្នា និងធ្វើសនិទានកម្មលើសកម្មភាពការងាររបស់ដៃគូអភិវឌ្ឍន៍

៥- កំណែទម្រង់ និងកែសម្រួលនីតិវិធីនៃការផ្តល់ហិរញ្ញប្បទាន ដើម្បីជម្រុញកិច្ចសហការ និងការតម្រឹម

៦- កំណត់និងអនុវត្តស្តង់ដាររួមគ្នា និងគណនេយ្យភាព (កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងលទ្ធកម្ម ។ល។)

៧- ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់រៀបចំនិងអនុវត្តយុទ្ធសាស្ត្រដោយផ្តោតលើលទ្ធផល

៨- ធានានូវភាពដែលអាចទស្សន៍ទាយជាមុន និងការសន្យាផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការពហុឆ្នាំ របស់ដៃគូអភិវឌ្ឍន៍

៩- បង្កើនការធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់មន្ត្រីរបស់ដៃគូអភិវឌ្ឍន៍នៅតាមប្រទេសជាដៃគូ និងពិនិត្យប្រព័ន្ធលាភការដើម្បីជម្រុញកិច្ចសហការ

១០- ធ្វើសមាហរណកម្មកម្មវិធីសកល និងកម្មវិធីគ្រប់គ្រងតាមរយៈខ្សែរយៈទទឹង ព្រមទាំងគំនិតផ្តួចផ្តើមនានា

១១- ពិនិត្យបញ្ហាតម្លាភាព និងអំពើពុករលួយ

## ***ការពង្រឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ការសម្រេចជោគជ័យនូវកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល***

បញ្ហាប្រឈមកម្រិតសកលទាំង ១១ ត្រូវបានអនុវត្តក្នុងបរិបទកម្ពុជា ដោយបានរំលេចទៅក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល សម្រាប់ដំណាក់កាលឆ្នាំ២០០៦-២០១០ ។ ទន្ទឹមនេះកម្ពុជាក៏បានយកចិត្តទុកដាក់ដល់ការបង្កើតនិងពង្រឹងទំនាក់ទំនងរវាងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។ សកម្មភាពមានអត្ថន័យខ្ពស់ ប្រសិនបើអាចសម្រេចនូវលទ្ធផលខ្ពស់ ។ ក្នុងបរិបទកម្ពុជា នេះគឺការអនុវត្តន៍ឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងយុទ្ធសាស្ត្រតាមវិស័យ និងការដ្ឋានកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ។

របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការកន្លងមក បានបញ្ជាក់អំពីទំនាក់ទំនងរវាងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ដូចរៀបរាប់ដោយសង្ខេបខាងក្រោម ÷

- *ភាពជាម្ចាស់និងភាពដឹកនាំ* : សក្ខីភាពទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតសកល បានបង្ហាញយ៉ាងច្បាស់ថាទំនាក់ទំនងដោយផ្ទាល់រវាងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល បានស្តែងចេញតាមរយៈការបង្កើតភាពពហុដៃគូជាមួយភាគីពាក់ព័ន្ធ ដោយត្រូវគោរព និងលើកតម្កើងភាពជាម្ចាស់របស់កម្ពុជា និងទំនាក់ទំនងប្រកបដោយជវភាព ។
- *គោលនយោបាយ ការងារផែនការកម្ម និងការគ្រប់គ្រងធនធាន* : ភាពជាដៃគូដ៏រឹងមាំ ការឯកភាពលើកម្មវិធីអភិវឌ្ឍន៍ និងការគ្រប់គ្រងព័ត៌មានស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ បានផ្តល់លទ្ធភាព និងសមត្ថភាព ក្នុងការធ្វើសមាហរណកម្មរវាងគោលនយោបាយ ផែនការកម្ម និងថវិកាកម្ម ។ លើសពីនេះទៀត ក៏អាចផ្តល់កាលានុវត្តភាពសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្វែងយល់រួមគ្នា និងបង្កើតគំនិតច្នៃប្រឌិតថ្មីៗបន្ថែមទៀត ។
- *លាភការនិងការលើកទឹកចិត្ត* ÷ ចំពោះកម្ពុជា លទ្ធភាពក្នុងការកំណត់គោលដៅអភិវឌ្ឍន៍ជាតិ និងទិសដៅនៃការអភិវឌ្ឍន៍ គឺជាអាទិភាពចំបង ។ ចំណែកឯដៃគូអភិវឌ្ឍន៍វិញ ក៏ត្រូវតែថ្លឹងថ្លែងប្រព័ន្ធ

លើកទឹកចិត្តឱ្យបានសមស្រប រវាងការតម្រឹម និងការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍របស់កម្ពុជា និងផលប្រយោជន៍របស់ទីស្នាក់ការកណ្តាលរបស់ខ្លួន ។

- *ការអភិវឌ្ឍន៍សមត្ថភាព* : ហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព គឺជាហិរញ្ញប្បទានដែលគាំទ្រដល់កិច្ចអភិវឌ្ឍន៍ប្រទេស ។ ក្នុងករណីនេះ យើងអាចសន្និដ្ឋានអំពីតួនាទីសំខាន់របស់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍សមត្ថភាព ដែលជាសមាសភាគសំខាន់មួយនៃកិច្ចអភិវឌ្ឍន៍ប្រទេស ។
- *ការផ្តល់សេវាកម្ម* : ហិរញ្ញប្បទានសហប្រតិបត្តិការ បាននិងកំពុងបន្តផ្តល់ការគាំទ្រសម្រាប់សេវាសាធារណៈសំខាន់ៗរបស់រាជរដ្ឋាភិបាល ។ ការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនឹងជម្រុញឱ្យមានកិច្ចសម្របសម្រួលក្នុងការផ្តល់សេវាសាធារណៈក្នុងបរិបទនៃទស្សនទានរយៈពេលវែង សម្រាប់កិច្ចអភិវឌ្ឍន៍សមត្ថភាពប្រកបដោយចីរភាព ។
- *ប្រព័ន្ធតាមដានប្រកបដោយប្រសិទ្ធភាព* : ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានឱ្យកាន់តែប្រសើរ ពិសេសព័ត៌មានស្តីពីការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់តាមដាននិងត្រួតពិនិត្យរួមគ្នា ព្រមទាំងសម្រាប់ដកស្រង់បទពិសោធន៍រួមគ្នា ដើម្បីឈានទៅបង្កើនទំនុកចិត្តរវាងដៃគូពាក់ព័ន្ធទាំងអស់ ។
- *គណនេយ្យភាព* : តម្រូវការក្នុងការកត់ត្រាឱ្យបានច្បាស់លាស់ និងការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានពាក់ព័ន្ធនឹងបរិមាណហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ រួមទាំងការបែងចែកនិងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនោះ គឺជាវិធីសាស្ត្រប្រកបដោយចីរភាព ក្នុងការធានាទំនាក់ទំនងរវាងធាតុចូល និងលទ្ធផល ។

## រចនាសម្ព័ន្ធ និងរបកគំហើញគន្លឹះនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០

របាយការណ៍នេះចាប់ផ្តើមដោយធ្វើការត្រួតពិនិត្យលើគំនិតផ្តួចផ្តើមនៃភាពជាដៃគូ ចាប់ពីវេទិកាសហ-ប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ នាខែធ្នូ ឆ្នាំ២០០៨ ដែលបានឆ្លុះបញ្ចាំងពីដំណើរការ និងដំណាក់កាលនៃការងារដំបូង ។ របាយការណ៍នេះបានបង្ហាញអំពីតម្រូវការចាំបាច់នៃជីវភាពរបស់ភាពជាដៃគូ ដើម្បីធ្វើសមា-ហរណកម្មការងារពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ទៅក្នុងរបៀបវារៈកំណែទម្រង់នានាដោយផ្តោតលើលទ្ធផល ។ ការពិនិត្យអំពីនិន្នាការទូទៅនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ បានបង្ហាញពីវឌ្ឍនភាពក្នុងការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការទៅនឹងអាទិភាពអភិវឌ្ឍន៍ជាតិ និងក្នុងការដោះស្រាយភាពបែកខ្ញែកនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ។ ប៉ុន្តែ ការពិនិត្យនេះឆ្លុះបញ្ចាំងឱ្យឃើញអំពីការងារសេសសល់ជាច្រើនទៀតដែលត្រូវប្រឈមដោះស្រាយ ប្រសិនបើការពង្រឹងកិច្ចប្រតិបត្តិការល្អៗស្តីពីការគ្រប់គ្រងត្រូវបានឆ្លុះបញ្ចាំងទៅក្នុងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។ នេះជាគោលដៅនៃជំពូកបន្ទាប់ ដែលផ្តោតទៅលើបញ្ហាគណនេយ្យភាពទ្វេទិស តាមរយៈសូចនាករតាមដានរួមគ្នា ដើម្បីបង្ហាញអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍សកម្មភាពដែលបានឯកភាពរួមគ្នា ក៏ដូចជាដោះស្រាយបញ្ហាប្រឈមនៃភាពជាដៃគូ សម្រាប់គាំទ្រដល់លទ្ធផលនានាដែលសម្រេចបានប្រកបដោយចីរភាព ។ ទិសដៅកម្រិតគោលនយោបាយ និងសេចក្តីសន្និដ្ឋាន បានផ្តល់

សក្ខីភាពជាក់ស្តែង ដើម្បីលើកឡើងនូវអនុសាសន៍នានាសម្រាប់ពិនិត្យរួមគ្នាអំពីការប្តេជ្ញាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងដំណាក់កាលក្រោយអនុវត្តផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។

របាយការណ៍នេះបញ្ជាក់ថា ស្ថិតក្នុងបរិការណ៍នៃកលិយុគសេដ្ឋកិច្ចសកលលោក ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់កម្ពុជានៅតែរក្សាបានក្នុងកម្រិតដូចបណ្តាឆ្នាំកន្លងមក ។ កិច្ចប្រឹងប្រែងសម្រាប់ធានាប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនេះ តម្រូវឱ្យយកចិត្តទុកដាក់ក្នុងការអនុវត្តន៍តាមកិច្ចប្រតិបត្តិការល្អៗ និងការបន្តធ្វើសមាហរណកម្មគោលការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ទៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនេះ ក៏មានសក្ខីភាពជាក់ស្តែងមួយចំនួនដែលតម្រូវឱ្យមានកំណែទម្រង់ខាងស្ថាប័នរបស់ដៃគូអភិវឌ្ឍន៍ ទើបអាចប្រែក្លាយការប្តេជ្ញាទាំងនោះឱ្យទៅជាសកម្មភាពជាក់ស្តែងសម្រាប់អនុវត្តនៅកម្រិតប្រទេស ។ អនុសាសន៍នៃរបាយការណ៍បានផ្អែកលើមូលដ្ឋាននៃការស្វែងយល់ និងការបង្កើតកាលានុវត្តភាពសម្រាប់វឌ្ឍនភាព ព្រមទាំងតថភាពក្នុងទំនាក់ទំនងនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានជម្រុញឱ្យមានកំណែទម្រង់ជាវិជ្ជមានក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ក៏ដូចជាយន្តការគ្រប់គ្រងហិរញ្ញប្បទានទាំងនេះផងដែរ ។ វឌ្ឍនភាពទាំងនេះរួមមាន ៖ ការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងការជម្រុញជវភាពនៃភាពជាដៃគូ ។ ការជម្រុញថាមភាពរវាងការអភិវឌ្ឍន៍សមត្ថភាព និងភាពជាម្ចាស់ គឺជាប្រធានបទស្នូលនៃរបាយការណ៍នេះ ។

---------------

# ជំពូក ២
# ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ឆ្នាំ ២០០៩- ២០១០

របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ បានផ្តល់អនុសាសន៍កម្រិតគោលនយោបាយមួយចំនួនសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តរៀងៗខ្លួនផង និងសម្រាប់អនុវត្តរួមគ្នាផង ។ ផ្អែកលើរបាយការណ៍វាយតម្លៃឆ្នាំ២០០៨ស្តីពីការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងរបាយការណ៍ស្តីពីការវាយតម្លៃឯករាជ្យ អនុសាសន៍បានផ្តោតលើសកម្មភាពមុតស្រួចមួយចំនួន ដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្រិតវិស័យ ។ លើសពីនេះ ផ្អែកតាម «ផែនការសកម្មភាពទីក្រុងអាក្រា» ដែលបានចុះហត្ថលេខាកាលពីខែកញ្ញា ឆ្នាំ២០០៨ អាទិភាពរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នៅកម្ពុជា គឺការឯកភាពគ្នាលើសកម្មភាពគន្លឹះនានាដែលពាក់ព័ន្ធនឹងកម្មវិធីអភិវឌ្ឍន៍តាមវិស័យនិងកំណែទម្រង់ស្ថាប័នរបស់រាជរដ្ឋាភិបាល ព្រមទាំងការឆ្លុះបញ្ចាំងការងារដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្ប-ទានសហប្រតិបត្តិការទៅក្នុងបណ្តាកម្មវិធីអាទិភាពទាំងនោះ ។ ក្នុងស្មារតីនេះ វិធានការកម្រិតបច្ចេកទេស និងវិធានការដែលពាក់ព័ន្ធនឹងភាពដឹកនាំ សម្រាប់ពង្រឹងភាពជាដៃគូ គឺជាអនុសាសន៍កម្រិតគោលនយោបាយសំខាន់ៗនៃរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ ។ សំណើលើកឡើងស្តីពីទិសដៅការងារនាពេលអនាគត ត្រូវបានទទួលការស្វាគមន៍ពីអ្នកចូលរួមនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ ។ សំណើទាំងនេះគឺជាការចង្អុលទិសការងាររបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងនិងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍សម្រាប់ដំណាក់កាលឆ្នាំ២០០៩ រហូតដល់ពាក់កណ្តាលឆ្នាំ២០១០ នេះ ។ ក្នុងរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០ ជំពូកទី២នេះនឹងរំលេចអំពីគំនិតផ្តួចផ្តើមនិងសកម្មភាពនានាដែលបានអនុវត្តចាប់ពីចុងឆ្នាំ២០០៨ ដើម្បីឆ្លុះបញ្ចាំងអំពីកម្រិតប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែង និងសកម្មភាពនានាដែលភាគីទាំងសងខាងបានឯកភាពអនុវត្តនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ ។

## *សូចនាករតាមដានរួមគ្នានៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ*

អនុសាសន៍សំខាន់នៃរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ ២០០៨ បានលើកឡើងថានៅតាមកម្រិតវិស័យនិមួយៗ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវពិភាក្សានិងកំណត់រួមគ្នា នូវសកម្មភាពមួយចំនួនដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនិងសូចនាករសម្រាប់តាមដាន ។ លក្ខខ័ណ្ឌវិនិច្ឆ័យសម្រាប់ជ្រើសរើសសកម្មភាពទាំងនេះគឺត្រូវកំណត់សកម្មភាពជាក់ស្តែង និងអាទិភាពខ្ពស់ ដែលទាមទារឱ្យមានការខិតខំរួមគ្នារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ហើយត្រូវផ្សារភ្ជាប់ទៅនឹងលទ្ធផលដែលត្រូវអនុវត្តឱ្យបានសម្រេច ក្នុងក្របខ័ណ្ឌនៃសមត្ថភាពនិងធនធានដែលមាន ។ បន្ទាប់ពីវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ រួចមក មន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនិងប្រធានក្រុមការងារបច្ចេកទេសចម្រុះបានប្រជុំពិភាក្សាគ្នា ដើម្បីពិនិត្យឡើងវិញនូវការប្តេជ្ញាកម្រិតជាតិ និងកម្រិតសកលដែលមានស្រាប់ ហើយបានប្រើប្រាស់ការប្តេជ្ញាទាំងនេះ

នៅក្នុងបរិបទកម្ពុជា និងវិស័យ ដើម្បីរៀបចំជម្រើសនានាសម្រាប់រំលេចសកម្មភាពនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមកម្រិតវិស័យ ។ សកម្មភាពសំខាន់ៗបីត្រូវបានផ្តោតការយកចិត្តទុកដាក់÷

១- ការពង្រឹងនិងការបង្កើតអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងយុទ្ធសាស្ត្ររបស់វិស័យ

២- ការកសាងសមត្ថភាព និងការប្រើប្រាស់ប្រព័ន្ធជាតិ និង

៣- ការលើកកំពស់ការអនុវត្តន៍ភាពជាដៃគូដោយផ្អែកលើគោលការណ៍នៃគណនេយ្យភាពទ្វេទិស។

ក្រោយកិច្ចពិភាក្សាយ៉ាងផុលផុសរយៈពេលពីរថ្ងៃ អំពីគោលការណ៍សកលក្នុងបរិបទជាតិ យើងបានកត់សំគាល់ថាមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលពុំមានចំណាប់អារម្មណ៍ថា ការបែងចែកពលកម្ម (Division of labor) ដែលបានលើកឡើងក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ ជាមធ្យោបាយដ៏សមស្របសម្រាប់កាត់បន្ថយភាពបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការឡើយ ។ ផ្ទុយទៅវិញ យើងត្រូវគ្រប់គ្រងភាពបែកខ្ញែកនេះ នៅក្នុងបរិបទនៃការពង្រឹងការគ្រប់គ្រងកម្មវិធីតាមវិស័យដែលដឹកនាំដោយរាជរដ្ឋាភិបាលក្នុងការរៀបចំផែនការនៃការប្រើប្រាស់ធនធានទាំងអស់ និងការពង្រឹងសមត្ថភាពសម្រាប់ប្រើប្រាស់ប្រព័ន្ធជាតិ ។ វឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ នឹងត្រូវលើកឡើងក្នុងជំពូកទី៣ ស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផលអភិវឌ្ឍន៍។ ទន្ទឹមនេះ ក៏បានកត់សំគាល់នូវបញ្ហាប្រឈមដូចជា÷១- ការសម្របសម្រួលអន្តរក្រសួង ។២- ការបន្តធ្វើឱ្យប្រសើរបន្ថែមទៀត នូវការតម្រឹមក្នុងការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសនៅតាមវិស័យ មិនមែននៅកម្រិតគម្រោង ឬកម្រិតអាទិភាពនានានោះឡើយ ។ ៣-ការព្រមព្រៀងគ្នាលើទិសដៅជាយុទ្ធសាស្ត្ររវាងភាគីពាក់ព័ន្ធ ។៤- ការបែងចែករវាងអាទិភាព និងការអនុវត្តន៍របស់ដៃគូអភិវឌ្ឍន៍ ។ ៥- ការស្វែងរកធនធានមនុស្សនិងហិរញ្ញវត្ថុ ។ កម្មវិធីតាមវិស័យដែលមានបទពិសោធន៍ក្នុងការអនុវត្តន៍ច្រើនឆ្នាំ ដូចជាវិស័យអប់រំ បានបង្ហាញអំពីកិច្ចប្រតិបត្តិល្អៗក្នុងការគ្រប់គ្រង និងការបង្កើនហិរញ្ញប្បទានរួមគ្នាក្នុងកញ្ចប់តែមួយ (Pooled Funding) ដើម្បីសម្រួលដល់ការរៀបចំធនធាន និងដើម្បីធានាថាធនធានទាំងនោះត្រូវបានប្រើប្រាស់សម្រាប់អភិវឌ្ឍសមត្ថភាពដើម្បីពង្រឹងនិងការប្រើប្រាស់ប្រព័ន្ធជាតិ ។

## ***<u>ការពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូ</u>***

ប្រធានបទទី២ ដែលបានលើកឡើងក្នុងរបកគំហើញនៃរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិ-បត្តិការឆ្នាំ២០០៨ ពាក់ព័ន្ធនឹងថាមវន្តនៃភាពជាដៃគូ ។ គំរូជាទូទៅនៃកិច្ចអភិវឌ្ឍន៍សកល បានសង្កត់ធ្ងន់លើការបំពេញការងារក្នុងភាពជាដៃគូដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ។ ប៉ុន្តែ សម្រាប់កម្ពុជា ភាពបែកខ្ញែកកម្រិតខ្ពស់នៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ បាននាំដល់ស្ថានភាពមួយដែលផលប្រយោជន៍ និងបន្ទាត់គណនេយ្យភាពមានភាពខុសគ្នាៗរវាងដៃគូអភិវឌ្ឍន៍ ។ ការវាយតម្លៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ ក្នុងការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល បានឆ្លុះបញ្ចាំងឱ្យឃើញថាការសម្រេចឱ្យបាននូវគោលដៅនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ មិនមែនជាបញ្ហាបច្ចេកទេសសុទ្ធសាធនោះឡើយ ។ ប៉ុន្តែ វាទាមទារឱ្យពង្រឹងភាពដឹកនាំ និងកែលំអភាពជាដៃគូបន្ថែមទៀត ។ ដោយទទួលស្គាល់អំពីភាពស្មុគ្រស្មាញនៃភាពជាដៃគូក្នុងបរិបទដែលមានភាគីពាក់ព័ន្ធជាច្រើន ទន្ទឹមនឹងសារៈ

សំខាន់នៃភាពជាដៃគូក្នុងការជម្រុញការអនុវត្តន៍ដោយជោគជ័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តួចផ្តើមសកម្មភាពមួយចំនួនសម្រាប់កសាង និងពង្រឹងភាពជាដៃគូ ។ ការផ្តួចផ្តើមនេះរួមមាន៤ដំណាក់កាល : ១- ការពិភាក្សានិងការធ្វើកោសល្យវិច័យ ។ ២- ដំណើរការសម្របសម្រួល ។ ៣- ការគាំទ្រនិងការត្រួតពិនិត្យឡើងវិញ ។ និង ៤- ការត្រួតពិនិត្យចុងក្រោយ និងការធ្វើរបាយការណ៍។ ការងារនេះបានចាប់ផ្តើមនាពាក់កណ្តាលឆ្នាំ២០០៩ ជាមួយនឹងការធ្វើកោសល្យវិច័យមួយចំនួន មុនពេលដែលកិច្ចប្រជុំយុទ្ធសាស្ត្រនៅខេត្តសៀមរាប នាខែកញ្ញា ឆ្នាំ២០០៩កន្លងមក ។ អ្នកចូលរួមដែលបានអញ្ជើញមកពីក្រុមការងារបច្ចេកទេស និងអ្នកសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ បានឯកភាពគ្នាថា កិច្ចប្រជុំនេះបានផ្តល់កាលានុវត្តភាពសម្រាប់បង្កើតការយល់ដឹងអំពីភាពជាដៃគូក្នុងការគ្រប់គ្រងពិពិធកម្មហិរញ្ញប្បទាន និងការបង្កើតទំនាក់ទំនងរវាងភាគីពាក់ព័ន្ធទាំងអស់ក្នុងក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ។ កិច្ចការងារនេះនឹងអនុវត្តក្នុងឆ្នាំ២០១០ បន្តទៀត សម្រាប់ពិនិត្យទិដ្ឋភាពមិនមែនបច្ចេកទេសនៃភាពជាដៃគូ និងការងារតាមវិស័យ ។

## *__បណ្តាញក្រុមការងារបច្ចេកទេសចម្រុះ និងយន្តការគាំទ្រ__*

យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ. ជ. នា/ ក. អ. ក) ដែលបានរៀបចំកាលពីឆ្នាំ២០០៦ បានកំណត់យ៉ាងច្បាស់អំពីអាណត្តិរបស់ គ. ជ. នា/ ក. អ. ក ជា «មជ្ឈមណ្ឌលយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ» និងសម្រាប់សម្របសម្រួលការងាររបស់បណ្តាក្រសួងនិងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ក្នុងតួនាទីជាចំណុចប្រមូលផ្តុំក្នុងការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ។ កិច្ចការនេះបានផ្តោតលើការបង្កើតវប្បធម៌នៃសកម្មភាពការងារ និងការបង្កើនសមត្ថភាពសម្រាប់ឆ្លើយតបទៅនឹងតម្រូវការប្រកបដោយប្រសិទ្ធភាពរបស់បណ្តាក្រសួងនិងស្ថាប័ន ក្រុមការងារបច្ចេកទេសចម្រុះ និងដៃគូអភិវឌ្ឍន៍ ។ បន្ទាប់ពីការបើកវគ្គបណ្តុះបណ្តាលចំនួន២លើក ដល់មន្ត្រីរាជការចំនួន៧០នាក់នៃក្រុមការងារបច្ចេកទេសចម្រុះទាំងអស់នៅប្រទេសហ្វីលីពីន កាលពីឆ្នាំ២០០៧និង២០០៨ កិច្ចខិតខំប្រឹងប្រែងរបស់ គ. ជ. នា/ ក. អ. ក ក្នុងការផ្តល់ការគាំទ្រដល់ការងារដែលពាក់ព័ន្ធនឹងការពង្រឹងបណ្តាញការងារ និងធនធាននៅកម្រិតវិស័យ ។

គំនិតផ្តួចផ្តើមទី១ គឺការបង្កើត «បណ្តាញក្រុមការងារបច្ចេកទេសចម្រុះ» ដែលបានផ្តល់តម្លៃដល់ការប្រាស្រ័យទាក់ទង ដែលអាចបំពេញបន្ថែមទៅលើរចនាសម្ព័ន្ធនៃសេវាកម្មសាធារណៈរបស់រដ្ឋ ។ កិច្ចការនេះបានកសាងទំនាក់ទំនងសម្រាប់ផលប្រយោជន៍រួម និងសម្រាប់សម្រួលការប្រាស្រ័យទាក់ទងគ្នាក្រៅផ្លូវការ និងការចែករំលែកព័ត៌មាន ។ បណ្តាញក្រុមការងារបច្ចេកទេសចម្រុះបានជួបប្រជុំគ្នាពី ២- ៣ដង ក្នុងមួយឆ្នាំដើម្បីពិគ្រោះយោបល់ ឬបណ្តុះបណ្តាល ហើយក៏បានផ្តល់កាលានុវត្តភាពសំខាន់សម្រាប់សិក្សារៀនសូត្រពីគ្នាទៅវិញទៅមក ព្រមទាំងពិភាក្សាអំពីដំណើរការក្នុងការអនុវត្តន៍សកម្មភាពនានាដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ គោលដៅសំខាន់នៃកិច្ចប្រជុំបានផ្តោតទៅលើ÷ សូចនាករតាមដានរួមគ្នា ការអភិវឌ្ឍន៍សមត្ថភាព និងការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេស ការកសាងភាពជាដៃគូ ការកំណត់គោលដៅអាទិភាព អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងកិច្ចសហការអន្តរក្រសួងដែលពាក់ព័ន្ធនឹងបញ្ហាអន្តរវិស័យ ដូចជា យេនឌ័រ

អេដស៍ និងសន្តិសុខស្បៀង ។ ការបណ្តុះបណ្តាលទី២ កាលពីខែវិច្ឆិកា ឆ្នាំ២០០៩ បានផ្តោតទៅលើ «ការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍» (Managing for Results) សម្រាប់បណ្តាញក្រុមការងារបច្ចេកទេសចម្រុះ និងមន្ត្រីនៃលេខាធិការដ្ឋានក្រុមការងារបច្ចេកទេស ព្រមទាំងដៃគូអភិវឌ្ឍន៍ផងដែរ ។ លើមូលដ្ឋាននៃចំណេះដឹងនៃវគ្គបណ្តុះបណ្តាលនេះ យើងបានពិនិត្យនិងកែសម្រួលឡើងវិញនូវទម្រង់នៃសូចនាករតាមដានរួមគ្នា សម្រាប់អនុមតិនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ។ ការកែសម្រួលឡើងវិញនូវទម្រង់នៃសូចនាករតាមដានរួមគ្នា នឹងជួយពង្រឹងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល ។

គំនិតផ្តួចផ្តើមក្នុងការផ្តល់កញ្ចប់ថវិកាប្រមាណ១៥.០០០-២០.០០០ដុល្លាអាមេរិក ដល់លេខាធិការដ្ឋានក្រុមការងារបច្ចេកទេស ដែលដៃគូអភិវឌ្ឍន៍កំពុងបំពេញការងារនៅកម្រិតវិស័យ ហើយមិនមានលទ្ធភាព ឬមិនមានឆន្ទៈផ្តល់ជូន ។ កញ្ចប់ថវិកាត្រូវបានផ្តល់ជូនប្រចាំឆ្នាំសម្រាប់សម្រួលការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ក្រុមការងារបច្ចេកទេសចំនួន ១០ បានទទួលការគាំទ្រក្នុងឆ្នាំ២០០៨ និង២០០៩ សម្រាប់ផ្តល់សម្ភារៈការិយាល័យ ចំណាយក្នុងការរៀបចំកិច្ចប្រជុំ ការងារវិភាគប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការផ្តល់លាភការរហូតដល់ការបញ្ឈប់របស់រាជរដ្ឋាភិបាល ។ គ.ជ.នា/ក.អ.ក បានស្នើដៃគូអភិវឌ្ឍន៍ឱ្យទទួលរ៉ាប់រងថវិកាសម្រាប់ចំណាយទាំងនោះ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏ដៃគូអភិវឌ្ឍន៍បានបញ្ជាក់អំពីជំហរថាអាចផ្តល់ការគាំទ្រក្នុងកម្រិតមួយតែប៉ុណ្ណោះនាឆ្នាំ២០១០ ដោយផ្អែកតាមតម្រូវការរបស់ក្រុមការងារបច្ចេកទេស ។

## ***<u>គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍</u>***

គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានជួបប្រជុំគ្នាចំនួន៣ដងចាប់តាំងពីវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានាចុងឆ្នាំ២០០៨មក ក្រោមការដឹកនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ។ កិច្ចប្រជុំទាំងនោះបានផ្តល់កាលានុវត្តភាពសម្រាប់ត្រួតពិនិត្យឡើងវិញនូវវឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា រួមទាំងសកម្មភាពនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការពិភាក្សាលើបញ្ហារួមដែលពាក់ព័ន្ធនឹងទិដ្ឋភាពសេដ្ឋកិច្ចជាទូទៅ បញ្ហាក្នុងកម្រិតវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម ។ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក៏បានពិភាក្សាលើការងារដែលពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មរវាងការងារផែនការ ការងារថវិកា និងការគ្រប់គ្រងហិរញ្ញប្បទានសហ-ប្រតិបត្តិការ ហើយបានប្រគល់កិច្ចការជូនគណៈកម្មាធិការដែលដឹកនាំដោយក្រសួងផែនការ ។ កិច្ចការនេះមានសារៈសំខាន់មិនត្រឹមតែសម្រាប់អនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសទេ ប៉ុន្តែ សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ ។ គណៈកម្មាធិការនេះបានប្រឹងប្រែងអនុវត្តកិច្ចការរបស់ខ្លួន ដើម្បីធ្វើឱ្យមានសុខដុមនីយកម្ម និងដើម្បីផ្សារភ្ជាប់កំណែទម្រង់ថវិកាក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងកម្មវិធីវិនិយោគសាធារណៈ និងការគ្រប់គ្រងព័ត៌មានស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការដែលគ្រប់គ្រងដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនាមរាជរដ្ឋាភិបាល ។

ការផ្ដល់ការគាំទ្រដល់ការងាររបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គឺក្រុមការងារបច្ចេកទេសស្ដីពីភាពជាដៃគូនិងសុខដុមនីយកម្ម ដែលបានជួបប្រជុំគ្នាចំនួន៣ដង ក្នុងឆ្នាំ២០០៩ និងឆ្នាំ ២០១០ ។ ក្នុងឆ្នាំ២០០៩ ក្រុមការងារបច្ចេកទេសនេះបានផ្ដោតលើការចរចាសូចនាករតាមដានរួមគ្នាស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ការបង្កើនពុទ្ធិស្ដីពី «ការកសាងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព » និងការបណ្ដុះបណ្ដាលស្ដីពីសូចនាករតាមដានរួមគ្នា និងការណែនាំដៃគូអភិវឌ្ឍន៍ឱ្យប្រើប្រាស់អ៊ិនធឺណែតសម្រាប់ប្រព័ន្ធព័ត៌មានស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងឆ្នាំ ២០១០ យើងនឹងវាយតម្លៃការអនុវត្តន៍«សេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីស» ការធ្វើកោសល្យវិច័យក្នុងការប្រើប្រាស់ប្រព័ន្ធជាតិ និងការបន្តពិភាក្សាលើសូចនាករតាមដានរួមគ្នាស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្រិតវិស័យ ។ ក្រុមការងារបច្ចេកទេសស្ដីពីភាពជាដៃគូនិងសុខដុមនីយកម្ម ដែលមានសហអ្នកសម្របសម្រួលជាតំណាងនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងស៊ុយអែតដែលបានជ្រើសរើសថ្មីៗក្នុងឆ្នាំ២០១០នេះ បានឯកភាពបន្តផ្ដោតការយកចិត្តទុកដាក់សំខាន់លើការប្រើប្រាស់ប្រព័ន្ធជាតិ និងការជម្រុញអនុវត្តន៍គោលការណ៍ណែនាំនានាស្ដីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ពីព្រោះកិច្ចការនេះពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍន៍សមត្ថភាព និងការផ្សារភ្ជាប់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការទៅនឹងកំណែទម្រង់សំខាន់ៗ ព្រមទាំងការធ្វើសមាហរណកម្មរវាងការងារផែនការ ការងារថវិកា និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ប្រធានបទរួមរបស់ក្រុមការងារបច្ចេកទេសស្ដីពីភាពជាដៃគូនិងសុខដុមនីយកម្ម គឺការជម្រុញអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលជាមធ្យោបាយមួយសម្រាប់គ្រប់គ្រងភាពបែកខ្ញែកក្នុងការផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការ ការជួយគាំទ្រផ្សេងៗ តាមរយៈការធ្វើសមាហរណកម្មធនធានទាំងអស់ ការសម្របសម្រួល គំនិតផ្ដួចផ្ដើមសម្រាប់ពង្រឹងសមត្ថភាព និងការត្រួតពិនិត្យរួមគ្នាដោយផ្អែកលើលទ្ធផល ។

## ការតាមដានគម្រោងអាទិភាពសម្រាប់ឆ្លើយតបទៅនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ច

ក្នុងការឆ្លើយតបនឹងបញ្ហាប្រឈមទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកសង្គមកិច្ច ដែលជាបច្ច័យអាក្រក់នៃវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលលោក មកលើកម្ពុជា កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នាខែមេសា ឆ្នាំ២០០៩ បានឯកភាពកំណត់ និងតាមដានការអនុវត្តន៍គម្រោងមួយចំនួន ដែលមានសក្ដានុពលខ្ពស់ក្នុងការកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះ ។ លក្ខខ័ណ្ឌវិនិច្ឆ័យត្រូវបានរៀបចំឡើង ដើម្បីកំណត់គម្រោងវិនិយោគសំខាន់ៗដែលគាំទ្រដល់កំណើនសេដ្ឋកិច្ច ពិសេស គម្រោងក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យកសិកម្ម និងគម្រោងសម្រាប់គាំពារជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងគម្រោងពាក់ព័ន្ធនឹងប្រព័ន្ធសុវត្ថិភាពសង្គម ។ គម្រោងចំនួន ៦៨ ដែលមានទំហំហិរញ្ញប្បទានចំនួន ៣៧០លានដុល្លារអាមេរិក ក្នុង ឆ្នាំ២០០៩ ត្រូវបានកំណត់ថាជាគម្រោងអាទិភាពខ្ពស់នៅក្នុងកិច្ចប្រជុំរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នាខែកក្កដា ឆ្នាំ ២០០៩ ។

កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នាខែកញ្ញា ឆ្នាំ២០០៩ បានរាយការណ៍ថា មានហិរញ្ញប្បទានចំនួន៥១% ប៉ុណ្ណោះ ត្រូវបានប្រើប្រាស់នៅក្នុងបីត្រីមាសដំបូងនៃឆ្នាំ២០០៩ ។ ទន្ទឹមនឹងនេះ ក៏បានរាយការណ៍បន្ថែមទៀតថា មានគម្រោងចំនួន២០ក្នុងចំណោមគម្រោងអាទិភាពចំនួន៦៨ អាច

***តារាងទី១ : ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គម្រោងអាទិភាព ឆ្នាំ២០០៩-១០***
***(លានដុល្លាអាមេរិក)***

| | ថវិកា ឆ្នាំ២០០៩ | ប្រើប្រាស់ ឆ្នាំ២០០៩ | % ប្រើប្រាស់ ឆ្នាំ២០០៩ | ថវិកា ឆ្នាំ២០១០ | ប្រើប្រាស់ ឆ្នាំ២០១០ (ប៉ាន់ស្មាន) | % ប្រើប្រាស់ ឆ្នាំ២០១០ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| កំណើនសេដ្ឋកិច្ច | ១៨០,៨ | ១៣៥,០ | ៧៥% | ១៣៦,៦ | ១៧១,៧ | ១២៦% |
| ជីវភាពរស់នៅ | ១២១,២ | ១០០,៣ | ៨៣% | ១១១,៨ | ១០៤,៦ | ៩៤% |
| ប្រព័ន្ធសុវត្ថិភាពសង្គម | ៦៨,២ | ៥២,១ | ៧៥% | ៥៨,៤ | ៥១,០ | ៨៧% |
| **សរុបៈ** | **៣៧០,២** | **២៨៦,៤** | **៧៧%** | **៣០៦,៨** | **៣២៧,៣** | **១០៧%** |

មានលទ្ធភាពពន្លឿនការអនុវត្តន៍បាន ។ លើសពីនេះ ក្រុមការងារបច្ចេកទេសចម្រុះ បានពិភាក្សាជាមួយដៃគូអំពីការអនុវត្តន៍គម្រោងអាទិភាពទាំងនេះ ហើយបានរកឃើញថា ក្នុងករណីខ្លះ បញ្ហារួមនៃការអនុវត្តន៍គម្រោងអាចពាក់ព័ន្ធនឹង (១) ការងារលទ្ធកម្ម (២) ទិដ្ឋភាពច្បាប់និងកិច្ចសន្យា (៣) សមត្ថភាពប្រតិបត្តិគម្រោង និង (៤) មហិច្ឆតាខ្ពស់ក្នុងការរៀបចំផែនការរបស់គម្រោង ។ ការវិភាគបឋម នាដើមឆ្នាំ២០១០ បានសន្និដ្ឋានថា ក្នុងឆ្នាំ២០០៩ ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការមានចំនួន២៨៦,៤ដុល្លាអាមេរិក ស្មើនឹង ៧៧%នៃផែនការវិភាជន៍ធនធាន (៨៣% សម្រាប់សមាសភាគ « *ជីវភាពរស់នៅរបស់ប្រជាជន* ») ។ ការពិភាក្សាបន្តទៀតជាមួយនឹងប្រធានគ្រប់គ្រងគម្រោង នាខែមិនា ឆ្នាំ២០១០ បានបង្ហាញអំពីលទ្ធភាពក្នុងការពង្រឹងទំនាក់ទំនងរវាងគម្រោងវិនិយោគសំខាន់ៗជាមួយនឹងការតាមដាន និងការពិភាក្សារបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ការងារនេះមានការពាក់ព័ន្ធនឹងតម្រូវការទូទៅ ដែលផ្តោតការពិភាក្សារបស់ក្រុមការងារបច្ចេកទេសចម្រុះទៅលើបញ្ហានានាដែលពាក់ព័ន្ធនឹងការអនុវត្តន៍គម្រោង និងការពង្រឹងសមត្ថភាពសម្រាប់អនុវត្តគម្រោងឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ។ ក្នុងឆ្នាំ២០១០ ការព្យាករណ៍ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គម្រោងអាទិភាពទាំងនេះ មានប្រមាណ៣២៧,៣លានដុល្លាអាមេរិក ។

## ***ការគ្រប់គ្រងព័ត៌មាន***

ការតាមដានការអនុវត្តន៍គម្រោងអាទិភាព បានបង្ហាញជាថ្មីម្តងទៀតនូវទំនាក់ទំនងយ៉ាងសំខាន់រវាងការគ្រប់គ្រងព័ត៌មាន និងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ។ កិច្ចការនេះក៏បានអនុវត្តសម្រាប់កិច្ចប្រឹងប្រែងក្នុងការពង្រឹងទំនាក់ទំនងរវាងការងារផែនការ ការងារថវិកា និងការងារគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ក៏ដូចជាការគាំទ្រកម្មវិធីតាមវិស័យ ដើម្បីតម្រឹមធនធានប្រកបដោយចីរភាព និងផ្តោតលើលទ្ធផល ។ ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា ដែលគ្រប់គ្រងដោយ គ.ជ.ន/ក.អ.ក ក្នុងនាមរាជរដ្ឋាភិបាល ត្រូវបានកែលំអរចនាសម្ព័ន្ធព័ត៌មានបន្ថែមក្នុងឆ្នាំ២០០៩-២០១០ ដើម្បីរៀបចំកម្មវិធីវិនិយោគសាធារណៈសម្រាប់វិស័យអប់រំ និងកត់ត្រាចំនួនបេសកកម្ម និងការសិក្សានានា ក្នុងគោលបំណងលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍តាមដាននិងសម្របសម្រួលបេសកកម្ម និងការសិក្សារបស់ខ្លួន ។ ក្នុងឆ្នាំ២០០៩ កន្លងមក

គ.ជ.នា/ក.អ.ក បានដាក់ឱ្យប្រើប្រព័ន្ធព័ត៌មានមួយបន្ថែមទៀត សម្រាប់កត់ត្រាហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានផ្តល់ និងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល (សូមមើលការវិភាគនៅក្នុងជំពូក៣)។

## កិច្ចដំណើរការកម្រិតសកលៈ ការអនុវត្តន៍ការប្តេជ្ញានានានៃ «ផែនការសកម្មភាពទីក្រុងអាក្រា»

បន្ថែមលើការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការរបស់កម្ពុជានៅឆ្នាំ២០០៨ យើងក៏បានជ្រួតជ្រាបបន្ថែមទៀតអំពីលទ្ធផលនៃការងារវិភាគមួយចំនួនសម្រាប់រៀបចំ «ផែនការសកម្មភាពទីក្រុងអាក្រា» និងសេចក្តីថ្លែងការណ៍នៃវេទិកាកំពូលលើកទី៣ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ជាទូទៅ ការប្តេជ្ញាកម្រិតសកល មានការពាក់ព័ន្ធនឹងការបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីអនុវត្តឱ្យបានប្រសើរជាងមុន ចំពោះការសន្យាកន្លងមក ព្រមទាំងបញ្ជាក់សារជាថ្មីឡើងវិញនូវការងារមួយចំនួនដែលមិនទាន់បានអនុវត្តតាមការសន្យាកន្លងមក ហើយដែលតម្រូវឱ្យបញ្ជាក់ម្តងទៀតនៅក្នុង «ផែនការសកម្មភាពទីក្រុងអាក្រា» ។ ការសន្យាទាំងនោះរួមមាន ÷

- <u>បង្កើននិងពង្រឹងទំនាក់ទំនងជាមួយសង្គមស៊ីវិល</u> ៖ បន្ថែមលើគំនិតផ្តួចផ្តើមតាមវិស័យ អង្គការមិនមែនរដ្ឋាភិបាលបានឯកភាពចូលរួមក្នុងកិច្ចចរចាស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ នេះរាប់បញ្ចូលកិច្ចប្រជុំនៅថ្នាក់ខេត្ត សម្រាប់ជំរុញសង្គមស៊ីវិលឱ្យអនុវត្ត «ផែនការសកម្មភាពទីក្រុងអាក្រា» នៅកម្ពុជា ព្រមទាំងបង្កើនការយល់ដឹងកាន់តែទូលំទូលាយអំពីបរិមាណ និងទម្រង់ការនៃការអនុវត្តន៍គម្រោងហិរញ្ញប្បទានរបស់អង្គការមិនមែនរដ្ឋាភិបាល ។ កិច្ចចរចាកំពូលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នាខែមិនា ឆ្នាំ២០១០ បានបញ្ជាក់អំពីសក្តានុពលរបស់អង្គការសង្គមស៊ីវិល ក្នុងការចូលរួម កិច្ចចរចាកម្រិតគោលនយោបាយ ហើយនេះជាការចាប់ផ្តើមដ៏ល្អមួយសម្រាប់បន្តពិភាក្សាលើគំនិតផ្តួចផ្តើមនានាដើម្បីពង្រឹងភាពជាដៃគូ និងការពង្រឹងការចូលរួមរបស់អង្គការសង្គមស៊ីវិលទាំងនេះ ។
- <u>ការប្រើប្រាស់ប្រព័ន្ធជាតិគឺជាជម្រើសទី១</u> ៖ ដោយនេះគឺជាការប្តេជ្ញាគន្លឹះនៃ «ផែនការសកម្មភាពទីក្រុងអាក្រា» ដៃគូអភិវឌ្ឍន៍នៃសហភាពអឺរ៉ុប ដែលសម្របសម្រួលដោយប្រទេសស៊ុយអែត ក្នុងជំហានទីមួយនឹងចាប់ផ្តើមសិក្សាលើប្រព័ន្ធជាតិមួយចំនួន ដើម្បីកំណត់វិធានការណ៍ជាក់លាក់ សម្រាប់ពង្រឹង និងប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាល ។ លទ្ធផលនៃការសិក្សានេះនឹងត្រូវលើកបង្ហាញក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ។
- <u>ការពង្រឹងទំនាក់ទំនងជាមួយរដ្ឋសភា</u> ៖ ការសិក្សាមួយដែលបានគាំទ្រដោយសហភាពអន្តរសភានៅក្នុងឆ្នាំ២០១០ ។ ការសិក្សាបានស្នើអនុសាសន៍ក្នុងការពង្រឹងសមត្ថភាពរបស់សភាសម្រាប់ចូលរួមក្នុងការពិភាក្សានានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចជាតិ ក៏ដូចជាការពង្រឹងទំនាក់ទំនងរវាងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។

ជាទូទៅ កម្ពុជានៅបន្តអនុវត្តការប្តេជ្ញារបស់ខ្លួន ក្នុងការគាំទ្រនិងចូលរួមកិច្ចដំណើរការនៃការអនុវត្តន៍ «ផែនការសកម្មភាពទីក្រុងអាក្រា» ហើយក៏បានចូលរួមចែករំលែក ព្រមទាំងបានដកស្រង់មេរៀនជាច្រើន ដែលទទួលបានពីការចូលរួមនេះ ។ កម្ពុជាបានចូលរួមក្នុងកិច្ចពិភាក្សាកម្រិតសកលចាប់តាំងពីកិច្ចដំណើរការដំបូង

របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) និងបានចូលរួមក្នុងការសិក្សាជាច្រើន សម្រាប់ការរៀបចំវេទិកាកំពូលទាំង៣លើកកន្លងមក (ទីក្រុងរ៉ូមនាឆ្នាំ២០០៣ ទីក្រុងប៉ារីសនាឆ្នាំ២០០៥ និងទីក្រុងអាក្រានាឆ្នាំ២០០៨) ។ ក្នុងឆ្នាំ២០០៩ កម្ពុជាបានចូលរួមក្នុងការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសកម្រិតសកល (Global Evaluation of the Paris Declaration) និងបានចូលរួមក្នុងគំនិតផ្តួចផ្តើមស្តីពីតម្លាភាពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ (International Aid Transparency Initiatives – IATI) ដោយបានទទួលរៀបចំទស្សនកិច្ចសិក្សាស្តីពីការគ្រប់គ្រងប្រព័ន្ធព័ត៌មានហិរញ្ញប្បទានសហប្រតិបត្តិការ ។ លើសពីនេះ កម្ពុជាក៏បានចែករំលែកបទពិសោធន៍ស្តីពីប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញប្បទានសហប្រតិបត្តការ ដល់មន្ត្រីនៃប្រទេសវៀតណាម ឡាវ ទីម័រខាងកើត ឥណ្ឌូណេស៊ី នេប៉ាល់ និងប៉ាពួញូហ្គីណេ ។ នៅកម្រិតតំបន់ និងអនុតំបន់ កម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំជាមួយអង្គការមិនមែនរដ្ឋាភិបាល និងគណៈកម្មាធិការសភា ព្រមទាំងបានចូលរួមពិនិត្យឡើងវិញនូវយន្តការស្តីពីគណនេយ្យភាពទ្វេទិស ។

តាមការសង្កេតកន្លងមក ទាំងនៅកម្រិតជាតិ និងកម្រិតសកល យើងពិនិត្យឃើញជារឿយៗអំពីគម្លាតរវាងការប្តេជ្ញានៅកម្រិតសកលរបស់ដៃគូអភិវឌ្ឍន៍ និងការអនុវត្តន៍របស់ពួកគេនៅតាមប្រទេសដៃគូ ដូចករណីប្រទេសកម្ពុជា ។ ដោយសារកម្ពុជាជាសមាជិកនៃក្រុមការងារស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៃអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD - Working Party on Aid Effectiveness) កម្ពុជាមានស្នើទៅសហប្រធាននៃក្រុមការងារនេះ នូវវិធានការសម្រាប់ការលើកទឹកចិត្ត សម្រាប់គណនេយ្យភាពដើម្បីឱ្យដៃគូអភិវឌ្ឍន៍អនុវត្តការប្តេជ្ញាកម្រិតសកលរបស់ពួកគេ ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ។ លើសពីនេះ ក្នុងកិច្ចប្រជុំនៅទីក្រុងប៉ែកឡាំងនាខែមិថុនា ឆ្នាំ២០០៩ និងបន្ទាប់មកនៅទីក្រុងសេអ៊ូលនាខែវិច្ឆិកា ឆ្នាំ២០០៩ អគ្គលេខាធិការ គ.ជ.ទ/ក.អ.ក បានធ្វើបទបង្ហាញអំពីទិសដៅការងារស្តីពី ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការក្រោយសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ សំណើរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការគិតគូរពិចារណាកម្រិតសកល បន្ទាប់ពីសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស រួមមាន ÷

១- ត្រូវដកស្រង់បទពិសោធន៍កន្លងមក និងប្រើប្រាស់សក្តីកម្មឱ្យបានត្រឹមត្រូវ

២- ត្រូវយល់ដឹងឱ្យបានច្បាស់ពីបរិស្ថាន និងត្រូវរៀបចំគោលនយោបាយឱ្យស៊ីសង្វាក់ និងសមស្របទៅនឹងបរិបទរបស់ប្រទេស

៣- ត្រូវមានឆន្ទៈខ្ពស់ និងចេះសម្របតាមអភិក្រម ព្រមទាំងត្រៀមរៀបចំក្នុងការបង្កើតគំនិតផ្តួចផ្តើមថ្មីតាមរយៈ ÷

ក- ការកំណត់សកម្មភាពត្រឹមត្រូវ និងអាទិភាព ដែលជាផ្នែកមួយនៃអភិក្រមនៃគ្រប់គ្រង

ខ- ផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍សមត្ថភាព ដែលជាគោលការណ៍ណែនាំសម្រាប់ទម្រង់ការនានានៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ

គ- កំណត់វិធានការដើម្បីពង្រឹងភាពជាដៃគូរវាងតួអង្គពាក់ព័ន្ធទាំងអស់ និង

ឃ- បង្កើតអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលជាយន្តការសម្រាប់គ្រប់គ្រងការបែកខ្ញែកក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គាំទ្រការអភិវឌ្ឍន៍សមត្ថភាពប្រកបដោយ

វិចារណកម្ម ព្រមទាំងការធ្វើសមាហរណកម្មកំណែទម្រង់ស្នូលនានា ព្រមទាំងជម្រុញគណនេយ្យភាពទ្វេទិសទៅក្នុងយុទ្ធសាស្រ្តរបស់វិស័យដោយផ្អែកលើលទ្ធផល ។

## ***ការវាយតម្លៃកម្រិតសកលនៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស***

សកម្មភាពសំខាន់ៗ ដែលគាំទ្រដល់ការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស នៅកម្ពុជាបានចាប់ផ្តើមក្នុងត្រីមាសទី១ឆ្នាំ២០១០កន្លងមកនេះ ។ ការវាយតម្លៃរបស់កម្ពុជាដែលនឹងផ្តល់ធាតុចូលក្នុងការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសក្នុងកម្រិតសកល នឹងត្រូវលើកបង្ហាញក្នុងវេទិកាកំពូលលើកទី៤ស្តីពីប្រសិទ្ធភាពនៃហិរញ្ញ-ប្បទានសហប្រតិបត្តិការ នៅទីក្រុងសេអ៊ូល នាខែវិច្ឆិកាឆ្នាំ២០១១ខាងមុខនេះ។ការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសកម្រិតសកលនេះ គឺជាការបូកសរុបសមិទ្ធផលដែលសម្រេចបាន ព្រមទាំងមេរៀនទាំងឡាយនៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសរយៈពេល៥ឆ្នាំកន្លងមក។ ការវាយតម្លៃនេះបានពិនិត្យមើល ទាំងការផ្លាស់ប្តូរខាងឥរិយាបថ និងទាំងផលប៉ះពាល់ទៅលើលទ្ធផលនៃការអភិវឌ្ឍន៍តាមរយៈសំណួរស្នូលចំនួន ៣ គឺ ÷

១- *__បរិបទ__* : តើកត្តាសំខាន់ៗអ្វីខ្លះដែលជះឥទ្ធិពលដល់ភាពសមស្រប និងដល់ការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងជះឥទ្ធិពលទៅលើប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ?។

២- *__ការផ្លាស់ប្តូរឥរិយាបទ__* : តើការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសបាននាំដល់ការកែលំអប្រសិទ្ធភាពក្នុងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ការគ្រប់គ្រងនិងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពជាដៃគូដែរឬទេ ? ។

៣- *__ការជះឥទ្ធិពលដល់លទ្ធផល__* : តាមរយៈការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស តើការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការបានជួយជំរុញការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផលប្រកបដោយចីរភាពដែរឬទេ?។

**__ការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស__**

***__បរិបទ__***

១- គំនិតផ្តួចផ្តើមដែលបានអនុវត្តនៅកម្ពុជាមុនសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស នៅរក្សានូវភាពត្រឹមត្រូវ និងឥទ្ធិពលនៅឡើយ ។

២- សមត្ថភាពនិងភាពដឹកនាំមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ដែលអាចនាំឱ្យសម្រេចលទ្ធផលនៅកម្រិតវិស័យ ។

៣- ច្រើនមើលរំលងបញ្ហាពាក់ព័ន្ធនឹងអំណាចនិងឥទ្ធិពល ដែលទាំងនេះជាកត្តាកំណត់ក្នុងទំនាក់ទំនងហិរញ្ញប្បទានសហប្រតិបត្តិការ ។

***__ការផ្លាស់ប្តូរឥរិយាបថ__***

៤- ដៃគូអភិវឌ្ឍន៍បានពិនិត្យអំពីគម្លាតរវាងការប្តេជ្ញានៅកម្រិតប្រទេស និងទម្រង់ការ និងតម្រូវការរបស់ទីស្នាក់ការកណ្តាល ។

៥- មានអន្តរសកម្មជាវិជ្ជមានជាមួយនឹងកំណែទម្រង់សំខាន់ៗរបស់រាជ-រដ្ឋាភិបាល ដូចជាកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការជាដើម ។

៦- របាយការណ៍នៃហិរញ្ញប្បទានសហប្រតិបត្តិការបានជំរុញតម្លាភាព ប៉ុន្តែមិនទាន់បានជំរុញការប្រើប្រាស់ប្រព័ន្ធជាតិនៅឡើយ ។

៧- ភាពនឿយណាយរបស់ដៃគូអភិវឌ្ឍន៍ពុំបានឆ្លុះបញ្ចាំងអំពីការកែលំអ ឬការផ្លាស់ប្តូរឥរិយាបថ និងលទ្ធផលនៅឡើយ ។

***__ការជះឥទ្ធិពលដល់លទ្ធផល__***

៨- តម្រូវការឱ្យមានប្រព័ន្ធតាមដាននិងត្រួតពិនិត្យដ៏រឹងមាំ សម្រាប់គាំទ្រដល់ការរៀបចំរបាយការណ៍ដោយផ្តោតលើលទ្ធផល ។

៩- វប្បធម៌ស្តីពីការគ្រប់គ្រងដោយផ្តោតលើលទ្ធផលទោះបីទើបបានចាប់ផ្តើមក៏ដោយ ក៏បានជួយពង្រឹងតម្លាភាពក្នុងការផ្តល់ហិរញ្ញប្បទានសហ-ប្រតិបត្តិការ ទាំងក្នុងកម្រិតគម្រោង ទាំងក្នុងកម្រិតវិស័យ និងទាំងក្នុងកម្រិតជាតិ ។

១០- វឌ្ឍនភាពក្នុងការបញ្ជ្រាបបញ្ហាអន្តរវិស័យ ដូចជាយេនឌ័រជាដើម ។

១១- ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការស្ថិតនៅតែជាពាក្យពេចន៍ ហើយមិនទាន់នាំទៅដល់ការផ្លាស់ប្តូរខាងឥរិយាបថ ។ ដូចនេះ មិនទាន់បានចូលរួមសម្រេចលទ្ធផលឱ្យបានពេញលេញនៅឡើយ ។

១២- សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដែលជាក្របខ័ណ្ឌមួយ អាចប្រឈមនឹងហានិភ័យ ដែលអាចបន្ទុចបន្ទាក់ដល់កិច្ចប្រតិបត្តិប្រកបដោយប្រសិទ្ធ-ភាពដទៃទៀត ។

សេចក្តីព្រាងរបាយការណ៍ស្តីពីការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជា ត្រូវបានលើកបង្ហាញដោយក្រុមត្រួតពិនិត្យឯករាជ្យ នាចុងខែមេសាឆ្នាំ២០១០ ។ ផ្អែកលើការពិនិត្យឯកសារដែលមានស្រាប់ ការសិក្សាស្រាវជ្រាវលំអិត ការពិនិត្យគម្រោង និងបទសម្ភាសន៍ ព្រមទាំងការធ្វើអង្កេតតាមប្រព័ន្ធអនឡាញ (On-Line) សេចក្តីព្រាងរបាយការណ៍បានបញ្ជាក់ថា តវិយាបថនិងលទ្ធផលក្នុងការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជា បានពឹងអាស្រ័យជាច្រើនទៅលើបរិបទរបស់ប្រទេស ។ កិច្ចប្រឹងប្រែងនានាដែលបានអនុវត្តមុនសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជា បានឆ្លុះបញ្ចាំងអំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាល ទន្ទឹមនឹងពេលដែលតវិយាបថរបស់ដៃគូអភិវឌ្ឍន៍ភាគច្រើនត្រូវស្ថិតក្រោមចំណុះទម្រង់ការ និងតម្រូវការផ្ទៃក្នុងរបស់ទីស្នាក់ការកណ្តាល ។

--------------

# ជំពូក ៣
# និន្នាការនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ជំពូកនេះនឹងពិពណ៌នាអំពីនិន្នាការសំខាន់ៗនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយផ្តោតការយកចិត្តទុកដាក់លើដំណាក់កាលឆ្នាំ២០០៨-២០០៩ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ឆ្នាំ២០១០-២០១២ ។ ជំពូកនេះក៏បានវិភាគផងដែរអំពីការអនុវត្តន៍គោលការណ៍ទាំង ៥ នៃ «សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ» សម្រាប់វាយតម្លៃអំពីកិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងការពង្រឹងភាពជាម្ចាស់ និងការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងបណ្តាអាទិភាពនៃការអភិវឌ្ឍន៍ និងប្រព័ន្ធជាតិ ព្រមទាំងការសម្របសម្រួលក្នុងកិច្ចការសុខដុមនីយកម្មរវាងបណ្តាដៃគូអភិវឌ្ឍន៍ ក៏ដូចជាការពង្រឹងប្រព័ន្ធនានាសម្រាប់ការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនិងការលើកកំពស់គណនេយ្យភាពទ្វេទិស ។

ទន្ទឹមនេះ ក៏មានសារៈប្រយោជន៍ផងដែរក្នុងការពិនិត្យឡើងវិញនូវការអនុវត្តន៍ «ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល» របស់រាជរដ្ឋាភិបាលដែលជាក្របខ័ណ្ឌសម្រាប់ជំរុញប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ក្នុងបរិបទនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម ដែលនេះជាក្របខ័ណ្ឌសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២ ។ បន្ថែមលើរបាយការណ៍ស្តីពីកំណែទម្រង់និងការងារតាមវិស័យដែលកំពុងអនុវត្ត សក្ខីកម្មជាច្រើនបានផ្តល់ជាមូលដ្ឋានដ៏រឹងមាំសម្រាប់វាយតម្លៃវឌ្ឍនភាពនិងសម្រាប់ផ្តល់អនុសាសន៍កម្រិតគោលនយោបាយ ។

## ***និន្នាការសរុបនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍***

ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងឆ្នាំ២០០៩ ដែលបានបង្ហាញក្នុងរូបភាពទី ១ ខាងក្រោម បានបញ្ជាក់អំពីកំណើនហិរញ្ញប្បទានជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០០៤មក ដែលបានកើនដល់ប្រមាណ៩៥៥,៦ លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៨ និង៩៨៩,៥លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៩ កើនឡើង៤% ធៀបនឹងឆ្នាំ២០០៨ ។ ការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការអាចកើនរហូតដល់ជាង១.០០០លានដុល្លាអាមេរិកសម្រាប់ឆ្នាំ២០១០ ពោលគឺអាចកើនឡើង១០% ក្នុងមួយឆ្នាំ ។ ទោះបីមានគំនាបខាងទំហំហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្រិតសកលដោយសារវិបត្តិសេដ្ឋកិច្ចក៏ដោយ ក៏ទំហំហិរញ្ញប្បទានសម្រាប់កម្ពុជាបានកើនឡើងបន្តិចបន្តួចក្នុងឆ្នាំ២០០៩ ហើយរំពឹងថានឹងបន្តកើនឡើងថែមទៀតក្នុងឆ្នាំ២០១០ ។ សមាមាត្រនៃហិរញ្ញប្បទានឥតសំណង ធៀបនឹងហិរញ្ញ-ប្បទានសរុប នៅបន្តស្ថេរភាពក្នុងកំឡុងឆ្នាំ២០០៤-២០០៩ ដែលបានកើនឡើងពី ៦៦% ទៅដល់៧១% ។ លើសពីនេះ ក៏គួរឱ្យកត់សំគាល់ផងដែរថា ទិន្នន័យសម្រាប់ឆ្នាំ២០១១ និងឆ្នាំ២០១២ គឺជាតួលេខព្យាករណ៍ដោយផ្អែកលើការសន្យាផ្តល់ធនធានរបស់ដៃគូអភិវឌ្ឍន៍ប៉ុណ្ណោះ ។ ដូចនេះ ទិន្នន័យនេះមិនទាន់ឆ្លុះបញ្ចាំងពីសុក្រឹត្យភាពនៃលំហូរហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ឆ្នាំទាំងពីរនេះឡើយ (សូមពិនិត្យអត្ថបទ ស្តីពីភាពអាចទស្សន៍ទាយជាមុន នៅក្នុងជំពូកនេះ) ។ ព័ត៌មានស្តីពីក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ នៅក្នុងវេទិកាលើកទី៣ នាខែមិថុនា ឆ្នាំ២០១០នេះ នឹងផ្តល់តួលេខប្រាកដប្រជាស្តីពីការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការ ។

*គំនូរទី១: ការប្រើប្រាស់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៤- ២០១២ (លានដុល្លាអាមេរិក)*




កំណត់សំគាល់: តួលេខសម្រាប់ឆ្នាំ២០១០- ២០១២ គឺជាតួលេខព្យាករណ៍ ដោយផ្អែកលើផែនការធនធាន

ទន្ទឹមនឹងនេះ  ក៏មានសារៈសំខាន់ផងដែរក្នុងការពិនិត្យនិន្នាការនៃការផ្តល់កិច្ចសហប្រតិបត្តិអភិវឌ្ឍន៍ក្នុងរយៈពេលមួយទសវត្សន៍កន្លងមកនេះ  ដើម្បីស្វែងយល់អំពីសារៈសំខាន់នៃធនធានទាំងនេះក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចនៅកម្ពុជា ។

*គំនូរទី២:Aid per Capita and Aid/GDP ratios*




គំនូរទី២បានបង្ហាញថា និន្នាការទូទៅនៃអត្រាផលធៀបហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងផលិតផលក្នុងស្រុកសរុប  ចាប់តាំងពីឆ្នាំ២០០០មានការធ្លាក់ចុះ ទោះបីកម្រិតហិរញ្ញប្បទានសហប្រតិបត្តិការសរុបបានកើនឡើងទ្វេដងក៏ដោយ ។ អត្រាផលធៀបធ្លាក់ចុះនេះ គឺ  បណ្តាលមកពីកំណើនខ្ពស់នៃផលិតផលក្នុងស្រុកសរុប ពិសេសចាប់ពីឆ្នាំ២០០២ ដែលសេដ្ឋកិច្ចបានកើនយ៉ាងខ្លាំងពី៤.២០០លានដុល្លាអាមេរិកក្នុងឆ្នាំ២០០២ ដល់ប្រមាណ១១.៥០០លានដុល្លាអាមេរិក ក្នុងឆ្នាំ២០១០ ។ ហេតុដូចនេះ អត្រាផលធៀបហិរញ្ញប្បទានសហប្រតិបត្តិការនិងផលិតផលក្នុងស្រុកសរុប ស្ថិតក្រោម ១០% ចាប់ពីឆ្នាំ២០០៥មក ហើយអត្រាផលធៀបនេះមានស្ថេរភាពនៅចន្លោះ៩-១០%នៃផលិតផលក្នុងស្រុកសរុប ។ ផ្ទុយទៅវិញ ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងមនុស្សម្នាក់បានកើនឡើងជាលំដាប់ ពីប្រមាណ៤០ដុល្លាអាមេរិក ក្នុងឆ្នាំ២០០០ដល់ប្រមាណ៧៨ដុល្លាអាមេរិកក្នុងឆ្នាំ២០១០ ។ ដោយសារអត្រាកំណើនប្រជាជនមានកម្រិតទាប ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ប្រជានម្នាក់បានកើនឡើងទ្វេដងក្នុងរយៈពេលមួយទស្សវត្សរ៍កន្លងមក ។

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣

គំនិតផ្តួចផ្តើមចម្បងរបស់រាជរដ្ឋាភិបាលនាឆ្នាំ២០០៩កន្លងមក គឺការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ ។ ការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះមានគោលដៅចំបង២ :

ទី១- តម្រឹមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាមួយនឹងអាណត្តិរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា និងទី២- ផ្សារភ្ជាប់ផែនការតាមវិស័យជាមួយនឹងអាទិភាពជាតិនានា សម្រាប់ឆ្លើយតបទៅនឹងបញ្ហាអាក្រក់ដែលបណ្តាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩ ។ ដើម្បីរក្សាឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រចតុកោណ ដែលផ្តោតទៅលើស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងអភិបាលកិច្ចល្អ ព្រមទាំងការបង្កើតបរិស្ថានអំណោយផលសម្រាប់កំណើនសេដ្ឋកិច្ច ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ក៏បានកំណត់ច្បាស់លាស់អំពីការទទួលខុសត្រូវក្នុងការអនុវត្តន៍គោលនយោបាយនានា ដែលត្រូវធានាសង្គតិភាពជាមួយនឹងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងធានាការផ្សារភ្ជាប់ដំណើរការផែនការនីយកម្ម«ពីលើចុះក្រោម» ដោយត្រូវផ្អែកលើធនធានសរុបជាមួយនឹងអភិក្រម «ពីក្រោមទៅលើ» ដែលត្រូវឆ្លើយតបទៅនឹងអាទិភាពដែលបានកំណត់ដោយក្រសួងនិងស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ដំណើរការនៃការធ្វើបច្ចុប្បន្នកម្មក៏បានជួយពង្រឹងការពិគ្រោះយោបល់ តាមរយៈយន្តការក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់ពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូនិងសម្រាប់បង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ តាមរយៈការជំរុញឱ្យប្រើប្រាស់«អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី» ។

ផ្អែកតាមលទ្ធផលនៃកិច្ចពិគ្រោះយោបល់នេះ គួបផ្សំជាមួយនឹងការត្រួតពិនិត្យនិងការវិភាគនានា ក្រសួងផែនការបានកែសម្រួលក្របខ័ណ្ឌធនធាន (តារាងទី២) ។ ក្របខ័ណ្ឌនេះបានបញ្ចូលកម្មវិធីអាទិភាពសម្រាប់វិស័យថ្មីៗមួយចំនួន ដូចជា ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងវិធានការណ៍សម្រាប់កាត់បន្ថយផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ច មកលើជនក្រីក្រនិងក្រុមជនងាយរងគ្រោះ ។ លើសពីនេះ ដោយផ្អែកលើតម្រូវការក្នុងការជំរុញ «អភិក្រមគ្រប់គ្រងដោយផ្តោតលើលទ្ធផល» ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ក៏បានពិនិត្យឡើងវិញ និងបានពង្រឹងក្របខ័ណ្ឌសម្រាប់តាមដានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្នុងស្មារតីនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានបញ្ចូលបន្ថែមសូចនាករនិងគោលដៅមួយចំនួនសម្រាប់តាមដានដោយបានបញ្ជាក់អំពីភារកិច្ចទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍ និងដោយបានបង្កើតប្រព័ន្ធប្រមូល និងតាមដានទិន្នន័យជាប្រចាំ ។ កិច្ចការនេះកំពុងត្រូវបានអនុវត្ត ដោយត្រូវពង្រឹងទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងកំណែទម្រង់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលដៅពង្រឹង និងផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធព័ត៌មាននានារបស់រាជរដ្ឋាភិបាល ក៏ដូចជាដើម្បីដកស្រង់បទពិសោធន៍និងគំនិតផ្តួចផ្តើមផ្សេងៗ ដូចជាការតាមដានលើគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជាជាដើម ។

ក្របខ័ណ្ឌធនធានដែលត្រូវបានកែសម្រួលក្នុង«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម» គឺជាមូលដ្ឋានបង្អែកយ៉ាងសំខាន់សម្រាប់ដៃគូអភិវឌ្ឍន៍ផងដែរ ដោយសារក្របខ័ណ្ឌនេះបានបង្ហាញការតម្រឹមធនធានទាំងនេះជាមួយនឹងអាទិភាពនៃកិច្ចអភិវឌ្ឍន៍ជាតិ ។ ទោះបីជាយ៉ាងនេះក្តី ក៏យើងត្រូវពិនិត្យឡើងវិញជាថ្មីទៀងទាត់អំពីធនធានដែលបានវិភាជន៍ ។ តារាងទី២ បានបង្ហាញអំពីបំរែបំរួលនៃធនធាន ទាំងធនធានក្នុងប្រទេស ទាំងធនធានក្រៅប្រទេស ចាប់តាំងពីឆ្នាំ២០០៦ ដែលជាឆ្នាំដំបូងសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ បន្ថែមលើផ្នែកថ្មីចំនួន២ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម (ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស និងការបញ្ចៀសភាពងាយរងគ្រោះ) យើងសង្កេតឃើញមានការធ្លាក់ចុះធនធានក្នុងវិស័យ

អប់រំ សុខាភិបាល កសិកម្ម និងដឹកជញ្ជូន ស្របពេលដែលមានការកើនឡើងសម្រាប់វិស័យអភិវឌ្ឍន៍ជនបទ ការផ្គត់ផ្គង់ថាមពលនិងអគ្គីសនី និងអភិបាលកិច្ច ព្រមទាំងការប្រែប្រួលអាកាសធាតុ និងបរិស្ថាន ។ ប្រការនេះបានបង្ហាញពីការប្ដេជ្ញាបន្តកិច្ចខំប្រឹងប្រែងក្នុងកំណែទម្រង់អភិបាលកិច្ច ពិសេសក្នុងការគ្រប់គ្រងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងការយកចិត្តទុកដាក់បន្ថែមដល់ការអភិវឌ្ឍន៍ជនបទ ។

*តារាងទី២ - តម្រូវការធនធាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦ - ២០១៣ (លានដុល្លាអាមេរិក)*

| វិស័យ | 2006 ផយអជ | 2008 MTR កែសម្រួល | 2009-2013 បច្ចុប្បន្នកម្ម |
|---|---|---|---|
| ***វិស័យសង្គមកិច្ច*** | | | |
| អប់រំ (មូលដ្ឋាន = ៦០ភាគរយ) | 550 | 670 | 700 |
| ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេស | | | 150 |
| សុខាភិបាល | 600 | 720 | 700 |
| ការជួយសម្រាលជនងាយរងគ្រោះ | | | 250 |
| ***សរុប*** | 1150 | 1.390 | 1.800 |
| ***វិស័យសេដ្ឋកិច្ច*** | | | |
| កសិកម្ម និង ការគ្រប់គ្រងដីធ្លី: ក្រៅពីធញ្ញជាតិ | 150 | 200 | 250 |
| ធញ្ញជាតិតាមរដូវៈ ស្រូវ ។ល។ | 200 | 370 | 250 |
| អភិវឌ្ឍន៍ជនបទ | 350 | 420 | 750 |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | 80 | 100 | 250 |
| ***សរុប*** | 780 | 1.090 | 1.500 |
| ***ហេដ្ឋារចនាសម្ព័ន្ធ*** | | | |
| ដឹកជញ្ជូន (ផ្លូវជាតិ និងផ្លូវខេត្ត- រាជធានី) | 550 | 690 | 750 |
| ទឹកស្អាត និងអនាម័យ (មិនគិតជនបទ) | 150 | 180 | 250 |
| ថាមពល និងអគ្គិសនី | 120 | 160 | 250 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 60 | 75 | 75 |
| ***សរុប*** | 880 | 1.105 | 1.325 |
| សេវាកម្ម និងកម្មវិធីអន្តរវិស័យ | | | |
| ការបញ្ច្រាបយេនឌ័រ | 30 | 40 | 50 |
| ទេសចរណ៍ | 30 | 45 | 50 |
| បរិស្ថាន និងអភិរក្ស | 100 | 120 | 250 |
| សហគមន៍ និងសេវាកម្មសង្គម | 80 | 100 | 100 |
| វប្បធម៌ និងវិចិត្រសិល្បៈ | 30 | 40 | 50 |
| អភិបាលកិច្ច និងរដ្ឋបាល | 220 | 270 | 500 |
| ***សរុប*** | 490 | 615 | 1.000 |
| ធនធានមិនទាន់វិភាជន៍ | 200 | | 116 |
| ***សរុប*** | 3.500 | 4.200 | 5.741 |

**ប្រភព** : ផយអជ ឆ្នាំ២០០៦ តារាងទី៥.២ ការត្រួតពិនិត្យពាក់កណ្ដាលអាណត្តិឆ្នាំ២០០៨ តារាងទី៤. ៣ និង ផយអជ- បច្ចុប្បន្នកម្ម តារាងទី២៥

*គំនូរទី៣: ការវិវត្តន៍នៃការវិភាជន៍ធនធានសម្រាប់គាំទ្របណ្តាអាទិភាពនៃផែនការណភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ*




## ***និន្នាការនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍***

និន្នាការទូទៅនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដូចបង្ហាញក្នុងគំនូរទី១ បានបញ្ជាក់អំពីការបន្តកើនឡើងនៃទំហំហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ។ ប្រការនេះបានឆ្លុះបញ្ចាំងពីការបន្តខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរធនធាន ក៏ដូចជាការប្តេជ្ញារបស់សហគមន៍ដៃគូអភិវឌ្ឍន៍ក្នុងការបន្តគាំទ្រកំណែទម្រង់និងបណ្តាអាទិភាពក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។ ក្នុងចន្លោះឆ្នាំ១៩៩២-២០០៩ ដៃគូអភិវឌ្ឍន៍បានរាយការណ៍ថាពួកគេបានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍មកកម្ពុជា ចំនួន៩.៧៩០លានដុល្លាអាមេរិក ។ គំនូរទី៤បង្ហាញអំពីទំហំហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ :

- ២.២៧០លានដុល្លាអាមេរិក (២៣,២%) បានផ្តល់ដោយប្រទេសជាសមាជិកសហភាពអឺរ៉ុបនិងសហគមន៍អឺរ៉ុប ។
- ១.៨៣០លានដុល្លាអាមេរិក បានផ្តល់ដោយជប៉ុន (១៨,៧%នៃចំនួនសរុបចាប់តាំងពីឆ្នាំ១៩៩២)។
- ៩៨០លានដុល្លាអាមេរិក បានផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ី ៨០០លានដុល្លាអាមេរិក បានផ្តល់ដោយអង្គការសហប្រជាជាតិ និង៦៤០លានដុល្លាអាមេរិក បានផ្តល់ដោយធនាគារពិភពលោក ។
- ២.៨២០លានដុល្លាអាមេរិក (២៨,៨%) បានផ្តល់ដោយភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នពហុភាគីដទៃទៀត ។
- ៨៦០លានដុល្លាអាមេរិក (៨,៨%) បានផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល ។
- ៥១០លានដុល្លាអាមេរិកបានផ្តល់ដោយសាធារណរដ្ឋប្រជាមានិតចិន ក្នុងនោះ៨៥%នៃហិរញ្ញប្បទានត្រូវបានប្រើប្រាស់ចាប់ពីឆ្នាំ២០០៤មក ។

គំនូរទី៤រំលេចពីវិស័យដែលបានទទួលហិរញ្ញប្បទានសហប្រតិបត្តិការច្រើនជាងគេ ។ វិស័យអភិបាលកិច្ចនិងរដ្ឋបាល (រួមទាំងការគាំទ្រដល់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ផ្សេងៗទៀត និងការបោះឆ្នោត) បានទទួលហិរញ្ញប្បទានច្រើនជាងគេ (ប្រមាណ១.៦០០លានដុល្លាអាមេរិក) ។ បន្ទាប់មកគឺ វិស័យសុខាភិបាល

(ប្រមាណ១.៥០០លានដុល្លាអាមេរិក) វិស័យដឹកជញ្ជូន (ប្រមាណ១.២០០លានដុល្លាអាមេរិក) វិស័យអប់រំ (ប្រមាណ១.០០០លានដុល្លាអាមេរិក) និងវិស័យអភិវឌ្ឍន៍ជនបទ (ប្រមាណ១.០០០លានដុល្លាអាមេរិក) ។

*គំនូរទី៤: ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសរុប ឆ្នាំ១៩៩២-២០១០*

សរុបហិរញ្ញប្បទានសហប្រតិបត្តការផ្លូវការ ឆ្នាំ១៩៩២-២០០៩ ចំនួន៩.៧៩០លានដុល្លាអាមេរិក




តារាងទី៣បង្ហាញពីការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិរបស់ដៃគូអភិវឌ្ឍន៍ ក្នុងបណ្តាឆ្នាំចុងក្រោយនេះ ដែលមានហិរញ្ញប្បទានសរុបប្រមាណ៩៨៩,៥លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៩ កើនឡើង ៣,៥% ធៀបនឹងឆ្នាំ ២០០៨ ។ ជប៉ុននៅតែជាដៃគូដែលបានផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍ច្រើនជាងគេ ចំនួន១៤៨,៤លានដុល្លាអាមេរិក ក្នុងឆ្នាំ២០០៩ កើនឡើង១៨% ធៀបនឹងឆ្នាំមុន ។ ទន្ទឹមនឹងនេះ សាធារណៈរដ្ឋប្រជាមានិតចិនបានផ្តល់ហិរញ្ញប្បទាន ចំនួន១១៤,៧លានដុល្លាអាមេរិក ដលវិស័យហេដ្ឋារចនាសម្ព័ន្ធ ពោលគឺស្មើនឹង១៣% នៃហិរញ្ញប្បទានសហប្រតិ-បត្តិការសរុប ហើយបានកើនឡើងចំនួន២០% ក្នុងមួយឆ្នាំ ។

កំណើននៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការគួរឱ្យកត់សំគាល់ដទៃទៀត រួមមាន អេស្ប៉ាញ (១៥៨%) សាធារណៈរដ្ឋកូរ៉េ (៤១%) ដាណឺម៉ាក (៤០%) ស៊ុយអ៊ែត (៤០%) ធនាគារពិភពលោក (៣៧%) និងមូលនិធិសកល (២៥%) ។ ការព្យាករណ៍ការផ្តល់ហិរញ្ញប្បទានក្នុងឆ្នាំ២០១០ នឹងកើនឡើងរហូតដល់១.០០០ លានដុល្លាអាមេរិក ពោលគឺអាចមានកំណើនប្រចាំឆ្នាំ១០% បន្ថែមទៀត ដោយសង្ឃឹមថាធនាគារពិភពលោកនឹងបង្កើនហិរញ្ញប្បទានទ្វេដង ហើយប្រទេសមួយចំនួនដែលជាសមាជិកនៃសហភាពអឺរ៉ុប និងសហភាពអឺរ៉ុបក៏បានបង្កើនហិរញ្ញប្បទាន ប្រមាណ២០% ទន្ទឹមនឹងពេលដែលអូស្ត្រាលីអាចបង្កើនប្រមាណ៥០% ។ ថ្វីត្បិតមិនទាន់មានភាពមិនទាន់ប្រាកដប្រជាខាងទិន្នន័យដែលដៃគូអភិវឌ្ឍន៍បានផ្តល់ក៏ដោយ ក៏តួលេខទាំងនេះត្រូវបានព្យាករណ៍ ដោយផ្អែកលើការសន្យាផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងកំពុងអនុវត្ត និងគម្រោងត្រៀមអនុវត្តតែប៉ុណ្ណោះ ទោះបីជាយើងដឹងថាមានដៃគូអភិវឌ្ឍន៍កំពុងគិតគូរនិងកាត់បន្ថយការផ្តល់ហិរញ្ញប្បទានរបស់ខ្លួនក៏ដោយ ។

គំនូរទី៥ បានបង្ហាញអំពីការប្រែប្រួលនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការជាក់ស្តែង ក្នុងឆ្នាំ ២០០៨-២០០៩ ។ ក្នុងបណ្តាដៃគូអភិវឌ្ឍន៍ទាំង២២ មានដៃគូអភិវឌ្ឍន៍ចំនួន១៣បានបង្កើនការគាំទ្ររបស់ខ្លួន ហើយ ដៃគូ៩ទៀតបានកាត់បន្ថយការគាំទ្ររបស់ខ្លួន ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ហិរញ្ញប្បទានបន្ទាន់ជាកម្ចី សម្រាប់ អនុវត្តគម្រោងមួយចំនួន ដើម្បីឆ្លើយតបទៅនឹងឥទ្ធិពលនៃវិបត្តិកលិយុគសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក ។

### តារាងទី៣- ការប្រើប្រាស់និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍ ឆ្នាំ២០០៤- ២០១២ (លានដុល្លាអាមេរិក)

| ដៃគូអភិវឌ្ឍន៍ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ (ប៉ាន់ស្មាន) | | ២០១០ (ព្យាករណ៍) | ២០១១ (ព្យាករណ៍) | ២០១២ (ព្យាករណ៍) |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ដុល្លា | % | | | |
| *អង្គការសហប្រជាជាតិ និងស្ថាប័នពហុភាគី* | | | | | | | | | | |
| កម្មវិធីអង្គការសហប្រជាជាតិ (ធនធានសរុប) | 73,8 | 91,8 | 96,3 | 98,6 | 109,0 | 127,3 | 12,9 | | | |
| អង្គការសហប្រជាជាតិ (ធនធានផ្ទាល់) | 36,3 | 41,1 | 54,0 | 58,3 | 68,3 | 74,8 | 7,6 | 95,8 | 12,2 | 5,0 |
| ធនាគារពិភពលោក | 49,5 | 37,8 | 24,5 | 47,5 | 44,0 | 60,4 | 6,1 | 122,7 | 109,6 | 93,8 |
| មូលនិធិរូបិយវត្ថុអន្តរជាតិ | 2,4 | 0,3 | 83,5 | 0,9 | | | | | | |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 76,7 | 89,4 | 67,5 | 69,4 | 145,7 | 89,5 | 9,0 | 124,5 | 116,8 | 92,8 |
| មូលនិធិសកល | | 18,8 | 21,9 | 21,1 | 38,6 | 47,9 | 4,8 | 41,2 | 27,2 | 14,8 |
| *សរុប* | **164,8** | **187,5** | **251,2** | **197,1** | **296,6** | **272,6** | **27,5** | **384,2** | **265,7** | **206,3** |
| *សហភាពអឺរ៉ុប* | | | | | | | | | | |
| បែលហ្ស៊ិក | 5,2 | 11,7 | 7,3 | 7,2 | 2,8 | 3,1 | 0,3 | 1,2 | 0,3 | |
| ដាណឺម៉ាក | 5,8 | 4,8 | 4,1 | 9,8 | 10,1 | 14,2 | 1,4 | 16,4 | 2,0 | 2,0 |
| ហ្វាំងឡង់ | 3,3 | 3,3 | 4,5 | 5,2 | 6,6 | 6,3 | 0,6 | 1,6 | 2,1 | 2,1 |
| បារាំង | 23,0 | 24,4 | 21,8 | 21,7 | 31,3 | 25,5 | 2,6 | 26,7 | 16,6 | 13,6 |
| អាល្លឺម៉ង់ | 14,1 | 27,3 | 32,4 | 20,7 | 36,5 | 32,5 | 3,3 | 60,2 | 47,5 | 29,5 |
| ហុល្លង់ | 1,6 | 1,1 | 0,1 | 0,1 | 2,2 | 0,7 | 0,1 | 1,2 | 0,1 | 0,0 |
| អេស្ប៉ាញ | | | 2,8 | 3,5 | 6,5 | 16,8 | 1,7 | 22,9 | 2,1 | |
| ស៊ុយអែត | 22,0 | 13,6 | 16,0 | 17,3 | 15,9 | 22,9 | 2,3 | 26,7 | 22,2 | 6,5 |
| ចក្រភពអង់គ្លេស | 17,0 | 20,6 | 20,7 | 23,7 | 29,6 | 32,5 | 3,3 | 31,6 | 16,5 | 13,9 |
| សហគមន៍អឺរ៉ុប | 15,0 | 23,7 | 46,5 | 44,0 | 47,2 | 50,3 | 5,1 | 57,8 | 53,4 | 41,5 |
| *សរុប* | **107,1** | **130,6** | **156,1** | **153,2** | **188,6** | **204,8** | **20,7** | **246,3** | **162,8** | **109,1** |
| *ដៃគូអភិវឌ្ឍន៍ទ្វេភាគី* | | | | | | | | | | |
| អូស្ត្រាលី | 24,3 | 16,8 | 22,5 | 29,6 | 31,2 | 23,7 | 2,4 | 36,3 | 42,8 | 19,0 |
| កាណាដា | 1,5 | 9,1 | 7,9 | 12,6 | 17,2 | 13,1 | 1,3 | 7,9 | 3,8 | 2,5 |
| សាធារណៈរដ្ឋប្រជាមានិតចិន | 32,5 | 46,6 | 53,2 | 92,4 | 95,4 | 114,7 | 11,6 | 100,2 | 64,7 | 28,7 |
| ជប៉ុន | 101,8 | 111,7 | 103,7 | 117,2 | 126,2 | 148,4 | 15,0 | 104,7 | 56,6 | 44,7 |
| ណូវែលហ្សេឡង់ | 2,4 | 2,1 | 1,7 | 4,5 | 2,8 | 2,7 | 0,3 | 3,3 | 2,5 | 0,8 |
| សាធារណរដ្ឋកូរ៉េ | 24,1 | 14,9 | 13,3 | 31,3 | 33,0 | 46,5 | 4,7 | 26,5 | 27,5 | 45,7 |
| ស្វីស | 3,2 | 2,8 | 2,4 | 3,6 | 3,9 | 2,8 | 0,3 | 2,8 | 2,8 | 2,8 |
| សហរដ្ឋអាមេរិក | 40,6 | 43,3 | 51,0 | 58,1 | 55,7 | 56,9 | 5,8 | 61,2 | 63,7 | |
| *សរុប* | **233,7** | **247,2** | **255,7** | **349,4** | **365,5** | **408,8** | **41,3** | **343,0** | **264,4** | **144,2** |
| អង្គការមិនមែនរដ្ឋាភិបាល (ធនធានផ្ទាល់) | **49,4** | **44,7** | **50,2** | **77,7** | **104,9** | **103,3** | **10,4** | **112,4** | **51,8** | **28,5** |
| *សរុប* | **555,0** | **610,0** | **713,2** | **777,5** | **955,6** | **989,5** | **100** | **1,085,9** | **744,7** | **488,1** |

### គំនូរទី៥: ការប្រែប្រួលប្រចាំឆ្នាំក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសរុប (ឆ្នាំ២០០៨- ២០០៩)



ដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលបានកាត់បន្ថយហិរញ្ញប្បទានសហប្រតិបត្តិការក្នុងឆ្នាំ២០០៩ រួមទាំងអូស្ត្រាលីផងដែរ នឹងអាចបង្កើនហិរញ្ញប្បទានជាថ្មីម្តងទៀតក្នុងឆ្នាំ២០១០ ។ ទន្ទឹមនឹងនេះ បារាំងនិងកាណាដាបានរៀបចំកម្មវិធីប្រចាំប្រទេសសារជាថ្មីឡើងវិញក្នុងឆ្នាំ២០០៩ ។ ក្នុងស្មារតីនេះ និន្នាការកើនឡើងជាទូទៅនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានបង្ហាញអំពីភាពប្រែប្រួលក្នុងការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ ។ ប្រការនេះអាចពិនិត្យឃើញក្នុងបរិបទនៃវិស័យនិងការគ្រប់គ្រងគម្រោង ប៉ុន្តែ ក៏ជាបញ្ហាដែលពាក់ព័ន្ធនឹងភាពអាចទស្សន៍ទាយជាមុន ។

*តារាងទី៤ - ភាពទស្សន៍ទាយជាមុនក្នុងការការប្រើប្រាស់និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការ*

| ដៃគូអភិវឌ្ឍន៍ | ២០០៩ | | | ២០១០ | | |
|---|---|---|---|---|---|---|
| | CDCF MYIFF | Actual disbursement | % delivered | CDCF MYIFF | Projected disbursement | Projected % delivery |
| អង្គការសហប្រជាជាតិ (ធនធានផ្ទាល់) | 81,8 | 74,8 | 91% | 64,5 | 95,8 | 148% |
| ធនាគារពិភពលោក | 99,1 | 60,4 | 61% | 84,1 | 122,7 | 146% |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 101,6 | 89,5 | 88% | 162,7 | 124,5 | 77% |
| មូលនិធិសកល | - | 47,9 | - | - | 41,2 | - |
| បែលហ្ស៊ិក | - | 3,1 | - | - | 1,2 | - |
| ដាណឺម៉ាក | 13,0 | 14,2 | 109% | 15,0 | 16,4 | 109% |
| ហ្វាំងឡង់ | 5,7 | 6,3 | 110% | 1,5 | 1,6 | 110% |
| បារាំង | 25,8 | 25,5 | 99% | 25,3 | 26,7 | 106% |
| អាល្លឺម៉ង់ | 38,4 | 32,5 | 85% | 19,5 | 60,2 | 308% |
| អេស្ប៉ាញ | 11,2 | 16,8 | 150% | 7,8 | 22,9 | 292% |
| ស៊ុយអែត | 29,8 | 22,9 | 77% | 33,5 | 26,7 | 80% |
| ចក្រភពអង់គ្លេស | 43,6 | 32,5 | 75% | 45,0 | 31,6 | 70% |
| សហគមន៍អឺរ៉ុប | 46,2 | 50,3 | 109% | 61,6 | 57,8 | 94% |
| អូស្ត្រាលី | 31,5 | 23,7 | 75% | 48,4 | 36,3 | 75% |
| កាណាដា | 7,7 | 13,1 | 169% | 5,3 | 7,9 | 150% |
| សាធារណរដ្ឋប្រជាមានិតចិន | 256,8 | 114,7 | 45% | 162,2 | 100,2 | 62% |
| ជប៉ុន | 112,3 | 148,4 | 132% | 112,3 | 104,7 | 93% |
| ណូវែលហ្សេឡង់ | 3,6 | 2,7 | 76% | 3,6 | 3,3 | 91% |
| សាធារណរដ្ឋកូរ៉េ | 41,0 | 46,5 | 113% | - | 26,5 | |
| ស្វីស | 2,5 | 2,8 | 112% | 2,5 | 2,8 | 112% |
| សហរដ្ឋអាមេរិក | - | 56,9 | | - | 61,2 | |
| ***សរុប*** | **951,5** | **885,5** | **93%** | **854,8** | **972,2** | **114%** |

ការអង្កេតស្តីពីការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនាឆ្នាំ២០០៨ បានបង្ហាញថា ការប្រើប្រាស់ហិរញ្ញប្បទានសរុបក្នុងឆ្នាំ២០០៧មានកម្រិតជិតស្មើនឹង១០០%នៃការព្យាករណ៍ ។ តារាងទី៤បានបង្ហាញថា ភាព

អាចទស្សន៍ទាយសរុបមានអត្រាខ្ពស់គួរជាទីគាប់ចិត្ត ។ ក្នុងឆ្នាំ២០០៩កន្លងមក ដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទានប្រមាណ៩៣% ធៀបនឹងហិរញ្ញប្បទានសរុប ដែលពួកគេបានសន្យានៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា នាខែធ្នូ ឆ្នាំ២០០៨ ។ ទន្ទឹមនឹងនេះ ក៏សង្កេតឃើញអត្រាខុសៗគ្នាក្នុងការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នីមួយៗដែរ ។ ទោះបីក្នុងឆ្នាំ២០១០នេះ តួលេខព្យាករណ៍នៃការផ្តល់ហិរញ្ញប្បទានមានចំនួន១១៤% ធៀបនឹងការសន្យា ហើយនេះជាសញ្ញាវិជ្ជមានក្នុងភាពអាចទស្សន៍ទាយជាមុនក៏ដោយ ក៏ប៉ុន្តែ គំលាតរវាងការផ្តល់ជាក់ស្តែង និងការសន្យាផ្តល់ហិរញ្ញប្បទានរបស់ដៃគូនីមួយៗអាចមានទំហំច្រើនជាងឆ្នាំ២០០៩ ។ ប្រការនេះប្រហែលជាបណ្តាលមកពីតួលេខក្របខ័ណ្ឌណែនាំស្តីពីហិរញ្ញប្បទានច្រើនឆ្នាំ សម្រាប់ឆ្នាំ២០១០ដែលបានផ្តល់នាចុងឆ្នាំ២០០៨ បានធ្វើឱ្យដៃគូអភិវឌ្ឍន៍ជួបការលំបាកក្នុងការប៉ាន់ស្មានទំហំហិរញ្ញប្បទានរបស់ខ្លួន ហើយតួលេខសម្រាប់ឆ្នាំ២០១០នេះគឺជាតួលេខព្យាការណ៍តែប៉ុណ្ណោះ ។ រាជរដ្ឋាភិបាលទទួលស្គាល់អំពីការលំបាកដែលដៃគូអភិវឌ្ឍន៍បានជួបប្រទះក្នុងការផ្តល់តួលេខប្រាកដប្រជា និងកំណែទម្រង់ប្រព័ន្ធផ្ទៃក្នុងសម្រាប់ផ្តល់តួលេខប៉ាន់ស្មានរឹងមាំសម្រាប់រយៈពេលមធ្យម ។ ដោយឡែក ការផ្តល់ហិរញ្ញប្បទានជាក់ស្តែងក៏ជាការលំបាកក្នុងការប៉ាន់ស្មានរបស់ដៃគូនីមួយៗដែរ ពីព្រោះបញ្ហានេះអាចចាកផុតពីសមត្ថភាពគ្រប់គ្រងរបស់ខ្លួន ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានទទួលស្គាល់អំពីកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ភាគច្រើន ដែលបានផ្តល់ព័ត៌មានដ៏សំខាន់នេះនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ក៏ដូចជាបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីការផ្តល់ហិរញ្ញប្បទានជាក់ស្តែង និងការព្យាករណ៍ទំហំហិរញ្ញប្បទាន នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ ។ ក្នុងបរិបទនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលនឹងបន្តធ្វើការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីដឹងច្បាស់អំពីធនធានដែលមានសម្រាប់រយៈពេលមធ្យម ហើយប្រើប្រាស់ព័ត៌មានទាំងនេះ សម្រាប់រៀបចំថវិកាជាតិ និងការធ្វើផែនការនីយកម្មតាមវិស័យ ។

## ***និន្នាការតាមវិស័យនិងការវិភាជន៍ធនធាន***

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គឺជាក្របខ័ណ្ឌសម្រាប់វិភាជន៍ធនធានដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ជាតិដូចមានចែងក្នុងយុទ្ធសាស្រ្តចតុកោណ- ដំណាក់កាលទី២ ។ តារាងទី៥ខាងក្រោមបង្ហាញអំពីនិន្នាការនៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ដំណាក់កាលឆ្នាំ២០០៤- ២០១០ ។ យើងអាចសន្និដ្ឋានបានថា ហិរញ្ញប្ប-ទានជាច្រើនត្រូវបានផ្តល់សម្រាប់បន្តគាំទ្រក្នុងវិស័យសង្គមកិច្ច ដូចជាសុខាភិបាល ហ៊ីវ/ អេដស៍ និងវិស័យអប់រំប្រមាណជាង៣០%នៃហិរញ្ញប្បទានសរុបក្នុងឆ្នាំ២០០៩ ។ រីឯហិរញ្ញប្បទានសម្រាប់វិស័យកសិកម្មមាន ៩១,២លានដុល្លាអាមេរិក ពោលគឺកើនឡើងប្រមាណ៦០% ធៀបទៅនឹងតួលេខឆ្នាំ២០០៩ (ដោយសារកំណើនហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍអាស៊ីនិងសហគមន៍អឺរ៉ុបសម្រាប់វិស័យនេះ) ។ លើសពីនេះ ហិរញ្ញប្បទានសម្រាប់វិស័យដឹកជញ្ជូនក៏កើនឡើងប្រមាណ២០% ក្នុងឆ្នាំ២០០៩ ដោយសារកំណើនហិរញ្ញប្បទានរបស់ជប៉ុន និងសាធារណៈរដ្ឋប្រជាមានិតចិន ។ ហិរញ្ញប្បទានសម្រាប់វិស័យសុខាភិបាល (ដោយមានការគាំទ្រពីមូលនិធិសកល និងចក្រភពអង់គ្លេស) និងវិស័យព័ត៌មាននិងទូរគមនាគមន៍ (ហិរញ្ញប្បទានរបស់សាធារណៈរដ្ឋកូរ៉េ) ក៏បានកើនឡើងគួរឱ្យកត់សំគាល់ផងដែរ (ឧបសម្ព័ន្ធទី ៣.១ និង៣.២ បង្ហាញពីការប្រៀបធៀបនៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ នៅតាមវិស័យនិមួយៗក្នុងឆ្នាំ២០០៨និង២០០៩)។ វិស័យដែលទំហំហិរញ្ញប្បទានសហប្រតិបត្តិការបាន

ធ្លាក់ចុះមានៈ វិស័យធនាគារនិងសេវាធុរៈកិច្ចថយចុះប្រមាណ៣១លានដុល្លាអាមេរិក ស្មើនឹង៧០% ។ ដោយឡែក ហិរញ្ញប្បទានសម្រាប់វិស័យកម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម ត្រូវថយចុះ២/៣ ពោលគឺធ្លាក់ចុះប្រមាណ១៧.៤លាន ដុល្លាអាមេរិកធៀបនឹងកម្រិតក្នុងឆ្នាំ២០០៨ ។ ហិរញ្ញប្បទានក្នុងវិស័យធនាគារនិងសេវាធុរៈកិច្ចបានកើនឡើងក្នុងឆ្នាំ ២០០៨ ដោយសារការបង្កើនល្បឿននៃការប្រើប្រាស់ធនធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ឆ្លើយតបទៅនឹង ឥទ្ធិពលនៃវិបត្តិកលិយុគសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក ។ យើងសង្ឃឹមថា ហិរញ្ញប្បទាននឹងកើនឡើងវិញក្នុង ឆ្នាំ២០១០ សម្រាប់វិស័យធនាគារនិងសេវាធុរៈកិច្ច និងវិស័យកម្មន្តសាល រ៉ែ និងពាណិជ្ជកម្មនេះ ។

*តារាងទី៥: ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមវិស័យ ឆ្នាំ២០០៤-២០១០*

| វិស័យ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | | ២០០៩ (ប៉ាន់ស្មាន) | | ២០១០ (ព្យាករណ៍) | |
|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លា | លានដុល្លា | លានដុល្លា | លានដុល្លា | លានដុល្លា | % | លានដុល្លា | % | លានដុល្លា | % |
| **វិស័យសង្គមកិច្ច** | | | | | | | | | | |
| សុខាភិបាល | 95,9 | 110,3 | 109,0 | 107,1 | 139,9 | 14,6 | 165,3 | 16,7 | 165,3 | 15,2 |
| ហ៊ីវ/អេដស៍ | | 25,4 | 35,4 | 42,0 | 51,3 | 5,4 | 45,0 | 4,5 | 60,5 | 5,6 |
| អប់រំ | 73,4 | 69,3 | 79,7 | 89,9 | 105,4 | 11,0 | 103,3 | 10,4 | 101,1 | 9,3 |
| **សរុប** | **169,3** | **205** | **224,1** | **239** | **296,6** | **31** | **313,6** | **31,6** | **169,3** | **205** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | | | |
| កសិកម្ម | 45,3 | 33,8 | 123,5 | 46,4 | 57,4 | 6,0 | 91,2 | 9,2 | 95,9 | 8,8 |
| កម្មន្តសាល រ៉ែ ពាណិជ្ជកម្ម | 7,0 | 10,0 | 24,2 | 16,4 | 25,7 | 2,7 | 8,3 | 0,8 | 14,4 | 1,3 |
| អភិវឌ្ឍន៍ជនបទ | 60,5 | 50,0 | 49,9 | 68,0 | 62,4 | 6,5 | 61,7 | 6,2 | 61,5 | 5,7 |
| សេវាកម្មធនាគារ និងធុរកិច្ច | | 12,7 | 9,7 | 15,9 | 44,9 | 4,7 | 13,2 | 1,3 | 58,5 | 5,4 |
| ផែនការទីក្រុងនិងការគ្រប់គ្រង | | 3,9 | 0,9 | 2,0 | 4,5 | 0,5 | 5,7 | 0,6 | 3,9 | 0,4 |
| **សរុប** | **112,8** | **110,4** | **208,2** | **148,7** | **194,9** | **20,4** | **180,1** | **18,1** | **112,8** | **110,4** |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | |
| ព័ត៌មាន និងទូរគមនាគមន៍ | 1,2 | 0,9 | 9,9 | 26,3 | 7,2 | 0,8 | 26,6 | 2,7 | 2,8 | 0,3 |
| ថាមពល និងអគ្គិសនី | 12,9 | 15,6 | 13,7 | 12,7 | 32,8 | 3,4 | 30,6 | 3,1 | 61,7 | 5,7 |
| ដឹកជញ្ជូន | 82,0 | 73,9 | 54,8 | 97,4 | 143,0 | 15,0 | 172,0 | 17,4 | 177,9 | 16,4 |
| ទឹកស្អាត និងអនាម័យ | 4,9 | 24,5 | 18,2 | 17,2 | 19,3 | 2,0 | 21,5 | 2,2 | 31,2 | 2,9 |
| **សរុប** | **101** | **114,9** | **96,6** | **153,6** | **202,3** | **21,2** | **250,7** | **25,4** | **101** | **114,9** |
| **សេវាកម្ម និងកម្មវិធីអន្តរវិស័យ** | | | | | | | | | | |
| សហគមន៍ | 43,7 | 35,3 | 38,5 | 56,9 | 49,2 | 5,2 | 53,2 | 5,4 | 26,2 | 2,4 |
| វប្បធម៌ និងសិល្បៈ | 18,4 | 4,8 | 14,1 | 7,3 | 10,1 | 1,1 | 8,6 | 0,9 | 8,8 | 0,8 |
| បរិស្ថាន និងអភិរក្ស | 19,6 | 12,3 | 14,6 | 8,3 | 7,6 | 0,8 | 12,9 | 1,3 | 11,1 | 1,0 |
| យេនឌ័រ | | 2,6 | 3,8 | 5,7 | 5,7 | 0,6 | 6,1 | 0,6 | 8,1 | 0,7 |
| អភិបាលកិច្ច និងរដ្ឋបាល | 46,8 | 67,3 | 96,8 | 108,0 | 120,1 | 12,6 | 109,6 | 11,1 | 141,2 | 13,0 |
| ទេសចរណ៍ | | 1,2 | 2,5 | 2,9 | 4,9 | 0,5 | 5,8 | 0,6 | 2,8 | 0,3 |
| ហិរញ្ញប្បទានទ្រទ្រង់ថវិកា | | 11,1 | 0,0 | 36,0 | 22,4 | 2,3 | 19,9 | 2,0 | 28,1 | 2,6 |
| ស្បៀង និងសង្គ្រោះបន្ទាន់ | | 3,0 | 0,4 | 1,9 | 2,6 | 0,3 | 4,2 | 0,4 | 1,5 | 0,1 |
| **សរុប** | **128,5** | **137,6** | **170,7** | **227** | **222,6** | **23,4** | **220,3** | **22,3** | **128,5** | **137,6** |
| ផ្សេងៗ | 43,9 | 42,0 | 13,4 | 9,2 | 38,9 | 4,1 | 24,8 | 2,5 | 23,5 | 2,2 |
| **សរុប** | **555,4** | **610,0** | **713,2** | **777,5** | **955,6** | **100** | **989,5** | **100** | **1.085,9** | **100** |

បើប្រៀបធៀបរវាងឆ្នាំ២០០៤ និងឆ្នាំ២០០៥ ដែលជាឆ្នាំមុនពេលបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ជាមួយនឹងឆ្នាំ២០០៨ និងឆ្នាំ២០០៩ យើងពិនិត្យឃើញថា វិស័យសុខាភិបាល ហ៊ីវ/អេដស៍ អប់រំ យេនឌ័រ

អភិបាលកិច្ច និងពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធគឺជាបណ្តាវិស័យដែលបានទទួលហិរញ្ញប្បទានច្រើនជាងវិស័យដទៃទៀត ក្នុងពេលដែលហិរញ្ញប្បទានក្នុងវិស័យកសិកម្មអាចកើនឡើងបន្តិចបន្តួចនាពេលអនាគត ។ ផ្ទុយទៅវិញ និន្នាការនៃហិរញ្ញប្បទានសម្រាប់វិស័យទឹកស្អាតនិងអនាម័យ និងវិស័យអភិវឌ្ឍន៍ជនបទ (រួមទាំងអនុវិស័យ- ការផ្គត់ផ្គង់ទឹកជនបទ) ព្រមទាំងវិស័យបរិស្ថាននិងអភិរក្ស បានទទួលហិរញ្ញប្បទានក្នុងកម្រិតថេរ (ទោះបីជាពេលបច្ចុប្បន្ន អាចទទួលហិរញ្ញប្បទានច្រើនជាងមុន សម្រាប់បន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុក៏ដោយ) ។

គំនូរទី៦ បង្ហាញពីនិន្នាការពីរនៃហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ ។ រូបភាពខាងឆ្វេងឆ្លុះបញ្ចាំងពីការកើនឡើងនៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូន ដែលជាវិស័យទទួលបានហិរញ្ញប្បទានច្រើនជាងគេបង្អស់ក្នុងឆ្នាំ២០១០ ជំនួសឱ្យវិស័យសុខាភិបាល (លើកលែងហ៊ីវ/អេដស៍) និងវិស័យកសិកម្ម ។ ទន្ទឹមនឹងនេះ ក៏មានការប្រែប្រួល«ឡើង- ចុះ»ក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យដទៃទៀតផងដែរ ដូចជាសេវាធនាគារនិងសេវាធុរៈកិច្ច អភិបាលកិច្ច និងហ៊ីវ/អេដស៍ ។ រីឯគំនូរខាងស្តាំវិញក៏បានបង្ហាញថា ទោះបីទំហំហិរញ្ញប្បទានមានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០០៨ និងឆ្នាំ២០០៩ក៏ដោយ ក៏មានបំរែបំរួលគួរឱ្យកត់សំគាល់ពីវិស័យមួយទៅវិស័យមួយដែរ ។ ជាក់ស្តែងគឺ ហិរញ្ញប្បទានផ្តល់សម្រាប់វិស័យចំនួនជិតពាក់កណ្តាល បានកើនឡើងប្រមាណ៣៣លានដុល្លាអាមេរិក ទន្ទឹមនឹងពេលដែលហិរញ្ញប្បទានសម្រាប់វិស័យដទៃបានធ្លាក់ចុះក្នុងបរិមាណប្រហាក់ប្រហែលគ្នា ។

*គំនូរទី៦:និន្នាកាតាមវិស័យ (លានដុល្លាអាមេរិក)*




## ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមបណ្តាខេត្ត

ការធ្វើសុពលភាពទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា បានលើកកំពស់គុណភាពក្នុងការវិភាគបានប្រសើរជាងមុនអំពីនិន្នាការនៃការផ្តល់ហិរញ្ញប្បទាននៅតាមបណ្តាខេត្ត ។ ក្នុងឆ្នាំ២០០៩ ហិរញ្ញប្បទានសហប្រតិបត្តិការប្រមាណ៦០% ត្រូវបានផ្តល់ជូនបណ្តាខេត្ត ។ តារាងទី៦បានបង្ហាញថា ក្នុងឆ្នាំ២០០៩ ខេត្តចំនួន១០បានទទួលហិរញ្ញប្បទានសហប្រតិបត្តិការច្រើនជាងគេ ប្រមាណ៣៧០លានដុល្លាអាមេរិក ធៀបនឹងខេត្ត១៤ទៀត ដែលទទួលបានត្រឹមតែ២៧៥លានដុល្លាអាមេរិកប៉ុណ្ណោះ ។ រាជធានីភ្នំពេញទទួលហិរញ្ញប្បទានច្រើនជាងគេ ប្រមាណ៧១លានដុល្លាអាមេរិក ។ បន្ទាប់មកគឺខេត្ត សៀមរាបប្រមាណ៥៦លានដុល្លាអាមេរិក និងខេត្តបាត់ដំបងទទួលប្រមាណ៣៧,៥លានដុល្លាអាមេរិក ។រីឯខេត្តកែប និងកោះកុង ទទួលហិរញ្ញ-ប្បទានទាបជាងគេ ប្រមាណ៤លានដុល្លាអាមេរិកតែប៉ុណ្ណោះសម្រាប់ខេត្តនិមួយៗ ។

*តារាងទី៦- ការគាំទ្រតាមខេត្ត (លានដុល្លា)*

| ខេត្ត/រាជធានី | 2007 | 2008 | 2009 (ប៉ាន់ស្មាន) | 2010 (ព្យាករណ៍) |
|---|---|---|---|---|
| ភ្នំពេញ | 69,1 | 75,0 | 71,1 | 59,9 |
| សៀមរាប | 43,2 | 55,4 | 56,1 | 58,6 |
| បាត់ដំបង | 21,2 | 29,9 | 37,5 | 36,7 |
| កណ្តាល | 53,8 | 77,9 | 37,0 | 45,9 |
| កំពង់ធំ | 16,6 | 20,6 | 36,4 | 43,4 |
| ព្រះសីហនុ | 41,6 | 25,3 | 36,3 | 43,6 |
| មណ្ឌលគីរី | 13,8 | 18,7 | 25,4 | 19,1 |
| ព្រះវិហារ | 4,8 | 8,8 | 25,1 | 27,7 |
| កំពង់ឆ្នាំង | 8,8 | 18,5 | 22,6 | 26,6 |
| បន្ទាយមានជ័យ | 15,9 | 21,6 | 22,5 | 27,0 |
| ខេត្តដទៃ | 164,7 | 190,6 | 214,5 | 291,9 |
| ទូទាំងប្រទេស | 324,0 | 413,2 | 404,9 | 405,4 |
| ***សរុប*** | **777,5** | **955,6** | **989,5** | **1085,5** |

*គំនូរទី៧: ការគាំទ្រតាមបណ្តាខេត្ត (ដុល្លាសម្រាប់ប្រជាជនម្នាក់ៗ)*




របាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឆ្នាំ២០០៨ បានគូសបញ្ជាក់ថា មានខេត្ត២ទទួលបានហិរញ្ញប្បទានខ្ពស់ជាងគេក្នុងប្រជាជនម្នាក់ ពោលគឺ ខេត្តព្រះសីហនុ និងខេត្តមណ្ឌលគីរី ។ គំនូរទី ៦ បង្ហាញថាក្នុងឆ្នាំ២០០៩ ខេត្តមណ្ឌលគីរីបន្តទទួលហិរញ្ញប្បទានកម្រិតខ្ពស់ជាងគេ ចំនួន ៤10ដុល្លាអាមេរិកក្នុងមនុស្សម្នាក់ ។ បន្ទាប់មក ខេត្តព្រះសីហនុទទួលបានចំនួន ១៦១ ដុល្លាអាមេរិក ។ ខេត្តព្រះវិហារចំនួន ១៤៥ ដុល្លាអាមេរិក និងខេត្តប៉ៃលិនចំនួន ១៤១ ដុល្លាអាមេរិក ។រីរាជធានីភ្នំពេញបានទទួលហិរញ្ញប្បទានសហប្រតិបត្តិការ ចំនួន៧៣ ដុល្លាអាមេរិកក្នុងមនុស្សម្នាក់ ទាបជាងបន្តិចបន្តួច ធៀបនឹងមធ្យមភាគទូទាំងប្រទេស ដែលមាន៧៣ដុល្លាអាមេរិកក្នុងមនុស្សម្នាក់។ ដោយឡែក ខេត្តកំពង់ចាមនិងខេត្តស្វាយរៀង បានទទួលហិរញ្ញប្បទានប្រមាណ១០-១៥ដុល្លាអាមេរិកក្នុងមនុស្ស ម្នាក់ ។ នេះបញ្ជាក់ថា ទិន្នន័យទាំងនេះមានសង្គតិភាពជាមួយនឹងទិន្នន័យដែលបានវិភាគ ក្នុងរយៈពេលកន្លងមក ។

គំនូរទី៧ក៏បង្ហាញអំពីភាពប្រសើរឡើង ក្នុងការប្រមូលទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ក្នុងនោះ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ការគាំទ្រជាដុំកំភួន នៅតាមបណ្តាខេត្តជាច្រើន ពិសេសនៅខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តមណ្ឌលគីរី ។ ជាទូទៅ ទិន្នន័យខាងលើនេះបានបង្ហាញថា ការគាំទ្រតាមខេត្តដោយដៃគូអភិវឌ្ឍន៍មានលក្ខណៈល្អប្រសើរ ពិសេសតាមរយៈការគាំទ្រមូលនិធិឃុំ/សង្កាត់ ។ ឧបសម្ព័ន្ធទី៣.៧ បង្ហាញអំពីទិន្នន័យលំអិតស្តីពីការគាំទ្រតាមបណ្តាខេត្ត ។

## ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស

ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាម«ប្រព័ន្ធអនឡាញ» សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៩ បានបង្កើនគុណភាពក្នុងការប្រមូលទិន្នន័យ និងការធ្វើសុពលភាពសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ប្រព័ន្ធទិន្នន័យនេះបានបង្ហាញអំពីតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ។ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានដឹកនាំការប្រមូលទិន្នន័យ ដើម្បីពង្រីកវិសាលភាពនៃការប្រមូលទិន្នន័យ និងដើម្បីបង្កើនគុណភាពនៃទិន្នន័យទាំងនេះ ។ ជាលទ្ធផលជាក់ស្តែង រហូតដល់ពេលបច្ចុប្បន្ន គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបណ្តុះបណ្តាលអំពីការបញ្ចូលទិន្នន័យ និងការប្រើប្រាស់ប្រព័ន្ធទិន្នន័យនេះ ដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិចំនួន២៦៩ និងក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលជាតិចំនួន១៦ ។ កម្មវិធីបណ្តុះបណ្តាលនេះបានផ្តល់កាលានុវត្តភាពសម្រាប់ពិគ្រោះយោបល់អំពីការចែករំលែកព័ត៌មាន ក្នុងទិសដៅដើម្បីបង្កើនគណនេយ្យភាព និងការសម្របសម្រួល ។

ម្យ៉ាងវិញទៀត តួនាទីក្នុងការផ្តល់សេវាកម្ម និងការគាំទ្រកម្រិតគោលនយោបាយរបស់អង្គការមិនមែនរដ្ឋាភិបាលកាន់តែមានសារៈសំខាន់ក្នុងកិច្ចការអភិវឌ្ឍន៍ជាតិ ។ ដូចនេះ ការចែករំលែកទិន្នន័យក្នុងឆ្នាំ២០០៩ ដោយផ្អែកលើមូលដ្ឋាននៃការកសាងមូលដ្ឋានទិន្នន័យក្នុងរយៈពេលកន្លងមក គឺជាកត្តាសំខាន់ក្នុងការបង្កើនការយល់ដឹងទៅលើសកម្មភាពរបស់អង្គការទាំងនោះ ។ ផ្អែកតាមទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល ធនធានផ្ទាល់របស់ពួកគេមានប្រមាណ១០៣លានដុល្លាអាមេរិកនៅឆ្នាំ២០០៩ ពោលគឺស្មើនឹង១០%នៃហិរញ្ញប្បទានសហប្រតិបត្តិការសរុប (មិនគិតបញ្ចូលធនធានដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍) ។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថានៅឆ្នាំ២០០៩ ហិរញ្ញប្បទានសហប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាលភាគច្រើន បានផ្តល់ឱ្យខេត្ត ប្រមាណ ២០%នៃហិរញ្ញប្បទានសរុបដែលបានផ្តល់ជូនថ្នាក់ក្រោមជាតិ ដែលហិរញ្ញប្បទាននេះមានទំហំប្រហាក់ប្រហែលនឹងឆ្នាំ២០០៧ និងឆ្នាំ២០០៨ដែរ ។ ហិរញ្ញប្បទានសហប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនបានផ្តល់ជូនខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តមណ្ឌលគិរី ។ ប៉ុន្តែ ខេត្តមួយចំនួនទៀតក៏ទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការច្រើនផងដែរ ដូចជាខេត្តតាកែវប្រមាណ៣៤% ខេត្តកោះកុង ៣១% ខេត្តព្រះវិហារ ២៦% និងខេត្តកំពង់ស្ពឺ ២៤% ។ លើសពីនេះ អង្គការមិនមែនរដ្ឋាភិបាល បានបន្តផ្តោតការយកចិត្តទុកដាក់របស់ខ្លួននៅក្នុងវិស័យសង្គមកិច្ច ។ តារាងទី៧ បានបង្ហាញថាធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាលបានផ្តោតជាសំខាន់ទៅលើវិស័យសុខាភិបាល ប្រមាណជាង៣០%នៃទំហំហិរញ្ញប្បទានផ្ទាល់ក្នុងឆ្នាំ២០០៨ និងឆ្នាំ២០០៩ ។ បន្ទាប់មកគឺវិស័យអប់រំ និងសុខុមាលភាពសហគមន៍ ។ របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលបានបង្ហាញថា ហិរញ្ញប្បទានផ្ទាល់សម្រាប់ចូលរួមក្នុងកិច្ចអភិវឌ្ឍន៍នៅឆ្នាំ២០០៩ មានត្រឹមតែ១០៣លានដុល្លាអាមេរិក ពោលគឺថយចុះបន្តិចបន្តួច ធៀបនឹងឆ្នាំ២០០៨ ដែលមានរហូតដល់ ១០៤,៧លានដុល្លាអាមេរិក ។

លើសពីនេះទៅទៀត ក្រៅពីការផ្តល់ហិរញ្ញប្បទានផ្ទាល់ អង្គការមិនមែនរដ្ឋាភិបាលបានដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍មួយចំនួនបន្ថែមទៀត ។ ក្នុងតួនាទីជាភ្នាក់ងារអនុវត្តន៍ អង្គការ

*តារាងទី៧: ធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាលសម្រាប់កិច្ចសហប្រតិបត្តិការនិងតាមវិស័យ ឆ្នាំ២០០៨-២០០ (លានដុល្លាអាមេរិក)*

| វិស័យ | ២០០៨ | | | | | | ២០០៩ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធនធានផ្ទាល់ | | គាំទ្រដោយដៃគូអភិវឌ្ឍន៍ | | សរុប | | ធនធានផ្ទាល់ | | គាំទ្រដោយដៃគូអភិវឌ្ឍន៍ | | សរុប | |
| | ដុល្លា | % | ដុល្លា | % | ដុល្លា | % | ដុល្លា | % | ដុល្លា | % | ដុល្លា | % |
| សុខាភិបាល | 36,7 | 35,1 | 21,2 | 21,2 | 57,9 | 28,3 | 32,4 | 31,4 | 21,2 | 21,2 | 53,6 | 26,4 |
| សុខុមាលភាពសហគមន៍ | 31,4 | 30,0 | 6,2 | 6,2 | 37,6 | 18,4 | 31,6 | 30,6 | 6,2 | 6,2 | 37,8 | 18,6 |
| អប់រំ | 26,8 | 25,6 | 6,9 | 6,9 | 33,7 | 16,4 | 27,5 | 26,7 | 6,9 | 6,9 | 34,4 | 16,9 |
| បរិស្ថាន និងអភិរក្ស | 1,5 | 1,4 | 1,9 | 1,9 | 3,4 | 1,7 | 5,1 | 4,9 | 1,9 | 1,9 | 7,0 | 3,4 |
| អេដស៍ | 5,2 | 5,0 | 18,5 | 18,5 | 23,7 | 11,6 | 3,1 | 3,0 | 18,5 | 18,5 | 21,6 | 10,6 |
| អភិវឌ្ឍន៍ជនបទ | 1,3 | 1,2 | 6,9 | 6,9 | 8,2 | 4,0 | 1,4 | 1,4 | 6,9 | 6,9 | 8,3 | 4,1 |
| កសិកម្ម | 1,2 | 1,1 | 2,6 | 2,6 | 3,8 | 1,9 | 1,3 | 1,3 | 2,6 | 2,6 | 3,9 | 1,9 |
| យេនឌ័រ | 0,2 | 0,2 | 1,9 | 1,9 | 2,1 | 1,0 | 0,3 | 0,3 | 1,9 | 1,9 | 2,2 | 1,1 |
| អភិបាលកិច្ច និងរដ្ឋបាល | 0,2 | 0,2 | 20,0 | 20,0 | 20,2 | 9,9 | 0,1 | 0,1 | 20,0 | 20,0 | 20,1 | 9,9 |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | 0,0 | 0,0 | 9,1 | 9,1 | 9,1 | 4,4 | 0,0 | 0,0 | 9,1 | 9,1 | 9,1 | 4,5 |
| ផ្សេងៗ | 0,2 | 0,2 | 5,0 | 5,0 | 5,2 | 2,5 | 0,3 | 0,3 | 5,0 | 5,0 | 5,3 | 2,6 |
| **សរុប** | **104,7** | **100** | **100,2** | **100** | **204,9** | **100** | **103,1** | **100** | **100,2** | **100** | **203,3** | **100** |

មិនមែនរដ្ឋាភិបាលបានអនុវត្តគម្រោងមួយចំនួនដែលហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ប្រមាណ១០០លានដុល្លាអាមេរិកទៀត នៅឆ្នាំ២០០៨ និងឆ្នាំ២០០៩ ។ តារាងទី៧ខាងលើបានបង្ហាញថា ហិរញ្ញប្បទានដែលបានទទួលពីដៃគូអភិវឌ្ឍន៍ ត្រូវបានប្រើប្រាស់នៅក្នុងវិស័យសំខាន់មួយចំនួន ប្រហាក់ប្រហែលនឹងវិស័យដែលធនធានផ្ទាល់របស់ខ្លួនត្រូវបានប្រើប្រាស់ដែរ ដូចជាការថែទាំសុខភាព ដែលត្រូវបានបំពេញបន្ថែមដោយដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងការផ្តល់សេវាថែទាំជម្ងឺអេដស៍ និងសេវាផ្នែកសុខុមាលភាពសហគមន៍ ។ ដៃគូអភិវឌ្ឍន៍ក៏បានផ្តល់ហិរញ្ញប្បទានបន្ថែមសម្រាប់គាំទ្រសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងវិស័យអប់រំ កសិកម្មនិងអភិវឌ្ឍន៍ជនបទផងដែរ ដោយពួកគេបានផ្តល់ហិរញ្ញប្បទានជាច្រើនបន្ថែមទៀត សម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទានជាច្រើនតាមរយៈអង្គការមិនមែនរដ្ឋាភិបាល សម្រាប់គាំទ្រវិស័យអភិបាលកិច្ចប្រមាណ២០%នៃហិរញ្ញប្បទានសរុបរបស់ដៃគូអភិវឌ្ឍន៍ ក្នុងពេលដែលអង្គការមិនមែនរដ្ឋាភិបាលបានចំណាយធនធានផ្ទាល់មួយភាគតូចសម្រាប់កិច្ចការនេះ ។ ដូចគ្នានេះដែរ អង្គការមិនមែនរដ្ឋាភិបាលក៏បានផ្តោតសកម្មភាពជាសំខាន់ ទៅលើការអភិវឌ្ឍន៍វិស័យឯកជន ក្នុងផ្នែកកម្មន្តសាលនិងពាណិជ្ជកម្ម ទោះបីជាហិរញ្ញប្បទាន ១០០% នេះត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ក៏ដោយ ។

អង្គការមិនមែនរដ្ឋាភិបាលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍន៍ប្រទេស ។ តារាងទី៧ ក៏បានបង្ហាញថា ពួកគេបានផ្តល់ ឬបានគ្រប់គ្រងហិរញ្ញប្បទានប្រមាណ២០%នៃហិរញ្ញប្បទានសរុបដែលបានផ្តល់ឱ្យកម្ពុជា ។ ទន្ទឹមនឹងនេះ យើងនៅមានការងារជាច្រើនដែលត្រូវប្រឹងប្រែងអនុវត្តបន្តទៀត ដើម្បីឈានទៅសម្រេច

គោលដៅនៃ«យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២» និង«គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា» ។ ភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ទាំងអស់ ត្រូវទទួលស្គាល់អំពីពិពិធកម្ម និងតួនាទីបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីធានាតួនាទីរបស់ដៃគូនីមួយៗនៅក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។ ក្នុងកិច្ចខិតខំប្រឹងប្រែងសម្រាប់ជម្រុញគណនេយ្យភាពក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន អង្គការមិនមែនរដ្ឋាភិបាលបានបង្កើត«ប្រព័ន្ធវិញ្ញាបនប័ត្រស្ម័គ្រចិត្ត» ហើយបានអនុវត្តប្រព័ន្ធនេះអស់រយៈពេល៣ឆ្នាំមក ។ ការរៀបចំប្រព័ន្ធនេះត្រូវបានដឹកនាំដោយគណៈកម្មាធិការសហប្រតិបត្តិការកម្ពុជា ហើយបានផ្អែកលើ«ក្រមសីលធម៌វិជ្ជាជីវៈ» និង«កម្រិតស្តង់ដារអប្បរមា» របស់សហគមន៍អង្គការមិនមែនរដ្ឋាភិបាល ។ នាចុងឆ្នាំ២០០៩ កន្លងមក អង្គការមិនមែនរដ្ឋាភិបាលចំនួន៣៨ បានអនុវត្តប្រព័ន្ធនេះ ហើយមានតែអង្គការមិនមែនរដ្ឋាភិបាលចំនួន១៦ប៉ុណ្ណោះ ដែលទទួលបានវិញ្ញាបនប័ត្រ ។

## ***<u>គោលការណ៍នានានៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការៈ សក្ខីកម្មនៃការអនុវត្តន៍</u>***

ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលរបស់រាជរដ្ឋាភិបាល បានឈានដល់ឆ្នាំចុងក្រោយនៃការអនុវត្តន៍ផែនការ៥ឆ្នាំរបស់ខ្លួន នាឆ្នាំ២០១០នេះ ។ ទន្ទឹមនឹងនេះ ការប្តេជ្ញាកម្រិតសកលនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ក៏រំពឹងថានឹងសម្រេចបាននាដំណាច់ឆ្នាំ២០១០ផងដែរ ។ ក្នុងស្មារតីនេះ របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅក្នុងជំពូកទី៣នេះនឹងផ្តល់កាលានុវត្តភាពសម្រាប់ពិនិត្យឡើងវិញអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍គោលការណ៍ទាំង៥ គឺ : ភាពជាម្ចាស់ ការតម្រឹម សុខដុមនីយកម្ម ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងគណនេយ្យភាពទ្វេទិស ដែលទាំងនេះគឺជាគោលការណ៍ណែនាំសម្រាប់ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ សក្ខីកម្មនានាក្នុងជំពូកនេះត្រូវបានដកស្រង់ចេញពីប្រភពជាច្រើន ពិសេសលទ្ធផលបឋមនៃការវាយតម្លៃកម្រិតសកលក្នុងការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដែលកម្ពុជានឹងផ្តល់ធាតុចូល តាមរយៈរបាយការណ៍វាយតម្លៃក្នុងការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងរបាយការណ៍នានារបស់ក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ របាយការណ៍ស្តីពីការអនុវត្តន៍សូចនាករតាមដានរួមគ្នា របាយការណ៍វាយតម្លៃ និងកម្មវិធីគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការដោយពហុដៃគូអភិវឌ្ឍន៍ (ធនធានដែលដៃគូអភិវឌ្ឍន៍បានគាំទ្រគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា) ព្រមទាំងឯកសារកម្រិតគោលនយោបាយ និងសុន្ទរកថាជាច្រើនទៀត ។

## ***<u>ភាពជាម្ចាស់</u>***

«ភាពជាម្ចាស់» ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស បានផ្តោតត្រឹមការរៀបចំនិងការអនុវត្តន៍ផែនការអភិវឌ្ឍន៍ជាតិដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាពតែប៉ុណ្ណោះ ។ ប៉ុន្តែ សក្ខីកម្មដែលបានទទួលពីការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជា បានបង្ហាញអំពីភាពខ្វះចន្លោះក្នុងការកំណត់និយមន័យនេះ ។ សក្ខីកម្មទាំងនេះបានគាំទ្រការវិភាគដែលបានធ្វើកន្លងមក ដោយផ្តោតទៅលើទំនាក់ទំនងរវាងភាពដឹកនាំ និងការអភិវឌ្ឍន៍សមត្ថភាព ដើម្បីឈានទៅពង្រឹង«ភាពជាម្ចាស់» ឱ្យបានពេញលេញ និងប្រកបដោយចីរភាព ។ ភាពដឹកនាំនិងការអភិវឌ្ឍន៍សមត្ថភាពគឺជាកត្តា២ ដែលជួយពង្រឹងឱ្យគ្នាទៅវិញទៅមកសម្រាប់កំណត់ភាពជាម្ចាស់ ហើយក៏ជាលទ្ធភាពសម្រាប់ឈានទៅសម្រេចលទ្ធផលផងដែរ ។

កន្លងមក យើងមានឧទាហរណ៍ជាវិជ្ជមានជាច្រើនសម្រាប់ឆ្លុះបញ្ចាំងអំពីគំនិតផ្តួចផ្តើមនានាសម្រាប់ពង្រឹងភាពដឹកនាំ និងសមត្ថភាពនៅកម្រិតវិស័យ តាមរយៈការរៀបចំផែនការយុទ្ធសាស្រ្តតាមវិស័យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមានសង្គតិភាព សម្រាប់ធ្វើជាមូលដ្ឋានគ្រឹះជម្រុញឱ្យដៃគូអភិវឌ្ឍន៍ចូលរួម និងផ្តល់ការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលបានរៀបចំបញ្ចប់អនុកម្មវិធីទាំង៥នៃយុទ្ធសាស្រ្តស្តីពីវិស័យកសិកម្មនិងទឹក ហើយកំពុងរៀបចំយន្តការសម្រាប់អនុវត្ត ដោយត្រូវរំលេចកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលក្នុងគោលដៅដើម្បីធានាសង្គតិភាពរវាងអាទិភាពនៃការអភិវឌ្ឍន៍សមត្ថភាពជាមួយនឹងគោលដៅរួមរបស់រាជរដ្ឋាភិបាល ។ ក្រសួងនិងស្ថាប័នពាក់ព័ន្ធដទៃទៀត ដូចជា ក្រសួងសុខាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងពាណិជ្ជកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កសិកម្មនិងជនបទ ព្រមទាំងអាជ្ញាធរមីនកម្ពុជា បានផ្តល់សារៈសំខាន់របស់ខ្លួនលើការរៀបចំផែនការយុទ្ធសាស្រ្ត សម្រាប់ធ្វើជាមូលដ្ឋាន ក្នុងការពង្រឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនាពេលអនាគត ។ នៅស្ទើរតែគ្រប់ករណីទាំងអស់ ផែនការយុទ្ធសាស្រ្តនេះ បានផ្តល់អត្ថប្រយោជន៍ជាច្រើនពិសេស សម្រាប់ស្វែងរកកុងសង់ស៊ុស និងភាពជាដៃគូ ដើម្បីធានាភាពជាម្ចាស់ សម្រាប់អនុវត្តប្រកបដោយជោគជ័យ ។

ស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល រួមទាំងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក្រុមការងារបច្ចេកទេសចម្រុះស្តីពីព្រៃឈើនិងបរិស្ថាន និងក្រុមការងារបច្ចេកទេសចម្រុះស្តីពីជលផល) បាន និងកំពុងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍សមត្ថភាព ។

**ការជំរុញភាពជាម្ចាស់និងលទ្ធផលក្នុងវិស័យអប់រំ**

វិស័យអប់រំផ្តល់នូវគំរូក្នុងការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីដើម្បីសម្រេចគោលដៅរបស់វិស័យនិងដើម្បីជម្រុញការអនុវត្តន៍ការប្តេជ្ញាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយភាពស៊ីសង្វាក់គ្នា និងដោយផ្តោតលើលទ្ធផល ។

១- ភាពជាម្ចាស់ ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងគណនេយ្យភាពទ្វេទិស គឺជាប្រការដែលបានយកចិត្តទុកដាក់ នៅក្នុងដំណើរការរៀបចំផែនការរបស់វិស័យ និងដំណើរការពិនិត្យឡើងវិញរួមគ្នាក្នុងវិស័យនេះ ។

២- ផែនការប្រតិបត្តិប្រចាំឆ្នាំគឺជាយន្តការសម្រាប់រំលេចធនធានទាំងអស់ ដែលនេះគឺជាផ្នែកមួយនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសម្រាប់ពិភាក្សាអំពីការវិភាជន៍ធនធានសម្រាប់គាំទ្រសកម្មភាពអាទិភាព ។

៣- ពង្រឹងការគ្រប់គ្រងព័ត៌មានតាមរយៈការកែលំអរចនាសម្ព័ន្ធព័ត៌មាន និងការប្រើប្រាស់ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈរបស់វិស័យ និងផែនការប្រតិបត្តិប្រចាំឆ្នាំនិងផែនការយុទ្ធសាស្រ្តថវិកា ។

៤- ការធ្វើអង្កេតស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្រិតវិស័យត្រូវបានអនុវត្ត ដើម្បីពង្រឹងសមត្ថភាពក្នុងការតាមដាននិងគណនេយ្យភាពទ្វេទិស ។

៥- ការធ្វើអង្កេតបានផ្តល់លទ្ធផលគួរឱ្យលើកទឹកចិត្ត ពិសេសបានបង្ហាញពីកិច្ចប្រឹងប្រែងក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការបច្ចេកទេស និងការបង្កើនលំហូរហិរញ្ញប្បទានសហប្រតិបត្តិការក្នុងកម្មវិធីរបស់វិស័យនេះ ។

៦- ដៃគូអភិវឌ្ឍន៍ ១១ ក្នុងចំណោម ២២ បានប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីសម្រាបវិស័យអប់រំ ។ ប៉ុន្តែ ការប្រើប្រាស់ប្រព័ន្ធរបស់ក្រសួងអប់រំ យុវជននិងកីឡា (ពោលគឺការផ្តល់ធនធានក្នុងកញ្ចប់តែមួយដោយប្រើប្រាស់ប្រព័ន្ធជាតិ) នៅមានកម្រិតទាបនៅឡើយ ។

៧- វិស័យអប់រំនៅមាន«អង្គភាពអនុវត្តគម្រោង» ជាច្រើន ហើយក៏មិនទាន់មានការវិភាគណាមួយដែលជួយកំណត់វិសាលភាពសម្រាបក្រសួងអប់រំ យុវជន និងកីឡា ពង្រឹងប្រព័ន្ធ និងសម្រាប់សម្របសម្រួលកម្មវិធីស្រាវជ្រាវតាមរយៈសន្និបាតបូកសរុបការងារអប់រំនៅឡើយ ។

៨- ផែនការសកម្មភាពជាយុទ្ធសាស្រ្តស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបានរៀបចំ ដោយផ្អែកលើសក្ខីកម្ម និងលទ្ធផលជាក់ស្តែងនៃការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ ។

ក្រសួងអប់រំ យុវជននិងកីឡាបានបញ្ជាក់អំពីតម្រូវការចាំបាច់ដើម្បីពង្រឹងសមត្ថភាពពិសេសសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងថ្នាក់ខេត្ត ដើម្បីឈានទៅសម្រេចភាពជាម្ចាស់ទាំងស្រុង ។ ដោយឡែក ដៃគូអភិវឌ្ឍន៍បានផ្តោតការលើកទឹកចិត្តរបស់ខ្លួន ទៅលើការគាំទ្រសមត្ថភាពសម្រាបវិស័យទាំងមូល និងការប្រើប្រាស់ធនធានរួមគ្នាក្នុងកញ្ចប់តែមួយសម្រាប់គាំទ្រការអនុវត្តន៍ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ។

រីឯក្រសួងអប់រំ យុវជននិងកីឡា និងក្រុមការងារបច្ចេកទេសចម្រុះរបស់ខ្លួន ទន្ទឹមនឹងការរៀបចំផែនការតាមវិស័យ ក៏បានប្រឹងប្រែងអភិវឌ្ឍសមត្ថភាព ដោយប្រើប្រាស់អភិក្រមនៃភាពជាដៃគូ ។ វឌ្ឍនភាពត្រូវបានបង្ហាញដោយសង្ខេបក្នុងប្រអប់ខាងលើនេះ សម្រាប់ធ្វើជាគំរូអនុវត្តដល់បណ្តាក្រសួងនិងស្ថាប័ន ព្រមទាំងក្រុមការងារបច្ចេ-កទេសចម្រុះដទៃទៀត ។

នៅកម្រិតជាតិ ក្នុងឆ្នាំ២០០៩ ក្រសួងផែនការបានបន្តរៀបចំ និងអនុវត្តផែនការយុទ្ធសាស្រ្តរបស់ក្រសួង ។ ប៉ុន្តែ ផែនការយុទ្ធសាស្រ្តនេះគឺជាគំនិតផ្តួចផ្តើមដ៏លំបាកមួយសម្រាប់ចរចាជាមួយដៃគូអភិវឌ្ឍន៍ ហើយកង្វល់ដែលបានចោទកន្លងមកគឺបញ្ហាធនធាន ។ លើសពីនេះ ក្រសួងផែនការបានដឹកនាំការរៀបចំ«ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣» ដើម្បីធានាសង្គតិភាពជាមួយនឹងអាណត្តិកាលនៃយុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី២ ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្មនេះ បានបញ្ជាក់អំពីតម្រូវការណែនាំខាងធនធាន និងបានផ្តល់គោលការណ៍ណែនាំសម្រាប់ពង្រឹងភាពជាដៃគូ ព្រមទាំងបានរំលឹកឡើងវិញនូវអនុសាសន៍ដែលបានស្នើឡើងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ ដើម្បីកំណត់អភិក្រមមួយដែលអាចឆ្លុះបញ្ចាំងកំណែទម្រង់ស្នូលនានា ដោយផ្អែកលើគណនេយ្យភាពទ្វេទិស និងលទ្ធផល ។

គំនិតផ្តួចផ្តើមគន្លឹះដែលកំពុងអនុវត្តគឺការធ្វើសមាហរណកម្មរវាងថវិកា កម្មវិធីវិនិយោគសាធារណៈ និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់ពង្រឹងការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងការរៀបចំផែនការតាមវិស័យ ។ គណៈកម្មាការដឹកនាំការងាររបស់រាជរដ្ឋាភិបាល ត្រូវបានបង្កើតឡើង ហើយមានសមាជិកអចិន្ត្រៃយ៍ដែលអញ្ជើញមកពីក្រសួងនិងស្ថាប័នសំខាន់៤ គឺ : ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដើម្បីជម្រុញការងារសមាហរណកម្មនេះឱ្យមានវឌ្ឍនភាពឆាប់រហ័ស ។ លើសពីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរាយការណ៍អំពីវឌ្ឍនភាពគួរជាទីពេញចិត្ត ក្នុងការអនុវត្តន៍កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានផ្តល់ការគាំទ្រសម្រាប់រៀបចំផែនការយុទ្ធសាស្រ្តថវិការបស់បណ្តាក្រសួង ដើម្បីបំពេញបន្ថែមលើយុទ្ធសាស្រ្តរយៈពេលវែងរបស់បណ្តាក្រសួង និងដើម្បីពង្រឹងសមត្ថភាពនិងភាពជាម្ចាស់ តាមរយៈអភិក្រមមួយដែលអាចរំលេចធនធានពីគ្រប់ប្រភពទាំងអស់ ។

ចំពោះសមត្ថភាពរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាចំណុចប្រមូលផ្តុំក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ការត្រួតពិនិត្យឯករាជ្យមួយត្រូវបានរៀបចំឡើងនាពាក់កណ្តាលឆ្នាំ២០០៩ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។ របាយការណ៍ឯករាជ្យនេះបានបង្ហាញអំពីវឌ្ឍនភាពសំខាន់ៗ ជាច្រើនក្នុងការសម្រេចធាតុចេញ ។ ទន្ទឹមនឹងនេះ ក៏បានលើកឡើងអំពីបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធនឹងកិច្ចប្រឹងប្រែងសម្រាប់បង្កើនប្រសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍន៍ ។

ការត្រួតពិនិត្យឯករាជ្យនេះបានប្រើប្រាស់អភិក្រមមួយ ដោយផ្អែកលើយុទ្ធសាស្រ្តអភិវឌ្ឍន៍សមត្ថភាពរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដែលត្រូវបានរៀបចំក្នុងឆ្នាំ២០០៦ ។ របាយការណ៍នេះបានផ្តោតលើការប្រមូលធាតុចូល និងគំនិតផ្តួចផ្តើមនានាដែលបានអនុវត្ត ដើម្បីពង្រឹងស្ថាប័ន និងពង្រឹងជំនាញរបស់

*គំនូរទី ៨: សមត្ថភាព ធាតុចូល និងលទ្ធផល*




*ប្រភព: របាយការណ៍ត្រួតពិនិត្យឯករាជ្យរបស់កម្មវិធីគាំទ្រពហុដៃគូអភិវឌ្ឍន៍ ខែវិច្ឆិកា ២០០៩*

មន្ត្រីម្នាក់ៗ ។ វិធីសាស្ត្រដែលបានបង្ហាញក្នុងគំនូរទី៨ បានគូសបញ្ជាក់អំពីអង្គភាពដែលអាចសម្រេចបាននូវធាតុចេញទាំងឡាយដែលខ្លួនទទួលខុសត្រូវ ។ ផ្ទុយមកវិញ ការសម្រេចឱ្យបានលទ្ធផលត្រូវចំណុះទៅលើបរិស្ថានអនុគ្រោះពីខាងក្រៅ និងកិច្ចសហការពីភាគីពាក់ព័ន្ធដទៃទៀត ។ ក្នុងករណីកម្ពុជា ភាគីពាក់ព័ន្ធគឺក្រសួងនិងស្ថាប័ននានារបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ទាំងនេះបានឆ្លុះបញ្ចាំងអំពីបទពិសោធន៍នានាក្នុងការអនុវត្តន៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ដែលតម្រូវឱ្យភាគីពាក់ព័ន្ធទាំងអស់ធ្វើការរួមគ្នា ដោយត្រូវផ្តោតលើលទ្ធផល ។

របាយការណ៍ចុងក្រោយក៏បានបង្ហាញថា គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានពង្រីកសមត្ថភាពរបស់ខ្លួន និងបានពង្រីកការយល់ដឹងអំពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការដល់បណ្តាក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ក្នុងស្មារតីនេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានបំពេញអាណត្តិស្នូលរបស់ខ្លួនក្នុងការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ។ ប៉ុន្តែ ក៏នៅមានបញ្ហាប្រឈមសេសសល់មួយចំនួនដែលត្រូវពុះពារ ដើម្បីពង្រឹងសមិទ្ធផលដែលសម្រេចបាន ទាំងនៅផ្ទៃក្នុងស្ថាប័នរបស់ខ្លួន និងទាំងនៅស្ថាប័នដទៃ ។ ប្រការនេះបានរំលេចនៅក្នុងរបកគំហើញនៃការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដែលបានបញ្ជាក់ថា នៅពេលដែលសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសត្រូវបានយល់ដឹងជាទូទៅរួចហើយនោះ យើងអាចស្វែងរកមាគ៌ាសម្រាប់អនុវត្តរួមគ្នា មុននឹងមានការផ្លាស់ប្តូរស៊ីជម្រៅអំពីរបៀបដែលរាជ-រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននេះ ។ ប្រការនេះបានជះឥទ្ធិពលដល់ការរៀបចំ និងការគ្រប់គ្រងការអភិវឌ្ឍន៍សមត្ថភាពនាពេលអនាគត ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់ដល់លទ្ធផលនៃការស្រាវជ្រាវកម្រិតសកលនាពេលថ្មីៗនេះ ដែលបានលើកឡើងដែរថា :

> «ទំនាក់ទំនងនៃហិរញ្ញប្បទានសហប្រតិបត្តិការមាននិន្នាការមើលស្រាលដល់ភាពជាម្ចាស់ ។ អតុល្យភាពរវាងធនធាន អំណាច និងចំណេះដឹង អាចធ្វើឱ្យប្រទេសទទួលហិរញ្ញប្បទានយល់ថា អ្នកផ្តល់ហិរញ្ញប្បទានកាន់តែមានប្រៀបទៅៗ ហើយប្រទេសទទួលហិរញ្ញប្បទានទាំងនោះកាន់តែពឹងផ្អែកកាន់តែច្រើនទៅលើ អ្នកផ្តល់ហិរញ្ញប្បទាន ។ លើសពីនេះ អ្នកផ្តល់ហិរញ្ញប្បទានអាចផ្តល់អ្នកជំនាញការបច្ចេកទេសសម្រាប់ផ្តល់ចំណេះដឹង ។ ប៉ុន្តែ ជានិច្ចជាកាល ពុំទាន់ប្រាកដថា អ្នកជំនាញការទាំងនោះអាចយល់ពីយន្តការ និងបរិបទរបស់ប្រទេសទទួលហិរញ្ញប្បទានឡើយ ។ ដូចនេះ គម្លាតនិងភាពទន់ខ្សោយទាំងនេះគឺជាបញ្ហាប្រឈមបន្ថែមពីលើការពឹងផ្អែកនិងការកាត់បន្ថយឥទ្ធិពលរបស់ប្រតិបត្តិករនៃប្រទេសទទួលហិរញ្ញប្បទាន ។ គំនិតផ្តួចផ្តើមនានាពីខាងក្រៅជាច្រើនត្រូវបានប្រែក្លាយយ៉ាងឆាប់រហ័សទៅជាគំនិតផ្តួចផ្តើមរបស់ដៃគូអភិវឌ្ឍន៍» ។
>
> ECDPM « *សមត្ថភាព ការផ្លាស់ប្តូរ និងលទ្ធផលនៃការងារ*» *(២០០៨ ទំព័រទី៣)*

ប្រការនេះបានរំលឹកយើងថា សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ទាមទារឱ្យមានកំណែទម្រង់រយៈពេលវែងរបស់ភាគីពាក់ព័ន្ធទាំងអស់ តាមរយៈអភិក្រមមួយប្រកបដោយចីរភាព និងភាពអត់ធ្មត់ សំដៅឈានទៅផ្លាស់ប្តូរឥរិយាបទរបស់ភាគីទាំងសងខាង ។ ដោយឡែករបាយការណ៍លើកមុនស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាល បានឯកភាពជាមួយនឹងរបកគំហើញកម្រិតសកល ដែលបានបញ្ជាក់ថា ការផ្លាស់ប្តូរនេះទាមទារភាពដឹកនាំនៅថ្នាក់កំពូល និងកិច្ចខិតខំប្រឹងប្រែងប្រកបដោយសង្គតិភាពសម្រាប់រយៈពេលវែង ។ ការយល់ដឹងអំពីជីវភាពនៃភាពជាម្ចាស់ ភាពដឹកនាំ និងសមត្ថភាព គឺជារបកគំហើញសំខាន់ៗនៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ហើយដែលត្រូវបានលើកក្នុងសុន្ទរកថាកម្រិតគោលនយោបាយរបស់អគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៅក្នុងកិច្ចប្រជុំរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍នៅទីក្រុងប៊ែរឡាំង នាខែមិថុនា ឆ្នាំ២០០៩ កន្លងមកនេះ ។ សុន្ទរកថានេះបានគូសបញ្ជាក់អំពីតម្រូវការក្នុងការរៀនសូត្រ និងការត្រិះរិះពិចារណាលើបទពិសោធន៍ក្នុងការអនុវត្តន៍ជាក់ស្តែង ទើបយើងអាចកំណត់អភិក្រមសមស្របសម្រាប់ការងារដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ ធ្វើដូចនេះ ទើបរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍អាច ជម្រុញអន្តរសកម្មរវាងសមត្ថភាព ភាពដឹកនាំ និងភាពជាម្ចាស់ ។ កម្ពុជានឹងបន្តប្រកាន់យកអភិក្រមនេះ ដើម្បីបង្ហាញដល់សហគមន៍អន្តរជាតិ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំកិច្ចព្រមព្រៀងមួយបន្ទាប់ពីសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។

## ***ការតម្រឹម***

ការតម្រឹមមានគោលដៅសំខាន់២គឺ : ទី១- ការធានាឱ្យការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍មានសង្គតិភាពជាមួយនឹងអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងទី២- ពង្រឹងនិងប្រើប្រាស់ប្រព័ន្ធថវិការជ្ជ ប្រព័ន្ធនៃការអនុវត្តន៍ និងប្រព័ន្ធធ្វើរបាយការណ៍របស់ជាតិ ។ ការគាំទ្រដល់អាទិភាពនានារបស់ប្រទេស តម្រូវឱ្យពង្រឹងភាពអាចទស្សន៍ទាយជាមុននូវទំហំហិរញ្ញប្បទាន ដែលរបាយការណ៍បានបញ្ជាក់ថា មានភាពល្អប្រសើរក្នុងរយៈពេល៥ឆ្នាំកន្លងមក ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ដែលការរៀបចំនេះបានផ្អែកលើរបាយការណ៍និងធាតុចូលពីបណ្តាវិស័យ បានរំលេចអំពីការចាត់វិធានការណ៍នានាសម្រាប់ឆ្លើយតបនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ច ដែលជាគោលដៅមួយក្នុងបណ្តាគោលដៅដទៃទៀត ។ ផ្អែកលើសក្ដីកម្មនៃស្ថានភាពសេដ្ឋកិច្ច និងបញ្ហាប្រឈមនានាដើម្បីសម្រេចគោលដៅក្នុងវិស័យសង្គមកិច្ច «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម» បានផ្តល់កាលានុវត្តភាពសម្រាប់កំណត់អំពីរបៀបគៀរគរ និងវិភាជន៍ធនធាន ដើម្បីដោះស្រាយបញ្ហារាំងស្ទះដែលកំពុងជួបប្រទះ ក៏ដូចជាសម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រឈមថ្មីៗដែលបានកើតឡើង ចាប់តាំងពីពេលដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានចាប់ផ្តើមអនុវត្តជាលើកដំបូង ។

ដូចបានពិភាក្សានៅខាងដើមនៃជំពូកនេះ «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម» បានកំណត់អាទិភាពថ្មីៗសម្រាប់ផ្តល់ហិរញ្ញប្បទានគាំទ្រ ព្រមទាំងបានផ្តល់អនុសាសន៍ឱ្យពិនិត្យការវិភាជន៍ធនធានឡើងវិញ ដើម្បីជំរុញភាពសក្តិសិទ្ធិ និងលទ្ធផល ។ វិស័យដែលទាមទារការគាំទ្របន្ថែមទៀតនោះគឺវិស័យបរិស្ថាន ពិសេស

សម្រាប់គ្រប់គ្រងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។ ក្រសួងបរិស្ថាន ដែលទទួលខុសត្រូវក្នុងការសម្រប សម្រួលយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ បានប្រជុំគណៈកម្មាការជាតិសម្រាប់ការប្រែប្រួល អាកាសធាតុ ដើម្បីធានាការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព តាមរយៈការបង្កើត សម្ព័ន្ធភាពនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា (Cambodia Climate Change Alliance-CCCA) ។

បើពិនិត្យបញ្ហាជារួមស្តីពីការតម្រឹម យើងត្រូវពិនិត្យវឌ្ឍនភាពនៃការតម្រឹមចាប់ពីឆ្នាំ២០០៦ ដែលជាឆ្នាំ ដំបូងនៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ។ គំនូរទី៩ បានបង្ហាញអំពីវិធីសាស្ត្រដែលបាន ប្រើប្រាស់ក្នុងរបាយការណ៍លើកមុនស្តីពីប្រសិទ្ធភាព ហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីវាយតម្លៃអំពី ការតម្រឹម ដោយផ្អែកលើតម្រូវការធនធានដែលមាន ចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ផ្អែកលើ ទំហំហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានបង្ហាញ ក្នុងរបាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនាឆ្នាំ២០០៨ យើង ឃើញថា តម្រូវការធនធានសរុបប្រចាំឆ្នាំសម្រាប់ អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិមានប្រមាណ ៨៤០លានដុល្លាអាមេរិក ។ រីឯទំហំហិរញ្ញប្បទាន សហប្រតិបត្តិការឆ្នាំ២០០៩ ប្រមាណ ៩៩០លានដុល្លា អាមេរិក បានបង្ហាញពីភាពគ្រប់គ្រាន់នៃហិរញ្ញប្បទាន សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយមិនទាន់រាប់បញ្ចូលធនធានក្នុងស្រុកឡើយ ។ លើសពីនេះ ការផ្តល់ហិរញ្ញប្បទានតាមរយៈការគាំទ្រ ថវិកា បានផ្តល់ភាពបត់បែនក្នុងការអនុវត្តន៍ សម្រាប់ បំពេញកង្វះខាតធនធាននៅតាមវិស័យដែលមិនបាន ទទួលហិរញ្ញប្បទានក្នុងស្រុកឬពីគម្រោង ។ ក្នុងឆ្នាំ ២០០៩ ការគាំទ្រថវិកាតាមរយៈកម្មវិធីសម្រាប់កាត់ បន្ថយភាពក្រីក្រនិងកំណើន បានកើនឡើងបន្តិច បន្តួច ប្រមាណ៣៦លានដុល្លាអាមេរិក ធៀបនឹងឆ្នាំ ២០០៨ ទោះបីតួលេខនេះមានកម្រិតទាប ពោលគឺ ប្រមាណ៥%នៃការប្រើប្រាស់ហិរញ្ញប្បទានសរុបក៏ដោយ ។

***ការតម្រឹមការគាំទ្រសម្រាប់ការប្រែប្រួលអាកាសធាតុ***

-សម្ព័ន្ធភាពបម្រែបម្រួលអាកាសធាតុនៅកម្ពុជាត្រូវបានបង្កើត ក្រោមការដឹកនាំរបស់ក្រសួងបរិស្ថាន នាខែកុម្ភៈ ឆ្នាំ២០១០ ។

-សម្ព័ន្ធភាពនេះនឹងសម្របសម្រួលការគាំទ្រទាំងឡាយសម្រាប់ អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបម្រែបម្រួលអាកាសធាតុ និងកម្មវិធី សកម្មភាពជាតិស្តីពីការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ ។

-សម្ព័ន្ធភាពបម្រែបម្រួលអាកាសធាតុនៅកម្ពុជាបានផ្តល់កាលា នុវត្តភាពសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍កសាងភាពជា ដៃគូ និងការតម្រឹមជាមួយនឹងអាទិភាពជាតិនានា ដែលបាន កំណត់ក្នុងវេទិកាជាតិស្តីពីបម្រែបម្រួលអាកាសធាតុលើកទីមួយ នាខែតុលា ឆ្នាំ២០០៩ ។

-កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិនឹងគ្រប់គ្រងកញ្ចប់ថវិកា ចំនួន៨.៩លានដុល្លាអាមេរិក ដែលគាំទ្រដោយសហភាពអឺរ៉ុប ភ្នាក់ងារអភិវឌ្ឍន៍ដាណឺម៉ាក ភ្នាក់ងារអភិវឌ្ឍន៍ស៊ុយអ៊ែត ដើម្បី ធានាឱ្យមានសង្គតិភាពខាងងអភិក្រមសម្រាប់ជម្រុញ និងលើកទឹក ចិត្តឱ្យដៃគូអភិវឌ្ឍន៍ដទៃទៀតចូលរួម ។

-កញ្ចប់ថវិកានេះនឹងគាំទ្រដល់ការកសាងសមត្ថភាព ការគ្រប់ គ្រងព័ត៌មាន និងការផ្ទេរបច្ចេកវិទ្យា ។

-ប្រធានគណៈកម្មាការជាតិសម្រាប់បម្រែបម្រួលអាកាសធាតុ បានបញ្ជាក់ថាសម្ព័ន្ធភាពបម្រែបម្រួលអាកាសធាតុនេះគឺជារបត់ ថ្មីមួយសម្រាប់ឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ ដោយ ត្រូវចាប់ផ្តើមផ្ទេរពីការអនុវត្តន៍គម្រោងទោលឆ្ពោះទៅអភិក្រម គ្រប់គ្រងទូទាំងកម្មវិធី ។

គំនូរទី៩បានបង្ហាញអំពីតម្រូវការនិងការផ្តល់ ហិរញ្ញប្បទានជាក់ស្តែង និងការវិភាជន៍ហិរញ្ញប្បទាន ។ ទន្ទឹមនឹងនេះ ក៏បញ្ជាក់អំពីនិន្នាការនៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ដែលមានសង្គតិភាពជាមួយនឹង

ការវិភាគដែលបានរៀបចំក្នុងបណ្តាឆ្នាំកន្លងមក ។ វិស័យអភិបាលកិច្ចនិងរដ្ឋបាល និងវិស័យសុខាភិបាល និងហ៊ីវ/អេដស៍ គឺជាវិស័យដែលស្ថិតនៅពីលើខ្សែបន្ទាត់ ដោយសារមានការគាំទ្រយ៉ាងពេញលេញពីដៃគូអភិវឌ្ឍន៍ ។ នេះឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃវិស័យទាំងនេះ ទាំងនៅកម្រិតសកល ទាំងនៅកម្រិតប្រទេស ។ ទន្ទឹមនឹងនេះ វិស័យអប់រំ អភិវឌ្ឍន៍ជនបទ និងកសិកម្មដែលជាបណ្តាវិស័យអាទិភាព បែរជាមិនទាន់ទទួលធនធានគ្រប់គ្រាន់តាមតម្រូវការដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឡើយ ។ ចំណែកឯវិស័យដឹកជញ្ជូនមានការប្រែប្រួលគួរឱ្យកត់សំគាល់ក្នុងប្រវត្តិនៃការផ្តល់ហិរញ្ញប្បទាន ដែលកន្លងមក វិស័យនេះមិនបានទទួលធនធានគ្រប់គ្រាន់ ប៉ុន្តែ បច្ចុប្បន្ន បែរជាបានទទួលធនធានសមល្មម ពោលគឺមានទំហំច្រើនជាងបន្តិចបន្តួច បើធៀបនឹងតម្រូវការធនធាននៅក្នុងរបាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៨ ។

*គំនូរទី៩: ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១០*




គំនូរទី១០ ដែលបានបង្ហាញក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០០៨ ត្រូវបានរៀបចំសារជាថ្មីសម្រាប់វាយតម្លៃវឌ្ឍនភាពនៃការតម្រឹមរវាងហិរញ្ញប្បទានសហប្រតិបត្តិការនិងអាទិភាពអភិវឌ្ឍន៍ជាតិ ។ គំនូរខាងស្តាំបានបង្ហាញថា ក្នុងឆ្នាំ២០០៦ និងឆ្នាំ២០០៩ ការតម្រឹមមានភាពប្រសើរឡើងច្រើន ។ ប្រការនេះអាចបញ្ជាក់បានតាមរយៈការវិភាគដែលបានបង្ហាញនៅក្នុងគំនូរខាងឆ្វេង ដែលបានបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងរវាងតម្រូវការធនធានដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការផ្តល់ហិរញ្ញ-ប្បទានជាក់ស្តែងក្នុងឆ្នាំ២០០៩ ។ ទំនាក់ទំនងនេះក៏បានបង្ហាញអំពីកម្រិតហិរញ្ញប្បទានដែលបានផ្តល់លើសពីការវិភាជន៍តម្រូវការសម្រាប់វិស័យមួយចំនួន ។ ចំពោះវិស័យខ្លះទៀត ការផ្តល់ហិរញ្ញប្បទានបែរជាទាបជាងតម្រូវការទៅវិញ (ការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យកសិកម្មក្នុងឆ្នាំ២០០៦មានកម្រិតខ្ពស់ ដោយសារការលុបបំណុលរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ) ។

ការតម្រឹមជាមួយនឹងអាទិភាពជាតិ គិតតាមបរិមាណសរុប និងតាមសមាមាត្រ ពិតជាមានវឌ្ឍនភាពជាវិជ្ជមាន ទោះបីជាទាមទារឱ្យមានកិច្ចប្រឹងប្រែងបន្តទៀតក៏ដោយ ។ ចំពោះគោលដៅទី២នៃការតម្រឹមគឺ ការប្រើប្រាស់ប្រព័ន្ធជាតិវិញ វឌ្ឍនភាពនៅមានកម្រិតនៅឡើយ ។ សហគមន៍អន្តរជាតិបានឯកភាពថា នេះគឺជាបញ្ហាទូទៅ ហើយពួកគេបានយល់ព្រមបញ្ចូល «ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលគឺជាជម្រើសទីមួយ» ទៅក្នុងផែនការសកម្មភាពទីក្រុងអាក្រា ឆ្នាំ២០០៨ ។ ទោះជាយ៉ាងនេះក្តី ក៏ជាការលំបាករបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តន៍ការប្តេជ្ញានេះនៅតាមគម្រោងនិងកម្មវិធីនានា ។ ក្នុងឆ្នាំ២០០៩ បញ្ហានេះមានលក្ខណៈកាន់តែស្រួច

ស្រាវទៅៗ ហើយភាគីទាំងសងខាងបានផ្តោតការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនទៅលើការអភិវឌ្ឍន៍សមត្ថភាព និងប្រព័ន្ធ ដើម្បីធានាសង្គតិភាពជាមួយនឹងគោលដៅទូទៅនៃកំណែទម្រង់រយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

*តំនូវទី១០: ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦*




ក្នុងរយៈពេលមធ្យម ការអនុវត្តន៍កម្មវិធីកំណែទម្រង់ស្នូល ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការនិងវិសហមជ្ឈការ គឺជាចំណុចចាប់ផ្តើមរបស់ដៃគូអភិវឌ្ឍន៍ ។ វិមជ្ឈការបានផ្តល់គំរូសម្រាប់រយៈពេលវែងក្នុងលំហូរហិរញ្ញប្បទានតាមរយៈប្រព័ន្ធរាជរដ្ឋាភិបាល ។ មូលនិធិឃុំ/ សង្កាត់ និងការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រថវិកាតាមបណ្តាក្រសួងពាក់ព័ន្ធ តាមរយៈកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងផ្តល់លទ្ធផលគួរឱ្យកត់សម្គាល់ក្នុងរយៈពេលវែង ។ ទន្ទឹមនឹងនេះ វិស័យអប់រំ និងសុខាភិបាលក៏បានផ្តល់ជាឧទាហរណ៍សំខាន់ផងដែរ សម្រាប់បញ្ជាក់អំពីសារៈសំខាន់នៃសមត្ថភាព និងភាពដឹកនាំ ក្នុងការបង្កើនបរិស្ថានអនុគ្រោះមួយសម្រាប់ជម្រុញដៃគូអភិវឌ្ឍន៍ក្នុងការពង្រឹងប្រព័ន្ធជាតិ ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា ដែលគ្រប់គ្រងដោយគណៈកម្មាធិការនីតិសម្បទានិងអភិឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា វិស័យអប់រំក៏អាចប្រើប្រាស់ប្រព័ន្ធព័ត៌មាននេះ សម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈ ដែលកិច្ចការនេះអាចជួយបង្កើនប្រសិទ្ធភាពការងារ ក៏ដូចជាជួយពង្រឹងការងារផែនការរបស់សាមីស្ថាប័ននិងដៃគូអភិវឌ្ឍន៍ផងដែរ ។ ប្រការនេះអាចចាត់ទុកជាឧទាហរណ៍ជាក់ស្តែង សម្រាប់អនុវត្តនៅតាមក្រសួងនិងក្រុមការងារបច្ចេកទេសដទៃទៀត ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍នៃសហភាពអឺរ៉ុបកំពុងផ្តល់ការគាំទ្រដល់ការងារដ៏សំខាន់នេះ ដែលអាចជួយជម្រុញឱ្យប្រើប្រាស់ប្រព័ន្ធជាតិនៅកម្ពុជា ។ នេះគឺជាគំនិតផ្តួចផ្តើមមួយដែលត្រូវរំលេចនៅក្នុងផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម សម្រាប់តាមដានលទ្ធផលការងារ ។

## ***ទម្រង់ការនានានៃហិរញ្ញប្បទានសហប្រតិបត្តិការ***

ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយនឹងអាទិភាពជាតិ និងប្រព័ន្ធរបស់រាជរដ្ឋាភិបាល ត្រូវបានវាយតម្លៃតាមរយៈទម្រង់ការនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទម្រង់ការមួយចំនួន ដូចជាកម្មវិធី

គាំទ្រថវិកាបានប្រើប្រាស់ប្រព័ន្ធជាតិ ។ ចំណែកឯងទម្រង់ការដទៃទៀត ដូចជាគម្រោងទោល ក្នុងករណីខ្លះ អាច មើលរំលងសារៈសំខាន់នៃសមត្ថភាពស្ថូល ហើយមិនបានផ្តោតការយកចិត្តទុកដាក់ទៅលើលទ្ធផលឡើយ ។ ប្រការ នេះបានផ្តល់ជំហរច្បាស់លាស់មួយសម្រាប់រាជរដ្ឋាភិបាល ដែលបានបញ្ជាក់ថា ទោះបីរាជរដ្ឋាភិបាលទទួលយក គ្រប់ទម្រង់ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ដោយផ្អែកលើលទ្ធផលនៃការចរចាតាមករណីនីមួយៗ ក៏ដោយ ក៏ទំនោររយៈពេលវែងរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងហិរញ្ញប្បទាន គឺការអនុវត្តន៍អភិក្រមគ្រប់គ្រង ទូទាំងកម្មវិធី ដោយផ្តល់ហិរញ្ញប្បទានជាកញ្ចប់ ឬការគាំទ្រថវិការដ្ឋ ។ នៅកម្ពុជានាបច្ចុប្បន្ននេះ ធនធានដែលផ្តល់ តាមរយៈការគាំទ្រថវិការដ្ឋនៅមានកម្រិតទាបនៅឡើយ ប្រមាណ៣,៦%នៃហិរញ្ញប្បទានក្នុងឆ្នាំ២០០៩ ពោលគឺ មានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំមុនដែរ ។

ការចរចាអំពីទម្រង់ការហិរញ្ញប្បទានក្នុងកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ទៅលើការប្រើប្រាស់កិច្ច សហប្រតិបត្តិការបច្ចេកទេស និងការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សមត្ថភាព ។ ការវិភាគកន្លងមកបានផ្តល់ មូលដ្ឋានសម្រាប់រៀបចំសេចក្តីណែនាំស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ។ ក្នុងពេលដែលសេចក្តីណែនាំនេះ ត្រូវបានជម្រុញឱ្យអនុវត្តនៅកម្រិតវិស័យ និងកម្រិតគម្រោង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបាននិងកំពុងយកចិត្ត ទុកដាក់ ដើម្បីបញ្ចូលកិច្ចការនេះទៅក្នុងការអភិវឌ្ឍន៍សមត្ថភាពក្នុងបរិបទនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ។ គំនូរទី១១បានបង្ហាញពីនិន្នាការនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមប្រភេទនៃទម្រង់ការផ្តល់ហិរញ្ញប្បទាន ក្នុងចន្លោះឆ្នាំ២០០៤-២០១០ ។ រីឯតារាងទី៨ ក៏បានបញ្ជាក់អំពីតួលេខផ្តល់ហិរញ្ញប្បទានលំអិតរបស់ដៃគូអភិវឌ្ឍន៍ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ ។ ប្រការគួរឱ្យកត់សំគាល់នោះគឺការធ្លាក់ចុះ គិតជាសមាមាត្រនៃកិច្ចសហ- ប្រតិបត្តិការបច្ចេកទេស ។ ប៉ុន្តែ ប្រការនេះមិនមែនបញ្ជាក់អំពីការធ្លាក់ចុះនៃទំហំកិច្ចសហប្រតិបត្តិការបច្ចេកទេស នោះឡើយ ប៉ុន្តែ ដោយសារកំណើនហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគ ។

*គំនូរទី១១ :ការប្រើប្រាស់តាមប្រភេទហិរញ្ញប្បទាន*




| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|
| មិនបានរាយការណ៍ | 4,6 | 8,5 | 1,4 | 0,9 | 2,4 | 14,4 | 18,4 |
| ជំនួយម្ហូបអាហារ/សង្គ្រោះបន្ទាន់ | 20,2 | 17,1 | 20,7 | 21,7 | 29,9 | 26,1 | 32,8 |
| ហិរញ្ញប្បទានគាំទ្រថវិការដ្ឋ | 6,4 | 6,9 | 91,2 | 42,0 | 15,8 | 36,0 | 30,0 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេស | 263,5 | 287,3 | 248,0 | 293,9 | 313,3 | 299,7 | 267,7 |
| ហិរញ្ញប្បទានសហប្រតិបត្តិការមូលធន | 260,8 | 290,1 | 351,9 | 419,1 | 594,3 | 613,3 | 737,0 |

## តារាងទី៨: ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមប្រភេទហិរញ្ញប្បទាន ២០០៧-២០០៩ (លានដុល្លាអាមេរិក)

| | ២០០៧ | | | | | | | ២០០៨ | | | | | | | ២០០៩ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | FTC | ITC | IPA | GBS | Food aid | other | Total | FTC | ITC | IPA | GBS | Food aid | other | Total | FTC | ITC | IPA | GBS | Food aid | other | Total |
| អង្គការសហប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និង ដៃគូពហុភាគី | | | | | | | | | | | | | | | | | | | | | |
| FAO | 0,3 | 0,1 | | | 1,0 | | 1,3 | 1,2 | | | | 0,8 | | 2,0 | 3,2 | | | | 1,3 | 0,1 | 4,6 |
| IFAD | | | 4,1 | | | | | 0,5 | | 4,1 | | | | 4,1 | | | 4,3 | | | | 4,3 |
| ILO | 6,0 | | 0,1 | | | | 6,1 | 2,1 | | 0,2 | | | | 2,2 | 3,1 | | | | | | 3,1 |
| UNAIDS | 0,4 | | | | | | 0,4 | | | | | | | | 0,6 | | | | | | 0,6 |
| UNCOHCHR | | | | | | | | | | | | | | | | | | | | | |
| UNDP | 11,3 | | | | 1,4 | | 12,7 | 9,7 | | | | 0,9 | | 10,6 | 10,6 | | | | 0,4 | | 11,0 |
| UNESCO | 1,7 | | | | | | 1,7 | 2,2 | | | | | | 2,2 | 3,0 | | | | | | 3,0 |
| UNFPA | 2,9 | | | | | | 2,9 | 6,9 | | | | | | 6,9 | 5,7 | | 0,3 | | | | 6,0 |
| UNICEF | 12,1 | | | | | | 12,1 | | 12,2 | | | | | 12,2 | | 12,2 | | | | | 12,2 |
| UNIDO | 0,5 | | | | | | 0,5 | 0,3 | | | | | | 0,3 | 0,2 | | | | | | 0,2 |
| UNODC | | | | | | | | | | | | | | | | | | | | | |
| WFP | 15,9 | | | | | | 15,9 | | | | | 23,2 | | 23,2 | | | | | 23,4 | | 23,4 |
| WHO | 0,6 | | | | | | 0,6 | 4,5 | | | | | | 4,5 | 6,3 | | | | | | 6,3 |
| World Bank | 1,0 | 3,9 | 27,0 | 15,5 | | | 47,5 | 1,5 | 7,2 | 35,3 | | | | 44,0 | 1,8 | 7,7 | 37,6 | 13,3 | | | 60,4 |
| IMF | 0,9 | | | | | | 0,9 | | | | | | | | | | | | | | |
| ADB | 1,9 | 6,1 | 61,4 | | | | 69,4 | 1,9 | 29,3 | 114,5 | | | | 145,7 | 2,4 | 7,2 | 79,9 | | | | 89,5 |
| Global Fund | 21,1 | | | | | | 21,1 | | | 38,6 | | | | 38,6 | | | 47,9 | | | | 47,9 |
| **Sub-total** | **27,5** | **22,1** | **113,7** | **15,5** | **18,3** | **0,0** | **197,1** | **30,4** | **48,6** | **192,6** | **0,0** | **24,9** | **0,0** | **296,6** | **37,0** | **27,1** | **170,0** | **13,3** | **25,1** | **0,1** | **272,6** |
| សហភាពអឺរ៉ុប | | | | | | | | | | | | | | | | | | | | | |
| Belgium | 6,2 | | 0,5 | | | 0,4 | 7,1 | 2,8 | | | | | | 2,8 | 3,1 | | | | | | 3,1 |
| Denmark | | | 9,8 | | | | 9,8 | | | 10,1 | | | | 10,1 | | | 14,2 | | | | 14,2 |
| Finland | 5,2 | | | | | | 5,2 | 6,6 | | | | | | 6,6 | 6,3 | | | | | | 6,3 |
| France | 2,8 | 0,9 | 18,0 | | | | 21,7 | 7,7 | 1,5 | 22,1 | | | | 31,3 | 8,2 | 1,3 | 16,0 | | | | 25,5 |
| Germany | 10,6 | | 9,2 | | 0,9 | | 20,7 | 26,8 | | 6,1 | | 3,5 | | 36,5 | 24,8 | | 7,7 | | | | 32,5 |
| Netherlands | 0,1 | | | | | | 0,1 | 0,3 | | | | | 1,9 | 2,2 | | | | | | 0,7 | 0,7 |
| Spain | 2,5 | | | | 0,7 | 0,4 | 3,5 | 4,7 | | | | 1,5 | 0,4 | 6,5 | 6,3 | | | | 0,3 | 10,1 | 16,8 |
| Sweden | 0,9 | 16,4 | | | | | 17,3 | 0,7 | 15,1 | | | | | 15,9 | 0,6 | 22,2 | | | | | 22,9 |
| UK | 12,8 | 0,1 | 10,3 | 0,5 | | | 23,7 | 18,6 | | 7,8 | 3,2 | | | 29,6 | 27,6 | | 4,4 | 0,5 | | | 32,5 |
| EC | 31,6 | | | 12,4 | | | 44,0 | 34,8 | 0,2 | 5,2 | 6,9 | | | 47,2 | 44,1 | | | 2,8 | | 3,5 | 50,3 |
| **Sub-Total** | **72,8** | **17,4** | **47,8** | **12,9** | **1,6** | **0,8** | **153,2** | **103,0** | **16,8** | **51,4** | **10,1** | **5,0** | **2,4** | **188,6** | **121,0** | **23,6** | **42,3** | **3,3** | **0,3** | **14,3** | **204,8** |
| ដៃគូអភិវឌ្ឍន៍ទ្វេភាគីផ្សេងទៀត | | | | | | | | | | | | | | | | | | | | | |
| Australia | 27,1 | 2,5 | | | | | 29,6 | 27,0 | 2,1 | 2,1 | | | | 31,2 | 16,1 | 1,9 | 5,7 | | | | 23,7 |
| Canada | 12,6 | | | | | | 12,6 | 17,2 | | | | | | 17,2 | 13,1 | | | | | | 13,1 |
| China | | | 92,4 | | | | 92,4 | | | 95,4 | | | | 95,4 | | 2,9 | 111,8 | | | | 114,7 |
| Japan | 37,2 | 0,1 | 66,3 | 13,6 | | | 117,2 | 34,8 | 19,5 | 66,3 | 5,7 | | | 126,2 | 49,1 | 0,5 | 79,5 | 19,4 | | | 148,4 |
| New Zealand | 2,0 | 2,5 | | | | | 4,5 | 1,4 | 1,4 | | | | | 2,8 | 1,5 | 1,2 | | | | | 2,7 |
| Rep of Korea | 23,7 | 0,6 | 6,9 | | | | 31,3 | 6,0 | 3,9 | 23,1 | | | | 33,0 | 3,7 | 1,1 | 41,7 | | | | 46,5 |
| Switzerland | 0,4 | 0,5 | 2,7 | | | | 3,6 | 0,9 | 0,3 | 2,8 | | | | 3,9 | | | 2,8 | | | | 2,8 |
| USA | | | 58,1 | | | | 58,1 | | | 55,7 | | | | 55,7 | | | 56,9 | | | | 56,9 |
| **Sub-Total** | **103,0** | **6,2** | **226,5** | **13,6** | | | **349,4** | **87,4** | **27,1** | **245,3** | **5,7** | | | **365,5** | **83,5** | **7,5** | **298,3** | **19,4** | | **0,0** | **408,8** |
| អង្គការក្រៅរដ្ឋាភិបាល (ធនធានផ្ទាល់) | **32,1** | **12,8** | **31,0** | | **1,8** | **0,1** | **77,7** | | | **104,9** | | | | **104,9** | | | **102,6** | | **0,7** | | **103,3** |
| **សរុប** | **235,3** | **58,6** | **419,1** | **42,0** | **21,7** | **0,9** | **777,5** | **220,8** | **92,5** | **594,3** | **15,8** | **29,9** | **2,4** | **955,6** | **241,5** | **58,2** | **613,3** | **36,0** | **26,1** | **14,4** | **989,5** |

*កំណត់សំគាល់:*

- FTC = កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ
- ITC = កិច្ចសហប្រតិបត្តិការបច្ចេកទេសភ្ជាប់ជាមួយការវិនិយោគ
- IPA = គំរោងវិនិយោគ
- GBS = ការគាំទ្រថវិកា
- Food Aid = ហិរញ្ញប្បទានជាស្បៀងអាហារ
- Other = ផ្សេងៗ
- Total = សរុប

ទន្ទឹមនឹងការកើនទំហំវិនិយោគនៅក្នុងវិស័យមួយចំនួន រួមមានវិស័យដឹកជញ្ជូនដែលហិរញ្ញប្បទានសហប្រតិបត្តិការបានកើនឡើងក្នុងឆ្នាំ២០០៩ ហើយដែលជាវិស័យអាទិភាពក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ យើងមានសក្ខីកម្មគួរជាទីគាប់ចិត្ត ដែលអាចបង្ហាញអំពីវឌ្ឍនភាពក្នុងការតម្រឹមហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ជាមួយនឹងអាទិភាពជាតិ ។ ទំហំហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការវិនិយោគមានប្រមាណ៦១៣លានដុល្លាអាមេរិក នាឆ្នាំ២០០៩ ពោលគឺស្មើ៦៧%នៃចំនួនហិរញ្ញប្បទានសហប្រតិបត្តិការសរុប ។ រីឯហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស មានត្រឹមតែ៣០០លានដុល្លាអាមេរិក ស្មើនឹង៣០% នៃហិរញ្ញប្បទានសហប្រតិបត្តិការសរុបប៉ុណ្ណោះ ។ ទោះបីជាទំហំហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសមានលំនឹងចាប់តាំងពីឆ្នាំ២០០៦មកក៏ដោយ ក៏សមាមាត្រនៃហិរញ្ញប្បទានស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេសនេះ បានធ្លាក់ចុះពីប្រមាណ៥០%នៃហិរញ្ញប្បទានសរុប មកត្រឹមតិចជាង១/៣ ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ ។ ជំនួយម្ហូបអាហារនិងជំនួយសង្គ្រោះបន្ទាន់ បានធ្លាក់ចុះមកត្រឹម២៦លានដុល្លាអាមេរិក ក្នុងឆ្នាំ២០០៩ ទោះបីជាមានព្យុះកេតសាណានៅខែកញ្ញា ឆ្នាំ២០០៩ ហើយជំនួយម្ហូបអាហារ និងជំនួយសង្គ្រោះបន្ទាន់ត្រូវបានផ្តល់ក្នុងក្របខ័ណ្ឌគម្រោងផ្សេងៗ និងការគាំទ្រសហគមន៍ក៏ដោយ ។

ការវិភាគបានបង្ហាញបន្ថែមទៀតថា កន្លងមក ពុំមានការផ្លាស់ប្តូរទម្រង់ជាដុំកំភួនក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ដោយសារពួកគេបានផ្អែកលើអាណត្តិរបស់ខ្លួន គោលនយោបាយរបស់ស្ថាប័ន និងអភិក្រមសម្រាប់គ្រប់គ្រងហានិភ័យដែលកើតឡើងតាមរយៈការប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ការអនុវត្តន៍គម្រោងទោលនៅតែមានភាពគ្រប់ដណ្តប់ដដែល ។ ករណីនេះបានបង្ហាញឱ្យឃើញថា ដើម្បីឱ្យកម្ពុជាមានវឌ្ឍនភាព កម្មវិធីកំណែទម្រង់តាមវិស័យ និងកម្មវិធីផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ត្រូវតែតម្រឹមជាមួយនឹងកំណែទម្រង់ស្នូល និងជម្រុញឱ្យមានវឌ្ឍនភាពក្នុងការធ្វើសមាហរណកម្មរវាងថវិកា ផែនការ និងហិរញ្ញប្បទានសហប្រតិបត្តិការ ។ លើសពីនេះ ដូចបានគូសបញ្ជាក់ក្នុងផ្នែកសុខដុមនីយកម្មនិងការបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការ ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការត្រូវអនុវត្តក្នុងបរិបទទូលំទូលាយនៃកំណែទម្រង់ស្នូល ហើយមិនត្រូវចាត់ទុកថា នេះជាគំនិតផ្តួចផ្តើមទោលដាច់ដោយឡែក ឬគំនិតផ្តួចផ្តើមស្របគ្នានោះឡើយ ។

## សុខដុមនីយកម្ម

គោលការណ៍ទី៣នៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ក្នុងការរួមសហការគ្នាឱ្យបានកាន់តែប្រសើរឡើង ដោយការធ្វើនិយាមកម្មនូវអភិក្រមរបស់ពួកគេ និងការបំពេញឱ្យគ្នាទៅវិញទៅមក ។ «ភាពបែកខ្ញែក»នៃហិរញ្ញប្បទានសហប្រតិបត្តិការដោយសារដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តគម្រោងជាច្រើន និងក្នុងវិស័យជាច្រើន គឺជាបញ្ហាដែលបានកើតយូរយាមកហើយនៅកម្ពុជា ។ ជារឿយៗ ការពិភាក្សាលើភាពបែកខ្ញែកច្រើនដាក់សម្ពាធលើសុខដុមនីយកម្ម ដោយផ្តោតទៅលើភាពសក្តិសិទ្ធិតែប៉ុណ្ណោះ ។ របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០០៧ និងឆ្នាំ២០០៨ បានផ្តល់ការវិភាគមួយដែលរក្សាបាននូវភាពត្រឹមត្រូវនាពេលបច្ចុប្បន្ននេះ (ឧបសម្ព័ន្ធ ៣.២ បង្ហាញ

ទិដ្ឋភាពរួមនៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០០៩) ។ របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិ-បត្តិការឆ្នាំ២០០៨ បានបង្ហាញពីគោលបំណង របស់រាជរដ្ឋាភិបាលសម្រាប់ពិចារណាអំពីគំនិតផ្តួចផ្តើមស្តីពី«ការបែងចែកពលកម្ម» ដែលគំនិតផ្តួចផ្តើមនេះត្រូវ បានការយកចិត្តទុកដាក់ក្នុងវេទិកាកម្រិតសកលថា ជាវិធានការណ៍ប្រកបដោយសក្តានុពលសម្រាប់ដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹង«ភាពបែកខ្ញែក ភាពជាន់គ្នា និងកង្វះភាពសក្តិសិទ្ធ» ។ ក្នុងខែធ្នូ ឆ្នាំ២០០៨ បន្ទាប់ពី វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ ដែល«ការបែងចែកពលកម្ម»គឺជារបៀបវារៈនៃវេទិកាដែរនោះ រាជរដ្ឋាភិបាលក៏បានបើកកិច្ចប្រជុំ ដើម្បីពិចារណាអំពីលទ្ធភាពក្នុងការអនុវត្តន៍ «ការបែងចែកពលកម្ម» សម្រាប់ធ្វើជាវិធានការណ៍ដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងភាពបែកខ្ញែក ។ ជាលទ្ធផល រាជរដ្ឋាភិបាលមិនបានគាំទ្រឱ្យអនុវត្តគំនិតផ្តួចផ្តើមនេះឡើយ ពីព្រោះមិនមែនជាអភិក្រមដែលរាជរដ្ឋាភិបាលចង់បាន សម្រាប់ដោះស្រាយភាពបែកខ្ញែកហិរញ្ញប្បទានសហប្រតិបត្តិការ និងម៉្យាងទៀតដោយសាររាជរដ្ឋាភិបាលមានអាទិភាពស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្រិតវិស័យជាច្រើននិងបន្ទាន់ដែលត្រូវអនុវត្ត ។

ប្រការនេះបាននាំឱ្យមានការត្រិះរិះពិចារណាបន្តទៀត ហើយការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍បានឯកភាពថា អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាវិធានការណ៍មួយដែលអាចដោះស្រាយបញ្ហាប្រឈមនានានៃភាពបែកខ្ញែកហិរញ្ញប្បទានសហប្រតិបត្តិការ ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍ក៏មានផលប្រយោជន៍បន្ថែមទៀតដែរ ដោយសារពួកគេអាចដោះស្រាយព្រមៗគ្នានូវគោលដៅដទៃទៀត ដូចជាការពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ការកែលំអអភិក្រមសម្រាប់ការអភិវឌ្ឍន៍សមត្ថភាព ការធ្វើសមាហរណកម្មកំណែទម្រង់ស្ថាប័ន និងការលើកកំពស់អភិក្រមនៃភាពជាដៃគូដោយផ្អែកលើលទ្ធផល ដូចដែលធ្លាប់បានត្រួតពិនិត្យរួមគ្នានៅក្នុងវិស័យសុខាភិបាល និងអប់រំជាដើម ។ នៅក្នុងកិច្ចប្រជុំរបស់អ្នករៀបចំគោលនយោបាយនាទីក្រុងប៉ៃកឡាំងកាលពីខែមិថុនា ឆ្នាំ២០០៩ សម្រាប់រៀបចំ និងអនុវត្តបន្ទាប់ពីសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស អគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបញ្ជាក់ជំហររបស់ខ្លួនលើទស្សនៈស្តីពីការបែងចែកពលកម្មនៅកម្ពុជា ដូចខាងក្រោម ៖

> «ជាទស្សនវិស័យរបស់រាជរដ្ឋាភិបាល យើងប្រាថ្នាចង់គ្រប់គ្រងពិពិធកម្ម ហើយមិនចង់កាត់បន្ថយចំនួនដៃគូអភិវឌ្ឍន៍ឡើយ ។ នៅក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន នេះគឺជាប្រការសមហេតុសមផលណាស់ដែលកម្ពុជាត្រូវកៀរគរប្រភពធនធានឱ្យបានអតិបរមា ។ រីឯនៅកម្រិតវិស័យវិញ យើងក៏ទទួលស្គាល់អំពីគុណតម្លៃនៃសមត្ថភាពផ្សេងៗពីគ្នារបស់បណ្តាដៃគូអភិវឌ្ឍន៍ផងដែរ ។ នៅក្នុងកិច្ចប្រជុំសម្រាប់កំណត់ការងារអាទិភាព យើងកត់សំគាល់ឃើញថា គ្មានក្រសួងណាមួយរបស់រាជរដ្ឋាភិបាលបានយល់ព្រមថា ការបែងចែកពលកម្មជាអភិក្រមសមស្របសម្រាប់អនុវត្តក្នុងបរិបទកម្ពុជាឡើយ ។
>
> ដៃគូអភិវឌ្ឍន៍មានទស្សនវិស័យថា យើងត្រូវពិចារណាអំពីលទ្ធភាពអនុវត្ត«ការបែងចែកពលកម្ម» ។ ធនាគារអភិវឌ្ឍន៍នានាបានដើរតួនាទីជា«អ្នកផ្តល់កម្ចីចុងក្រោយគេ» ហើយពួកគេមានវត្តមាននៅក្នុងវិស័យជាច្រើនដោយសារតួនាទីសំខាន់របស់ខ្លួន និងដោយសាររាជរដ្ឋាភិបាលបានមើលឃើញអំពីគុណតម្លៃរបស់ពួកគេ ទាំងខាងធនធាន និងទាំងខាងជំនាញ ។

១- ភ្នាក់ងារអង្គការសហប្រជាជាតិទាំង២៣ និងមូលនិធិខ្សែបណ្តោយ (Vertical Fund) ដូចជា GAVI និងមូលនិធិសកល (Global Fund) មានអាណត្តិពិសេសរបស់ខ្លួន ដែលផ្តោតលើការគាំទ្របច្ចេកទេស ។ ប្រការនេះបានធ្វើឱ្យអង្គការទាំងនេះចូលរួមអនុវត្ត «ការបែងចែកពលកម្ម» ក្នុងកម្រិតមួយតែប៉ុណ្ណោះ ។

២- ដៃគូអភិវឌ្ឍន៍ទ្វេភាគីសំខាន់ជាច្រើនមានអភិក្រមជាយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់ប្រតិបត្តិការក្នុងវិស័យជាច្រើន ហើយពួកគេក៏មិនបានផ្តល់សារៈសំខាន់ដល់ «ការបែងចែកពលកម្ម» ឡើយ ។

៣- ដៃគូអភិវឌ្ឍន៍ទ្វេភាគីតូចៗជាច្រើនបានធ្វើប្រតិភូកម្មនៃការគ្រប់គ្រងធនធានរបស់ខ្លួន តាមរយៈស្ថាប័នពហុភាគី ។

៤- ផ្អែកតាមហេតុផលខាងលើ យើងនៅសល់តែបណ្តាប្រទេសជាសមាជិកសហភាពអឺរ៉ុបប៉ុណ្ណោះ ។ សហភាពអឺរ៉ុបកំពុងអនុវត្ត «ការបែងចែកពលកម្ម» យ៉ាងសកម្ម ។ រាជរដ្ឋាភិបាលបានគាំទ្រគំនិតផ្តួចផ្តើមនេះ ហើយប្រកាន់យកតួនាទីដឹកនាំកិច្ចការនេះទៅតាមពេលវេលាសមស្រប ។

៥- ថ្វីត្បិតតែមានបញ្ហាប្រឈមជាច្រើនខាងផ្នែកបច្ចេកទេសសម្រាប់អនុវត្ត «ការបែងចែកពលកម្ម» យើងមានទស្សនៈថា យោងតាមតក្កភាពជាក់ស្តែង «ការបែងចែកពលកម្ម» មិនមែនជាអភិក្រមសមស្របហើយក៏មិនអាចផ្តល់អត្ថប្រយោជន៍ក្នុងបរិបទកម្ពុជាឡើយ » ។

ការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលជាវិធានការណ៍សម្រាប់ដោះស្រាយបញ្ហាប្រឈមនានានៃភាពបែកខ្ញែកហិរញ្ញប្បទានសហប្រតិបត្តិការ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការពង្រឹងនិងការប្រើប្រាស់ប្រព័ន្ធជាតិ ។ កម្ពុជាមិនមែនជាករណីដោយឡែក ដែលបានជួបប្រទះការលំបាកក្នុងការសម្របសម្រួលជាមួយនឹងដៃគូពាក់ព័ន្ធទាំងអស់ ដើម្បីពង្រឹង និងបន្ទាប់មកប្រើប្រាស់ប្រព័ន្ធជាតិឡើយ ។ ការសិក្សាកម្រិតសកលក្នុងពេលថ្មីៗកន្លងមកនេះ (ខ្លឹមសារសង្ខេបនៅប្រអប់ខាងលើ) បានបង្ហាញថាការបែកខ្ញែកហិរញ្ញប្បទានសហ-ប្រតិបត្តិការគឺបណ្តាលមកពីប្រព័ន្ធជាតិទន់ខ្សោយក្នុង«វដ្តវិលវល់ដដែលៗ» ។ ប្រទេសអភិវឌ្ឍន៍មួយចំនួនបានរៀបចំ និងគ្រប់គ្រងប្រព័ន្ធអប់រំនិងសុខាភិបាលដ៏ទំនើប ដែលផ្តល់លទ្ធភាពឱ្យប្រើប្រាស់ហិរញ្ញប្បទានពីប្រភពផ្សេងៗគ្នា ដោយមិនបានឆ្លងកាត់ប្រព័ន្ធជាតិ ។

ការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជា បានកត់សំគាល់អំពីបញ្ហាប្រឈមរបស់ដៃគូអភិវឌ្ឍន៍ក្នុងការធ្វើសុខដុមនីយកម្ម ដោយមានវឌ្ឍនភាពតិចតួចក្នុងការធ្វើសុខដុមនីយកម្មប្រព័ន្ធរបាយការណ៍និងទម្រង់ការត្រួតពិនិត្យនិងវាយតម្លៃ ។ ករណីនេះប្រហែលជាតម្រូវឱ្យមានការណែនាំស៊ីជម្រៅនៅកម្រិតសកលទើបអាចអនុវត្តសុខដុមនីយកម្មនៃទម្រង់ការនានានៅកម្រិតប្រទេសបាន ។ គំនិតផ្តួចផ្តើមកម្រិតសកលដទៃទៀតដូចជាការបែងចែកពលកម្មកម្រិតសកល ដែលដៃគូអភិវឌ្ឍន៍បានសម្របសម្រួលហិរញ្ញប្បទាន ប្រហែលជាមិនមានវឌ្ឍនភាពដូចការរំពឹងទុកឡើយ ។ ការផ្តោតទៅលើការដកខ្លួនថយ ឬការបង្កើនការគាំទ្រដល់ប្រទេសជាដៃគូពុំទាន់បានលេចចេញជារូបរាងនៅឡើយ ។ ទន្ទឹមនឹងនេះ ដៃគូអភិវឌ្ឍន៍បន្តដកខ្លួន ឬក៏រៀបចំកម្មវិធីសារជាថ្មីដោយមិនបានយកចិត្តទុកដាក់ដល់កង្វះធនធានដែលត្រូវបានបំពេញបន្ទាប់ពីការចាកចេញរបស់ពួកគេឡើយ ។

លើសពីនេះ ក៏មានសក្ខីកម្មជាច្រើនដែលអាចបញ្ជាក់អំពីការលំបាករបស់ដៃគូអភិវឌ្ឍន៍ក្នុងការធ្វើសុខ-ដុមនីយកម្មដែរ ។ សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសបានកត់សំគាល់ថា ចំនួនបេសកកម្មនិងការសិក្សាបានបង្កើនបន្ទុកដ៏ធ្ងន់ធ្ងរដល់ប្រទេសជាដៃគូ ពិសេសនៅក្នុងវិស័យសុខាភិបាលនៅកម្ពុជា ។ កិច្ចប្រឹងប្រែងសម្រាប់រៀបចំ

**ការបែកខ្ញែក និងប្រព័ន្ធជាតិ**

ការសិក្សាកម្រិតសកលថ្មីៗនេះ បានបង្ហាញថា «ការផ្តល់ហិរញ្ញប្បទានតាមរយៈគម្រោងដោយគ្មានការសម្របសម្រួលនៅក្នុងវិស័យជាច្រើន បាននាំទៅដល់វដ្តវិលវល់ដដែលៗ ដែលធ្វើឱ្យវិស័យអភិបាលកិច្ចមានភាពទន់ខ្សោយ ។ ភាពទន់ខ្សោយខាងគោលនយោបាយតាមវិស័យ ខាងស្ថាប័ន និងខាងប្រព័ន្ធផ្តល់សេវា បាននាំទៅដល់ស្ថានភាពមួយដែលដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធរៀងៗខ្លួនដោយគ្មានការសម្របសម្រួល ។ ឥរិយាបទនេះបានមើលស្រាលដល់គោលនយោបាយតាមវិស័យ ស្ថាប័ន និងប្រព័ន្ធផ្តល់សេវាកម្មតាមវិស័យ ហើយបានពង្រឹងតួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការឆ្លើយតបទៅនឹងស្ថានការណ៍ជាក់ស្តែង » ។

ក្របខ័ណ្ឌស្តីពីវិធីសាស្ត្រនៃការសិក្សានេះ បានប្រើប្រាស់អភិក្រម «សង្វាក់លទ្ធផល» ដែលបង្ហាញអំពីសារៈសំខាន់នៃទម្រង់ការនានានៃហិរញ្ញប្បទាន និងការបែកខ្ញែក ក្នុងការគាំទ្រកិច្ចប្រឹងប្រែងសម្រាប់បង្កើតនិងប្រើប្រាស់ប្រព័ន្ធជាតិ ដើម្បីធានាចីរភាពនៃការផ្តល់សេវាប្រកបដោយគុណភាព ។




ប្រភព: OID (2008) *"អភិបាលកិច្ចល្អ ទម្រង់ការនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនិងការកាត់បន្ថយភាពក្រីក្រ"*

ផែនការនិងការសម្របសម្រួលបេសកកម្ម មិនទាន់មានវឌ្ឍនភាពជាដុំកំភួននៅឡើយ ។ ក្នុងស្មារតីនេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំទិន្នន័យស្តីពីបេសកកម្ម នៅក្នុងប្រព័ន្ធទិន្នន័យ ។ ប៉ុន្តែ រហូតមកដល់បច្ចុប្បន្ននេះ មានដៃគូអភិវឌ្ឍន៍តិចតួចបំផុត ដែលបានប្រើប្រាស់ប្រព័ន្ធព័ត៌មាននេះ ។ នេះបង្ហាញអំពីការលំបាកក្នុងការផ្លាស់ប្តូរឥរិយាបទ និងក្នុងការលើកទឹកចិត្តឱ្យចែករំលែកព័ត៌មាន ព្រមទាំងធ្វើការឱ្យជិតស្និទ្ធជាមួយគ្នា ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍ភាគច្រើនបានបង្ហាញអំពីភាពនឿយណាយ ក្នុងការសម្របសម្រួលកិច្ចប្រជុំច្រើនពេក ។ ប៉ុន្តែប្រសិនដៃគូអភិវឌ្ឍន៍យល់ថា ការអនុវត្តន៍គំនិតផ្តួចផ្តើមសាមញ្ញ ដូចផែនការបេសកកម្មតាមរយៈប្រព័ន្ធគឺជាការលំបាកនោះ យើងត្រូវបន្តខន្តីចំពោះលទ្ធផលរំពឹងទុក ក្នុងការអនុវត្តន៍កំណែទម្រង់នានា ដែលមានភាពស្មុគ្រស្មាញនិងប្រកបដោយមហិច្ឆិតា ។

## ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល

កិច្ចប្រឹងប្រែងជម្រុញឱ្យមានលទ្ធផលការងារនៅកម្រិតវិស័យ ត្រូវបានយកចិត្តទុកដាក់គួរឱ្យកត់សម្គាល់ ចាប់តាំងពីការវាយតម្លៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ក្នុងឆ្នាំ២០០៨ និងក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ មក ។ ការផ្តោតទៅលើសកម្មភាពសមស្របមួយចំនួនតូច ហើយផ្សារភ្ជាប់សកម្មភាពទាំងនេះជាមួយនឹងលទ្ធផល បានចាប់ផ្តើមបង្ហាញអំពីគុណប្រយោជន៍ ហើយបានចាក់គ្រឹះទៅក្នុងកិច្ចការជាប្រចាំនៅកម្រិតវិស័យ (សូមមើលផ្នែកភាពជាម្ចាស់នៃជំពូកនេះ) ។ ក្រសួងនិងស្ថាប័នបានដឹកនាំកិច្ចការនេះ និងបានចរចាក្នុងក្រុមការងារបច្ចេកទេសចម្រុះរបស់ខ្លួន ដើម្បីកំណត់សកម្មភាពស្តីពីប្រសិទ្ធភាពហិរញ្ញប្បទាន

ដោយផ្ដោតលើលទ្ធផល ។ ក្រសួងនិងស្ថាប័នបានបង្ហាញចំណាប់អារម្មណ៍ខ្ពស់ចំពោះអភិក្រមនេះ ។ សកម្មភាពស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានទាំងនេះបានផ្ដោតលើខ្លឹមសារសំខាន់៣ គឺៈ

១- *អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងយុទ្ធសាស្ត្រតាមវិស័យ:* ក្រុមការងារបច្ចេកទេសចម្រុះចំនួន១២ ក្នុងចំណោម១៩ មានមហិច្ឆិតាបង្កើត ឬពង្រឹងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងយុទ្ធសាស្ត្រតាមវិស័យ ។ ក្រុមការងារទាំងនេះមានក្រុមការងារបច្ចេកទេសចម្រុះវិស័យព្រៃឈើ យេនឌ័រ ផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ កសិកម្មនិងទឹក សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងសកម្មភាពមីន ។ លើសពីនេះ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ និងសុខាភិបាល ក៏មានវឌ្ឍនភាពក្នុងការប្រែក្លាយយុទ្ធសាស្ត្ររយៈពេលមធ្យមឱ្យទៅជាផែនការប្រតិបត្តិការប្រចាំឆ្នាំ ស្របតាមកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។

*តារាងទី៩: សូចនាករតាមដានរួមគ្នាស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ*

| ក្រសួង/ ស្ថាប័ន ក្រុមការងារ | សកម្មភាពអាទិភាព | វឌ្ឍនភាព | បញ្ហាប្រឈម |
|---|---|---|---|
| ក្រសួងផែនការ<br>PPR TWG | ១- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម និង ផែនការសកម្មភាព ឆ្នាំ២០០៩ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការ<br>២- គោលការណ៍ភាពជាដៃគូ | ១- រៀបចំរួច និងដាក់ជូនគណៈរដ្ឋមន្ត្រី ផែនការសកម្មភាពខ្វះធនធាន<br>២- បានរៀបចំរួច | ធនធានសម្រាប់អនុវត្ត |
| កអក/ គជនា<br>P&H TWG | សម្របសម្រួលការអនុវត្តន៍គោលនយោបាយដែលបានកំណត់នៅក្នុងតារាងនេះ | កំពុងបន្ត : វឌ្ឍនភាពរាយការណ៍ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ | |
| *អាទិភាពក្នុងវិស័យសង្គមកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* | | | |
| ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រុមការងារអប់រំ | ១- ការពិនិត្យឡើងវិញវិស័យអប់រំរួមគ្នាមានលក្ខណៈវិភាគ និងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំឱ្យបានប្រាកដប្រជា និងទាន់ពេលវេលា<br>២- សម្របសម្រួលការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព | ១- សន្និបាតអប់រំ ឆ្នាំ២០០៩ និង ២០១០ ផែនការប្រតិបត្តិឆ្នាំ២០១០ មានលក្ខណៈប្រាកដប្រជា និងទាន់ពេលវេលា<br>២- រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យម និងកំពុងពិភាក្សាសម្រាប់វិស័យទាំងមូល | |
| ក្រសួងសុខាភិបាល<br>ក្រុមការងារសុខាភិបាល | ១- អនុវត្តផែនការប្រតិបត្តិឆ្នាំ២០០៩ និងផែនការបីឆ្នាំ<br>២- អនុវត្តផែនការសកម្មភាពភាព IHP | ១- មានវឌ្ឍនភាព<br>២- មានវឌ្ឍនភាព | |
| អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ / ក្រុមការងារអេដស៍ | វិភាគមុខងារ និងតួនាទីយន្តការឆ្លើយតបនឹងជំងឺអេដស៍ | បានរៀបចំរួច | ធនធានសម្រាប់អនុវត្ត |
| ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ / FSN TWG | ១- បញ្ចីសំណាញ់សុវត្ថិភាពសង្គមដែលមានបច្ចុប្បន្ន<br>២- ផ្សព្វផ្សាយក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ១- សម្រេចគោលដៅ<br>២- បានប្រកាស និងផ្សព្វផ្សាយ | ការអនុវត្តន៍នៅថ្នាក់ក្រោមជាតិ |
| *អាទិភាពក្នុងវិស័យសេដ្ឋកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* | | | |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ / ក្រសួងធនធានទឹក និងឧតុនិយម<br>A&W TWG | ១- រៀបចំបញ្ចប់ ធ្វើសុខដុមនីយកម្ម និងអាទិភាវូបនីយកម្មកម្មវិធីទាំង៥ នៃយុទ្ធសាស្ត្រកសិកម្ម និងទឹក<br>២- ក្របខ័ណ្ឌ និងយន្តការរួមសម្រាប់អនុវត្តយុទ្ធសាស្ត្រ | ១- កម្មវិធីទាំង៥ រៀបចំបញ្ចប់<br>២- រង់ចាំការអនុមតិកម្មវិធីសុខដុមនីយកម្មនៃយុទ្ធសាស្ត្រកសិកម្មនិងទឹក | |

| | | | |
|---|---|---|---|
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>ក្រុមការងារដីធ្លី | ១- ជម្រុញអភិក្រមកម្មវិធីក្នុង LAMDP<br>២- គោលការណ៍ភាពជាដៃគូក្នុងក្របខ័ណ្ឌ LAMDP<br>៣- គោលនយោបាយរៀបចំដែនដី<br>៤- ប្រព័ន្ធតាមដាន និងវាយតម្លៃសម្រាប់វិស័យដីធ្លី | ១- មានវឌ្ឍនភាព LASSP LMSSP LDSSP<br>២- បានចុះហត្ថលេខា<br>៣- កំពុងបន្ត<br>៤- កំពុងបន្ត | |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>F&E TWG | ១- ពង្រឹងសមត្ថភាពខាងផែនការ អនុវត្ត តាមដាន និងវាយតម្លៃ និងប្រព័ន្ធតាមដាននិងវាយតម្លៃសម្រាប់វិស័យព្រៃឈើ<br>២- រៀបចំនិងអនុវត្តកម្មវិធីជាតិព្រៃឈើ | ១- ផែនការសកម្មភាពឆ្នាំ២០១០ និងបានបង្កើតការិយាល័យតាមដាននិងវាយតម្លៃ<br>២- រៀបចំបញ្ចប់ ហើយរង់ចាំការអនុមតិ | ធនធានមនុស្ស និងហិរញ្ញវត្ថុ ការចែករំលែកព័ត៌មាន |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>Fisheries TWG | ១- ពង្រឹងយន្តការតាមដាន និងវាយតម្លៃ<br>២- រៀបចំសូចនាករនៅក្នុងផែនការសកម្មភាពរដ្ឋបាលជលផល | ១- កិច្ចសហប្រតិបត្តិការបច្ចេកទេស បានផ្ដល់ដើម្បីគាំទ្រការតាមដាននិងវាយតម្លៃ<br>២- សម្រេចតាមគោលដៅ | |
| អាជ្ញាធរមីន / ក្រុមការងារមីន | រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់សកម្មភាពមីន | សេចក្ដីព្រាងរំពឹងអនុមតិត្រីមាសទី២/២០១០ | |
| ក្រុមការងារអភិវឌ្ឍន៍វិស័យឯកជន | ១- របៀបវារៈគតិយុត្តិសម្រាប់វិស័យឯកជន<br>២- ផែនការរំកិលបីឆ្នាំកំណែទម្រង់ពាណិជ្ជកម្ម | ១- បញ្ជីច្បាប់ចែករំលែកជាមួយវិស័យឯកជន<br>២-វិធានការអនុវត្តបានមួយចំនួន | |
| *អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* | | | |
| ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រុមការងារហេដ្ឋារចនាសម្ព័ន្ធ | បន្តការកំណត់បញ្ជីនៃការគាំទ្រសម្រាប់ជាមូលដ្ឋាន ចែករំលែកព័ត៌មាន និងសម្របសម្រួល | មានវឌ្ឍនភាព - មន្ត្រីបង្គោលត្រូវបានចាត់តាំងនៅតាមអនុវិស័យ | ការចូលរួមសកម្មពីមន្ត្រីបង្គោល និងការចែករំលែកព័ត៌មាន |
| ក្រសួងអភិវឌ្ឍន៍ជនបទ<br>RWSSH TWG | រៀបចំយុទ្ធសាស្ត្រ និងផែនការវិស័យ សម្រាប់ជាមូលដ្ឋានដល់ការពង្រឹងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី | វឌ្ឍនភាពគួរកត់សំគាល់ | ភាពជាម្ចាស់ និងសមត្ថភាព |
| *អាទិភាពក្នុងវិស័យអភិបាលកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* | | | |
| ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល<br>PAR TWG | យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព | | |
| ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ / LJR TWG | ពង្រឹងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ សម្រាប់សម្របសម្រួលនិងតាមដាន ដើម្បីធានាប្រសិទ្ធភាព និងចីរភាពក្នុងការអនុវត្តន៍ផែនការសកម្មភាពកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ | កំពុងមានវឌ្ឍនភាព | សមត្ថភាព ការផ្សារភ្ជាប់នឹងកំណែទម្រង់ ការចូលយ៉ាងរួមសកម្មពីដៃគូអភិវឌ្ឍន៍ |
| ក្រសួងមហាផ្ទៃ<br>D&D TWG | រៀបចំបញ្ចប់កម្មវិធីជាតិ | រំពឹងអនុមតិត្រីមាសទី ២ ឆ្នាំ ២០១០ | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>PFM TWG | អនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | មានវឌ្ឍនភាព | |
| ក្រសួងកិច្ចការនារី<br>GENDER TWG | ១- ពិគ្រោះយោបល់យុទ្ធសាស្ត្រ៥ឆ្នាំក្រសួងកិច្ចការនារី (នារីរតនៈទី៣)<br>២- អភិក្រមតាមកម្មវិធីសម្រាប់បញ្ជ្រាបយេនឌ័រ | ១- នារីរតនៈទី៣ ត្រូវបានអនុមតិ<br>២- រៀបចំផែនទីផ្លូវសម្រាប់អភិក្រមកម្មវិធី | |

២- *ការអភិវឌ្ឍន៍សមត្ថភាព*: ចំពោះអាទិភាពពាក់ព័ន្ធនឹងសមត្ថភាព ក្រុមការងារបច្ចេកទេសចម្រុះចំនួន៦ រួមមានវិស័យអប់រំ សុខាភិបាល ដីធ្លី ព្រៃឈើនិងបរិស្ថាន ជលផល និងកំណែទម្រង់រដ្ឋបាលសាធារណៈ បានកំណត់ការតាមដាននិងវាយតម្លៃ ការពង្រឹងប្រព័ន្ធជាតិ ឬការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាអាទិភាពក្នុងការអភិវឌ្ឍន៍សមត្ថភាព ។ រីឯក្រុមការងារបច្ចេកទេសចម្រុះវិស័យជលផលបានបន្តកិច្ចប្រឹងប្រែង និងបានបង្កើតវឌ្ឍនភាពផងដែរក្នុងការបង្កើតប្រព័ន្ធជាតិ រួមទាំងប្រព័ន្ធតាមដានការអនុវត្តន៍កម្មវិធី ។ ក្រុមការងារបច្ចេកទេសចម្រុះដទៃទៀត បានរាយការណ៍អំពីវឌ្ឍនភាពគួរជាទីគាប់ចិត្ត និងបានកែលំអការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេស និងសេវាទីប្រឹក្សា ។

៣- *គណនេយ្យភាពទ្វេទិស* : ក្រុមការងារបច្ចេកទេសចម្រុះស្តីពីផែនការនិងកាត់បន្ថយភាពក្រីក្រ និងក្រុមការងារបច្ចេកទេសចម្រុះស្តីពីដីធ្លីបានកំណត់យ៉ាងច្បាស់អំពីការប្រើប្រាស់គោលការណ៍ភាពជាដៃគូ ។ ក្រុមការងារបច្ចេកទេសចម្រុះដទៃទៀត រួមមាន សុខាភិបាល សកម្មភាពមីន ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ វិមជ្ឈការនិងវិសហមជ្ឈការ និងយេនឌ័រ បានបញ្ជាក់អំពីតម្រូវការក្នុងការពង្រឹងភាពជាម្ចាស់តាមរយៈគោលការណ៍ភាពជាដៃគូ និងការពិគ្រោះយោបល់រួមគ្នា ។ ក្រុមការងារបច្ចេកទេសចម្រុះភាគច្រើនក៏បានរាយការណ៍អំពីការកែលំអក្នុងការចែករំលែកព័ត៌មានជាមួយនឹងភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ តាមរយៈការពិគ្រោះយោបល់ ។

វឌ្ឍនភាពរបស់ក្រសួងនិងក្រុមការងារបច្ចេកទេសចម្រុះនិមួយៗត្រូវបានរំលេចក្នុងតារាងទី៩ ។ ក្នុងខែវិច្ឆិកាឆ្នាំ២០០៩ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(គ.ជ.ន៑/ក.អ.ក.) បានបើកវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងដោយផ្តោតលើលទ្ធផល សម្រាប់បង្កើនការយល់ដឹងអភិក្រមស្តីពី «ខ្សែសង្វាក់លទ្ធផល» ។ វគ្គបណ្តុះបណ្តាលនេះបានពង្រឹងលទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ក្នុងការអនុវត្តន៍អភិក្រមនេះក្នុងការងាររបស់ខ្លួន ។ លើសពីនេះ វគ្គបណ្តុះបណ្តាលនេះក៏ផ្តល់ឧទាហរណ៍គំរូក្នុងការបញ្ចូលសកម្មភាពស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការទៅក្នុងការងារប្រចាំថ្ងៃរបស់ក្រុមការងារ ដោយមិនចាត់ទុកថាការងារស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការជាកិច្ចការបន្ថែម ឬដាច់ដោយឡែកឡើយ ។




ដោយផ្សារភ្ជាប់សកម្មភាពស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការរបស់ក្រសួងនិងស្ថាប័ន ដៃគូអភិវឌ្ឍន៍និងគម្រោង ទៅនឹង «ខ្សែសង្វាក់លទ្ធផល» (រូបភាពខាងលើ) យើងសង្កេតឃើញថា ដំណាក់កាលនិមួយៗទាមទារចាំបាច់នូវវឌ្ឍនភាព ដើម្បីគ្រប់គ្រងដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ផលិតចេញជា

លទ្ធផល ។ ចំពោះគម្រោងវិញ អភិក្រមស្តីពី «ខ្សែសង្វាក់លទ្ធផល» នេះនឹងជួយកំណត់សកម្មភាពនានា ដែលអាចជួយលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការផង និងលទ្ធផលនៅកម្រិតវិស័យផង ។ ការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជាបានបង្ហាញថា គម្រោងភាគច្រើនមិនទាន់បានគ្រប់គ្រងតាមរបៀបមួយដែលអាចបង្ហាញពីការរួមចំណែករបស់គម្រោងក្នុងការផលិតចេញជាលទ្ធផល ក្នុងខណៈដែលធាតុចូលមិនបានរំលេចក្នុងយុទ្ធសាស្រ្តតាមវិស័យ ឬក៏មិនបានបញ្ចូលទៅក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំ ផែនការយុទ្ធសាស្រ្តថវិកា ដើម្បីធានាថា ធាតុចូលទាំងនោះត្រូវបានគ្រប់គ្រងតាម«អភិក្រមផ្តោតលើលទ្ធផលនៅកម្រិតវិស័យ» ។ គំនិតផ្តួចផ្តើមដទៃទៀតនៅកម្រិតវិស័យ (ដូចជាការពិនិត្យឡើងវិញរួមគ្នាក្នុងវិស័យអប់រំ និងសុខាភិបាល) កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងការពិនិត្យឡើងវិញអំពីក្របខ័ណ្ឌតាមដានការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បានផ្តល់កាលានុវត្តភាពសម្រាប់ពង្រឹងប្រព័ន្ធនិងសមត្ថភាពនៅគ្រប់ដំណាក់កាលនៃ«ខ្សែសង្វាក់លទ្ធផល» ដើម្បីផ្សារភ្ជាប់ធាតុចេញនៃគម្រោងទៅនឹងលទ្ធផលនៅកម្រិតវិស័យ ។

## ***គណនេយ្យភាពទ្វេទិស***

គណនេយ្យភាពទ្វេទិស គឺជាគោលការណ៍មួយក្នុងបណ្តាគោលការណ៍ទាំង៥នៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល ពីព្រោះគោលការណ៍នេះបានផ្តោតលើកិច្ចដំណើរការ ដែលអនុញ្ញាតឱ្យគ្រប់ភាគីទាំងអស់អាចចូលរួមវាយតម្លៃលទ្ធផលការងារ ពិសេសផ្តោតលើលទ្ធផលនៃការអភិវឌ្ឍន៍ ។ គំនិតផ្តួចផ្តើមស្តីពី «ការជម្រុញប្រសិទ្ធភាពនៃភាពជាដៃគូនៅកម្ពុជា» របស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០០៩ បានឯកភាពជាមួយនឹងការសង្កេតកន្លងមកដែលបានអះអាងថា ក្នុងករណីជាច្រើន ដៃគូអភិវឌ្ឍន៍មិនបានចូលរួមឱ្យបានពេញលេញក្នុងកិច្ចដំណើរការរួមគ្នា ដែលអាចជួយជម្រុញប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងគណនេយ្យភាពរបស់ពួកគេ ។ ដោយផ្អែកលើសមធិម តម្លាភាព និងផលប្រយោជន៍ទ្វេទិស ដែលជាគោលការណ៍គន្លឹះទាំង៣នៃភាពជាដៃគូប្រកបដោយប្រសិទ្ធភាព គំនិតផ្តួចផ្តើមស្តីពី «ការជម្រុញប្រសិទ្ធភាពនៃភាពជាដៃគូ» មានគោលដៅសម្រាប់បង្កើតទំនុកចិត្ត និងការយោគយល់គ្នាទៅវិញទៅមក ដែលទាំងនេះគឺជាបុរេលក្ខខ័ណ្ឌសម្រាប់ជម្រុញឱ្យមានការផ្លាស់ប្តូរក្នុងរបៀបគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ កិច្ចការនេះនឹងអនុវត្តបន្តក្នុងឆ្នាំ២០១០ ដើម្បីដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងឥរិយាបទក្នុងការកសាងភាពជាដៃគូ បន្ថែមលើទិដ្ឋភាពខាងបច្ចេកទេស ដែលត្រូវបានដោះស្រាយតាមរយៈការអនុវត្តន៍សូចនាករតាមដានរួមគ្នាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការបណ្តុះបណ្តាលបន្ថែម ។

អង្គការសង្គមស៊ីវិលក៏បានអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន ដោយផ្អែកលើការប្តេជ្ញានានារបស់ដៃគូអភិវឌ្ឍន៍និងប្រទេសជាដៃគូរដែលមានចែងក្នុងផែនការសកម្មភាពទីក្រុងអាក្រា ដើម្បីបង្កើនទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធជាមួយនឹងអង្គការសង្គមស៊ីវិល ។ នេះបានបញ្ជាក់ថា អង្គការសង្គមស៊ីវិលដែលជាប្រតិបត្តិករសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍(ដូចបានជម្រាបពីខាងដើមនៃជំពូកនេះ) តម្រូវឱ្យការចូលរួមរបស់ពួកគេមានប្រសិទ្ធភាព ហើយពួកគេ

ត្រូវមានគណនេយ្យភាពចំពោះសកម្មភាពរបស់ខ្លួន ។ ក្នុងឆ្នាំ២០០៩ និង២០១០ កិច្ចពិគ្រោះយោបល់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានផ្តល់កាលានុវត្តភាពសម្រាប់អង្គការសង្គមស៊ីវិលបញ្ចេញទស្សនៈរបស់ខ្លួន សម្រាប់អនុវត្ត គោលការណ៍នានាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ហើយបានត្រិះរិះរកវិធីសម្រាប់ ឱ្យពួកខ្លួនអាចអនុវត្តការប្តេជ្ញាស្តីពីគណនេយ្យភាព ។ កិច្ចការនេះនឹងបន្តដំណើរទៅមុខទៀត ដោយសង្ឃឹមថា អង្គការសង្គមស៊ីវិលអាចបង្កើនការចូលរួម និងការរួមចំណែករបស់ពួកគេនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះ និងយន្តការសម្របសម្រួលដទៃទៀត ។

«ផែនការសកម្មភាពទីក្រុងអាក្រា» ក៏បានកំណត់អំពីតួនាទីរបស់សភា ។ របកគំហើញបឋមនៃការសិក្សា ថ្មីៗនេះរបស់សម្ព័ន្ធអន្តរសភាបានរកឃើញអំពីសកម្មភាពមួយចំនួន ដែលអាចជួយកែលំអការចែករំលែកព័ត៌មាន ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ក៏ដូចជាក្នុងកិច្ចការនានាដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ផងដែរ ។

គណនេយ្យភាពទ្វេទិស រួមមានការអនុវត្តន៍សូចនាករតាមដានរួមគ្នា នឹងបង្ហាញលំអិតក្នុងជំពូកទី៤ ។

--------------

# ជំពូក ៤
# គណនេយ្យភាពទ្វេទិសចំពោះលទ្ធផល

សូចនាករតាមដានរួមគ្នា ឆ្លុះបញ្ចាំងពីគោលការណ៍នៃការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនៃការអភិវឌ្ឍន៍ និងគណនេយ្យភាពទ្វេទិសក្នុងការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ បញ្ហាប្រឈមដែលមានចរិតបច្ចេកទេសនៃគោលការណ៍ទាំង៣ គឺ÷ភាពជាម្ចាស់ ការតម្រឹម និងសុខដុមនីយកម្ម ត្រូវបានយកចិត្តទុកដាក់នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តន៍ផែនការសកម្មភាពសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ។ ទន្ទឹមនឹងនេះ ចាប់ពីដើមឆ្នាំ២០០៩មក ការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនិងគណនេយ្យភាពទ្វេទិស បានក្លាយជាកង្វល់ចម្បង សម្រាប់ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ។ គោលការណ៍ទាំង២ចុងក្រោយនេះសំដៅផ្តល់ការគាំទ្រជាវិជ្ជមានដល់ជវភាពនៃភាពដឹកនាំ និងសមត្ថភាពក្នុងភាពជាដៃគូ ដោយផ្អែកលើការយោគយល់គ្នាទៅវិញទៅមកដើម្បីសម្រេចបាននូវលទ្ធផលដែលបានឯកភាព ។ ក្នុងស្មារតីនេះ ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងគណនេយ្យភាពទ្វេទិស គឺជាកត្តាមូលដ្ឋាននៃភាពជាដៃគូសម្រាប់ឈានទៅសម្រេចរួមគ្នានូវគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព និងមានគណនេយ្យភាព ។

ដូចបានគូសបញ្ជាក់នៅក្នុងជំពូកមុនខាងដើម ទម្រង់ការនិងដំណើរការរៀបចំសូចនាករតាមដានរួមគ្នាត្រូវបានកែសម្រួលយ៉ាងច្រើន ចាប់តាំងពីវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ ។ ឆ្លងតាមការពិគ្រោះយោបល់ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានឯកភាពថា សូចនាករតាមដានរួមគ្នាទាមទារឱ្យមានការចូលរួមក្នុងការរៀបចំ ក្នុងការអនុវត្តន៍ និងតាមដាននូវលទ្ធផលនៅកម្រិតវិស័យ ។ សូចនាករតាមដានរួមគ្នាក៏តម្រូវឱ្យមានមហិច្ឆតាក្នុងការសម្រេចលទ្ធផលកម្រិតខ្ពស់ និងមានសង្គតិភាពនៅក្នុងការតាមដានបណ្តាសកម្មភាពអាទិភាពដែលបានព្រមព្រៀង ហើយដែលរួមចំណែកដោយផ្ទាល់ក្នុងការសម្រេចលទ្ធផលទាំងនោះ ។ ទម្រង់ការ និងគោលការណ៍សម្រាប់សូចនាករតាមដានរួមគ្នា ត្រូវបានពិនិត្យឡើងវិញនិងកែសម្រួលដោយផ្តោតលើលទ្ធផល ហើយត្រូវបានបង្ហាញក្នុងកិច្ចពិភាក្សា និងបានការឯកភាពនៅក្នុងវគ្គបណ្តុះបណ្តាលដែលបានរៀបចំនាខែវិច្ឆិកា ឆ្នាំ២០០៩ និងកិច្ចប្រជុំរវាងប្រធានលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសចម្រុះរបស់រាជរដ្ឋាភិបាល និងអ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសចម្រុះ នាខែកុម្ភៈ ឆ្នាំ២០១០ ។

## គោលការណ៍នៃសូចនាករតាមដានរួមគ្នា

គោលការណ៍ខាងក្រោម ដែលមានគោលដៅធានានូវចរិតទ្វេទិសនៃសូចនាករតាមដានរួមគ្នា ត្រូវបានគូសបញ្ជាក់ឡើងវិញ និងមានខ្លឹមសារសង្ខេបដូចខាងក្រោម÷

១- សូចនាករតាមដានរួមគ្នាឆ្លុះបញ្ចាំងអំពីការព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដោយផ្អែកលើគោលការណ៍នៃគណនេយ្យភាពទ្វេទិស លើសកម្មភាពដែលត្រូវអនុវត្តរួមគ្នា ដើម្បីឈានទៅសម្រេចគោលដៅនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងគោលដៅតាមវិស័យ ។

២- សូចនាករតាមដានរួមគ្នាសង្កត់ធ្ងន់លើទំនាក់ទំនងរវាងសកម្មភាព ធាតុចេញ និងលទ្ធផល ក្នុងបរិបទផែនការយុទ្ធសាស្ត្រតាមវិស័យ កំណែទម្រង់ស្ថូល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២ ។

៣- សូចនាករតាមដានរួមគ្នាមិនមែនជាកិច្ចការបន្ថែមលើដំណើរការការងារ និងការតាមដានដែលមានស្រាប់នោះឡើយ ។ ប៉ុន្តែ សូចនាករតាមដានរួមគ្នាបានដកស្រង់ពីផែនការនិងប្រព័ន្ធតាមដានដែលមានស្រាប់ជាប្រចាំរបស់រាជរដ្ឋាភិបាល ឬរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។

៤-«រួមគ្នា» មានន័យថា រួមគ្នាក្នុងការកំណត់អាទិភាព ក្នុងការរៀបចំ និងក្នុងការអនុវត្តន៍និងតាមដានដោយផ្អែកលើគោលការណ៍នៃភាពជាដៃគូ និងគណនេយ្យភាពទ្វេទិស ។

៥- ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ត្រូវជម្រុញលើកទឹកចិត្តឱ្យមានការពិភាក្សាលើវឌ្ឍនភាពក្នុងការអនុវត្តន៍ផែនការទូទាំងវិស័យ និងរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នានេះ ជាប្រចាំជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

## ***វឌ្ឍនភាពក្នុងការអនុវត្តន៍***

មូលដ្ឋាននៃការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានឯកភាពក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ នាថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០០៨ កន្លងមក បានទទួលធាតុចូល ពីក្រុមការងារបច្ចេកទេសចម្រុះ ក្នុងខែមិនា ឆ្នាំ២០១០ និងរបាយការណ៍ស្តីពីវឌ្ឍនភាពដែលក្រុមការងារបានផ្តល់មកគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងឆ្នាំ២០០៩។ ទន្ទឹមនឹងវឌ្ឍនភាព ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់នឹងបន្តកិច្ចពិភាក្សាដើម្បីដោះស្រាយបញ្ហាប្រឈម ដើម្បីអាចឈានទៅរកការឯកភាពរួមគ្នា នៅវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣នេះ ។

ជារួម យើងសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ទោះបីឆ្នាំ២០០៩ គឺជាឆ្នាំដ៏លំបាកដែលបណ្តាលមកពីកលិយុគហិរញ្ញវត្ថុសកលលោក និងបច្ច័យអាក្រក់ដែលបក់បោកលើសេដ្ឋកិច្ចកម្ពុជា ។ វឌ្ឍនភាពទាំងនេះអាចគូសបញ្ជាក់បានថា ភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នៅតែមានភាពរឹងមាំ បើទោះមានបញ្ហាប្រឈមទាំងនេះក៏ដោយ ។ រាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (សូចនាករទី១) រហូតដល់ឆ្នាំ២០១៣ ដើម្បីធានាសង្គតិភាពរវាងគោលនយោបាយរបស់រាជរដ្ឋាភិបាលជាមួយនឹងចក្ខុវិស័យដែលបានកំណត់ក្នុង**«យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព- ដំណាក់កាលទី២»** ដែលជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៤ នៃរដ្ឋសភា ។ អាទិភាពក្នុងការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ (សូចនាករទី២) ដែលបានកំណត់នៅក្នុង «ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល» ក៏ត្រូវបានកែសម្រួលដើម្បីឆ្លើយតបនឹងសកម្មភាពអាទិភាពនៅកម្រិតវិស័យ និងលក្ខណៈដោយឡែករបស់វិស័យ ដើម្បីធានាភាពសមស្រប និងផ្តល់ការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់វិស័យ ។

## អាទិភាពក្នុងវិស័យសង្គមកិច្ច

អាទិភាពដែលកំណត់ក្នុងវិស័យសង្គមកិច្ចសម្រេចបានតាមគោលដៅស្ទើរតែទាំងអស់ ពិសេស វឌ្ឍនភាពក្នុងវិស័យអប់រំនិងសុខាភិបាល ។ ការបន្ថយបង្កើនអត្រាឡើងថ្នាក់របស់សិស្សនៅបឋមសិក្សា (សូចនាករទី៣) និងកាត់បន្ថយអត្រាស្លាប់របស់មាតានិងទារក (សូចនាករទី៤) នៅតែជាអាទិភាពសំខាន់បំផុតមួយសម្រាប់វិស័យទាំង ២នេះ ។ ទន្ទឹមនឹងនេះ វិធានការណ៍សម្រាប់ឆ្លើយតបនឹងការរីករាលដាលនៃជម្ងឺអេដស៍ពីម្តាយទៅកូន (សូចនាករទី៥) និងសម្រាប់បន្ធូរបន្ថយហានិភ័យបណ្តាលមកពីការកើនឡើងនៃតម្លៃស្បៀងតាមរយៈការផ្តល់ការគាំពារសង្គម (សូចនាករទី៦) ក៏បានចាត់ទុកថាជាអាទិភាពផងដែរ ។

## អាទិភាពក្នុងវិស័យសេដ្ឋកិច្ច

វឌ្ឍនភាពក្នុងវិស័យសេដ្ឋកិច្ចមិនមានកម្រិតដូចៗគ្នានៅគ្រប់ការដ្ឋានការងារនោះឡើយ ។ កម្មវិធីទាំង ៥សម្រាប់យុទ្ធសាស្ត្រកសិកម្មនិងទឹកទើបបានរៀបចំបញ្ចប់ និងកំពុងរង់ចាំការអនុមតិពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹកនិងឧតុនិយម ដើម្បីចាប់ផ្តើមអនុវត្ត (សូចនាករទី៧) ។ គោលដៅដែលបានកំណត់ដោយក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន (សូចនាករទី៩) នៅមិនទាន់សម្រេចបានទាំងស្រុងនៅឡើយ ពិសេសគោលដៅស្តីពីសហគមន៍ព្រៃឈើ និងតំបន់ព្រៃអភិរក្ស ។ សម្រាប់វិស័យដទៃទៀត ដូចជាដីធ្លី (សូចនាករទី៨) ជលផល (សូចនាករទី១០) និងការដោះមីន (សូចនាករទី១១) ក្រសួងនិងស្ថាប័នទទួលខុសត្រូវនឹងបន្តកិច្ចប្រឹងប្រែងបន្ថែមទៀត ទើបអាចឈានទៅសម្រេចគោលដៅដែលបានកំណត់ ។ បញ្ហាប្រឈមរួមដែលជួបប្រទះ គឺស្តែងឡើងតាមរយៈភាពស្មុគ្រស្មាញនៃបញ្ហាដែលត្រូវដោះស្រាយ និងតម្រូវការធនធានចាំបាច់សម្រាប់អនុវត្តសកម្មភាព ។ ក្នុងការគាំទ្រការអភិវឌ្ឍន៍ផ្នែកឯកជន (សូចនាករទី១២) ដំណើរការរៀបចំបញ្ជីលិខិតគតិយុត្តិបានជួបការលំបាក និងទាមទារពេលវេលាច្រើន ប៉ុន្តែ កិច្ចការនេះកំពុងដំណើរការទៅមុខ ។ ការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងវិស័យពាណិជ្ជកម្ម ក៏មានវឌ្ឍនភាពគួរឱ្យកត់សំគាល់ បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវអនុក្រឹត្យសម្រាប់រៀបចំរចនាសម្ព័ន្ធខាងស្ថាប័នរួចមក ។

## អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ

វិស័យហេដ្ឋារចនាសម្ព័ន្ធសម្រេចបាននូវវឌ្ឍនភាពលើសកម្មភាពមួយចំនួន ទន្ទឹមនឹងវឌ្ឍនភាពយឺតលើសកម្មភាពដទៃទៀតក៏ដោយ (ដូចជាពាក់ព័ន្ធនឹងយន្តការថែទាំផ្លូវ) ដោយសារនីតិវិធីស្មុគ្រស្មាញ និងទាមទារពេលវេលា (សូចនាករទី១៣) ។ ការរៀបចំយុទ្ធសាស្ត្រទឹកស្អាត និងអនាម័យជនបទ (សូចនាករទី១៤) ក៏រំពឹងថានឹងបញ្ចប់នាពាក់កណ្តាលឆ្នាំ២០១០ផងដែរ ដែលយុទ្ធសាស្ត្រនេះនឹងរួមចំណែកក្នុងការផ្តល់ទឹកស្អាតនិងអនាម័យជូនប្រជាជននៅតាមតំបន់ដាច់ស្រយាល ពិសេសសម្រាប់ក្រុមជនងាយរងគ្រោះ ។

## អាទិភាពក្នុងវិស័យអភិបាលកិច្ច និងអន្តរវិស័យ

វិស័យអភិបាលកិច្ចមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ។ ចំណុចគន្លឹះបំផុតនោះគឺការស្នើសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយជូនរដ្ឋសភាអនុមតិ (សូចនាករទី១៧) ។ ទោះបីការចាប់ផ្តើមអនុវត្តច្បាប់នេះទាមទារពេលវេលាសម្រាប់រៀបចំយន្តការខាងស្ថាប័នឱ្យមានលក្ខណៈរឹងមាំ វិធានការណ៍ដែលបានប្រកាន់យកដោយអង្គភាព

ប្រឆាំងអំពើពុករលួយរបស់រាជរដ្ឋាភិបាល គឺជាសញ្ញាបញ្ជាក់ឱ្យឃើញច្បាស់ថាការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយជាកិច្ចការដែលត្រូវអនុវត្តដូចភ្លៀងរលឹម ។ ក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ (សូចនាករទី១៥) ការងារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្ស និងការពង្រឹងសមត្ថភាព មានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ដោយបានរៀបចំសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយចាំបាច់សម្រាប់ស្នើជូនរាជរដ្ឋាភិបាលអនុមតិ ។ ទន្ទឹមនឹងការបញ្ចប់កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ឧបករណ៍ដទៃទៀតសម្រាប់ពង្រឹងគណនេយ្យភាព និងគុណភាពការងារក៏ត្រូវបានដាក់ឱ្យអនុវត្តផងដែរ ដូចជា ទីភ្នាក់ងារប្រតិបត្តិការពិសេសកំពុងត្រូវបានដាក់ឱ្យអនុវត្តបន្ត ដើម្បីលើកកំពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។ រីឯក្នុងកំណែទម្រង់ប្រព័ន្ធច្បាប់និងតុលាការ (សូចនាករទី១៦) ទោះបីច្បាប់មូលដ្ឋានមិនទាន់ត្រូវបានអនុមតិក៏ដោយ (លើកលែងក្រមព្រហ្មទណ្ឌ) ក៏សេចក្តីព្រាងច្បាប់មូលដ្ឋានទាំងនេះបានស្ថិតក្នុងដំណាក់កាលបញ្ចប់ ទន្ទឹមនឹងវឌ្ឍនភាពក្នុងការកែសម្រួលច្បាប់នានាពាក់ព័ន្ធនឹងការប្រព្រឹត្តិទៅនៃប្រព័ន្ធតុលាការ ។ ទន្ទឹមនឹងនេះ ក៏មានវឌ្ឍនភាពជាដុំកំភួនក្នុងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (សូចនាករទី១៨) ក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (សូចនាករទី១៩) និងយេនឌ័រ (សូចនាករ ទី២០) ផងដែរ ។ វឌ្ឍនភាពទាំងនេះរួមមាន : ការបញ្ចប់ការរៀបចំកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការឱ្យបានស៊ីជម្រៅ ដែលកម្មវិធីនេះនឹងត្រូវអនុមតិពីរាជរដ្ឋាភិបាលក្នុងពេលខាងមុខ និងការអនុវត្តន៍កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ- ដំណាក់កាលទី២ ដែលផ្តោតលើការកែលំអគណនេយ្យភាពហិរញ្ញវត្ថុ ។

ទោះបីសម្រេចបាននូវវឌ្ឍនភាពដូចបានរៀបរាប់ខាងលើ កំណត់សំគាល់នៅក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនាឆ្នាំ២០០៨ «យើងត្រូវពន្លឿនល្បឿនអនុវត្តបន្ថែមទៀត » ត្រូវបានលើកឡើងសារជាថ្មីម្តងទៀត សម្រាប់ឆ្លុះបញ្ចាំងអំពីកំណាត់ផ្លូវដ៏វែងឆ្ងាយដែលត្រូវធ្វើដំណើរទៅមុខ ។ យើងមានសក្ខីកម្មគួរឱ្យមោទនៈជាច្រើនសម្រាប់បញ្ជាក់អំពីលទ្ធភាពការបង្កើនល្បឿនក្នុងការអនុវត្តន៍ ។ ប៉ុន្តែ ភាពជាដៃគូក៏ទាមទារនូវភាពឈ្លាសវៃ ភាពទន់ភ្លន់និងបត់បែនក្នុងការអនុវត្តន៍ផងដែរ ។ ដំណើរការនៃការកំណត់សូចនាករតាមដានរួមគ្នាបានបញ្ជាក់យ៉ាងច្បាស់អំពីភាពចាំបាច់ក្នុងការផ្តោតការយកចិត្តទុកដាក់ទៅលើ «លទ្ធផល » នៅកម្រិតវិស័យ ។ ដូចដែលរបកគំហើញនៃការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជាបានគូសបញ្ជាក់ថា ទោះបីជាកិច្ចប្រតិបត្តិនេះស្ថិតនៅក្នុងកម្រិតដំបូងក៏ដោយ ក៏ការផ្តោតការយកចិត្តទុកដាក់លើលទ្ធផលគឺជាវិធីសាស្រ្តប្រកបដោយសក្តានុពលមួយ សម្រាប់របៀបរបបបំពេញការងារនៅតាមវិស័យ បន្ថែមពីលើការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ ស្ថានភាពលំអិតនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា បានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៤នៃរបាយការណ៍នេះ ។

## ការស្វែងយល់ និងការអនុវត្តន៍ទស្សនទានស្តីពីគណនេយ្យភាពទ្វេទិស

និយមន័យនៃគណនេយ្យភាពទ្វេទិសនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស បញ្ជាក់ពីការប្តេជ្ញាក្នុងការពង្រឹងតួនាទីរបស់ស្ថាប័ននីតិបញ្ញត្តិនៅក្នុងដំណើរការនៃការរៀបចំយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងការរៀបចំថវិកា និងការអនុវត្តន៍ «អភិក្រមស្តីពីការចូលរួម» ក្នុងការរៀបចំ ការអនុវត្តន៍ និងការត្រួតពិនិត្យការអនុវត្តន៍យុទ្ធសាស្រ្ត

អភិវឌ្ឍន៍ជាតិ ។ ដៃគូអភិវឌ្ឍន៍បានប្តេជ្ញាផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលា អំពីលំហូរនៃហិរញ្ញប្បទាន ក្នុងពេលដែលការត្រួតពិនិត្យឡើងវិញរួមគ្នាអំពីវឌ្ឍនភាព បានផ្តោតទៅលើការអនុវត្តន៍ការប្តេជ្ញាដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសតែប៉ុណ្ណោះ ។«ផែនការសកម្មភាពទីក្រុងអាក្រា» ឆ្នាំ២០០៨ បានពង្រីកវិសាលភាពនៃនិយមន័យគណនេយ្យភាពទ្វេទិស ដោយត្រូវពង្រឹងភាពជាដៃគូបន្ថែមទៀតជាមួយនឹងអង្គការសង្គមស៊ីវិល និងដោយជម្រុញឱ្យដៃគូអភិវឌ្ឍន៍បង្ហាញតម្លាភាពមួយកម្រិតថែមទៀត ព្រមទាំងពង្រឹងការពិនិត្យឡើងវិញរួមគ្នាអំពីលទ្ធផល ។

ទស្សនទានដែលថាស្ថានភាពបច្ចុប្បន្នទទួលរងនូវឥទ្ធិពលពីអតីតកាល គឺជាកត្តាមិនអាចប្រកែកបានមួយនៅក្នុងបរិបទនៃដំណើរការអភិវឌ្ឍន៍កម្ពុជា ។ ក្នុងស្មារតីនេះ កិច្ចប្រឹងប្រែងដែលបានអនុវត្តមុនសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដូចជាការប្រើប្រាស់សូចនាករតាមដានរួមគ្នា កិច្ចប្រឹងប្រែងក្នុងការកសាងភាពជាដៃគូក្នុងកម្រិតវិស័យ និងការប្តេជ្ញាអនុវត្តឥតរាថយកំណែទម្រង់ស្នូលក្នុងវិស័យសាធារណៈ នៅរក្សាភាពត្រឹមត្រូវសម្រាប់សម្រួចទិសដៅនៃការពង្រឹងភាពជាដៃគូនាពេលបច្ចុប្បន្ន ។ របកគំហើញនៃការវាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសក៏បានសង្កេតឃើញអំពីបែបផែនប្រហាក់ប្រហែលនេះដែរក្នុងចំណោមដៃគូអភិវឌ្ឍន៍ ពិសេស ភាពផ្ទុយគ្នារវាងការប្តេជ្ញាដែលដៃគូអភិវឌ្ឍន៍បានប្រកាសជាឱឡារិកអំពីការធ្វើប្រតិភូកម្មអំណាច ការធ្វើសុខដុមនីយកម្ម និងការប្រើប្រាស់ប្រព័ន្ធជាតិ ជាមួយនឹងប្រព័ន្ធលើកទឹកចិត្ត ទាំងនៅកម្រិតបុគ្គល និងទាំងនៅកម្រិតស្ថាប័ន សម្រាប់ធានាការធ្វើរបាយការណ៍និងបន្ទាត់គណនេយ្យភាពចំពោះស្ថាប័នរបស់ខ្លួន សំខាន់ជាងការផ្តល់អាទិភាពដល់ការធ្វើសុខដុមនីយកម្មរវាងបណ្តាដៃគូអភិវឌ្ឍន៍ ឬការគាំទ្រដល់គំនិតផ្តួចផ្តើមរបស់ប្រទេសជាដៃគូ ។

ការស្វែងយល់អំពីប្រព័ន្ធលាភការ ទាំងនៅកម្រិតបុគ្គល ទាំងនៅកម្រិតស្ថាប័ន ក្នុងបរិបទដែលមានដៃគូច្រើន (ដូចជាការចូលរួមក្នុងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ការធ្វើប្រតិភូកម្មកិច្ចសហប្រតិបត្តិការ ឬការចូលរួមក្នុងក្រុមការងារបច្ចេកទេសចម្រុះ គឺជាជំហានដំបូងសំខាន់និងចាំបាច់ ដើម្បីកំណត់វិធីសាស្រ្តសមស្រប សម្រាប់គ្រប់គ្រងផលប្រយោជន៍ដែលមានលក្ខណៈខុសៗគ្នា ក្នុងគោលដៅបង្កើតគុណតំលៃ ។ ក្នុងកិច្ចប្រជុំស្តីពី «ប្រសិទ្ធភាពនៃភាពជាដៃគូ» នាខែកញ្ញា ឆ្នាំ២០០៩ អគ្គលេខាធិការនៃ ក.អ.ក/គ.ជ.ទា បានគូសបញ្ជាក់ថា «ភាពជាដៃគូនៅតែមានសារៈសំខាន់ ។ យើងត្រូវចំណាយពេលដើម្បីរិះរកមធ្យោបាយសម្រាប់ពង្រឹងភាពជាដៃគូឱ្យកាន់តែមានប្រសិទ្ធភាព ។ យើងត្រូវទទួលស្គាល់អំពីផលប្រយោជន៍ផ្សេងៗគ្នា អំពីខ្សែបន្ទាត់រាយការណ៍ខុសៗគ្នា និងខ្សែបន្ទាត់គណនេយ្យភាព និងវប្បធម៌ផ្សេងៗគ្នា ។ នេះជាកត្តាសត្យានុម័តដែលតម្រូវឱ្យធ្វើការជាមួយគ្នា ដើម្បីកំណត់ផលប្រយោជន៍និងគោលដៅរួមរបស់យើង» ។

## *វឌ្ឍនភាពសង្ខេបក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា*

ផ្អែកតាមខ្លឹមសារដូចបានរៀបរាប់ខាងលើ តារាងទី១០បានរំលេចអំពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នាទាំង២០ ។

*តារាងទី១០: សង្ខេបវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា*

| គោលដៅ | សកម្មភាពចាំបាច់ | វឌ្ឍនភាពសង្ខេប |
|---|---|---|
| ***ការអនុវត្តន៍ និងការគ្រប់គ្រងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** | | |
| ១- អនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការដោយសម្របសម្រួលការគាំទ្រ | ១- ក្រសួងផែនការរៀបចំផែនការសកម្មភាពឆ្នាំ២០០៩ ដៃគូផ្តល់បញ្ជីគម្រោងទាំងអស់ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍<br>២- បញ្ចប់ការវាយតម្លៃសមត្ថភាពស្ថាប័ន ការខ្វះចន្លោះ និងតម្រូវការ និងផ្នែកតម្រឹម នៃរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ | ១- រៀបចំរួច<br>២- បញ្ចប់ការវាយតម្លៃ |
| ២- អនុវត្តអាទិភាពស្តីពីការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ | រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ឯកភាពលើសកម្មភាពអនុវត្តរួមគ្នាមួយចំនួន ដែលជាក់ស្តែង និងអាចតាមដានបាន ផ្អែកលើផែនការសកម្មភាពសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល | សូចនាករតាមដានរួមគ្នាត្រូវបានអនុមតិ |
| ***អាទិភាពក្នុងវិស័យសង្គមកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** | | |
| ៣- បង្កើនអត្រាឡើងថ្នាក់នៅកម្រិតបឋមសិក្សា | ១- កាត់បន្ថយចំនួនសាលារៀនមិនគ្រប់កម្រិត<br>២- ពង្រាយគ្រូចេញថ្មីនៅសាលាដែលខ្វះគ្រូ និងនៅតាមតំបន់ដាច់ស្រយាល<br>៣- កែសម្រួលបទបញ្ជាផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការឡើងថ្នាក់ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ | ១- ថយចុះមកត្រឹម ១៨%<br>២- ពង្រាយគ្រូបាន ៩៥%<br>៣- បានកែសម្រួល និងផ្សព្វផ្សាយ |
| ៤- បង្កើនអត្រាស្ត្រីសម្រាលកូនដោយពេទ្យឆ្មបឱ្យបាន៥០% សម្រាប់ឆ្នាំ ២០០៩ | ១- ជ្រើសរើស និងពង្រាយបុគ្គលិកឆ្មប ៧៩ នាក់ នៅតាមមណ្ឌលសុខភាពចំនួន ៧៩ ដែលមិនទាន់មានឆ្មប<br>២- ផ្តល់ប្រៀវត្សរ៍លើកទឹកចិត្តដល់បុគ្គលិកឆ្មប<br>៣- បង្កើនធនធានដល់គម្រោងផ្នែក RMNCH ឆ្នាំ ២០០៩ | ១- សម្រេចគោលដៅ<br>២- កំពុងពិចារណា<br>៣- ធនធានកើនឡើងបន្តបន្ទាប់ |
| ៥- ពង្រឹងការឆ្លើយតបនឹងការឆ្លងជំងឺអេដស៍ | បង្កើនភាគរយនៃស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ ដែលទទួលឱសថប្រឆាំងនឹងមេរោគពី ៣០-៤០% | សម្រេចបាន ៣២,៣ % |
| ៦- បន្ធូរបន្ថយផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ និងធានាសន្តិសុខស្បៀង | បង្កើតប្រព័ន្ធត្រួតពិនិត្យរួមសម្រាប់តាមដានផលប៉ះពាល់នៃការឡើងតម្លៃស្បៀងទៅលើសន្តិសុខស្បៀងតាមគ្រួសារ | អនុវត្តបានមួយផ្នែក- កំពុងបន្ត |
| ***អាទិភាពក្នុងវិស័យសេដ្ឋកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** | | |
| ៧- អនុវត្តយុទ្ធសាស្ត្រកសិកម្មនិងទឹក | ១- បញ្ចប់ការរៀបចំកម្មវិធី និងយន្តការអនុវត្ត<br>២- យុទ្ធសាស្ត្រកសិកម្មនិងទឹកជាក្របខ័ណ្ឌសម្រាប់សកម្មភាពក្នុងកម្រិតវិស័យ<br>៣- កែលំអការសម្របសម្រួល និងធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យពីរដងក្នុងមួយឆ្នាំ | ១- អនុមតិឆាប់ៗ<br>២- អនុវត្តបន្ទាប់ពីការអនុមតិ<br>៣- បានអនុវត្ត |
| ៨- អនុវត្តក្របខ័ណ្ឌគតិយុត្តិរបស់ច្បាប់ភូមិបាល | ១- ដីរបស់សហគមន៍ជនជាតិភាគតិច- អនុក្រឹត្យស្តីពីការចុះបញ្ជីរៀបចំឆ្នាំ២០០៩<br>២- វាយតម្លៃវិធានការណ៍បណ្តោះអាសន្នសម្រាប់ការពារដីសហគមន៍ជនជាតិភាគតិច<br>៣- ការកាន់កាប់ដីធ្លី- សេចក្តីព្រាងគោលនយោបាយស្តីពីលំនៅដ្ឋាន<br>៤- ការរៀបចំដែនដី- សេចក្តីព្រាងគោលនយោបាយផែនការកម្មស្តីពីដែនដី | ១- អនុក្រឹត្យត្រូវបានអនុមតិ<br>២- គោលនយោបាយអនុមតិ<br>៣- សេចក្តីព្រាងរៀបចំរួច<br>៤- សេចក្តីព្រាងរៀបចំរួច |
| ៩- អនុវត្តច្បាប់ព្រៃឈើ និងបញ្ចប់ការរៀបចំកម្មវិធីជាតិព្រៃឈើ | ១- អនុវត្តច្បាប់និងលិខិតបទដ្ឋាន (ផ្សព្វផ្សាយបញ្ជីដីសម្បទានសេដ្ឋកិច្ច)<br>២- បោះព្រំប្រទល់ព្រៃឱ្យបាន ១.០០០គម និងកំណត់តំបន់ការពារធម្មជាតិឱ្យបានពីរ<br>៣- អនុមតិសហគមន៍ព្រៃឈើ១០០ និងតំបន់ការពារសហគមន៍ ១០ យ៉ាងតិច<br>៤- បញ្ចប់ការរៀបចំគម្រោងកម្មវិធីជាតិព្រៃឈើ និងចាប់ផ្តើមអនុវត្តចុងឆ្នាំ២០០៩ | ១- សម្បទានសេដ្ឋកិច្ច ៧២<br>២- អនុវត្តបានមួយផ្នែក- កំពុងបន្ត<br>៣- វឌ្ឍនភាពយឺត<br>៤- រៀបចំបញ្ចប់ រង់ចាំការសម្រេច |

| គោលដៅ | សកម្មភាពចាំបាច់ | វឌ្ឍនភាពសង្ខេប |
|---|---|---|
| ១០- រំលេចអាទិភាពជលផល ក្នុងផែនការអភិវឌ្ឍន៍គ្រប់កម្រិត | ១- យ៉ាងហោច៨០%នៃផែនការប្រចាំឆ្នាំត្រូវបានគាំទ្រតាមអភិក្រមគ្រប់គ្រងទូទាំងវិស័យ<br>២- ក្រមប្រតិបត្តិនេសាទប្រកបដោយការទទួលខុសត្រូវត្រូវអនុមតិ និងអនុវត្ត | ១- មានវឌ្ឍនភាព<br>២- ពង្រាងដំណាក់កាលចុងក្រោយ |
| ១១- កាត់បន្ថយករណីគ្រោះថ្នាក់ ដោយសារមីន ៥០ ករណី និង ៧- ១០ %ផ្ទៃដីដែលមានមីន | ១- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍គោលនយោបាយសកម្មភាពមីន<br>២- រៀបចំយុទ្ធសាស្ត្រជាតិស្តីពីការបោសសំអាតមីនរយៈពេល ១០ឆ្នាំ<br>៣- អនុវត្តផែនការយុទ្ធសាស្ត្រ២០០៩-២០១១ ដើម្បីកាត់បន្ថយការបែកខ្ញែកនៃការគាំទ្រ<br>៤- កែលំអទិន្នន័យស្តីពីការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ | ១- មានវឌ្ឍនភាព<br>២- ដំណាក់កាលចុងក្រោយ<br>៣- ការងារបន្ត<br>៤- ការងារបន្ត |
| ១២- បង្កើតបរិយាកាស អំណោយផល សម្រាប់កិច្ច អភិវឌ្ឍន៍វិស័យឯកជន | ១- វឌ្ឍនភាពក្របខ័ណ្ឌគតិយុត្តិដើម្បីបង្កើតបរិយាកាសអំណោយផលដល់វិស័យឯកជន<br>២- អនុមតិផែនការរំកិលបីឆ្នាំសម្រាប់កំណែទម្រង់ពាណិជ្ជកម្ម | ១- មានវឌ្ឍនភាព<br>២- សម្រេចបានមួយផ្នែក |
| *អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* | | |
| ១៣- ចីរភាពនិងសុវត្ថិភាពនៃ បណ្តាញផ្លូវជាតិ និងជនបទ | ១- កែលំអយន្តការថែទាំផ្លូវ<br>២- ការគ្រប់គ្រងការដឹកជញ្ជូនលើសទំងន់<br>៣- អនុវត្តកម្មវិធីយល់ដឹងពីសុវត្ថិភាពផ្លូវថ្នល់ | ១- វឌ្ឍនភាពយឺត<br>២- នីតិវិធីវែង<br>៣- មានវឌ្ឍនភាព |
| ១៤- បង្កើនការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតាមជនបទ | រៀបចំនិងអនុវត្តយុទ្ធសាស្ត្រស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទនិងអនាម័យ ព្រមទាំងថវិកា ដោយផ្អែកលើគោលនយោបាយស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទ | រៀបចំបញ្ចប់ពាក់កណ្តាលឆ្នាំ ២០១០ |
| *អាទិភាពក្នុងវិស័យអភិបាលកិច្ច និងពហុវិស័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* | | |
| ១៥- កែលំអគុណភាពនៃការ ផ្តល់សេវាសាធារណៈ | ១- អនុវត្តយន្តការនៃការត្រួតពិនិត្យគុណភាពសេវា និងគណនេយ្យភាពដោយបង្កើតភ្នាក់ងារ ប្រតិបត្តិការពិសេស កន្សោមអាទិភាពនិងលាភការផ្អែកលើលទ្ធផលការងារ<br>២- អនុមតិគោលនយោបាយស្តីពីការគ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍន៍ធនធាន មនុស្ស និងការអភិវឌ្ឍន៍សមត្ថភាព | ១- យន្តការលើកទឹកចិត្តថ្មីកំពុងត្រូវ បានពិនិត្យ និងពិភាក្សាឡើងវិញ<br>២- សេចក្តីព្រាងកំពុងរង់ចាំការ អនុមតិ |
| ១៦- បង្កើតប្រព័ន្ធច្បាប់ និង តុលាការ ដែលការពារ សិទ្ធិបុគ្គល | ១- បញ្ចប់សេចក្តីព្រាងច្បាប់ដែលនៅសេសសល់ទាំងបួន<br>២- អនុវត្តក្របខ័ណ្ឌកំណែទម្រង់ច្បាប់និងតុលាការ- តុលាការគំរូទាំងបួន<br>៣- បន្តបណ្តុះបណ្តាលមន្ត្រីតុលាការដើម្បីកែលំអគុណភាពសេវា និងកិច្ចដំណើរការ | ១- កំពុងអនុវត្តបន្ត<br>២- មានវឌ្ឍនភាព<br>៣- កំពុងអនុវត្តបន្ត |
| ១៧- ប្រយុទ្ធប្រឆាំងអំពើ ពុករលួយ | ១- បន្ទាប់ពីអនុមតិក្រមព្រហ្មទណ្ឌ រៀបចំបញ្ចប់ច្បាប់ប្រឆាំងអំពើពុករលួយ<br>២- រៀបចំផែនការដើម្បីអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ<br>៣- ផ្សព្វផ្សាយព័ត៌មានស្តីពីករណីអំពើពុករលួយ និងការផ្តន្ទាទោស<br>៤- រៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មាន | ១- សម្រេចគោលដៅ ។ រីឯ វិធានការណ៍ផ្សេងៗ ដូចជាការអប់រំ និងការផ្សព្វផ្សាយ កំពុងត្រូវបាន អនុវត្ត |
| ១៨- ក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិ ស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ | ១- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត- ក្រុង ស្រុក- ខណ្ឌ ស្របតាមច្បាប់អង្គការ<br>២- បញ្ចប់ការរៀបចំ និងអនុមតិកម្មវិធីជាតិ | ១- សម្រេចគោលដៅ<br>២- រៀបចំបញ្ចប់ រង់ចាំការអនុមតិ |
| ១៩- កម្មវិធីកែទម្រង់ហិរញ្ញវត្ថុ សាធារណៈ- ដំណាក់កាលទី២ | បន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយអនុវត្ត និង តាមដានផែនការសកម្មភាពជំហានទី២ និងសម្រេចតាមគោលដៅដែលបានឯកភាព | វឌ្ឍនភាពបន្ត |
| ២០- អនុមតិនិងអនុវត្តច្បាប់ ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងអាជីវកម្មលើស្ត្រី និងកុមារ | ១- អនុក្រឹត្យស្តីពីការសម្រេចចិត្តផ្នែករដ្ឋបាលស្តីពីអំពើហិង្សាក្នុងគ្រួសារ<br>២- ក្របខ័ណ្ឌតាមដានការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ<br>៣- កែសម្រួលនិងអនុមតិផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី<br>៤- ពិនិត្យឡើងវិញនូវបទបញ្ញត្តិ និងគោលនយោបាយស្តីពីអន្តោប្រវេសន៍ | ១- នៅមិនទាន់បានសម្រេច<br>២- មានវឌ្ឍនភាព<br>៣- សម្រេចតាមគោលដៅ<br>៤- មានវឌ្ឍនភាព |

------------

# ជំពូក ៥
# ទិសដៅកម្រិតគោលនយោបាយក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ

លំហូរហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់កម្ពុជានៅបន្តកើនឡើង ថ្វីត្បិតមានសម្ពាធខាងធនធានកម្រិតសកលលោកក៏ដោយ ។ ទំហំហិរញ្ញប្បទានសហប្រតិបត្តិការបានបន្តជួយគាំទ្រដល់ការអនុវត្តន៍កម្មវិធីរបស់រាជរដ្ឋាភិបាល ហើយសំខាន់ជាងនេះ បានក្លាយជាការងារសំខាន់ដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានផ្តោតការយកចិត្តទុកដាក់ សម្រាប់ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានហិរញ្ញប្បទានសហប្រតិបត្តិការទាំងនោះ ។ ជំពូកខាងដើមបានបញ្ជាក់ច្បាស់អំពីវឌ្ឍនភាពជាច្រើនដែលត្រូវលើកទឹកចិត្ត ពិសេសនៅកម្រិតវិស័យ ។ ប៉ុន្តែ ទោះបីយ៉ាងនេះក្តី ក៏ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត សម្រាប់ជម្រុញការផ្លាស់ប្តូរឥរិយាបទ ការកែលំអប្រព័ន្ធ និងរបៀបប្រតិបត្តិការការងារជាមួយគ្នា សម្រាប់ពង្រឹងវឌ្ឍនភាពដែលសម្រេចបានកន្លងមក ។

របកគំហើញនៃការវាយតម្លៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដែលគាំទ្រដោយសក្ខីកម្មខាងគុណភាព បានបង្ហាញអំពីបញ្ហាប្រឈមក្នុងកំណែទម្រង់ការអនុវត្តន៍ហិរញ្ញប្បទានសហប្រតិបត្តិការឱ្យបានល្អ ។ ស្ថានការណ៍ដែលបានកើតឡើងចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក ហើយដែលត្រូវបានចាត់ទុកក្នុងរបាយការណ៍វិភាគកន្លងមកថាជាហានិភ័យដ៏អាក្រក់ នៅបន្តអត្ថិភាពរហូតមកដល់បច្ចុប្បន្ននេះ ។ ស្ថានការណ៍នេះចំណុះទាំងស្រុងទៅលើទំនាក់ទំនងនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលតម្រូវឱ្យមានការខិតខំប្រឹងប្រែងរួមគ្នា និងឆន្ទៈខាងនយោបាយទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងសមត្ថភាពខាងស្ថាប័ន និងធនធានមនុស្ស ព្រមទាំងកែប្រែទម្លាប់នៃការអនុវត្តន៍ការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ គំនូរខាងក្រោមបានបង្ហាញអំពីការខិតខំប្រឹងប្រែងរយៈពេលយូរ សម្រាប់ជម្រុញការអនុវត្តន៍ហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឱ្យឈានដល់កម្រិតខ្ពស់មួយដែលមានតុល្យភាពគ្នារវាងប្រសិទ្ធភាពនិងលទ្ធផល ។ ប៉ុន្តែ ស្ថានភាពបច្ចុប្បន្នបានបន្ទុចបង្អាក់និងរារាំងដល់ដំណើរវិវត្តន៍នេះ ។ ស្ថានការណ៍នេះតម្រូវឱ្យមាន÷ ទី១- កិច្ចប្រឹងប្រែងរយៈពេលវែងសម្រាប់ជម្រុះបញ្ហារារាំងទាំងឡាយក្នុងដំណើរវិវត្តន៍នេះ ។ និងទី២- ការរៀនសូត្របន្ថែមទៀត ដើម្បីធានាការសម្រេចកម្រិតគោលនយោបាយមានភាពត្រឹមត្រូវ ស្របតាមតក្កភាពរបស់ប្រទេស និងមានប្រសិទ្ធភាពសម្រាប់សម្រួលដល់ការផ្លាស់ប្តូរឥរិយាបទ ។

របកគំហើញនៃការងារវិភាគសម្រាប់ជាមូលដ្ឋាននៃ «គំនិតផ្តួចផ្តើមស្តីពីការបង្កើនប្រសិទ្ធភាពនៃភាពជាដៃគូ» ហើយដែលមានសង្គតិភាពជាមួយនឹងសក្ខីកម្មកម្រិតសកល បានបញ្ជាក់ថា ដំណោះស្រាយទាំងឡាយកម្រិតបច្ចេកទេសមិនទាន់មានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ សម្រាប់ឆ្លើយតបនឹងបញ្ហាប្រឈមនានាក្នុងការកែលំអការអនុវត្តន៍ជាក់ស្តែងនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅឡើយ ។ ការកំណត់បញ្ហានេះថាជាបញ្ហាបច្ចេក-ទេសគឺជាការវិនិច្ឆ័យខុសឆ្គងមួយ ។ អភិក្រមដែលមានលក្ខណៈសមស្របនោះគឺមិនត្រូវផ្តោតលើស្ថានភាពអនាគតដែលយើងចង់បាន ឬផ្តោតច្រើនហួសហេតុលើដំណាក់កាលផែនការ ឬដំណាក់កាលអន្តរកាលនោះឡើយ ។ ផ្ទុយទៅវិញ បញ្ហាគន្លឹះគឺការស្វែងយល់ឱ្យបានច្រើនអំពីស្ថានការណ៍បច្ចុប្បន្ន ។ នៅកម្ពុជា ទំនាក់ទំនងក្នុងហិរញ្ញប្បទានសហប្រតិបត្តិការនៅមានកម្រិតទាប ប៉ុន្តែមានតុល្យភាព ។ កិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅកម្រិតខ្ពស់ជាងកម្រិត

បច្ចុប្បន្ន តាមគំរូដូចបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស គឺជាបញ្ហាប្រឈម ហើយគឺជាកិច្ចប្រឹងប្រែង ដែលគ្មានហេតុផលសមស្រប ។ នៅពេលអនុវត្តការផ្លាស់ប្តូរ នោះប្រហែលជាមាននិន្នាការត្រឡប់ថយក្រោយ ទៅកាន់កម្រិតទាបដូចកាលពីមុន ប្រសិនបើគ្មានចលនការគ្រប់គ្រាន់ និងរឹងមាំ ហើយក៏មិនអាចរក្សាបាននូវអន្តរកាលសម្រាប់ឈានទៅកែលំអស្ថានការណ៍បានឡើយ ។ ការស្វែងយល់អំពីមូលហេតុដែលនាំឱ្យតុល្យភាពស្ថិតក្នុងកម្រិតទាប និងមានស្ថេរភាពបែបនេះ-«ឥទ្ធិពលនៃស្ថានការណ៍បច្ចុប្បន្ន»- នឹងផ្តល់ការយល់ដឹងកាន់តែច្បាស់អំពីវិធីជម្រុញនិងអនុវត្តន៍សម្រាប់ធានាឱ្យមានការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាព ។ ការខិតខំប្រឹងប្រែងដើម្បីស្វែងយល់អំពីចរិកនៃស្ថានការណ៍នេះមានសារៈសំខាន់ ពិសេសសម្រាប់ដំណើរការសកល ប្រសិនបើចង់ឱ្យសេចក្តីថ្លែងការណ៍ណាមួយបន្តពីសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស អាចអនុវត្ត និងទទួលផលបានល្អប្រសើរជាងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសបច្ចុប្បន្ន ។

*គំនូរទី១២ : អន្តរកាលឆ្ពោះទៅរកតុល្យភាពកម្រិតខ្ពស់ស្តីពីប្រសិទ្ធភាពនិងលទ្ធផល*




## <u>ការបន្ត និងការផ្លាស់ប្តូរក្នុងគោលនយោបាយគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ</u>

នៅប្រទេសកម្ពុជា យើងបានប្រឹងប្រែងរួមគ្នាដើម្បីស្វែងយល់កត្តារាំងស្ទះនិងឧបសគ្គទាំងឡាយ ដែលត្រូវដោះស្រាយ ។ ការត្រិះរិះពិចារណា និងការរៀនសូត្រ ព្រមទាំងការដកស្រង់បទពិសោធន៍បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបន្សុំខ្លួនទៅនឹងបទដ្ឋានកម្រិតសកល ។ រាជរដ្ឋាភិបាលបានធ្វើអាទិភាពភាវូបនីយកម្ម

សកម្មភាពឱ្យកាន់តែស៊ីសង្វាក់ជាងមុន និងស្របទៅនឹងបរិបទជាតិ ពិសេស តាមរយៈការចាត់វិធានការណ៍មុតស្រួចមួយចំនួនស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្រិតវិស័យ ដោយប្រើប្រាស់សូចនាករតាមដានរួមគ្នា ជាឧបករណ៍សម្រាប់តាមដាន ។ ទិសដៅកម្រិតគោលនយោបាយបានវិវត្តន៍ ហើយបានសម្របទៅនឹងគោលដៅដែលបានកំណត់ក្នុង «ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលឆ្នាំ២០០៦» និងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសឆ្នាំ២០០៥ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។

យើងបានបន្តកិច្ចប្រឹងប្រែងរបស់យើងក្នុងការរៀបចំគោលនយោបាយឱ្យបានកាន់តែប្រសើរឡើង ដោយចាប់ផ្តើមរៀបចំ «របាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការលើកទី១ នាឆ្នាំ២០០៧» ។ របាយការណ៍នេះបានស្នើនូវអនុសាសន៍សំខាន់ៗចំនួន ៤ គឺ ÷

១- អនុវត្តគោលការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្រិតវិស័យ ដោយប្រើប្រាស់ «ឯកសារណែនាំស្តីពីមុខងារនិងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះឆ្នាំ២០០៧» ។

២- អនុវត្តតួនាទីរបស់ គ.ជ.នា/ក.អ.ក សម្រាប់សម្របសម្រួលការកៀរគរធនធាន និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ។

៣- ពង្រឹងការកសាងសមត្ថភាពក្នុងកិច្ចប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និង

៤- ជម្រុញគណនេយ្យភាពទ្វេទិសតាមរយៈយន្តការនៃការពិនិត្យរួមគ្នា សូចនាករតាមដានរួមគ្នា និងកិច្ចប្រឹងប្រែងសម្រាប់ពង្រឹងជវភាពនៃភាពជាដៃគូ។

របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ បានស្នើអនុសាសន៍មួយចំនួនដោយផ្អែកលើសក្ខីកម្មនៃការវាយតម្លៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលការតាមដាននៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសលើកទី២ និងការសិក្សាជាច្រើនអំពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ព្រមទាំងការកសាងសមត្ថភាព ដែលទាំងអស់នេះគឺជាមូលដ្ឋាននៃការរៀបចំឯកសារណែនាំស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ។ សក្ខីកម្មដែលទទួលបានពីរបាយការណ៍តាមវិស័យ ពីបណ្តាញក្រុមការងារបច្ចេក-ទេសចម្រុះ ពីការដ្ឋានកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល និងរបាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ នាឆ្នាំ២០០៨ បានផ្តល់ជាមូលដ្ឋានសំខាន់សម្រាប់បូកសរុបសក្ខីកម្មទាំងអស់នេះ ។ ការកែសម្រួលកម្រិតគោលនយោបាយសំខាន់ៗត្រូវបានរៀបចំឡើង ដោយផ្អែកលើមូលដ្ឋាននៃសក្ខីកម្មទាំងនេះ ពិសេស ដើម្បីទទួលស្គាល់ និងឆ្លើយតបទៅនឹងបញ្ហានានាដែលចោទឡើងសម្រាប់ពង្រឹងភាពជាដៃគូ ការបែកខ្ញែកខាងផលប្រយោជន៍ និងអតុល្យភាពខាងអំណាចក្នុងទំនាក់ទំនងហិរញ្ញប្បទានសហប្រតិ-បត្តិការ ។ ការងារនេះគឺជាមូលដ្ឋាននៃ «គំនិតផ្តួចផ្តើមស្តីពីប្រសិទ្ធភាពក្នុងភាពជាដៃគូ» ក៏ដូចជាការប្រកាន់យកវិធានការមុតស្រួចមួយចំនួននៅកម្រិតវិស័យសម្រាប់ពង្រឹងសមត្ថភាព និងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល ។

អនុសាសន៍មួយចំនួននៅក្នុងរបាយការណ៍នេះបានផ្អែកលើការវិភាគកន្លងមក និងការទទួលស្គាល់អំពីតម្រូវការចាំបាច់ក្នុងការបន្តការប្រែក្លាយគោលដៅនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសឱ្យទៅជាក្របខ័ណ្ឌដែលមានលក្ខណៈស្របនឹងបរិបទកម្ពុជា ហើយត្រូវផ្តោតលើលទ្ធផល ។ កិច្ចប្រតិបត្តិស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហ-

ប្រតិបត្តិការត្រូវទទួលស្គាល់អំពីតថភាពនៃទំនាក់ទំនងហិរញ្ញប្បទានសហប្រតិបត្តិការ និងត្រូវលើកគំនិតផ្តួចផ្តើមនានាសម្រាប់គាំទ្រតថភាពទាំងនេះ ទន្ទឹមនឹងការគាំទ្រដល់កំណែទម្រង់សម្រាប់រយៈពេលវែងផងដែរ ។ ការងារនេះអាចសម្រេចទៅបាន លុះត្រាតែយើងទទួលស្គាល់គោលការណ៍នៃភាពជាម្ចាស់ និងតួនាទីដ៏សំខាន់នៃការកសាងសមត្ថភាព ដែលទាំងអស់នេះគឺជាគន្លឹះសម្រាប់សម្រួលដល់ការអនុវត្តន៍គំនិតផ្តួចផ្តើមថ្មីៗទៀតស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ នៅក្នុងកម្រិតប្រតិបត្តិការ បញ្ហាគន្លឹះគឺត្រូវផ្តោតទៅលើថាមភាពរវាង «ភាពដឹកនាំ» និង «សមត្ថភាព» ដូចដែលបានលើកឡើងក្នុងរបាយការណ៍វាយតម្លៃ ឆ្នាំ២០០៨ ស្តីពីការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមនិងលទ្ធផល ហើយដែលបានលើកឡើងសារជាថ្មីម្តងទៀតក្នុងរបាយការណ៍វាយតម្លៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ឆ្នាំ២០១០ ។ ភាពដឹកនាំដ៏រឹងមាំគឺជាកត្តាចំបងសម្រាប់បង្កើត និងពង្រឹងសមត្ថភាពជាតិ ហើយសមត្ថភាពនេះអាចបង្កើនទំនុកចិត្តនិងទេពកោសល្យរបស់ថ្នាក់ដឹកនាំ សម្រាប់អនុវត្តការគ្រប់គ្រងកម្មវិធីតាមវិស័យ និងកំណែទម្រង់នានា សម្រាប់ឈានទៅសម្រេចកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។

## ***<u>ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី</u>***

ដោយទទួលស្គាល់តថភាពនៃការបែកខ្ញែកហិរញ្ញប្បទានសហប្រតិបត្តិការ និងសមត្ថភាពមានកម្រិត ការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាទំនោររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងភាពជាម្ចាស់ ការជម្រុញការអភិវឌ្ឍន៍សមត្ថភាពប្រកបដោយចីរភាព និងការធ្វើសមាហរណកម្មធនធានទាំងអស់ទៅក្នុងយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងកម្រិតវិស័យសម្រាប់រយៈពេលមធ្យម ដែលយុទ្ធសាស្ត្រនេះត្រូវតម្រឹមជាមួយនឹងគោលដៅអភិវឌ្ឍន៍ជាតិ ។ កម្ពុជាមានមហិច្ឆិតាខ្ពស់ក្នុងការជម្រុញឱ្យប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី មិនត្រឹមតែដើម្បីសម្រេចទិសដៅនៃសុខដុមនីយកម្មតែមួយមុខ ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសតែប៉ុណ្ណោះទេ ។ គំនូរនៅទំព័រខាងលើអាចផ្តល់ការយល់ដឹងអំពីលំដាប់លំដោយក្នុងស្ថានភាពបច្ចុប្បន្ននៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គាំទ្រស្ថានភាពអន្តរកាលឱ្យឈានឡើងដល់កម្រិតខ្ពស់ជាង ស្របតាមគោលដៅ ។

អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍/គណៈកម្មាធិការហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ បានកំណត់និយមន័យនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី សម្រាប់គោលដៅនៃការតាមដានការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសតែប៉ុណ្ណោះ ។ និយមន័យនេះរួមមាន ÷ ក- ភាពដឹកនាំរបស់ប្រទេសលើកម្មវិធីអភិវឌ្ឍន៍ ។ ខ- ការប្រើប្រាស់ក្របខ័ណ្ឌយុទ្ធសាស្ត្រតាមវិស័យនិងថវិកា ។ និង គ- យន្តការសម្រាប់សម្របសម្រួល និងការប្រើប្រាស់ប្រព័ន្ធជាតិ ។ កម្ពុជាបានប្រកាន់យកអភិក្រមដែលមានភាពទន់ភ្លន់ជាង ដោយបានបញ្ជាក់ថា អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាដំណើរការនៃការផ្លាស់ប្តូរ និងការសង្កេតអំពីស្ថានភាពបញ្ចប់ ។ ដូចបានបញ្ជាក់ពីខាងដើម ការផ្តោតលើចំណុចបញ្ចប់មានសារៈប្រយោជន៍សម្រាប់ស្វែងរកការឯកភាពគ្នាលើគោលដៅ ។ ក៏ប៉ុន្តែយើងមិនត្រូវមើលស្រាលអំពីកាលានុវត្តភាពដែលអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីបានបង្កើតឡើងសម្រាប់ពិនិត្យបញ្ហាដែលពាក់ព័ន្ធនឹងភាពជាដៃគូ (លើសពីវោហារសាស្ត្រ) ហើយសំខាន់ជាងនេះទៀត ការកសាងកុងសង់ស៊ុសសម្រាប់ពិនិត្យអំពីការផ្លាស់ប្តូរស្ថានការណ៍បច្ចុប្បន្ន ដើម្បីធានាឱ្យមានអត្ថប្រយោជន៍ទ្វេទិសសម្រាប់ភាគីពាក់ព័ន្ធ

ទាំងអស់ ។ ក្នុងស្មារតីនេះ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីត្រូវបានប្រើប្រាស់សម្រាប់បង្កើនការយល់ដឹងពីស្ថានភាពបច្ចុប្បន្នផង និងសម្រាប់ឯកភាពលើគោលដៅចុងក្រោយផង ព្រមទាំងសម្រាប់កំណត់មាគ៌ាក្នុងដំណាក់កាលអន្តរកាលផង ។

ការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដូចជាក្នុងវិស័យអប់រំ និងសុខាភិបាលមានភាពចាស់ទុំហើយ ។ ការយល់ដឹងអំពីលក្ខខ័ណ្ឌដោយឡែករបស់វិស័យនិមួយៗមានសារៈសំខាន់ណាស់ ។ ទន្ទឹមនេះ ក៏ត្រូវយកចិត្តទុកដាក់ដល់លក្ខណៈពិសេសបន្ថែមទៀត ដែលវិស័យនិងកម្មវិធីដទៃទៀតមានបំណងអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដូចជាវិស័យកសិកម្មនិងទឹក សកម្មភាពមីន ពាណិជ្ជកម្ម ផែនការនិងការកាត់បន្ថយភាពក្រីក្រ ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ និងយេនឌ័រ រួមទាំងកម្មវិធីដែលទើបបង្កើតថ្មី ដូចជាការប្រែប្រួលអាកាសធាតុជាដើម ។ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីអាចផ្តល់យល់ដឹងបានពេញលេញអំពីស្ថានភាពជាក់ស្តែងនៃវិស័យ ហើយអាចសម្របនិងរៀបចំការងាររបស់ខ្លួនឱ្យបានស្របទៅនឹងតម្រូវការនិងសមត្ថភាពរបស់វិស័យនិមួយៗ ។

យើងអាចកំណត់លក្ខណៈពិសេសនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីសម្រាប់រៀបចំអភិក្រមនេះនៅតាមវិស័យ និងសម្រាប់ពង្រឹងភាពដឹកនាំរបស់រាជរដ្ឋាភិបាល ព្រមទាំងជួយតម្រង់ដៃគូអភិវឌ្ឍន៍ឱ្យសម្របទម្រង់នៃការផ្តល់ហិរញ្ញប្បទានបច្ចុប្បន្នរបស់ខ្លួន ដើម្បីចូលរួមក្នុងកម្មវិធីតាមវិស័យប្រកបដោយប្រសិទ្ធភាព។

***លក្ខណៈពិសេសរួម :***

១- អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅកម្ពុជា មានលក្ខណៈស្របនឹងនិយមន័យដែលកំណត់ដោយអង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍/គណៈកម្មាធិការហិរញ្ញប្បទានសហប្រតិបត្តិការ ។ ប៉ុន្តែ ចំណុចដែលខុសគ្នាគឺ ការអនុវត្តន៍ជាជំហានៗ ស្របតាមកាលៈទេសៈនិងតម្រូវការនៃវិស័យនិមួយៗ ។

២- ឯកសារណែនាំឆ្នាំ ២០០៧សម្រាប់ក្រុមការងារបច្ចេកទេសចម្រុះ បានផ្តល់ការគាំទ្រដល់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដោយបានកំណត់វិធានការមួយចំនួនសម្រាប់ធានាការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាមួយនឹងកម្មវិធីតាមវិស័យ ហើយរំលេចធនធានគ្រប់ប្រភពទាំងអស់នៅក្នុងក្របខ័ណ្ឌរយៈពេលមធ្យមតែមួយ ។

៣- ជម្រុញឱ្យអនុវត្តគំនិតផ្តួចផ្តើមស្តីពីការអភិវឌ្ឍន៍សមត្ថភាពដោយមានការសម្របសម្រួលនៅកម្រិតវិស័យ និងការធ្វើសមាហរណកម្មសកម្មភាពស្តីពីប្រសិទ្ធិភាពហិរញ្ញប្បទានសហប្រតិបត្តិការ ព្រមទាំងប្រើប្រាស់យន្តការត្រួតពិនិត្យរួមគ្នានៅកម្រិតវិស័យ និងការត្រួតពិនិត្យវឌ្ឍនភាពដោយផ្អែកលើលទ្ធផល ។

***អត្ថប្រយោជន៍ដែលរំពឹងទុក :***

១- ការពង្រឹងភាពដឹកនាំ និងទិសដៅយុទ្ធសាស្ត្រដោយផ្អែកលើលទ្ធផលដែលបានឯកភាពគ្នា ដោយកាត់បន្ថយកម្រិតនៃការយកចិត្តទុកដាក់ និងធនធានសម្រាប់គ្រប់គ្រងលទ្ធផលក្នុងកម្រិតគម្រោង ។

២- សក្តានុពលនៃការផ្លាស់ប្តូរ «វិធាននៃល្បែង» តាមរយៈការពង្រឹងសមត្ថភាពជាតិ សម្រាប់រៀបចំ និងវាយតំលៃគម្រោង ជាជាងការតម្រឹមជាក្រោយរវាងក្របខ័ណ្ឌជាតិជាមួយនឹងគម្រោងបរទេស ។

៣- ការបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការអាចដោះស្រាយបានតាមរយៈ÷១- រំលេចទម្រង់ការនានាទៅក្នុងក្របខ័ណ្ឌតែមួយ និង២- ពង្រឹងប្រព័ន្ធជាតិសម្រាប់រយៈពេលវែងដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការរបស់គម្រោង ។

៤- ការសម្របសម្រួល និងការអនុវត្តន៍កំណែទម្រង់ស្នូលក្នុងវិស័យសាធារណៈ ដូចជាកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ អាចអនុវត្តប្រកបដោយចីរភាព ។

### សំណើសម្រាប់ដៃគូអភិវឌ្ឍន៍ :

១- ផ្តល់កាលានុវត្តភាពសម្រាប់គម្រោងចូលរួមក្នុងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី តាមរយៈការជម្រុញការចរចារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដទៃទៀត ។

២- គាំទ្រដល់ការប្រឹងប្រែងឱ្យលើសពីវិសាលភាពនៃលទ្ធផលគម្រោង ដើម្បីពង្រឹងនិងប្រើប្រាស់ប្រព័ន្ធផែនការ ប្រព័ន្ធថវិកា ការអនុវត្តន៍ ការធ្វើរបាយការណ៍ និងប្រព័ន្ធត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល ។

៣- ឆ្លើយតបទៅនឹងតម្រូវការ ដើម្បីធានា «ភាពល្អប្រសើរជាមុនក្នុងការងារសុខដុមនីយកម្ម និងការសម្របសម្រួល ដែលនៅតែជាបញ្ហាប្រឈមចំបងក្នុងការបង្កើនប្រសិទ្ធភាពនៃការពង្រឹងសមត្ថភាពរបស់ដៃគូអភិវឌ្ឍន៍» (របាយការណ៍របស់អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ ឆ្នាំ២០០៩)។

### អាទិភាពរូបនីយកម្ម និងលំដាប់លំដោយការងារ :

១- អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីពុំមែនជាគំរូដាច់ខាតទេ ។ ប៉ុន្តែ អភិក្រមនេះបានផ្តល់កាលានុវត្តភាពសម្រាប់អនុវត្តផែនការនិងនីតិវិធីដែលមានស្រាប់ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ និងសម្រាប់សម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ។

២- សារៈសំខាន់ក្នុងការកំណត់ និងការពង្រឹងសមិទ្ធផលក្នុងសមាសភាគនានានៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដូចជាសមត្ថភាពក្នុងភាពដឹកនាំ យុទ្ធសាស្រ្តនិងប្រព័ន្ធ ព្រមទាំងយន្តការសម្របសម្រួល ។

៣- ការប្រើប្រាស់ឧបករណ៍នានា ដូចជាការវាយតំលៃរួមគ្នាអំពីសមត្ថភាព ការប្រតិបត្តិនៃភាពជាដៃគូ ការត្រួតពិនិត្យគម្រោងនិងកម្មវិធីរួមគ្នា អាចកសាងថាមភាពរវាងភាពជាម្ចាស់ សមត្ថភាព និងលទ្ធផលនៃការអនុវត្តន៍ ។

អនុសាសន៍ខាងលើគឺជាការប្តេជ្ញាក្នុងការរៀបចំកម្មវិធីតាមវិស័យនិងកំណែទម្រង់នានា ដែលបានកំណត់ក្នុង«ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣» ។ គោលដៅចម្បងនៃការស្នើអនុសាសន៍ទាំងនេះ គឺការពង្រឹងការងាររបស់វិស័យនានា ដែលបានចាប់ផ្តើមអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ កិច្ចប្រឹងប្រែងនេះមានសង្គតិភាពជាមួយនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ទួននាករស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ការរៀបចំផែនការតាមវិស័យ ព្រមទាំងយន្តការសម្របសម្រួលនិងត្រួតពិនិត្យ ។ នេះមិនមែនមានន័យថាជាការសម្រេចប្រកបដោយមនសិការតែប៉ុណ្ណោះទេ ប៉ុន្តែគឺជាជំហានការងារបន្ទាប់របស់បណ្តាវិស័យជាច្រើន ។ ការកំណត់គោលដៅ និងរបៀបដំណើរការរួមគ្នាដើម្បីឈានទៅសម្រេចគោលដៅរួម

ទាំងនេះ អាចចាត់ទុកថាជាវិធីសាស្ត្រល្អប្រសើរជាងការជជែកអំពីគំនិតដែលរុំព័ទ្ធទៅដោយវោហារ និង វាក្យស័ព្ទ ហើយដែលត្រូវបានលើកឡើងជារឿយៗ តែមិនទាន់បានចុះសម្រុងគ្នាឡើយ ក្នុងវេទិកាកម្រិតសកល ។

## ការរៀបចំបណ្តាញការងារ និងចំណេះដឹងផ្នែកគ្រប់គ្រង ដើម្បីពង្រឹងភាពជាម្ចាស់ សមត្ថភាព និងភាពជាដៃគូ

បន្ថែមលើការងារបច្ចេកទេសដែលមានសារៈសំខាន់ចាំបាច់ សម្រាប់ជម្រុញការងារស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្រិតវិស័យ បញ្ហាសំខាន់ដទៃទៀតដែលត្រូវយកចិត្តទុកដាក់ គឺ÷ភាពដឹកនាំជាយុទ្ធសាស្ត្រ សមត្ថភាពការងារ និងភាពជាដៃគូ ។ កិច្ចប្រឹងប្រែងក្នុងការពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូដែលប្រើប្រាស់«បណ្តាញការងារ» សម្រាប់បំពេញបន្ថែមរចនាសម្ព័ន្ធផ្លូវការនៃរាជរដ្ឋាភិបាលនិងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានបង្ហាញអំពីតម្លៃដែលយើងខិតខំចំណាយពេលវេលាសម្រាប់ស្វែងយល់ឱ្យកាន់តែប្រសើរឡើងអំពីជីវភាពនៃភាពជាដៃគូ ក្នុងបរិការណ៍ដែលមានដៃគូអភិវឌ្ឍន៍ចម្រុះជាច្រើន និងដើម្បីកំណត់អំពីគុណប្រយោជន៍របស់ដៃគូអភិវឌ្ឍន៍និមួយៗក្នុងកិច្ចដំណើរការពង្រឹងភាពជាដៃគូនេះ ។ ក្នុងស្មារតីនេះ ការស្វែងយល់និងការពង្រឹងភាពជាដៃគូ នឹងជួយភាគីពាក់ព័ន្ធទាំងអស់ ទាំងខាងដៃគូអភិវឌ្ឍន៍ ទាំងខាងរាជរដ្ឋាភិបាលបានយល់ជ្រួតជ្រាបអំពីចំណុចចាប់ផ្តើម ហើយឯកភាពលើទិសដៅ ព្រមទាំងរបៀបអនុវត្តសម្រាប់សម្រេចបានតាមទិសដៅទាំងនោះ ។

សក្ខីកម្មដទៃទៀត ដូចជាបទពិសោធន៍នៃបណ្តាញការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ បានបញ្ជាក់អំពីសារៈសំខាន់នៃការប្រើប្រាស់បណ្តាញទំនាក់ទំនងក្រៅផ្លូវការ ក្នុងពេលដែលត្រូវពង្រឹងយន្តការផ្លូវការ ដូចជាយន្តការនៃក្រុមការងារបច្ចេកទេសចម្រុះ ។ ការរៀបចំទម្រង់បណ្តាញការងារមានប្រសិទ្ធភាពសម្រាប់÷ ក- ការរៀនសូត្ររួមគ្នា ឧទាហរណ៍ដូចជាការចែករំលែកព័ត៌មាន និងបទពិសោធន៍ក្នុងការអនុវត្តន៍កម្មវិធីកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ។ ខ- ការយល់ដឹងអំពីការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តាមរយៈការផ្សារភ្ជាប់បណ្តាញការងារទៅនឹងតម្រូវការរួម ។ គ- ការធ្វើសមាហរណកម្មរវាងកំណែទម្រង់ស្នូល និងអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងទម្រង់តាមដានត្រួតពិនិត្យ ដោយផ្សារភ្ជាប់ស្ថាប័នថ្នាក់ជាតិជាមួយនឹងបណ្តាក្រសួងពាក់ព័ន្ធ ។ ឃ- បង្កើនការយល់ដឹង និងអនុវត្តថាមភាពនិងទំនាក់ទំនងរវាងភាពជាម្ចាស់និងសមត្ថភាពដែលពង្រឹងឱ្យគ្នាទៅវិញទៅមក ។ រីឯដៃគូអភិវឌ្ឍន៍ក៏បានបង្កើតបណ្តាញទំនាក់ទំនងរបស់ខ្លួនដែរ តាមរយៈការប្រជុំក្រៅផ្លូវការប្រចាំខែ នាពេលអាហារថ្ងៃត្រង់ ។ ប៉ុន្តែ កិច្ចប្រជុំក្រៅផ្លូវការទាំងនេះមិនទាន់ប្រាកដថាផ្តល់អត្ថប្រយោជន៍ ឬក៏អាចកាត់បន្ថយសារៈសំខាន់នៃកិច្ចប្រជុំផ្លូវការនានានៅឡើយ។

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) បានប្តេជ្ញាផ្តល់ការគាំទ្របន្តដល់បណ្តាញការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពង្រឹងភាពជាដៃគូ និងសុខដុមនីយកម្មរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដែលជារចនាសម្ព័ន្ធបន្ថែមសម្រាប់ពិភាក្សា ព្រមទាំងដើម្បីជម្រុញការអនុវត្តន៍«ការពង្រឹងភាពជាដៃគូឱ្យមានប្រសិទ្ធភាព»ប្រកបដោយជោគជ័យ ។ ការប្តេជ្ញានេះទាមទារឱ្យមានការបន្តចូលរួមនៅកម្រិតវិស័យ ព្រមទាំងការប្តេជ្ញានិងការគាំទ្ររបស់ប្រធានស្ថាប័ន ក៏ដូចជាតំណាងដៃគូអភិវឌ្ឍន៍នៅតាមវិស័យទាំងនោះផងដែរ ។ ទន្ទឹមនេះដែរ ការប្រើប្រាស់បណ្តាញការងារក្រៅផ្លូវការកន្លងមក

សម្រាប់ពង្រឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ក៏អាចចាត់ទុកថាជាគំនិតផ្តួចផ្តើមត្រឹមត្រូវសម្រាប់ពង្រឹងសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលផងដែរ ។ តាមរយៈកិច្ចប្រឹងប្រែងរួមគ្នាសម្រាប់កសាងនិងពង្រឹងបណ្តាញការងារប្រកបដោយប្រសិទ្ធភាព អង្គការមិនមែនរដ្ឋាភិបាលអាចកំណត់គោលដៅរបស់ខ្លួនស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងមានលទ្ធភាពកំណត់បញ្ហាប្រឈម ព្រមទាំងអាចយល់ដឹងអំពីការបែកខ្ញែកខាងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ ។ លើសពីនេះ ក៏អាចរៀបចំគំនិតផ្តួចផ្តើមនានាសម្រាប់ផ្សារភ្ជាប់ទំនាក់ទំនងរវាងសហគមន៍អង្គការមិនមែនរដ្ឋាភិបាល ជាមួយនឹងតំណាងរបស់ខ្លួននៅតាមក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ដើម្បីបង្កើនការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ នៅក្នុងកិច្ចពិភាក្សាកម្រិតនយោបាយ ។

## ***ការពង្រឹងការអនុវត្តន៍កម្រិតសកលសម្រាប់កែលំអកិច្ចប្រតិបត្តិក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ***

សេចក្តីថ្លែងការណ៍បន្ទាប់ពីសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ត្រូវគិតគូរឱ្យលើសពីយន្តការផ្លូវការតាមបទដ្ឋានសកល សម្រាប់អនុវត្តប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ នេះមានន័យថា ត្រូវទទួលស្គាល់និងត្រូវ ឆ្លើយតបទៅនឹងតក្កភាពនៃការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរួមមាន ÷ ប្រព័ន្ធលាភការ ការពង្រឹងជវភាពនៃភាពជាដៃគូ ព្រមទាំងស្វែងយល់អំពីប្រសិទ្ធភាពនៃបណ្តាញការងារ ដែលជាផ្នែកមួយនៃរបៀបវារៈនៃកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល និងគណនេយ្យភាពទ្វេទិស ។ ការចូលរួមរបស់កម្ពុជានៅក្នុងដំណើរការកម្រិតសកល ដែលសម្របសម្រួលដោយអង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍/គណៈកម្មាធិការហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ បានផ្តល់កាលានុវត្តភាពសម្រាប់ឱ្យកម្ពុជាចែកផ្សាយសារខាងលើនេះ ហើយរាជរដ្ឋាភិបាលបន្តចែករំលែកបទពិសោធន៍ល្អៗរបស់កម្ពុជា នៅក្នុងវេទិកាកម្រិតសកល និងការសិក្សានានាសម្រាប់វេទិកាកម្រិតខ្ពស់លើកទី៤ ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ ក្នុងឆ្នាំ២០១១ ខាងមុខនេះ ។

## ***ការត្រួតពិនិត្យតាមដានរួមគ្នាស្តីពីការអនុវត្តន៍គោលនយោបាយ***

អនុសាសន៍ទាំងអស់នេះ រួមទាំងអនុសាសន៍សម្រាប់អនុវត្តបន្ត និងអនុសាសន៍សម្រាប់កែសម្រួល គឺជាលទ្ធផលដែលបានឯកភាពគ្នា ដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងការផ្សារភ្ជាប់ជាមួយកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។ សូចនាករត្រួតពិនិត្យតាមដានរួមគ្នាដែលបានរៀបចំថ្មីមានដូចខាងក្រោម ÷

***លទ្ធផល*** **:** សុខដុមនីយកម្មនិងការតម្រឹមក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍បានរួមចំណែកក្នុងការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈការស្តែងចេញជាលទ្ធផលនៅកម្រិតវិស័យ ។

***ធាតុចេញ*** : ការកែលំអអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ឬការបង្កើតអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីថ្មីបន្ថែមទៀត ព្រមទាំងភាពជាដៃគូ សម្រាប់អនុវត្តកម្មវិធីតាមវិស័យដោយផ្តោតលើលទ្ធផលអាចកាត់បន្ថយភាពបែកខ្ញែកក្នុងការផ្តល់ហិរញ្ញប្បទាន ព្រមទាំងបង្កើនភាពអាចទស្សន៍ទាយទុកជាមុនដែលរួមមាន÷ផែនការតាមវិស័យ ផែនការប្រតិបត្តិការប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រនៃថវិកា ការវាយ

តម្លៃរួមគ្នាអំពីសមត្ថភាព សកម្មភាពរួមគ្នាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការត្រួតពិនិត្យរួមគ្នាស្តីពីវឌ្ឍនភាពដោយផ្តោតលើលទ្ធផល ។

***សកម្មភាព:***

១- គ.ជ.នា/ក.អ.ក សម្របសម្រួលបណ្តាញការងារនៃក្រុមការងារបច្ចេកទេសចម្រុះ (ព្រមទាំងការបណ្តុះបណ្តាល) ។

២- គ.ជ.នា/ក.អ.ក សម្របសម្រួលការតាមដានវាយតម្លៃស្តីពីសមត្ថភាពនៃក្រុមការងារបច្ចេកទេសចម្រុះ និងក្រសួងនិងស្ថាប័នតាមវិស័យ ។

៣- គ.ជ.នា/ក.អ.ក ជម្រុញការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងការកសាងសមត្ថភាព ដើម្បីកាត់បន្ថយភាពបែកខ្ញែក និងបង្កើនភាពអាចទស្សន៍ទាយទុកជាមុននៃហិរញ្ញប្បទាន ។

៤- គ.ជ.នា/ក.អ.ក បញ្ចប់ និងតាមដានការងារស្តីពី «ការពង្រឹងភាពជាដៃគូឱ្យមានប្រសិទ្ធភាព» ។

៥- ក្រុមការងារបច្ចេកទេសចម្រុះស្តីពីសុខដុមនីយកម្មនិងភាពជាដៃគូ គឺជាវេទិកាសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះដទៃទៀត ផ្លាស់ប្តូរបទពិសោធន៍និងចំណេះដឹង ។

៦- ក្រុមការងារបច្ចេកទេសចម្រុះស្តីពីសុខដុមនីយកម្មនិងភាពជាដៃគូ ផ្តល់ការគាំទ្រដល់ការសិក្សាស្តីពីការប្រើប្រាស់ប្រព័ន្ធជាតិ ។

៧- ដៃគូអភិវឌ្ឍន៍បញ្ជាក់ពីការប្តេជ្ញារបស់ខ្លួនក្នុងការអនុវត្តន៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។

ដូចបានពិភាក្សាក្នុងជំពូកខាងដើម ចាប់ពីដើមឆ្នាំ២០១០នេះ សូចនាករតាមដានត្រួតពិនិត្យរួមគ្នាទាំងអស់ត្រូវរំលេចអំពីសកម្មភាពការងារស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការធ្វើបែបនេះសំដៅគាំទ្រសកម្មភាពការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ ដែលត្រូវសម្រេចឱ្យបាននូវធាតុចេញផងនិងលទ្ធផលផងដោយផ្អែកតាមគោលការណ៍នៃគណនេយ្យភាពទ្វេទិស ។ គ.ជ.នា/ក.អ.ក នឹងបន្តសម្របសម្រួលបណ្តាញការងារនៃក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីផ្តល់កាលានុវត្តភាពតាមរយៈការបណ្តុះបណ្តាល និងដើម្បីធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យទាំងអស់ ។រីឯក្រុមការងារបច្ចេកទេសចម្រុះស្តីពីសុខដុមនីយកម្មនិងភាពជាដៃគូ គឺជាវេទិកាសម្រាប់កិច្ចពិគ្រោះយោបល់ រវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍និងអង្គការសង្គមស៊ីវិល ដើម្បីផ្សារភ្ជាប់ការងារស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការទៅនឹងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។

ការអនុវត្តន៍ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល នឹងត្រូវបញ្ចប់ក្នុងឆ្នាំ២០១០នេះ ។ សេចក្តីថ្លែងការណ៍របស់កម្ពុជាដែលអនុវត្តការប្តេជ្ញាស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការកម្រិតសកល នៅក្នុងបរិបទនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏នឹងត្រូវបញ្ចប់ក្នុងឆ្នាំ២០១០នេះដែរ ។ ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ គ.ជ.នា/ក.អ.ក តាមរយៈក្រុមការងារបច្ចេកទេសចម្រុះរបស់ខ្លួនស្តីពីសុខដុមនីយកម្មនិងភាពជាដៃគូ នឹងបន្តកិច្ចសម្របសម្រួលដំណើរការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដើម្បីឈានទៅកំណត់ក្របខ័ណ្ឌគោលនយោបាយថ្មី ។ ការរៀបចំគោលនយោបាយថ្មីនេះត្រូវផ្អែកលើ

សក្ខីកម្មជាក់ស្តែង ទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតសកល ដែលត្រូវរៀបចំសម្រាប់ជាធាតុចូលក្នុងវេទិកាកម្រិតខ្ពស់លើកទី៤ ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ នាឆ្នាំ ២០១១ ដោយកំណត់អាទិភាព គោលការណ៍ និងអភិក្រម សម្រាប់គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព រៀបចំទម្រង់ការខាងស្ថាប័ន ពង្រឹងទំនាក់ទំនងរវាងកម្មវិធីតាមវិស័យនិងកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ពង្រឹងសមត្ថភាព និងជម្រុញការប្រើប្រាស់ប្រព័ន្ធជាតិ ព្រមទាំងការរៀបចំប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ ។

-------------

# ជំពូកទី ៦
# សេចក្តីសន្និដ្ឋាន

របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជាឆ្នាំ២០១០បានផ្តល់កាលានុវត្តភាព សម្រាប់ពិនិត្យសក្ខីកម្មនៃការអនុវត្តន៍ផែនការសកម្មភាពសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ដែលនឹងត្រូវបញ្ចប់ក្នុងឆ្នាំ២០១០នេះ ។ លើសពីនេះទៀត របាយការណ៍ក៏បានឆ្លុះបញ្ចាំងអំពីកិច្ចប្រឹងប្រែងក្នុងការដកស្រង់បទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍ សម្រាប់កែទម្រង់របៀបគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងស្មារតីនេះ បទពិសោធន៍អាចផ្តល់ព័ត៌មានសម្រាប់ពិភាក្សាកម្រិតគោលនយោបាយ និងសម្រាប់កំណត់ទិសដៅនៃការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនាពេលអនាគតដើម្បីបង្កើនលទ្ធផលនៃកិច្ចអភិវឌ្ឍន៍កម្ពុជា ។

របាយការណ៍នេះបានបង្ហាញថា ទោះបីស្ថិតក្នុងស្ថានភាពប្រឈមនៃវិបត្តិសេដ្ឋកិច្ចសកលលោកក៏ដោយ ក៏ទំហំហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍បានបន្តកើនឡើងសម្រាប់កម្ពុជា ។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវផ្តោតការយកចិត្តទុកដាក់ដល់កម្រិតខ្ពស់ ដើម្បីធានាការប្រើប្រាស់ធនធានទាំងនោះឱ្យមានគណនេយ្យភាព និងមានប្រសិទ្ធភាពសម្រាប់គាំទ្របណ្តាអាទិភាពនៃការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។ កន្លងមក យើងសម្រេចបានវឌ្ឍនភាពសំខាន់ៗជាច្រើន ដូចជា ការពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើនគុណភាពផែនការតាមវិស័យ ភាពទស្សន៍ទាយទុកជាមុននិងការតម្រឹមរបស់ដៃគូអភិវឌ្ឍន៍ ។

របាយការណ៍នេះក៏បានបង្ហាញផងដែរអំពីសកម្មភាពមួយចំនួនដែលត្រូវបន្តដោះស្រាយ ។ របាយការណ៍បានបញ្ជាក់ថា យើងបានអនុវត្តសកម្មភាពជាច្រើន ។ ប៉ុន្តែ បញ្ហាគឺស្ថិតនៅត្រង់ថា តើយើងបានប្រឹងប្រែងអនុវត្តសកម្មភាពទាំងនេះឬទេ ? ។ ធាតុពិត យើងបានប្រឹងប្រែងអនុវត្ត ។ សំណួរចោទសួរបន្តអំពីគុណវឌ្ឍន៍នៃការរៀបចំ និងអនុវត្តន៍សកម្មភាពទាំងនេះ សម្រាប់អភិវឌ្ឍសមត្ថភាពជាតិ និងសម្រាប់កាត់បន្ថយចំណាយប្រតិបត្តិការ ព្រមទាំងការរួមចំណែកក្នុងការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។ បញ្ហាសំខាន់ជាងនេះគឺកម្រិតនៃការផ្លាស់ប្តូរឥរិយាបទធៀបនឹងការរំពឹងទុកក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ របកគំហើញនៃការពិនិត្យឡើងវិញក្នុងការអនុវត្តន៍គំនិតផ្តួចផ្តើមបានបង្ហាញថា ប្រាកដជាមានការផ្លាស់ប្តូរនៅកម្រិតបច្ចេកទេស តាមរយៈការបញ្ចេញថាមភាពក្នុងការរៀបចំគោលនយោបាយ និងការអភិវឌ្ឍន៍ខាងស្ថាប័ននិងសមត្ថភាព ។ ប៉ុន្តែ ការផ្លាស់ប្តូរក្នុងរបៀបគ្រប់គ្រងនិងផ្តល់ហិរញ្ញប្បទាននៅពុំទាន់មានភាពច្បាស់លាស់នៅឡើយ ។

លក្ខណៈពិសេសនៃជវភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ដូចជាភាពពឹងអាស្រ័យរយៈពេលវែងលើហិរញ្ញប្បទានសហប្រតិបត្តិការ ភាពទន់ខ្សោយខាងស្ថាប័ន ឥរិយាបទប្រកួតប្រជែងរបស់ដៃគូអភិវឌ្ឍន៍ និងវប្បធម៌របស់កម្ពុជា ព្រមទាំងធុរៈកិច្ចហិរញ្ញប្បទានសហប្រតិបត្តិការ មិនត្រូវមើលរំលងឬមើលស្រាលបានឡើយ ។ ប៉ុន្តែ បញ្ហាទាំងនេះ ប្រហែលជាមិនមែនសាមញ្ញធម្មតា ដូចការដែលយើងបានគិតឡើយ ។

| Siem Reap | United Nations Agencies | 2.685 | 5.269 | 6.294 | 7.309 |
| | Int'l Financial Institutions | 6.284 | 9.593 | 10.990 | 14.158 |
| | European Union | 9.299 | 7.796 | 12.757 | 15.667 |
| | Bilateral | 4.788 | 7.708 | 4.685 | 7.392 |
| | NGO | 20.187 | 24.998 | 21.386 | 14.077 |
| | TOTAL | 43.244 | 55.365 | 56.112 | 58.604 |
| Preah Sihanouk | United Nations Agencies | 110 | 242 | 303 | 538 |
| | Int'l Financial Institutions | 632 | 2.732 | 1.686 | 9.509 |
| | European Union | 1.758 | 1.667 | 1.387 | 1.518 |
| | Bilateral | 37.023 | 16.864 | 28.823 | 28.843 |
| | NGO | 2.061 | 3.784 | 4.052 | 3.238 |
| | TOTAL | 41.583 | 25.289 | 36.251 | 43.647 |
| Stung Treng | United Nations Agencies | 544 | 930 | 951 | 1.272 |
| | Int'l Financial Institutions | 863 | 1.278 | 1.536 | 569 |
| | European Union | 2.831 | 2.456 | 2.760 | 2.678 |
| | Bilateral | 1.875 | 292 | 7.769 | 9.612 |
| | NGO | 598 | 883 | 863 | 1.814 |
| | TOTAL | 6.712 | 5.838 | 13.878 | 15.945 |
| Svay Rieng | United Nations Agencies | 3.178 | 2.644 | 2.307 | 2.966 |
| | Int'l Financial Institutions | 819 | 253 | 35 | 1.205 |
| | European Union | 1.272 | 984 | 1.828 | 1.251 |
| | Bilateral | 1.286 | 1.296 | 1.317 | 1.074 |
| | NGO | 921 | 912 | 1.123 | 4.577 |
| | TOTAL | 7.476 | 6.090 | 6.610 | 11.073 |
| Takeo | United Nations Agencies | 733 | 1.164 | 1.022 | 1.246 |
| | Int'l Financial Institutions | 1.689 | 6.289 | 4.431 | 5.802 |
| | European Union | 1.258 | 1.092 | 3.024 | 5.069 |
| | Bilateral | 1.604 | 1.812 | 2.167 | 4.945 |
| | NGO | 3.435 | 5.274 | 4.463 | 4.666 |
| | TOTAL | 8.720 | 15.631 | 15.107 | 21.727 |
| Otdar Meanchey | United Nations Agencies | 845 | 1.156 | 1.206 | 1.517 |
| | Int'l Financial Institutions | 4.737 | 7.583 | 5.711 | 5.281 |
| | European Union | 3.155 | 2.081 | 3.935 | 2.645 |
| | Bilateral | 921 | 263 | 457 | 253 |
| | NGO | 651 | 1.124 | 1.542 | 2.645 |
| | TOTAL | 10.308 | 12.207 | 12.851 | 12.341 |
| Kep | United Nations Agencies | 4 | 42 | 47 | 115 |
| | Int'l Financial Institutions | 342 | 253 | 18 | 635 |
| | European Union | 951 | 825 | 1.095 | 1.132 |
| | Bilateral | 285 | 0 | 0 | 0 |
| | NGO | 356 | 210 | 162 | 687 |
| | TOTAL | 1.938 | 1.330 | 1.322 | 2.570 |
| Pailin | United Nations Agencies | 126 | 221 | 262 | 313 |
| | Int'l Financial Institutions | 608 | 680 | 131 | 635 |
| | European Union | 326 | 56 | 300 | 357 |
| | Bilateral | 1.895 | 4.222 | 9.184 | 3.758 |
| | NGO | 134 | 289 | 200 | 2.242 |
| | TOTAL | 3.089 | 5.469 | 10.078 | 7.306 |
| Nation-Wide | United Nations Agencies | 28.540 | 29.932 | 31.875 | 42.537 |
| | Int'l Financial Institutions | 74.655 | 104.259 | 79.148 | 129.901 |
| | European Union | 81.912 | 120.831 | 115.165 | 130.438 |
| | Bilateral | 116.128 | 118.769 | 129.402 | 60.755 |
| | NGO | 1.724 | 825 | 1.456 | 580 |
| | Others | 21.067 | 38.601 | 47.883 | 41.183 |
| | TOTAL | 324.026 | 413.218 | 404.929 | 405.394 |
| Unknown | United Nations Agencies | | | | |
| | Int'l Financial Institutions | 0 | 0 | 0 | 450 |
| | European Union | 932 | 963 | 2.928 | 15.468 |
| | Bilateral | 33.474 | 32.845 | 38.257 | 40.905 |
| | NGO | | 297 | 295 | 40 |
| | TOTAL | 34.406 | 34.105 | 41.480 | 56.864 |
| GRAND TOTAL | United Nations Agencies | 58.324 | 68.276 | 74.818 | 95.830 |
| | Int'l Financial Institutions | 117.751 | 189.696 | 149.856 | 247.175 |
| | European Union | 153.235 | 188.626 | 204.796 | 246.277 |
| | Bilateral | 349.350 | 365.511 | 408.826 | 343.031 |
| | NGO | 77.736 | 104.915 | 103.282 | 112.424 |
| | Others | 21.067 | 38.601 | 47.883 | 41.183 |
| | TOTAL | 777.463 | 955.624 | 989.460 | 1.085.920 |

(*) : តួលេខប៉ាន់ស្មាននៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ

# ចំណាត់ថ្នាក់វិស័យ និងអនុវិស័យ

| វិស័យ និងអនុវិស័យ | |
|---|---|
| **វិស័យសង្គមកិច្ច** | |
| ***វិស័យសុខាភិបាល*** | ***វិស័យអប់រំ*** |
| មន្ទីរពេទ្យ | មត្តេយ្យ និងបឋមសិក្សា |
| ការចាក់ថ្នាំបង្ការ និងយុទ្ធនាការការពារជំងឺផ្សេងៗ | សាលារៀន និងមូលដ្ឋានសំភារៈ |
| ការអប់រំផ្នែកវេជ្ជសាស្ត្រ | ទុតិយភូមិ |
| ឱសថ និងឧបករណ៍វេជ្ជសាស្ត្រ | ការរៀបចំគោលនយោបាយ |
| សុខភាពបឋម | អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី |
| សុខភាពបន្តពូជ | ការបណ្តុះបណ្តាលគ្រូ |
| ការរៀបចំគោលនយោបាយវិស័យសុខាភិបាល | ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧត្តមសិក្សា |
| អភិក្រមគ្រប់គ្រងទូទាំងវិស័យ | |
| **វិស័យសេដ្ឋកិច្ច** | |
| ***វិស័យកសិកម្ម*** | ***កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម*** |
| សេវាកម្មហិរញ្ញប្បទានកសិកម្ម | ការអភិវឌ្ឍន៍ឧស្សាហកម្ម |
| ធាតុចូលសំរាប់កសិកម្ម | ការជីករុករករ៉ែ និងប្រេងហ្វូស៊ីល |
| ការរៀបចំគោលនយោបាយ និងគ្រប់គ្រងវិស័យកសិកម្ម | គោលនយោបាយ និងរដ្ឋបាល |
| ធនធានទឹកសំរាប់ធ្វើកសិកម្ម | គោលនយោបាយ និងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច |
| ធនធាន និងនាំចេញ | ការស្រាវជ្រាវបច្ចេកវិជ្ជាថ្មីៗ |
| ការអប់រំ បណ្តុះបណ្តាល | គោលនយោបាយពាណិជ្ជកម្ម និងការចរចា |
| សេវាកម្មប្រពលវប្បកម្ម | |
| ជលផល | ***វិស័យអភិវឌ្ឍន៍ជនបទ*** |
| ដំណាំ គ្រាប់ពូជ | ផែនការ និងការគ្រប់គ្រងដីធ្លី |
| សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | បោសសំអាតមីន |
| ព្រៃឈើ | ផ្លូវជនបទ |
| ការចិញ្ចឹមសត្វ និងពេទ្យសត្វ | ការរៀបចំគោលនយោបាយ និងរដ្ឋបាលជនបទ |
| ឧតុនិយម | ទឹកស្អាត និងអនាម័យជនបទ |
| ការប្រមូលកសិផល | |
| | ***ធនាគារ និងសេវាកម្មធុរកិច្ច*** |
| | សេវាគាំទ្រធុរកិច្ច |
| ***ផែនការទីក្រុង និងការគ្រប់គ្រង*** | គោលនយោបាយវិស័យហិរញ្ញវត្ថុ ផែនការនិងបទបញ្ញត្តិ |
| ការគ្រប់គ្រងដីធ្លី និងផែនការដោះស្រាយទំនាស់ | ស្ថាប័នហិរញ្ញវត្ថុផ្លូវការ |
| ផែនការវិស័យរៀបចំទីក្រុង និងរដ្ឋបាល | ស្ថាប័នហិរញ្ញវត្ថុក្រៅផ្លូវការ |
| **ហេដ្ឋារចនាសម្ព័ន្ធ** | |
| ***វិស័យដឹកជញ្ជូន*** | ***ទឹកស្អាត និងអនាម័យ*** |
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវអាកាស និងដឹកជញ្ជូន | ការអប់រំ និងបណ្តុះបណ្តាល |
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក និងដឹកជញ្ជូន | ការអភិវឌ្ឍន៍ទន្លេ |
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវ និងដឹកជញ្ជូន | ការរៀបចំគោលនយោបាយ និងផែនការ |
| គោលនយោបាយ និងការគ្រប់គ្រងការដឹកជញ្ជូន | ការគ្រប់គ្រងកាកសំណល់ |

| | |
|---|---|
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក (កំពង់ផែ) | ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យទីក្រុង |
| | |
| ***<u>ថាមពល និងអគ្គីសនី</u>*** | ***<u>ព័ត៌មាន និងទូរគមនាគមន៍</u>*** |
| ការស្រាវជ្រាវពីថាមពល | បច្ចេកវិជ្ជាព័ត៌មានវិទ្យា |
| ការរៀបចំគោលនយោបាយ និងការគ្រប់គ្រង | ប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ការផលិតថាមពល | វិទ្យុ / ទូរទស្សន៍ / ព័ត៌មានបោះពុម្ពផ្សាយ |
| ការចែកចាយថាមពល | |
| **<u>សេវា និងកម្មវិធីអន្តរវិស័យ</u>** | |
| ***<u>សហគមន៍ និងសេវាសុខមាលភាពសង្គម</u>*** | ***<u>អភិបាលកិច្ច និងរដ្ឋបាល</u>*** |
| វប្បធម៌ និងវិចិត្រសិល្បៈ | សេដ្ឋកិច្ច និងការអភិវឌ្ឍន៍គោលនយោបាយ / ផែនការ |
| បរិស្ថាន និងការអភិរក្ស | ការបោះឆ្នោត |
| យេនឌ័រ | សិទ្ធិមនុស្ស |
| ហ៊ីវ/អេដស៍ | ច្បាប់ និងតុលាការ |
| ទេសចរណ៍ | វិមជ្ឈការ និងវិសហមជ្ឈការ |
| ការគាំទ្រថវិកា និងជញ្ជីងទូទាត់ | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ជំនួយសង្គ្រោះបន្ទាន់ និងម្ហូបអាហារ | កំណែទម្រង់រដ្ឋបាលសាធារណៈ |
| | អង្គការសង្គមស៊ីវិល |

<u>ឧបសម្ព័ន្ធទី ៤</u>

## របាយការណ៍ស្តីពីវឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានឯកភាព នៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ២ ថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០០៨

របាយការណ៍នេះសរុបអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានឯកភាពក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ នាថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០០៨ ។ មូលដ្ឋាននៃការរៀបចំ របាយការណ៍ស្តីពីវឌ្ឍនភាពនេះគឺធាតុចូលរបស់ក្រុមការងារបច្ចេកទេសចម្រុះនៅក្នុងខែមិនា ឆ្នាំ២០១០ និងរបាយការណ៍ស្តីពីវឌ្ឍនភាព ដែលក្រុមការងារបានផ្តល់ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងឆ្នាំ២០០៩កន្លងមក ។

### ***សូចនាករទី១ : អនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការដោយសម្របសម្រួលការគាំទ្រ***

*ក- <u>ផែនការសកម្មភាពប្រចាំឆ្នាំ២០០៩ និងការវាយតម្លៃសមត្ថភាពខាងស្ថាប័ន</u>*

ក្រសួងផែនការបានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០០៩ នាខែមិនា ឆ្នាំ២០០៩ កន្លងមក ។ ការវាយតម្លៃសមត្ថភាពស្ថាប័នសម្រាប់អគ្គនាយកដ្ឋានផែនការក៏ត្រូវបានរៀបចំ ដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅក្នុងឆ្នាំ២០០៩ ផងដែរ ។ លើសពីនេះ ក៏មិនទាន់មានការឯកភាពណាមួយសម្រាប់បន្តរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពរបស់អគ្គនាយកដ្ឋានផែនការសម្រាប់ជំហានបន្តទៀតឡើយ ។ ការអនុវត្តន៍ផែនការសកម្មភាពឆ្នាំ២០០៩ មិនទាន់បាន អនុវត្តឱ្យបានពេញលេញដោយកង្វះធនធាន ។ ក្រសួងផែនការបានគូសបញ្ជាក់កាលពីដើមឆ្នាំ២០០៩ ថាគ្មានសញ្ញាណាមួយដែលបញ្ជាក់អំពីការសន្យាធនធានសម្រាប់អនុវត្តផែនការ សកម្មភាពនោះឡើយ ។ នៅក្នុងខែកញ្ញា ឆ្នាំ២០០៩ ក្រសួងបានរាយការណ៍ថា ការអនុវត្តន៍ផែនការកសាងសមត្ថភាពមិនអាចមានលទ្ធភាពចាប់ផ្តើមភ្លាមៗនោះទេ ។ មូលហេតុចំបងគឺកង្វះធនធាន ហើយក៏មិនទាន់មានវិធានការច្បាស់លាស់ណាមួយសម្រាប់ដោះស្រាយបញ្ហានេះនៅឡើយ ។ បញ្ហាធនធានក៏ត្រូវបានលើកពិភាក្សាក្នុងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសផែនការនិងកាត់បន្ថយភាពក្រីក្រ និងនៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ផងដែរ ។

*ខ- <u>សម្របសម្រួលការគាំទ្រសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការ</u>*

ដូចបានគូសបញ្ជាក់ពីខាងលើ កង្វះធនធានបានប៉ះពាល់ដល់ការអនុវត្តន៍ផែនការសកម្មភាពឆ្នាំ២០០៩ ដើម្បី អនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការ ។ ការពិភាក្សាជាមួយធនាគារពិភពលោកកំពុងដំណើរការដើម្បីកៀរគរធនធានពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់អង់គ្លេស ។ ក្រសួងផែនការបានគូសបញ្ជាក់ថា ការគាំទ្រការអនុវត្តន៍ផែនការយុទ្ធសាស្ត្រក្រសួងផែនការនឹងប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។

### ***សូចនាករទី២ : អនុវត្តនិងត្រួតពិនិត្យការអនុវត្តន៍អាទិភាពស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការក្នុងបរិបទនៃភាពជាដៃគូ ដើម្បីសម្រេចគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ***

*សូចនាករតាមដានរួមគ្នាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ*

ដោយទទួលស្គាល់ភាពចាំបាច់ ក្នុងការពន្លឿនល្បឿននៃការអនុវត្តន៍ការប្តេជ្ញាស្តីពីការបង្កើនប្រសិទ្ធភាព ហិរញ្ញប្បទានសហប្រតិបត្តិការ រួមទាំងតម្រូវការនៃការធ្វើអាទិភាពភាវូបនីយកម្ម ដោយផ្តោតលើតែសកម្មភាព ដែលមានឥទ្ធិពលវិជ្ជមានដល់លទ្ធផលនៃកិច្ចអភិវឌ្ឍន៍ សូចនាករតាមដានរួមគ្នាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទាន សហប្រតិបត្តិការត្រូវបានឯកភាពរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក្នុងបរិបទនៃភាពជាដៃគូ សម្រាប់អនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ សូចនាករតាមដានរួមគ្នានេះត្រូវបានឯកភាពក្នុងកិច្ចប្រជុំលើកទី១៤នៃគណៈ-កម្មាធិការ សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ កាលពីខែមេសា ឆ្នាំ២០០៩ និងអនុវត្តដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ជាមួយនឹងដៃគូអភិវឌ្ឍន៍ នៅតាមក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ។ វឌ្ឍនភាព ដែលសម្រេចបានកន្លងមក មានសង្ខេបក្នុងជំពូកទី៣ ស្តីពីការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។

## ***សូចនាករទី៣ : បង្កើនអត្រាឡើងថ្នាក់របស់សិស្សនៅកម្រិតបឋមសិក្សា ពី ៧៨,៦% ក្នុងឆ្នាំសិក្សា ២០០៦-០៧ ដល់ ៨៤% ក្នុងឆ្នាំសិក្សា ២០០៨-០៩***

*ក- បង្កើនអត្រាឡើងថ្នាក់*

អត្រាឡើងថ្នាក់នៅកម្រិតបឋមសិក្សាមិនបានសម្រេចតាមចំណុចដៅ ដែលបានកំណត់ ៨៤% នោះទេ ។ អត្រាឡើងថ្នាក់នៅបឋមសិក្សាបានកើនឡើងពី ៧៨,៦% នៅក្នុងឆ្នាំសិក្សា២០០៦-២០០៧ មកដល់ ៨២,៨% ក្នុង ឆ្នាំសិក្សា ២០០៨-២០០៩ កើនឡើង៤,២% ។ នៅតាមបណ្តាខេត្តមួយចំនួន បទបញ្ញត្តិក្នុងស្តីពីការឡើងថ្នាក់នៅ បឋមសិក្សា មិនទាន់បានផ្សព្វផ្សាយឱ្យទូលំទូលាយដល់សាលាបឋមសិក្សាទាំងអស់នៅឡើយទេ ។ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយដៃគូអភិវឌ្ឍន៍នឹងប្រឹងប្រែងបន្ថែមទៀតដើម្បីឈានទៅសម្រេចគោលដៅដែលបាន កំណត់នាពេលខាងមុខ ។

*ខ-កាត់បន្ថយភាគរយនៃសាលាបឋមសិក្សាមិនគ្រប់កម្រិត និងពង្រាយគ្រូចេញថ្មីទៅតំបន់ដាច់ស្រយាល*

ចំនួនសាលាបឋមសិក្សាដែលមិនគ្រប់កម្រិតបានកាត់បន្ថយពី ២៧% មកនៅត្រឹម ១៨% តាមការគ្រោង ទុក ។ ក្រសួងអប់រំ យុវជននិងកីឡា ក៏បានអនុវត្តគោលនយោបាយពង្រាយគ្រូថ្មីដែលទើបចេញពីសាលា គរុកោសល្យ ៩៥% ទៅឱ្យសាលារៀនដែលខ្វះគ្រូបង្រៀន និងសាលារៀននៅតំបន់ដាច់ស្រយាលផងដែរ ។

*គ-កែសម្រួលឡើងវិញបទបញ្ញត្តិក្នុងស្តីពីការឡើងថ្នាក់របស់សិស្សនៅបឋមសិក្សា*

បទបញ្ញត្តិក្នុងស្តីពីការឡើងថ្នាក់របស់សិស្សនៅបឋមសិក្សា ត្រូវបានកែសម្រួល និងដាក់ចេញឱ្យអនុវត្ត នៅគ្រប់សាលារៀនទាំងអស់ នៅក្នុងខែមិនា ឆ្នាំ២០០៩ ។ សម្រាប់សិស្សថ្នាក់ទី១ ដល់ថ្នាក់ទី៦ ដែលមានពិន្ទុទាប ជាង៥,០ក្នុងពិន្ទុសរុប១០ បានផ្តល់ឱកាសឱ្យប្រឡងឡើងវិញម្តងទៀត នៅចំណាច់ឆ្នាំសិក្សា ឬនៅដើមឆ្នាំសិក្សា បន្ទាប់ ។ លើសពីនេះទៀត លទ្ធផលនៃការធ្វើតេស្ត៍ ចាប់ពីថ្នាក់ទី៣ ដល់ថ្នាក់ទី៦ ក៏ត្រូវបានប្រើប្រាស់សម្រាប់ កំណត់អំពីការឡើងថ្នាក់របស់សិស្សផងដែរ ។

### *សូចនាករទី៤ : បង្កើនចំនួនស្ត្រីសម្រាលកូនដោយឆ្មបជំនាញឱ្យបាន ៥០% នៅខែធ្នូ ឆ្នាំ២០០៩*

ក្នុងការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំ២០០៩ អត្រាស្ត្រីសម្រាលកូនដោយឆ្មបជំនាញ បានកើនឡើងដល់ ៥៨% នៅក្នុងឆ្នាំ២០០៨ ។ គោលដៅសម្រាប់ឆ្នាំ២០០៩ (ដែលពីមុនកំណត់ត្រឹម៥០%) ត្រូវបានកែសម្រួលទៅជា៦៥% វិញ ។

*ក- ការជ្រើសរើស និងការពង្រាយបុគ្គលិកឆ្មប*

បុគ្គលិកឆ្មបចំនួន២៧៩រូប (ក្នុងនោះ ៤៥ រូបកម្រិតមធ្យម និង ២៣៤ រូបកម្រិតបឋម) ត្រូវបានជ្រើសរើស ។ ក្នុងចំណោមនោះ ២៥៨រូបត្រូវបានដាក់ពង្រាយដល់មណ្ឌលសុខភាពនានា នៅក្នុងឆ្នាំ២០០៩ ។ គិតត្រឹមពេលនេះ យ៉ាងហោចណាស់ក៏មានបុគ្គលិកឆ្មបមួយរូបនៅប្រចាំការតាមមណ្ឌលសុខភាពនិមួយៗ ។

*ខ- ការលើកទឹកចិត្តដល់បុគ្គលិកឆ្មប*

ជាក់ស្តែង វិធានការលើកទឹកចិត្តនានាដែលបានអនុវត្តកន្លងមក បានជម្រុញការសម្រាលកូនដោយឆ្មបជំនាញ ។

*គ- បង្កើនធនធានទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍សម្រាប់សុខភាពបន្តពូជមាតា និងទារក*

ថវិកាសម្រាប់ផែនការប្រតិបត្តិការប្រចាំឆ្នាំបានកើនឡើងក្នុងរយៈពេលបីឆ្នាំកន្លងមក ពី ២០០លានដុល្លានាឆ្នាំ២០០៨ ដល់ ២៨៥,២៥លានដុល្លាក្នុងឆ្នាំ២០១០នេះ ។ ព័ត៌មានលំអិតមានក្នុងតារាងខាងក្រោម ។

| ឆ្នាំ | ផែនការប្រតិបត្តិការប្រចាំឆ្នាំ (លានដុល្លា) | សុខភាពបន្តពូជមាតា និងទារក (លានដុល្លា) | |
|---|---|---|---|
| | | រាជរដ្ឋាភិបាល | ដៃគូអភិវឌ្ឍន៍ |
| ២០០៨ | ២០០,០០ | ១,៩២ | ៥,៩៣ |
| ២០០៩ | ២៣២,៦០ | ២,៨២ | ២០,៨៩ |
| ២០១០ | ២៨៥,២៥ | ៥,៩២ | ១៨,៧៥ |

### *សូចនាករទី៥ : ពង្រឹងការឆ្លើយតបទៅនឹងការរាលដាលនៃជម្ងឺអេដស៍*

ក- <u>បង្កើនអត្រាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ក្នុងការទទួលថ្នាំប្រឆាំងមេរោគ</u>

អត្រាភាគរយនៃស្ត្រីមានផ្ទៃពោះដែលមានផ្ទុកមេរោគអេដស៍ និងដែលបានទទួលថ្នាំប្រឆាំងមេរោគ ដើម្បីកាត់បន្ថយការចម្លងពីមាតាទៅទារក កើនដល់ ៣២,៣% ក្នុងឆ្នាំ២០០៩ មិនសម្រេចបានតាមគោលដៅដែលបានកំណត់ ៤០% ឡើយ ។ បញ្ហាប្រឈមរួមមានការខ្វះខាតធនធាន ជំនាញបច្ចេកទេស និងទព្វសម្ភារៈ ដែលសុទ្ធតែជាកត្តាដែលធ្វើឱ្យខកខានមិនអាចសម្រេចតាមគោលដៅដែលបានគ្រោង ។ បញ្ហាទាំងនេះត្រូវតែដោះស្រាយដើម្បីធានាថាការ បង្កើនវិសាលភាពគ្របដណ្តប់អាចឆ្លើយតបនឹងតម្រូវការពិតប្រាកដ ។ ក្នុងរបាយការណ៍មួយក្នុងឆ្នាំ២០០៩ មណ្ឌលផ្តល់សេវាត្រូវបានបង្កើតឡើងចំនួន ១៦៧កន្លែង នៅតាមមណ្ឌលសុខភាពប្រតិបត្តិ ៦៧ (មណ្ឌលផ្តល់សេវាមាន ១៥៨ ក្នុងឆ្នាំ២០០៨) ។ ក្នុងចំណោមមណ្ឌលផ្តល់សេវាទាំងនេះ មានតែមណ្ឌលចំនួន៨៨ប៉ុណ្ណោះដែលមានសម្ភារៈគ្រប់គ្រាន់ ដែលរួមបញ្ចូលការថែទាំពេលមានគភ៌ ការធ្វើតេស្តរកមេរោគ និងប្រឹក្សាយោបល់

ការផ្តល់ថ្នាំប្រឆាំងមេរោគដល់មាតា ដែលមានផ្ទុកមេរោគ ។ ក្រុមការងារបច្ចេកទេសស្តីពីជំងឺអេដស៍បានគូសបញ្ជាក់រួចហើយអំពីតម្រូវការនៃការកៀរគរធនធាន និងការពង្រឹងសមត្ថភាពបន្ថែមដល់បុគ្គលិកដែលបំរើការនៅតាមមណ្ឌលផ្តល់សេវាទាំងនោះ ដើម្បីឆ្លើយតបបានទាន់ពេលវេលាទៅនឹងតម្រូវការ និងការបង្កើនការផ្តល់សេវា ។

### សូចនាករទី៦ : បង្កើតអភិក្រមសមស្របនិងរួមគ្នាមួយ សម្រាប់បន្ធូរបន្ថយផលប៉ះពាល់នៃការកើនឡើងតម្លៃស្បៀង ទៅលើសន្តិសុខស្បៀងតាមគ្រួសារ និងសកម្មភាពអាទិភាពមួយចំនួនត្រូវបានអនុវត្ត និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់

ក- <u>ប្រព័ន្ធត្រួតពិនិត្យរួមដើម្បីតាមដានផលប៉ះពាល់នៃការកើនឡើងតម្លៃស្បៀង</u>

ការអង្កេតមនុស្សមាត្រនៅកម្ពុជាត្រូវបានធ្វើឡើងដោយក្រសួងផែនការ កាលពីខែវិច្ឆិកា ឆ្នាំ២០០៨ ដោយសហការជាមួយ UNICEF និង UNDP ដើម្បីវាយតម្លៃពីផលប៉ះពាល់ដែលបណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ និងពីវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោកមកលើសុខភាព និងសន្តិសុខស្បៀងរបស់ស្ត្រី និងកុមារនៅកម្ពុជា ។ លើសពីនេះ ការអង្កេតស្តីពីផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក ក៏ត្រូវបានរៀបចំដោយ UNDP ផងដែរ ប៉ុន្តែលទ្ធផលផ្លូវការមិនទាន់បានផ្សព្វផ្សាយនៅឡើយ ។

ក្រុមការងារគ្រប់គ្រងប្រព័ន្ធព័ត៌មានសន្តិសុខស្បៀង ត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេក-ទេសចម្រុះស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដើម្បីរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ ក្រុមការងារនេះនឹងផ្តល់ការគាំទ្រដល់ការបង្កើតបណ្តាញព័ត៌មាននៅកម្ពុជា និងជម្រុញឱ្យមានការសម្របសម្រួល និងសហការពីបណ្តាភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធានាឱ្យមានសង្គតិភាពរវាងគំនិតផ្តួចផ្តើមនានាដែលកំពុងអនុវត្តដោយបណ្តាស្ថាប័នរបស់រាជរដ្ឋាភិបាល និងគាំទ្រដោយដៃគូអភិវឌ្ឍន៍ ។ ក្រុមការងារបច្ចេកទេសសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនឹងធានាការអនុវត្តន៍ការងាររបស់ក្រុមការងារនេះ ឱ្យប្រព្រឹត្តទៅដោយមានភាពរលូន ។

### សូចនាករទី៧ : អនុវត្តយុទ្ធសាស្ត្រស្តីពីកសិកម្មនិងទឹក

*ក- <u>រៀបចំបញ្ចប់កម្មវិធីនៅក្នុងយុទ្ធសាស្ត្រស្តីពីកសិកម្មនិងទឹក</u>*

យុទ្ធសាស្ត្រស្តីពីកសិកម្មនិងទឹកត្រូវបានរៀបចំបញ្ចប់ និងបានអនុម័តពីសហប្រធាននៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីកសិកម្ម និងទឹក ។ សេចក្តីព្រាងកម្មវិធីនឹងត្រូវស្នើជូនប្រធានស្ថាប័នទាំងពីរអនុម័ត ។

*ខ- <u>ក្របខ័ណ្ឌនិងយន្តការរួមដើម្បីអនុវត្តយុទ្ធសាស្ត្រកសិកម្មនិងទឹក</u>*

ក្រុមការងារកំពុងពិនិត្យលទ្ធភាពក្នុងការរៀបចំក្របខ័ណ្ឌ និងយន្តការរួមមួយដើម្បីអនុវត្តយុទ្ធសាស្ត្រកសិកម្ម និងទឹក ក្នុងពេលរង់ចាំការអនុមតិកម្មវិធីគាំទ្រពីក្រសួងសាមីទាំងពីរ ។ ក្របខ័ណ្ឌរួមនេះនឹងបញ្ចូលការគ្រប់គ្រង និងការអនុវត្តន៍កម្មវិធី កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាល ផែនការវិនិយោគសាធារណៈ ការពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ និងការសន្យាផ្តល់ហិរញ្ញប្បទានពីដៃគូ និងថវិការបស់រាជរដ្ឋាភិបាល ។

## ***សូចនាករទី៨ : អនុវត្តបទដ្ឋានគតិយុត្តិនៃច្បាប់ភូមិបាល***

### *ក- ដីសហគមន៍ជនជាតិដើមភាគតិច*

ការរៀបចំគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តិ÷គោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីរបស់ជនជាតិដើមភាគតិចត្រូវបានអនុមតិដោយរាជរដ្ឋាភិបាល កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ ។ អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ក៏ត្រូវរាជរដ្ឋាភិបាលអនុម័ត នៅថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០០៩ ផងដែរ ។ ឯកសារទាំងពីរនេះគឺជាមូលដ្ឋានដ៏សំខាន់ក្នុងការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលធានាដោយច្បាប់ភូមិបាល ។ ជាងនេះទៅទៀត ឯកសារទាំង២នេះត្រូវបានរៀបចំឡើងប្រកបដោយតម្លាភាព តាមគោលការណ៍ប្រជាធិបតេយ្យ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ពិសេសជនជាតិដើមភាគតិចតែម្តង ។

ការអនុវត្តន៍គម្រោងសាកល្បងចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច÷ការអនុវត្តន៍គម្រោងសាកល្បងចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចត្រូវបានអនុវត្តនៅក្នុងភូមិចំនួនបី គឺ÷ភូមិល្មើនក្រែន ភូមិឡាអ៊ុន (ខេត្តរតនះគិរី) ភូមិអណ្តូងក្រឡឹង (ខេត្តមណ្ឌលគិរី) ។ ថវិកាសម្រាប់អនុវត្តគម្រោងសាកល្បងចុះបញ្ជីដីជនជាតិដើមភាគតិចទាំងបីភូមិ គឺជាថវិការបស់ GTZ ។ សម្ភារៈចាំបាច់ទាំងឡាយ ដូចជា GPS COMPUTER និងម៉ូតូត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ ។ ផែនការអនុវត្តន៍ជាជំហានៗក្នុងការឈានទៅចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចត្រូវ បានរៀបចំរួចហើយ និងបច្ចុប្បន្នកំពុងអនុវត្ត (នៅខេត្តរតនះគិរី កំពុងបោះបង្គោល - រីឯនៅខេត្តមណ្ឌលគិរី បានបោះបង្គោលព្រំដីសហគមន៍រួចហើយ និងកំពុងវាស់វែង) ។ ជារួម ការសាកល្បងចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចទាំងបីភូមិ មានភាពរលូនតាមផែនការដែលបានគ្រោងទុក និងកំពុងបន្ត ដើម្បីឈានទៅចុះបញ្ជី និងចេញប័ណ្ណជូនសហគមន៍ ។

### *ខ- សិទ្ធិកាន់កាប់ដីធ្លី*

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានបង្កើតក្រុមការងារមួយឱ្យទទួលបន្ទុករៀបចំគោលនយោបាយលំនៅដ្ឋាន ដោយសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។ នៅដើម និងពាក់កណ្តាលឆ្នាំ២០១០ ដោយមានការគាំទ្រពីអង្គការ GTZ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងក្រុមការងារបានជួបពិភាក្សាជាមួយស្ថាប័នមួយចំនួន រួមទាំងអង្គការសង្គមស៊ីវិល និងអាជ្ញាធររាជធានីភ្នំពេញ ព្រមទាំងអ្នកអភិវឌ្ឍន៍អចលនវត្ថុ ក្នុងការប្រមូលគំនិតចម្បងៗសម្រាប់ចងក្រងដើម្បីបញ្ចូលក្នុងគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន ។ នៅខែធ្នូ ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដោយសហការជាមួយក្រុមការងារតាក់តែងគោលនយោបាយលំនៅដ្ឋាន បានរៀបចំបញ្ចប់សេចក្តីព្រាងគោលនយោបាយលំនៅដ្ឋាន ។ ក្នុងខែមករា ឆ្នាំ២០១០ សេចក្តីព្រាងបឋមត្រូវបានពិគ្រោះយោបល់ជាមួយអ្នកជំនាញអន្តរជាតិជាច្រើនលើកច្រើនសារ និងបានពិគ្រោះយោបល់ផ្ទៃក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រួមជាមួយអគ្គនាយកដ្ឋានជំនាញទាំងបួន ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លីកំពុងរៀបចំ

ផ្ញើជូនក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងអង្គការសង្គមស៊ីវិល ដើម្បីផ្តល់អនុសាសន៍ មុននឹងដាក់ឆ្លងក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

*គ- គោលនយោបាយរៀបចំដែនដី*

ដោយមានការគាំទ្រពីអង្គការ GTZ កាលពីខែធ្នូ ឆ្នាំ២០០៨ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានរៀបចំសិក្ខាសាលា ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធរៀបចំដែនដី និងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ដើម្បីស្វែងរកការឯកភាពលើគោលគំនិតសម្រាប់រៀបចំសេចក្តីព្រាងគោល-នយោបាយរៀបចំដែនដី ។ សេចក្តីព្រាងបញ្ចប់នេះត្រូវបានរៀបចំរួច កាលពីដើមឆ្នាំ២០០៩ និងបានដាក់ឆ្លងការពិគ្រោះយោបល់ជាច្រើនលើកក្នុងផ្ទៃក្នុងក្រសួង ពិសេសជាមួយនាយកដ្ឋានជំនាញ ។ នៅក្នុងខែតុលា ឆ្នាំ២០០៩ សេចក្តីព្រាងបឋមត្រូវបានពិគ្រោះយោបល់ជាមួយមន្ត្រីបង្គោលនៃគ្រប់ក្រសួងនិងស្ថាប័នដែលជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១០ សិក្ខាសាលាមួយទៀតត្រូវបានរៀបចំសម្រាប់ពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយគ្រប់ក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងអង្គការសង្គមស៊ីវិល ។ សេចក្តីព្រាងនេះត្រូវបានរៀបចំសម្រាប់ស្នើជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី មុននឹងស្នើសុំការអនុមតិពីគណៈរដ្ឋមន្ត្រី នាពេលខាងមុខនេះ ។

***សូចនាករទី៩ : ក្នុងគោលដៅបញ្ចប់ការបាត់បង់ធនធានព្រៃឈើសម្រាប់ឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងយុទ្ធសាស្ត្រចតុកោណ និងដើម្បីគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព ដើម្បីកាត់បន្ថយភាពក្រីក្រ និងបម្រែបម្រួលអាកាសធាតុ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្របខ័ណ្ឌគតិយុត្ត ដែលមានចែងក្នុងច្បាប់ព្រៃឈើ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ភូមិបាល ច្បាប់រ៉ែ និងពិសេស អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចនៅគ្រប់កម្រិត ព្រមទាំងរៀបចំបញ្ចប់កម្មវិធីព្រៃឈើជាតិ និងការអភិវឌ្ឍន៍សហគមន៍***

*ក- ផ្សព្វផ្សាយជាសាធារណៈបញ្ជីសម្បទានដីសេដ្ឋកិច្ច សម្បទានរ៉ែ និងសម្បទានដទៃទៀត*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់ដីសម្បទានសេដ្ឋកិច្ចសរុប ៩៩២.៨០០ហិចតា ដល់ក្រុមហ៊ុន ចំនួន៨៧ ដោយបានចុះបញ្ជីក្នុងសៀវភៅ ។ ព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ចលើក្រុមហ៊ុនចំនួន ៧២ ត្រូវបានផ្សព្វផ្សាយក្នុងគេហទំព័រ www.elc.maff.gov.kh ដោយបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ។ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលបានផ្តល់អាជ្ញាប័ណ្ណរុករករ៉ែចំនួន ១០០ ដល់ក្រុមហ៊ុនចំនួន ៦៧ ហើយមានតែក្រុមហ៊ុន ២- ៣ ប៉ុណ្ណោះ ដែលកំពុងធ្វើការសិក្សា ។ ដោយឡែក ក្រសួងបរិស្ថានបានផ្តល់ដីវិនិយោគអភិវឌ្ឍន៍ចំនួន ៣៤៨.៦៥៦ហិចតា ដល់ ក្រុមហ៊ុននានា ។ ការផ្តល់ដីសម្បទានគឺជាបញ្ហាប្រឈមមួយដល់កិច្ចប្រឹងប្រែងថែរក្សាគម្របព្រៃឈើឱ្យបានចំនួន ៦០% នៃផ្ទៃប្រទេស ដែលទាំងនេះគឺជាគោលដៅនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

*ខ- ការបោះព្រំប្រទល់ដែនព្រៃឈើ*

ក្នុងឆ្នាំ២០០៩ រដ្ឋបាលព្រៃឈើ និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូ បានបោះព្រំប្រទល់ព្រៃឈើរដ្ឋបានប្រវែង ២២៨,៥៨៥គម ។ ក្រសួងបរិស្ថានបានកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ ទាំងនៅលើផែនទី និងមូលដ្ឋាន ចំនួន ពីរតំបន់ (តំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស និងគូលែនព្រហ្មទេព) ។ បញ្ហាប្រឈមគឺកង្វះធនធាន និងខ្វះកិច្ចសហការ ពីអាជ្ញាធរមូលដ្ឋាន ។

*គ- អនុម័តសហគមន៍ព្រៃឈើ ១០០ និងសហគមន៍តំបន់ការពារ ១០ យ៉ាងតិច*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានអនុម័តសហគមន៍ព្រៃឈើចំនួន ៤ ។ ដោយឡែក ក្រសួង បរិស្ថាន បានអនុម័តសហគមន៍តំបន់ការពារបានចំនួន១១ ។ បញ្ហាប្រឈមគឺការយឺតយ៉ាវក្នុងការពិនិត្យនិងសម្រេច លើសំណើសុំបង្កើតសហគមន៍ព្រៃឈើ ។ សំណើសុំបង្កើតសហគមន៍ព្រៃឈើចំនួន ១៧៥ ទៀត កំពុងរង់ចាំ ការអនុមតិពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

*ឃ- កម្មវិធីជាតិព្រៃឈើ*

ការរៀបចំកម្មវិធីជាតិស្តីពីព្រៃឈើ ត្រូវបានបញ្ចប់កាលពីខែតុលា ឆ្នាំ២០០៩ ហើយបានដាក់ជូនក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យនិងសម្រេច មុននឹងសុំការអនុម័តពីរាជរដ្ឋាភិបាល ។ ទន្ទឹមនេះ រដ្ឋបាល ព្រៃឈើ កំពុងរៀបចំផែនការកម្មវិធីជាតិព្រៃឈើសម្រាប់ឆ្នាំ២០១០ និងផែនការរយៈពេល៥ឆ្នាំខាងមុខទៀត ។

## ***សូចនាករទី១០ : បាតវិធានការសមស្របដើម្បីរំលេចអាទិភាពវិស័យជលផលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ស្រុក ខេត្ត ដោយបញ្ជាក់ពីកម្រិតនៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍***

*ក- ការគាំទ្រតាមរយៈកម្មវិធីគ្រប់គ្រងទូទាំងវិស័យដល់ផែនការសកម្មភាពប្រចាំឆ្នាំរបស់រដ្ឋបាលជលផល*

DANIDA/DFID/NZAID និង WorldFish Center បានផ្តល់ថវិកាប្រមាណ៦៧%នៃថវិកាសរុប សម្រាប់ គាំទ្រការអនុវត្តន៍ផែនការសកម្មភាពប្រចាំឆ្នាំរបស់រដ្ឋបាលជលផល តាមរយៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ហើយ បានប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីដែលមានស្រាប់របស់រដ្ឋបាលជលផល ។ ទន្ទឹមនឹងនេះ ក៏នៅមានបញ្ហាប្រឈម ដែលត្រូវដោះស្រាយផងដែរ ។ ដៃគូអភិវឌ្ឍន៍ដទៃទៀតបានប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីរៀងៗខ្លួន ។ ប្រការនេះ ទាមទារពេលវេលាបន្ថែមទៀតសម្រាប់ដៃគូអភិវឌ្ឍន៍សម្របសម្រួលបន្តិចម្តង តាមរយៈយន្តការក្រុមការងារ បច្ចេកទេសចម្រុះ ។ នៅពេលដែលក្របខ័ណ្ឌផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំរបស់វិស័យជលផលត្រូវបាន អនុម័ត យើងសង្ឃឹមថាមាននីតិវិធី និងទម្រង់ឯកភាពដែលអនុម័តដោយក្រុមការងារបច្ចេកទេសចម្រុះ ដោយ កំណត់អំពីតួនាទីរបស់រដ្ឋបាលជលផល និងដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រនេះ ។

*ខ- ក្រមប្រតិបត្តិសម្រាប់ការនេសាទដោយការទទួលខុសត្រូវនៅកម្ពុជា*

CAMCODE បានឈានដល់សេចក្តីព្រាងចុងក្រោយ បន្ទាប់ពីបានពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ និងក្នុង ក្រុមការងារបច្ចេកទេសចម្រុះ ក្នុងឆ្នាំ២០០៩កន្លងមក ។ ឯកសារកំពុងប្រែសម្រួលជាខេមរភាសា មុនដាក់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអនុម័ត នាត្រីមាសទី២ ឆ្នាំ២០១០ ។ ក្នុងឆ្នាំ២០០៩កន្លងមក ក្រុមការងារ បច្ចេកទេសបានចំណាយពេលវេលាជាច្រើន ក្នុងការរៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ១០ឆ្នាំរបស់វិស័យ

ផលផល ។ លើសពីនេះ រដ្ឋបាលជលផលក៏បានចំណាយពេលវេលាច្រើនផងដែរ ក្នុងការពិគ្រោះយោបល់លើ CAMCODE ដែលទាំងនេះ គឺជាមូលហេតុចម្បងដែលបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការអនុមតិឯកសារនេះ ។

## *សូចនាករទី១១ : កាត់បន្ថយគ្រោះថ្នាក់ដោយសារមីនចំនួន៥០ករណី និងកាត់បន្ថយចំនួន៧-១០% ផ្ទៃដីដែលមានមីន*

ក្នុងឆ្នាំ២០០៩ មានករណីគ្រោះថ្នាក់ដោយសារគ្រាប់មីនចំនួន ២៤៣ ពោលគឺថយចុះ ចំនួន ២៨ ករណី ធៀបនឹងឆ្នាំមុន ។ ក្នុងឆ្នាំ២០០៩ ផ្ទៃដី៥២,៦គមក្រឡា ត្រូវបានបោសសំអាតមីនដោយប្រតិបត្តិករនានា ។

## *សូចនាករទី១២ : បង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន*

ក- វឌ្ឍនភាពក្របខ័ណ្ឌគតិយុត្តិដើម្បីបង្កើតបរិយាកាសអំណោយផលដល់ការអភិវឌ្ឍន៍វិស័យឯកជន

បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានត្រូវបានស្នើឡើងនៅខែកញ្ញា ឆ្នាំ ២០០៩ និងកំពុងពិគ្រោះយោបល់ជាមួយតំណាងវិស័យឯកជន ដោយផ្អែកលើកាតព្វកិច្ចជាសមាជិកភាពរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ។ បញ្ញត្តិច្បាប់អាទិភាពនេះនឹងត្រូវអនុមតិនៅក្នុងឆ្នាំ២០១០នេះ ដែលជាផ្នែកមួយនៃកម្មវិធីការងារក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក មុននឹងរៀបចំការពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្ម នាឆ្នាំ២០១១ ។

ខ- ផែនការរំកិលបីឆ្នាំសម្រាប់កំណែទម្រង់ពាណិជ្ជកម្ម (កម្មវិធីគ្រប់គ្រងទូទាំងវិស័យ)

វឌ្ឍនភាពនៅមានកម្រិតនៅឡើយ គិតត្រឹមដំណាច់ឆ្នាំ ២០០៩ នៅពេលដែលរាជរដ្ឋាភិបាលចេញអនុក្រឹត្យ (និងបន្ទាប់មកចេញប្រកាសអន្តរក្រសួង) ក្នុងការបង្កើតយន្តការខាងស្ថាប័នសម្រាប់ដឹកនាំកំណែទម្រង់ពាណិជ្ជកម្ម តាមអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី (គណៈកម្មាការដឹកនាំការអនុវត្តន៍អន្តរក្រសួងមួយ និងក្រុមការងារបី) ។ ជាលទ្ធផល សេចក្តីព្រាងផែនទីបង្ហាញផ្លូវ ដោយមានក្របខ័ណ្ឌតាមដាននិងវាយតម្លៃរឹងមាំ ត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌសសរទ្រូងទី១នៃកំណែទម្រង់(កំណែទម្រង់សម្រាប់បញ្ហាអន្តរវិស័យ) ។ ជំហានការងារដូចគ្នានេះនឹងត្រូវពង្រីកដល់សសរទ្រូងពីរផ្សេងទៀតនៃកំណែទម្រង់ ។ នាបច្ចុប្បន្ន ផែនការរំកិលបីឆ្នាំមិនទាន់ត្រូវបានរៀបចំដូចការគ្រោងទុកនៅឡើយ ។

បើទោះបីជាវឌ្ឍនភាពមានល្បឿនយឺតក៏ដោយ ក៏វិធានការដែលបានដាក់ចេញឱ្យអនុវត្តកន្លងមក នឹងជួយជម្រុញឱ្យសម្រេចវឌ្ឍនភាពស្របតាមការគ្រោងទុក ។ លេខាធិការដ្ឋានកំណែទម្រង់ពាណិជ្ជកម្ម (ស្ថិតក្នុងនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងពាណិជ្ជកម្ម) បានកសាងសមត្ថភាពជាបណ្តើរៗ និងបានរៀបចំគេហទំព័រស្តីពីកំណែទម្រង់ពាណិជ្ជកម្ម និងបានដឹកនាំការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០១០ ផងដែរ ។ ការធ្វើសុខដុមនីយកម្មការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក៏មានរីកចម្រើន តាមរយៈការបង្កើតមូលនិធិពហុដៃគូស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម ដែលផ្តល់ហិរញ្ញប្បទានដោយ DANIDA EC និង UNIDO ហើយគ្រប់គ្រងដោយធនាគារពិភពលោក ។ ព្រមជាមួយនេះ ក៏មានក្របខ័ណ្ឌ Enhanced Integrated Framework-EIT ដែលជាមូលនិធិពហុដៃគូសកល ដែលគ្រប់គ្រងដោយអង្គការពាណិជ្ជកម្មពិភពលោក ។ ដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត

រួមទាំង UNDP បានឯកភាពលើគោលការណ៍ស្តីពីភាពជាដៃគូជាមួយក្រសួង ដែលនឹងជម្រុញឱ្យបានល្អប្រសើរនូវការសម្របសម្រួល ការចែករំលែកព័ត៌មាន និងការតម្រឹម ។

## សូចនាករទី១៣ : ចីរភាពនិងសុវត្ថិភាពនៃបណ្តាញផ្លូវជាតិ និងជនបទ

### ក- វិធានការថែទាំផ្លូវ

យន្តការសម្រាប់កែលំអការថែទាំផ្លូវមានវឌ្ឍនភាពមួយចំនួន បើទោះមានល្បឿនយឺតនៅឡើយក្តី រួមមាន÷ ការផ្សព្វផ្សាយ និងការណែនាំអនុវត្តគោលការណ៍ស្តីពីការថែទាំផ្លូវដល់បណ្តានាយកដ្ឋានដែលពាក់ព័ន្ធ ការអនុវត្តគម្រោងពង្រឹង ការគ្រប់គ្រងគុណភាពផ្លូវដែលមានគោលដៅបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងគុណភាពនៃការសាងសង់ផ្លូវនិងស្ពាន និងការជ្រើសរើសទីប្រឹក្សាសម្រាប់គម្រោងគ្រប់គ្រងធនធានផ្លូវថ្នល់ ។ ទន្ទឹមនឹងនេះក៏មានការយឺតយ៉ាវ ក្នុងការអនុវត្តន៍សកម្មភាពមួយចំនួន ដោយសារតម្រូវការខាងនីតិវិធីសម្រាប់គាំទ្រគម្រោងដូចជាការធ្វើលទ្ធកម្ម ការធ្វើរបាយការណ៍ ការផ្តល់ការលើកទឹកចិត្ត និងការជ្រើសរើសទីប្រឹក្សាគម្រោង ។

ការគ្រប់គ្រងការដឹកជញ្ជូនលើសទម្ងន់ : លិខិតបទដ្ឋានចាំបាច់នានាត្រូវបានរៀបចំ និងដាក់ចេញឱ្យអនុវត្តដើម្បីត្រួតពិនិត្យសកម្មភាពដឹកជញ្ជូនមិនលើសទម្ងន់ ដូចជាអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការដឹកជញ្ជូនលើសទំងន់កំណត់ ប្រកាសស្តីពីការកម្រិតកំណត់អតិបរមារបស់យានយន្តដែលបើកបរលើបណ្តាញផ្លូវថ្នល់នៃព្រះរាជាណាចក្រកម្ពុជា សៀវភៅណែនាំប្រតិបត្តិ និងបទបញ្ជាផ្ទៃក្នុងសម្រាប់ស្ថានីយ៍ត្រួតពិនិត្យទម្ងន់អចិន្ត្រៃយ៍ ការផ្សព្វផ្សាយស្តីពីសកម្មភាពទប់ស្កាត់ការដឹកជញ្ជូនលើសទម្ងន់ ការបង្កើតស្ថានីយ៍ថ្លឹងចំនួន៧ទីតាំងនៅតាមបណ្តាផ្លូវជាតិសំខាន់ៗ ។ កង្វះមន្ត្រី និងសមត្ថភាពជំនាញនៅតែជាបញ្ហាប្រឈមរបស់ស្ថាប័ន ។

### ខ- កម្មវិធីយល់ដឹងពីសុវត្ថិភាពផ្លូវថ្នល់

ការរៀបចំឱ្យមានទិវាស្តីពីសុវត្ថិភាពផ្លូវកំពុងដំណើរការ ក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិសុវត្ថិភាពផ្លូវថ្នល់ ។ ការគាំទ្រ ទាំងខាងបច្ចេកទេស ទាំងខាងហិរញ្ញវត្ថុ ដល់គណៈកម្មាធិការនេះ មានសារៈសំខាន់ដើម្បីធានាភាពជោគជ័យនៃការអនុវត្តន៍សកម្មភាពនេះ ។

## សូចនាករទី១៤ : បង្កើនការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតាមជនបទ

### ក- យុទ្ធសាស្ត្រស្តីពីការផ្គត់ផ្គង់ទឹកនិងអនាម័យនៅជនបទ

ក្រោមការដឹកនាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដៃគូអភិវឌ្ឍន៍បានផ្តល់ការគាំទ្រដោយមានការសម្របសម្រួលដល់ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត ការធ្វើអនាម័យ និងអនាម័យជនបទ ។ ទីប្រឹក្សាថ្មីត្រូវបានជ្រើសរើសដើម្បីជំនួសទីប្រឹក្សាមួយរូបដែលបានលាឈប់ ហើយបានចាប់ផ្តើមការងារតាំងពីខែកញ្ញា ឆ្នាំ២០០៩មក ។ ការសិក្សាមួយចំនួនត្រូវបានបញ្ចប់ ឬកំពុងដំណើរការ ដូចជា÷ ការវិភាគអំពីយេនឌ័រ ការវិភាគពីមុខងាររបស់ក្រសួង យុទ្ធសាស្ត្រសម្រាប់ផ្តល់ហិរញ្ញប្បទាន តួនាទីនិងការទទួលខុសត្រូវ និងសមត្ថភាពរបស់ទីភ្នាក់ងារអនុវត្តការងារជាដើម ។ ការវិនិយោគលើវិស័យនេះមានសន្ទុះកើនឡើង ជាមួយការចាប់ផ្តើមគម្រោង MEF/MRD RWSSH ដែលផ្តល់មូលនិធិតាមរយៈការលុបចោលបំណុលរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ

និងគម្រោងដែលផ្តល់មូលនិធិ ដោយធនាគារអភិវឌ្ឍន៍អាស៊ីដែលបច្ចុប្បន្ន កំពុងស្ថិតក្នុងដំណាក់កាលចរចានៅឡើយ ។

*ខ- សេវាផ្គត់ផ្គង់ទឹកស្អាត*

ជំរឿនប្រជាជនឆ្នាំ២០០៨ បានបង្ហាញអំពីកំណើននៃអនាម័យនៅជនបទ ពី៨,៦%ក្នុងឆ្នាំ១៩៩៨ ទៅ ២៣% នាឆ្នាំ២០០៩ ។ វឌ្ឍនភាពនេះអាចបញ្ជាក់ថាគោលដៅ ៣០% នៃការគ្របដណ្តប់ការផ្តល់អនាម័យដែលបានកំណត់សម្រាប់ឆ្នាំ ២០១៥ អាចនឹងសម្រេចបាន ប្រសិនបើអាចរក្សាកិច្ចប្រឹងប្រែងដូចកម្រិតបច្ចុប្បន្ន ។ ចំពោះការប្រើប្រាស់ទឹកស្អាតវិញ ជំរឿនឆ្នាំ២០០៨ បានបង្ហាញការប្រើប្រាស់ទឹកគ្របដណ្តប់ ៤០% នៅជនបទ ។ តួលេខនេះមានកម្រិតទាបជាងតួលេខ CDHS ឆ្នាំ២០០៥ (៥៣,៧%) និង CSES ឆ្នាំ២០០៧ (៦៧ %) ។ ភាពខុសគ្នានៃតួលេខទាំងនេះ គឺបណ្តាលមកពីការប្រើប្រាស់និយមន័យផ្សេងៗគ្នានៃទឹកស្អាតក្នុងពេលធ្វើអង្កេត ។ ក្រសួងអភិវឌ្ឍន៍ជនបទបានពិភាក្សាជាមួយវិទ្យាស្ថានជាតិស្ថិតិ ដើម្បីដោះស្រាយបញ្ហានេះ ដោយវិទ្យាស្ថានជាតិស្ថិតិបានឯកភាពរៀបចំសិក្ខាសាលារួមគ្នាមួយ នាខែមិថុនា ឆ្នាំ២០០៩កន្លងមក ជាមួយនឹង WHO/UNICEF ។

កំណើនវិនិយោគសម្រាប់វិស័យនេះទាមទារចាំបាច់នូវយុទ្ធសាស្ត្រជាតិមួយ ដែលផ្តល់ការណែនាំដល់ការកំណត់មុខសញ្ញា ការធ្វើហិរញ្ញប្បទាន ការរៀបចំផែនការ ការកំណត់និយមន័យ និងបញ្ហាមួយចំនួនទៀត ។ នាពេលបច្ចុប្បន្ន ការរៀបចំយុទ្ធសាស្ត្របានផ្តល់កាលានុវត្តភាពក្នុងការដកស្រង់បទពិសោធន៍សម្រាប់ទំនាក់ទំនងការរៀបចំផែនការ ការប្រមូលទិន្នន័យនិងការវិភាគ និងការកំណត់អាទិភាព ព្រមទាំងដោះស្រាយបញ្ហាប្រឈមនានា ។ នៅពេលដែលយុទ្ធសាស្ត្រនេះត្រូវបានរៀបចំបញ្ចប់ និងអនុម័ត យុទ្ធសាស្ត្រនេះនឹងអាចជួយដោះស្រាយបញ្ហាជាច្រើន ដូចជា÷ ការធ្វើហិរញ្ញប្បទាន ការជួយឧបត្ថម្ភ និងការផ្តល់សេវាអនាម័យដល់ជនក្រីក្រ និងក្រុមជនងាយរងគ្រោះ ការទទួលសេវានិងអនាម័យដែលមានតម្លៃសមស្រប បច្ចេកវិទ្យាទឹកស្អាត អនាម័យនៅតាមសាលារៀន និងតាមទីសាធារណៈជាដើម ។ ប៉ុន្តែ ក៏មានបញ្ហាប្រឈមសំខាន់ៗជាច្រើនទៀតដែលត្រូវបន្តដោះស្រាយ ដូចជា÷ការរៀបចំផែនការសម្រាប់វិស័យ និងការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងការធ្វើវិមជ្ឈការតួនាទីនិងការទទួលខុសត្រូវ ស្របតាមទិសដៅនៃកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល ។

## ***សូចនាករទី១៥ : កែលំអគុណភាពនៃការផ្តល់សេវាសាធារណៈ***

*ក- ការដាក់ឱ្យប្រើប្រាស់ឧបករណ៍ពង្រឹងប្រសិទ្ធភាពការងារ និងគណនេយ្យភាព*

កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ត្រូវបានបញ្ចប់កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ។ ទីភ្នាក់ងារប្រតិបត្តិការពិសេសកំពុងត្រូវបានបន្តដាក់ឱ្យអនុវត្តដើម្បីលើកកំពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។ ក្រសួងសុខាភិបាលកំពុងប្រើប្រាស់ឧបករណ៍នេះ យ៉ាងទូលំទូលាយនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនានា ។ ក្រសួងនិងស្ថាប័នដទៃទៀតក៏កំពុងពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់ឧបករណ៍នេះសម្រាប់ការបណ្តុះបណ្តាល មន្ទីរពិសោធន៍ និងការផ្តល់សេវាឯកទេសនានា ។

*ខ- គោលនយោបាយគ្រប់គ្រង ការអភិវឌ្ឍន៍ធនធានមនុស្ស ការពង្រាយ និងការអភិវឌ្ឍន៍សមត្ថភាព*

សេចក្តីព្រាងគោលនយោបាយស្តីពីការគ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍន៍ធនធានមនុស្ស និងការអភិវឌ្ឍន៍សមត្ថភាពត្រូវបានរៀបចំបញ្ចប់សម្រាប់អនុមតិ ។ ទន្ទឹមនេះដែរ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលក៏បានទទួលភារកិច្ចសំខាន់មួយបន្ថែមទៀត ។ នោះគឺការពិនិត្យឡើងវិញអំពីកិច្ចដំណើរការក្នុងការជ្រើសរើសក្របខ័ណ្ឌថ្មី ការតម្លើងឋានៈ និងការចូលនិវត្តន៍ ដើម្បីពង្រឹងយន្តការទាំងនេះ ។ ការពិនិត្យឡើងវិញនឹងត្រូវអនុវត្តបញ្ចប់ក្នុងពេលដ៏ខ្លីខាងមុខនេះ ។ ស្របពេលជាមួយគ្នានេះ ឯកសារណែនាំ និងឯកសារសង្ខេបខ្លឹមសារអំពីការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល កំពុងត្រូវបានរៀបចំផងដែរ និងត្រៀមលក្ខណៈសម្រាប់ដាក់ឱ្យអនុវត្ត នៅពេលដែលគោលនយោបាយខាងលើត្រូវបានអនុមតិ ។ លើសពីនេះ ក៏មានវឌ្ឍនភាពក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីការពង្រាយមន្ត្រីរាជការ ដែលគ្រោងនឹងបញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០១០ នេះ ។ បញ្ហាប្រឈមនៃការរៀបចំគោលនយោបាយទាំងនេះ គឺការស្វែងរកកុងសង់ស៊ុសរវាងបណ្តាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ ។

## ***សូចនាករទី១៦ : រៀបចំប្រព័ន្ធច្បាប់និងតុលាការឱ្យដំណើរការល្អ ប្រកបដោយគណនេយ្យភាព និងតម្លាភាពដែលគោរពសិទ្ធិបុគ្គលដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ***

*ក- គោលដៅជាយុទ្ធសាស្ត្រទី២ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ*

ក្រមព្រហ្មទណ្ឌត្រូវបានប្រកាសឱ្យប្រើរួចហើយ ។ ដោយឡែក ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានសិក្សាតសំរាំងបញ្ចប់ដោយក្រុមការងារពិសេសនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

*ខ- អនុវត្តក្របខ័ណ្ឌនៃកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ*

សៀវភៅចុះបញ្ជីសំណុំរឿងក្តីសាកល្បងត្រូវបានអនុវត្តនៅសាលាដំបូងខេត្តកណ្តាល និងខេត្តសៀមរាប ។ កិច្ចដំណើរការត្រូវបានពិនិត្យឡើងវិញ ដើម្បីឱ្យស្របនឹងស្ថានភាពបច្ចុប្បន្ននៃរដ្ឋបាលតុលាការ ។ ទន្ទឹមនឹងនេះដែរ ផែនការក៏ត្រូវបានរៀបចំដើម្បីពង្រីកការចុះបញ្ជីរឿងក្តីទៅសាលាដំបូងរាជធានីភ្នំពេញ ខេត្តកំពង់ចាម និងខេត្តបន្ទាយមានជ័យ ។

ការបណ្តុះបណ្តាលមន្ត្រីយុត្តិធម៌នៅអនុវត្តបន្ត ដើម្បីកែលំអការផ្តត់ផ្គង់សេវាយុត្តិធម៌ និងការប្រព្រឹត្តិទៅរបស់សាលាជម្រះក្តី ។ ការជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញាត្រូវបានអនុវត្តជារៀងរាល់ឆ្នាំ មិនមែនរាល់ពីរឆ្នាំម្តងដូចមុនទេ ដើម្បីឈានទៅសម្រេចឱ្យបាន តាមគោលដៅរបស់ក្រសួងយុត្តិធម៌ ។ ការបណ្តុះបណ្តាលមន្ត្រីក្រឡាបញ្ជីត្រូវបានបង្កើនឡើងដើម្បីឆ្លើយតបនឹងតម្រូវការនៅតាមសាលាជម្រះក្តីនានា ។ លើសពីនេះ ការបណ្តុះបណ្តាលអាជ្ញាសាលា និងសារការីក៏បានចាប់ផ្តើមផងដែរ ។

ទោះបីមានវឌ្ឍនភាពដូចរៀបរាប់ខាងលើ ក៏នៅមានបញ្ហាប្រឈមច្រើនដែរក្នុងការអនុវត្តន៍សូចនាករ ដូចជា ÷ ធនធានហិរញ្ញប្បទានសម្រាប់អនុវត្តសាលាក្តីគំរូ រថទាសម្ព័ន្ធនៃសេវាសាធារណៈនៅមានកម្រិត (ការគ្រប់គ្រង ទំនាក់ទំនង និងប្រព័ន្ធលាភការ) ការឆ្លើយតបនឹងទម្រង់បែបបទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ស្នើសុំថវិកា និងសមត្ថភាពនៅមានកម្រិតក្នុងការរៀបចំថវិកា និងគោលនយោបាយខុសគ្នាក្នុងចំណុចគន្លឹះៗនៃច្បាប់មូលដ្ឋាន ។

## សូចនាករទី១៧ : ការប្រយុទ្ធប្រឆាំងអំពើពុករលួយ

### ក- សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ

នាខែមិនា ឆ្នាំ២០១០ សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយត្រូវបានរដ្ឋសភាអនុម័តរួចហើយ ។ ការអនុវត្តន៍ច្បាប់នេះនឹងប្រព្រឹត្តទៅដោយមានសង្គតិភាពជាមួយនឹងក្រមព្រហ្មទណ្ឌ ។

### ខ- ការងារអប់រំ និងផ្សព្វផ្សាយ

ការអប់រំរួមមានការផ្សព្វផ្សាយទស្សនទានស្តីពីការប្រឆាំងអំពើពុករលួយដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ការផ្សព្វផ្សាយស្ប៉តអប់រំស្តីពីការប្រឆាំងអំពើពុករលួយ នៅលើកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា ដោយដកស្រង់ខ្លឹមសុន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ការបោះពុម្ព និងផ្សព្វផ្សាយកម្រងឯកសារស្តីពីការយល់ដឹងពីការប្រឆាំងអំពើពុករលួយដល់មន្ត្រីកងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកព្រំដែនអន្តរជាតិ ជាដើម ។

ពាក្យបណ្តឹងបានទទួលចំនួន២៦ករណី និងកំពុងចាត់ចែង និងដោះស្រាយទៅតាមនីតិវិធីច្បាប់ ក្នុងនោះរួមមានពាក្យបណ្តឹងពាក់ព័ន្ធអំពើពុករលួយ និងលិខិតស្នើសុំឱ្យជួយអន្តរាគមន៍ ។

វិធានការអនុវត្តច្បាប់ ៖ ជាមួយនឹងការប្តេជ្ញាដ៏មោះមុតក្នុងការប្រឆាំងអំពើពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយបានតាមដានស្តាប់សវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ២៣១៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៦ និងសំណុំរឿងព្រហ្មទណ្ឌលេខ ១២៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ ស្តីពីការតាំងលក់ទំនិញខុសច្បាប់ (រថយន្តចង្កូតស្តាំ) នៅសាលាដំបូងរាជធានីភ្នំពេញ និងសំណុំរឿងលេខ៦២០ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ និងលេខ ១៤៨ ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៩ ស្តីពីការលក់ទំនិញខុសច្បាប់ (រថយន្តចង្កូតស្តាំ) នៅសាលាខុទ្ទរណ៍ ។

កិច្ចសហការជាតិ និងអន្តរជាតិ ៖ ថ្នាក់ដឹកនាំ និងមន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយបានចូលរួមកិច្ចប្រជុំសន្និសីទ និងវគ្គបណ្តុះបណ្តាល សិក្ខាសាលាពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយនៅក្រៅប្រទេស និងក្នុងប្រទេស ដើម្បីពង្រឹងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ក្នុងក្របខ័ណ្ឌប្រទេសជាសមាជិកអាស៊ាន និងតំបន់អាស៊ីប៉ាស៊ីហ្វិច ។ កិច្ចព្រមព្រៀងក៏ត្រូវបានចុះហត្ថលេខាជាមួយអង្គការ USAID-PACT CAMBODIA ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពីយន្តការប្រយុទ្ធប្រឆាំងអំពើពុករលួយផងដែរ ។

## *ស្ទួចនាករទី១៨ : ការរៀបចំសម្រាប់អនុវត្តឱ្យបានពេញលេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ*

### *ក- ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខ័ណ្ឌ*

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខ័ណ្ឌ បានរៀបចំនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៩ ។ ជាលទ្ធផល ក្រុមប្រឹក្សារាជធានីចំនួន ១ ក្រុមប្រឹក្សាខេត្តចំនួន ២៣ ក្រុមប្រឹក្សាក្រុងចំនួន ២៦ ក្រុមប្រឹក្សាស្រុកចំនួន ១៥៩ និងក្រុមប្រឹក្សាខ័ណ្ឌចំនួន ៨ ត្រូវបានបង្កើតចាប់ពីខែមិថុនា ឆ្នាំ២០០៩ ។ លើសពីនេះ លិខិតបទដ្ឋានគតិយុត្តិ (ដូចជាអនុក្រឹត្យ និងប្រកាស) ត្រូវបានតាក់តែង និងដាក់ចេញឱ្យអនុវត្ត ដើម្បីគាំទ្រដល់ដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាទាំងនេះ ។ សមាជិកក្រុមប្រឹក្សា និងគណៈអភិបាលនៅរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក៏បានទទួលការបណ្តុះបណ្តាលស្តីពីច្បាប់អង្គការ និងគោលការណ៍ជាមូលដ្ឋាននានាសម្រាប់គ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ទន្ទឹមនេះដែរ ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ ដែលបានដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រូវបានរៀបចំបញ្ចប់ និងកំពុងពិភាក្សា មុននឹងស្នើជូនគណៈកម្មាធិការជាតិដឹកនាំការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

### *ខ- កម្មវិធីជាតិសម្រាប់វិមជ្ឈការនិងវិសហមជ្ឈការ*

យោងតាមភាពស្មុគ្រស្មាញនៃការតាក់តែងកម្មវិធីជាតិ រយៈពេលមួយឆ្នាំ២០០៩ ត្រូវបានប្រើប្រាស់សម្រាប់ពិគ្រោះយោបល់ជាមួយគ្រប់ភាគីដែលពាក់ព័ន្ធ ។ ការពិគ្រោះយោបល់កម្រិតបច្ចេកទេសចំនួនពីរលើកត្រូវបានរៀបចំ ដើម្បីពិនិត្យសេចក្តីព្រាងលើកទី ៥ និងទី៦ ដោយមានការចូលរួមពីថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល (ប្រមាណ៣០០ រូបសម្រាប់ការពិគ្រោះយោបល់និមួយៗ) ។ ការតាក់តែងកម្មវិធីជាតិបានឈានដល់សេចក្តីព្រាងទី៧ និងត្រូវបានបញ្ចប់រួចរាល់ ដោយរំពឹងថានឹងស្នើរាជរដ្ឋាភិបាលអនុម័តនាដើមត្រីមាសទី២ ឆ្នាំ ២០១០ នេះ ។

## *ស្ទួចនាករទី១៩ : អនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី២ ដើម្បីពង្រឹងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

### *ក- កែលំអការប្រមូលនិងគ្រប់គ្រងចំណូល ការរៀបចំ និងអនុវត្តថវិកា*

ភាពជឿទុកចិត្តបានប្រកបដោយភាពរឹងមាំនៃថវិកាត្រូវបានធានា ទោះបីប្រឈមនឹងលក្ខខ័ណ្ឌសេដ្ឋកិច្ចមិនអំណោយផលយ៉ាងណាក៏ដោយ ។ ការប្រមូលចំណូលសម្រេចបានតាមគោលដៅដែលបានកំណត់ក្នុងច្បាប់ថវិកា (៩៥,១%) ។ ការសន្សំចំណាយមានភាពសមស្របនឹងថវិកា និងការព្យាករណ៍ចំណូល ។ ដោយឡែក ចំណាយតាមប្រភេទ (ចំណាយចរន្ត និងចំណាយមូលធន) ស្ថិតក្នុងរង្វង់ដែលបានកំណត់ដោយថវិកាជាតិ ។

### *ខ- ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ*

វិធានច្បាស់លាស់ត្រូវបានរៀបចំ ដើម្បីកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងថវិកានៅតាមក្រសួងនិងស្ថាប័ន ដូចជា : ការកំណត់អង្គភាពនិងរចនាសម្ព័ន្ធអង្គភាពថវិកា ក្របខ័ណ្ឌថ្មីសម្រាប់គណនេយ្យភាព និងដំណើរការព្រមទាំងការពិនិត្យឡើងវិញនូវមុខងារ ។

### គ- ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ

កម្រិតនៃការយល់ដឹង និងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុត្រូវបានពង្រឹង ។ ការរៀបចំសម្រាប់លទ្ធកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ដំណាក់កាលទី២ ត្រូវបានបញ្ចប់ ។ ទន្ទឹមនឹងនេះ ដំណើរការ និងនីតិវិធីធុរកិច្ចសម្រាប់ដំណាក់កាលនិមួយៗត្រូវបានកំណត់អត្តសញ្ញាណរួចហើយ ។ លើសពីនេះ ឯកសារយុទ្ធសាស្ត្រស្តីពីប្រព័ន្ធព័ត៌មានវិទ្យា និងការគ្រប់គ្រងការផ្លាស់ប្តូរនិងទំនាក់ទំនងក៏ត្រូវបានរៀបចំបញ្ចប់ហើយដែរ ។

### ឃ- ការកែសម្រួលប្លង់គណនេយ្យ

សេចក្តីណែនាំអំពីចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មីសម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ ត្រូវបានតាក់តែងបញ្ចប់ ។ ចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មីក៏ត្រូវបានកែលំអ ពិសេសការកត់ត្រាគណនេយ្យមូលធនចំណូល និងចំណាយ ។ ព្រមជាមួយនេះ ការបែងចែកតាមមុខងារ តាមរដ្ឋបាល និងតាមភូមិសាស្ត្រ ព្រមទាំងប្រភពហិរញ្ញប្បទានក៏ត្រូវបានសិក្សាលំអិតហើយដែរ ។ ប្លង់គោលគណនេយ្យថ្មីត្រូវបានកែសម្រួលឱ្យប្រសើរឡើង ។ ការធ្វើស្វ័យប្រវត្តិកម្មជាអន្តរកាលក៏ត្រូវបានសិក្សារួចរាល់ផងដែរ ។

### ង- តម្លាភាពពេញលេញចំពោះកាតព្វកិច្ចជាប់ពន្ធ

ខិត្តប័ណ្ណស្តីពីអាករលើតម្លៃបន្ថែម សេចក្តីណែនាំអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងសេចក្តីណែនាំអំពីប្រភេទពន្ធ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត ។ គេហទំព័រព័ត៌មានស្តីពីពន្ធដារក៏ត្រូវបានរៀបចំឡើង ។ រីឯប្រព័ន្ធប្រកាសពន្ធដោយស្ម័គ្រចិត្តនៅតាមសាខាពន្ធដារនៅតាមខេត្ត ក៏ត្រូវបានដាក់ចេញឱ្យអនុវត្ត ។ លើសពីនេះ ប្រកាសស្តីពីអត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនបរទេសក៏ត្រូវបានរៀបចំ និងប្រកាសឱ្យអនុវត្តផងដែរ ។

### ច- បង្កើនតម្លាភាពក្នុងការរាយការណ៍ជូនរដ្ឋសភា និងសាធារណជន

ព្រឹត្តិបត្រព័ត៌មាននិងហិរញ្ញវត្ថុត្រូវបានកែសម្រួលឱ្យប្រសើរឡើង ។ ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានរៀបចំស្របតាមចំណាក់ថ្នាក់សេដ្ឋកិច្ចថ្មី និងប្លង់គោលស្តីពីគណនេយ្យដែលត្រូវបានកែសម្រួល ។ យោងតាមច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ របាយការណ៍អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបានផ្ញើជូនរដ្ឋសភាពីរលើកក្នុងមួយឆ្នាំ ។ ក្រៅពីនេះ ព័ត៌មានស្តីពីការអនុវត្តន៍ថវិកាជាតិក៏ត្រូវបានចែករំលែកជាសាធារណៈ ។ របាយការណ៍សវនកម្មសម្រាប់ឆ្នាំ២០០៦ ត្រូវបានបោះពុម្ពផ្សាយផងដែរ ។

### ឆ- ទំនាក់ទំនងហិរញ្ញវត្ថុច្បាស់លាស់ និងមានតម្លាភាពរវាងថ្នាក់ជាតិ និងអង្គភាពហិរញ្ញវត្ថុនៅថ្នាក់មូលដ្ឋាន

សេចក្តីព្រាងច្បាប់ស្តីពីទ្រព្យសម្បត្តិ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចូលរួមក្នុងការរៀបចំផែនការជាតិសម្រាប់រយៈពេល១០ឆ្នាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

*ជ- ទណ្ឌកម្មតឹងរឹងចំពោះការគ្រប់គ្រងហិរញ្ញវត្ថុមិនត្រឹមត្រូវ*

ក្របខ័ណ្ឌគតិយុត្តិសម្រាប់ការគ្រប់គ្រងធនធានកំពុងត្រូវបានសិក្សា ។ អនុក្រឹត្យស្តីពីការកែលំអដំណើរការចំណាយចរន្ត និងការស្នើបុរេប្រទានសាច់ប្រាក់សម្រាប់ចំណាយមូលធនមុនត្រូវបានរាជរដ្ឋាភិបាលអនុម័ត ។ សារាចរណែនាំស្តីពីការកត់ត្រាចំណាយសាច់ប្រាក់ដែលមានទំហំតូចៗនៅតាមក្រសួងនិងស្ថាប័ន ត្រូវបានដាក់ឱ្យអនុវត្ត ។ ការកត់ត្រាគណនេយ្យដើម្បីតាមដានចំណាយទាំងនេះ និងការប្រមូលចំណូលក៏ត្រូវបានរៀបចំផងដែរ ។

*ឈ- យន្តការសវនកម្មក្រោយចំណាយរឹងមាំ*

ក្រសួងចំនួន ២៦ បានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលក្នុងនោះ ១៨ បានដំណើរការ ។ សហគ្រាសរដ្ឋចំនួន ៣ ក៏បានបង្កើតសវនកម្មផ្ទៃក្នុងផងដែរ ។ សៀវភៅណែនាំស្តីពីនីតិវិធីសវនកម្ម ផែនការសវនកម្ម ២០០៩ និង ២០១០ និងផែនការសវនកម្ម ២០០៩-២០១១ កំពុងបានរៀបចំ ។ ផែនការអធិការកិច្ច ឆ្នាំ២០០៩- ២០១១ និងកម្មវិធី អធិការកិច្ចហិរញ្ញវត្ថុ ឆ្នាំ២០០៩ ក៏ត្រូវបានរៀបចំរួចរាល់ផងដែរ ។ ក្រមវិជ្ជាជីវៈសម្រាប់អ្នកអធិការកិច្ចហិរញ្ញវត្ថុ ការវាយតម្លៃពីលទ្ធផលការងារ និងសកម្មភាពរបស់មន្ត្រីអធិការកិច្ច ក៏ត្រូវបានរៀបចំជាសេចក្តីព្រាងរួចហើយ ។ ទន្ទឹមនេះ ក្រសួងកំពុងពិនិត្យឡើងវិញនូវនីតិវិធីសម្រាប់អធិការកិច្ចហិរញ្ញវត្ថុផងដែរ ។

*ញ- សមត្ថភាពអប្បបរមាត្រូវបានបង្កើតនៅតាមក្រសួងនិងស្ថាប័ន*

ផែនការកសាងសមត្ថភាព- ជំហានទី២ ត្រូវបានរៀបចំ ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានគ្រោងក្នុងនោះ វគ្គសិក្សារយៈពេលខ្លី និងវែងត្រូវបានរៀបចំឡើងសម្រាប់មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងក្រសួង និងស្ថាប័នដទៃទៀត ។ ជាលទ្ធផល មន្ត្រីត្រូវបានបញ្ជូនឱ្យចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនៅក្រៅប្រទេស ក្នុងនោះ ៩ រូបត្រូវបានបញ្ជូនទៅសិក្សាកម្រិតក្រោយឧត្តមរយៈពេលវែង និងបានត្រឡប់មកបំរើការងារវិញ ចំនួន ៤រូប ។

## ***សូចនាករទី២០ : អនុម័តច្បាប់ អនុក្រឹត្យ និងផែនការស្តីពីការប្រឆាំងអំពើហិង្សា និងអាជីវកម្មលើស្ត្រី និងកុមារ***

*ក- អនុក្រឹត្យស្តីពីការសម្រេចចិត្តផ្នែករដ្ឋបាលស្តីពីអំពើហិង្សាក្នុងគ្រួសារ*

អនុក្រឹត្យស្តីពីការសម្រេចចិត្តផ្នែករដ្ឋបាលមិនទាន់បានរៀបចំនៅឡើយ ។ ប៉ុន្តែ ការងារមួយចំនួនត្រូវបានអនុវត្តដោយក្រសួងមហាផ្ទៃ ដើម្បីរៀបចំឧបករណ៍គតិយុត្តិសម្រាប់ពង្រឹងការអនុវត្តន៍ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារនៅតាមមូលដ្ឋាន (ឃុំ សង្កាត់) ។ ចំពោះបទបញ្ញាស្តីពីការការពារ ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារីបានបង្កើតក្រុមការងារមួយ ដើម្បីរៀបចំសេចក្តីព្រាងបទបញ្ញានេះ និងបន្ទាប់មក ចៅក្រមនឹងចាប់ផ្តើមអនុវត្តតាមបទបញ្ញាការពារនេះ ។

*ខ- ក្របខ័ណ្ឌតាមដាននិងអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ*

វឌ្ឍនភាពឱ្យគួរកត់សំគាល់ក្នុងការឈានទៅរៀបចំក្របខ័ណ្ឌរួមមួយសម្រាប់តាមដាន និងអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើស្ត្រីនិងកុមារ ។ ក្នុងខែកញ្ញា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបការជួញដូរ និងរត់ពន្ធមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និងពលកម្មលើស្ត្រីនិងកុមារ ។ គណៈកម្មាធិការជាតិត្រូវបានបង្កើតជាផ្លូវការ នៅក្នុងខែធ្នូ

ឆ្នាំ២០០៩កន្លងមក ។ ការបង្កើតយន្តការកំពូលតែមួយនេះមានគោលដៅទប់ស្កាត់ ការពារ ព្រមទាំងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ក៏ដូចជាការបង្កើនការយកចិត្តទុកដាក់ដល់ស្ត្រីនិងកុមារ និងកិច្ចសហការជាអន្តរជាតិ ។

*គ- ផែនការសកម្មភាពជាតិប្រឆាំងអំពើហិង្សាលើស្ត្រី*

ផែនការសកម្មភាពជាតិត្រូវបានកែសម្រួល និងអនុម័តដោយរាជរដ្ឋាភិបាល ។ ដៃគូអភិវឌ្ឍន៍បានផ្តល់ការគាំទ្រដល់ការអនុវត្តន៍ផែនការសកម្មភាពនេះ តាមរយៈការរៀបចំកម្មវិធីគាំទ្រ ដូចជាក្របខ័ណ្ឌហិរញ្ញប្បទានអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ សម្រាប់រយៈពេល២០១១-២០១៥ ជាដើម ។

*ឃ- គោលនយោបាយស្តីពីចំណាកស្រុក*

គណៈកម្មាធិការអន្តរក្រសួងស្តីពីចំណាកស្រុកបានជួបប្រជុំដើម្បីពិនិត្យលើបញ្ហាចំណាកស្រុក ការរៀបចំគោលនយោបាយស្តីពីចំណាកស្រុក និងស្វែងរកវិធានការណ៍នានាដើម្បីការពារស្ត្រី និងកម្មករចំណាកស្រុក ។ ក្រៅពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាក់ព័ន្ធមួយចំនួន ដូចជាក្រសួងកិច្ចការនារីជាដើម ភាគីពាក់ព័ន្ធដទៃទៀត ដូចជា UNIFEM ILO IOM សមាគមជ្រើសរើសកម្មករ និងសហជីព ក៏បានចូលរួមកិច្ចការនេះផងដែរ ។ ការពិនិត្យឡើងវិញកម្រិតគោលនយោបាយស្តីពីច្បាប់ពលកម្មត្រូវបានបញ្ចប់ ហើយជំនួយបច្ចេកទេសត្រូវបានផ្តល់ដោយអង្គការពលកម្មអន្តរជាតិ សម្រាប់ពិគ្រោះយោបល់បន្តទៀតក្នុងគោលដៅរៀបចំគោលនយោបាយស្តីពីចំណាកស្រុកនេះ ។ គោលនយោបាយស្តីពីចំណាកស្រុកនឹងផ្តោតការយកចិត្តទុកដាក់លើបញ្ហាចម្បងបី គឺ ÷ ១- ការគ្រប់គ្រងពលកម្មចំណាកស្រុក ។ ២- ការការពារ និងការធានាសិទ្ធិរបស់កម្មករចំណាកស្រុក និងទី៣- ការចូលរួមរបស់កម្មករចំណាកស្រុកនៅក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម និងការកាត់បន្ថយភាពក្រីក្រ ។

# វាក្យស័ព្ទប្រើប្រាស់ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍

| English definition | Khmer translation |
|---|---|
| **General terms** | **វាក្យស័ព្ទទូទៅ** |
| ***Country Analytic Work (CAW)***<br>Country analytic work (CAW) encompasses the analysis and advice necessary to strengthen policy dialogue, develop and implement country strategies in support of sound development assistance. Good analytic work is essential for well-focused development policy and programmes. It should include major pieces of analytical work such as: Diagnostic reviews (e.g. Country Procurement Assessment Report, Country Financial Accountability Assessments etc.). Country or sector studies and strategies. Country or sector evaluations. Cross-cutting analytical work such as gender assessments.<br><br>***Coordinated Country Analytic Work***<br>Coordinated country analytic work is: (i) CAW undertaken by one or more donor jointly; (ii) CAW undertaken by one donor on behalf of another donor (including work undertaken by one and/or used by another when it is co financed and formally acknowledged in official documentation); (iii) CAW undertaken with substantive involvement from government. | ***ការសិក្សាវិភាគរបស់ដៃគូអភិវឌ្ឍន៍***<br>ការសិក្សាវិភាគរបស់ដៃគូអភិវឌ្ឍន៍រួមមាន ការវិភាគ និងការផ្តល់អនុសាសន៍ដែលចាំបាច់ ដើម្បីពង្រឹងការពិភាក្សាកម្រិតគោលនយោបាយ ការតាក់តែង និងអនុវត្តយុទ្ធសាស្រ្តប្រទេស ដោយមានការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការសិក្សាវិភាគដែលមានលក្ខណៈត្រឹមត្រូវមានសារៈសំខាន់ សម្រាប់ការរៀបចំគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ឱ្យចំទិសដៅ ។ ការសិក្សាវិភាគរួមបញ្ចូលការពិនិត្យវិនិច្ឆ័យពីបញ្ហា (ដូចជារបាយការណ៍វាយតម្លៃប្រព័ន្ធលទ្ធកម្មរបស់ប្រទេស ការវាយតម្លៃគណនេយ្យភាពហិរញ្ញវត្ថុជាដើម) ។ យុទ្ធសាស្រ្ត និងការសិក្សាកម្រិតប្រទេស ឬកម្រិតវិស័យ ការវាយតម្លៃកម្រិតប្រទេស ឬកម្រិតវិស័យ និងការសិក្សាវិភាគពីបញ្ហាដែលមានចរិតអន្តរវិស័យ ដូចជាការវាយតម្លៃផ្នែកយេនឌ័រជាដើម) ។<br><br>***ការសិក្សាវិភាគរបស់ដៃគូអភិវឌ្ឍន៍ដោយមានការសម្របសម្រួល***<br>គឺជាការសិក្សាដែល (១) បានធ្វើឡើងរួមគ្នាដោយដៃគូអភិវឌ្ឍន៍មួយ ជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ឬ (២) បានធ្វើឡើងដោយដៃគូអភិវឌ្ឍន៍មួយ ក្នុងនាមដៃគូអភិវឌ្ឍន៍ផ្សេងទៀត (រាប់បញ្ចូលទាំងការសិក្សាដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍មួយ និងត្រូវបានប្រើប្រាស់ដោយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ក្នុងខណៈដែលដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទានរួមគ្នាសម្រាប់រៀបចំការសិក្សានេះ និងបានទទួលស្គាល់ជាផ្លូវការ) (៣) ត្រូវបានធ្វើឡើងដោយមានការចូលរួមសម្របសម្រួលពីរាជរដ្ឋាភិបាល ។ |
| ***Donor / Development Partner***<br>The funding agency or country making a financial commitment to the project from its core funds. Agencies who receive funds from others as part of a co-funded project are not donors (or are donors only for that portion of funding that they have contributed from their own core funds). Donors can be multilateral, bilateral and/or NGOs. | ***ប្រទេសផ្តល់ហិរញ្ញប្បទាន- ដៃគូអភិវឌ្ឍន៍***<br>ជាភ្នាក់ងារឬប្រទេសដែលសន្យាផ្តល់ធនធានហិរញ្ញវត្ថុផ្ទាល់សម្រាប់គាំទ្រគម្រោង ។ ភាគីដែលទទួលហិរញ្ញប្បទានពីភាគីដទៃទៀត ក្រោមទម្រង់សហហិរញ្ញប្បទាន មិនមែនជាប្រទេសផ្តល់ហិរញ្ញប្បទានទេ (ឬគឺជាប្រទេសផ្តល់ហិរញ្ញប្បទានចំពោះតែចំណែកហិរញ្ញប្បទានដែលខ្លួនបានផ្តល់ផ្ទាល់ប៉ុណ្ណោះ) ។ ដៃគូអភិវឌ្ឍន៍អាចជាស្ថាប័នពហុភាគី ឬទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាល ។ |
| ***Implementing Partner***<br>The partner who receives funds from the donor. Implementing partners cannot commit or disburse funds (unless they are own core resources) according to the terminology used in the ODA Database. Disbursements from other sources should be recorded as such in Section IV. | ***ភ្នាក់ងារអនុវត្តន៍***<br>ជាភាគីដែលទទួលហិរញ្ញប្បទានពីប្រទេសឬស្ថាប័នផ្តល់ហិរញ្ញប្បទាន ។ ភ្នាក់ងារអនុវត្តន៍មិនអាចធ្វើការសន្យា ឬប្រើប្រាស់ហិរញ្ញប្បទានបានឡើយ (លើកលែងតែធនធានផ្ទាល់) យោងតាមវាក្យស័ព្ទដែលប្រើនៅក្នុងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។ ហិរញ្ញប្បទានដែលបានមកពីប្រភពផ្សេងគួរតែកត់ត្រាចូលទៅក្នុងផ្នែកទី៤ ។ |

| English definition | Khmer translation |
| --- | --- |
| ***Paris Declaration on Aid Effectiveness***<br>An agreement brokered by the OECD/DAC and signed by over 100 donor and partner countries in 2005, designed to increase the impact and effectiveness of aid. The agreement is associated with 12 indicators of effectiveness, some of which are monitored locally. The agreement can be accessed on www.oecd.org. | ***សេចក្តីថ្លែងការណ៍ក្រុងប៉ារីសស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ***<br>កិច្ចព្រមព្រៀង ដែលផ្តួចផ្តើមដោយអង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ និងបានចុះហត្ថលេខាដោយប្រទេសជាដៃគូ និងដៃគូអភិវឌ្ឍន៍ជាង១០០ប្រទេស និងស្ថាប័ននាឆ្នាំ២០០៥ មានគោលបំណងបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហ-ប្រតិបត្តិការ ។ នៅក្នុងកិច្ចព្រមព្រៀងមានសូចនាករ ១២ ដែលសូចនាករខ្លះត្រូវតាមដានក្នុងកម្រិតប្រទេសជាដៃគូ ។ សេចក្តីថ្លែងការណ៍ក្រុងប៉ារីសមាននៅក្នុងគេហទំព័រ www.oecd.org ។ |
| ***Programme-Based Approach (PBA)***<br>Programme-based approaches (PBA) are a way of engaging in development cooperation based on the principles of coordinated support for a locally owned programme of development, such as a national development strategy, a sector programme, a thematic programme or a programme of a specific organisation. Programme based approaches share the following features: Leadership by the host country or organisation. A single comprehensive programme and budget framework. A formalised process for donor coordination and harmonisation of donor procedures for reporting, budgeting, financial management and procurement. Efforts to increase the use of local systems for programme design and implementation, financial management, monitoring and evaluation. Donors can support and implement programme-based approaches in different ways and across a range of aid modalities including budget support, sector budget support, project support, pooled arrangements and trust funds.<br><br>In order to qualify as a PBA for purposes of the monitoring survey it is suggested that all 4 of the following criteria should be met: Criterion 1 Is the host country or organisation exercising leadership over the programme supported by donors? (Y/N) Criterion 2 Is a single comprehensive programme and budget framework used? (Y/N) Criterion 3 Is there a formal process for donor coordination and harmonisation of donor procedures for reporting budgeting, financial management and procurement? (Y/N) Criterion 4 Does your support to the programme use at least two | ***អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី***<br>អភិក្រមគ្រប់គ្រងតាមកម្មវិធីជារបៀបមួយដើម្បីចូលរួមក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឈរលើគោលការណ៍សម្របសម្រួលការគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ ដែលផ្តួចផ្តើម និងដឹកនាំដោយប្រទេសជាដៃគូ ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីតាមវិស័យ ឬតាមប្រធានបទ និងកម្មវិធីរបស់ស្ថាប័ន ។ អភិក្រមគ្រប់គ្រងតាមកម្មវិធីមានចរិតលក្ខណៈរួមដូចតទៅ ÷ ភាពជាអ្នកដឹកនាំនៃប្រទេសជាដៃគូ ឬស្ថាប័ន កម្មវិធីអភិឌ្ឍន៍គ្រប់ជ្រុងជ្រោយ និងក្របខ័ណ្ឌថវិការួមមួយ យន្តការសម្របសម្រួលផ្លូវការ និងសុខដុមនីយកម្មនៃនីតិវិធីរបស់ដៃគូអភិវឌ្ឍន៍ ដូចជាការរៀបចំរបាយការណ៍ ថវិកាកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម ។ ក្រៅពីនេះ ក៏មានកិច្ចប្រឹងប្រែងដើម្បីបង្កើនការប្រើប្រាស់ប្រព័ន្ធរបស់ជាតិ សម្រាប់រៀបចំកម្មវិធី ការអនុវត្តន៍ ការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យ និងវាយតម្លៃគម្រោង ។ ដៃគូអភិវឌ្ឍន៍អាចគាំទ្រ និងអនុវត្តអភិក្រមគ្រប់គ្រងតាមកម្មវិធី និងទម្រង់ការផ្សេងៗគ្នា ដូចជាការគាំទ្រថវិកា ការគាំទ្រថវិកាសម្រាបវិស័យ ការគាំទ្រតាមគម្រោង ការបញ្ចូលធនធាន និងមូលនិធិរួមគ្នា ។<br><br>ក្នុងការធ្វើអង្កេតស្តីពីការអនុវត្តន៍សេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ដើម្បីចាត់ទុកថាជាអភិក្រមគ្រប់គ្រងតាមកម្មវិធី ត្រូវបំពេញល័ក្ខខ័ណ្ឌបួន ÷<br>១- ភាពជាម្ចាស់របស់ប្រទេសជាដៃគូ ឬស្ថាប័នលើកម្មវិធីដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ ។<br>២- មានកម្មវិធីគ្រប់ជ្រុងជ្រោយ និងក្របខ័ណ្ឌថវិការួមមួយ ។<br>៣- មានយន្តការផ្លូវការដើម្បីសម្របសម្រួលរវាងដៃគូអភិវឌ្ឍន៍ និងការធ្វើសុខដុមនីយកម្មនីតិវិធីរបស់ដៃគូអភិវឌ្ឍន៍ ក្នុងការរៀបចំរបាយការណ៍ ការប្រើប្រាស់ថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម ។<br>៤- ដៃគូអភិវឌ្ឍន៍ប្រើប្រាស់នូវប្រព័ន្ធជាតិយ៉ាងតិច២ ក្នុងចំណោមប្រព័ន្ធខាងក្រោម : ការ |

| English definition | Khmer translation |
| --- | --- |
| of the following local systems: (i) programme design, (ii) programme implementation, (iii) financial management and (iv) monitoring and evaluation? (Y/N) Donors are invited to review their portfolio of activities with a view to determining which of them meet all four of the above criteria (activities that meet less than four criteria do not qualify as ODA provided in support PBAs). For the purpose of the 2008 PD survey, direct budget support provided in support of PBAs is tracked separately from other PBA modality: Direct budget support provided in support of PBAs. Other assistance in support of programme-based approaches. | រៀបចំកម្មវិធី ការអនុវត្តន៍កម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យនិងវាយតម្លៃ ។ ដៃគូអភិវឌ្ឍន៍គួរតែពិនិត្យសកម្មភាពក្នុងកញ្ចប់ហិរញ្ញប្បទានរបស់ខ្លួន ដើម្បីកំណត់ថាបានបំពេញលក្ខខ័ណ្ឌទាំង៤ខាងលើឬទេ (សកម្មភាពដែលបានបំពេញលក្ខខ័ណ្ឌតិចជាង ៤ ខាងលើមិនអាចចាត់ទុកថាជាហិរញ្ញប្បទានសហប្រតិបត្តិការដែលគាំទ្រដល់អភិក្រមគ្រប់គ្រងតាមកម្មវិធីឡើយ) ។ សម្រាប់ការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ ២០០៨ នេះដែរ ការគាំទ្រថវិកាដោយផ្ទាល់ដល់អភិក្រមគ្រប់គ្រងទូទាំងវិស័យ ត្រូវបានកត់ត្រាដាច់ដោយឡែកពីទម្រង់ការផ្សេងទៀតនៃអភិក្រមគ្រប់គ្រងតាមកម្មវិធី ដូចជាការផ្តល់ហិរញ្ញប្បទានក្នុងទម្រង់ការផ្សេងៗដើម្បីគាំទ្រដល់អភិក្រមគ្រប់គ្រងតាមកម្មវិធីណាមួយ ។ |
| ***Project Implementation Unit***<br>When providing development assistance in a country some donors establish Project Implementation Units (They are also commonly referred to as project management units, project management consultants, project management offices, project coordination offices etc.). These are dedicated management units designed to support the implementation and administration of projects or programmes.<br><br>PIUs typically share the following key features: PIUs are TYPICALLY required to perform subsidiary (rather than principal) tasks with regard to the implementation of a project or programme: monitoring and reporting on technical and/or financial progress, accounting, procurement of works, goods and services, drawing-up of terms of reference, contract supervision, detailed design or equipment specification. PIUs are often established at the request of a donor following the inception of a project or programme. The staff of PIUs vary considerably in size and composition. Staff size can vary from 1 to as many as 200 but most count less than 10 professional staff. Although a significant number of PIUs make use of government staff, most PIUs are externally recruited (e.g. long-term local consultants). A distinction is made here between a PIU and technical advice provided directly to national administrations. | ***អង្គភាពអនុវត្តន៍គម្រោង***<br>ក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់ប្រទេសមួយ ដៃគូអភិវឌ្ឍន៍មួយចំនួនបង្កើតអង្គភាពអនុវត្តន៍គម្រោង (ឬហៅថា អង្គភាពគ្រប់គ្រងគម្រោង ទីប្រឹក្សាគ្រប់គ្រងគម្រោង ការិយាល័យគ្រប់គ្រងគម្រោង ការិយាល័យសម្របសម្រួលគម្រោង) ។ អង្គភាពទាំងនេះត្រូវបង្កើតឡើងដើម្បីគាំទ្រការអនុវត្តន៍ និងគ្រប់គ្រងកម្មវិធី ឬគម្រោង។<br><br>អង្គភាពអនុវត្តន៍គម្រោង មានចំណុចរួមដូចខាងក្រោម : អង្គភាពត្រូវបានតម្រូវឱ្យអនុវត្តមុខងារបន្ទាប់បន្សំទាក់ទងនឹងការអនុវត្តន៍គម្រោងឬកម្មវិធី ដូចជាការត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពផ្នែកបច្ចេកទេស ឬផ្នែកហិរញ្ញវត្ថុ កិច្ចការគណនេយ្យ លទ្ធកម្មសេវា ការរៀបចំល័ក្ខខ័ណ្ឌការងារ គ្រប់គ្រងកិច្ចសន្យានិងការរៀបចំចុះបញ្ជីសារពើភ័ណ្ឌ ។ អង្គភាពអនុវត្តន៍គម្រោងបង្កើតឡើងតាមសំណើរបស់ដៃគូអភិវឌ្ឍន៍ បន្ទាប់ពីបានចាប់ផ្តើមគម្រោង ឬកម្មវិធី ។ អង្គភាពអនុវត្តន៍គម្រោងនីមួយៗមានចំនួនបុគ្គលិក និងសមាសភាពខុសៗគ្នា ។ ចំនួនបុគ្គលិកអាចមានចាប់ពី ១ រហូតដល់ ២០០ ។ ប៉ុន្តែ ជាទូទៅ មានបុគ្គលិកគម្រោងតិចជាង ១០ នាក់ ។ ថ្វីត្បិតអង្គភាពអនុវត្តន៍គម្រោងជាច្រើនដំណើរការដោយមន្ត្រីរបស់រាជរដ្ឋាភិបាល អង្គភាពអនុវត្តន៍គម្រោងភាគច្រើនជួលបុគ្គលិកពីខាងក្រៅ (ដូចជាទីប្រឹក្សាក្នុងប្រទេសសម្រាប់រយៈពេលវែង) ។ អង្គភាពអនុវត្តន៍គម្រោង ខុសពីការផ្តល់ប្រឹក្សាបច្ចេកទេសដោយផ្ទាល់សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។ |
| ***Parallel PIU***<br>A PIU is parallel when it is created and operates outside existing country institutional and | ***អង្គភាពអនុវត្តន៍គម្រោងដាច់ដោយឡែក***<br>អង្គភាពអនុវត្តន៍គម្រោងដាច់ដោយឡែក ត្រូវបានបង្កើតឡើង និងដំណើរការខាងក្រៅរចនា |

| English definition | Khmer translation |
| --- | --- |
| administrative structures at the behest of a donor. In practice, there is a continuum between parallel and integrated PIUs. The criteria below have been designed to help donors and partner authorities draw a line within this continuum and identify with greater certainty parallel PIUs.<br><br>For the purpose of the 2008 PD survey, PIUs are said to be parallel when they meet at least three out of the four criteria set out below (anything less counts as integrated): <u>Criterion 1</u>: Are the PIUs accountable to the external funding agencies/donors rather than to the country implementing agencies (ministries, departments, agencies etc)? (Y/N) <u>Criterion 2</u>: Are the terms of reference for externally appointed staff determined by the donor (rather than by the country implementing agencies)? (Y/N) <u>Criterion 3</u>: Is most of the professional staff appointed by the donor (rather than the country implementing agencies)? (Y/N) <u>Criterion 4</u>: Is the salary structure of national staff (including benefits) higher than those of civil service personnel? (Y/N) | សម្ព័ន្ធស្ថាប័ន និងរដ្ឋបាលដែលមានស្រាប់របស់រដ្ឋ ក្រោមការគ្រប់គ្រងរបស់ដៃគូ អភិវឌ្ឍន៍ ។ តាមការអនុវត្តន៍ជាក់ស្តែង មានភាពខុសគ្នារវាងអង្គភាពអនុវត្តន៍គម្រោងដាច់ដោយឡែក ជាមួយនិងអង្គភាពអនុវត្តន៍គម្រោងដែលបានធ្វើសមាហរណកម្មជាមួយស្ថាប័នរដ្ឋ ។ លក្ខខណ្ឌខាងក្រោមជាជំនួយសម្រាប់ញែកឱ្យដាច់ពីគ្នានូវប្រភេទនានានៃអង្គភាព អនុវត្តន៍គម្រោងពិសេសកំណត់អង្គភាពអនុវត្តគម្រោងដាច់ដោយឡែក ។<br><br>ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ អង្គភាពអនុវត្តន៍គម្រោង ត្រូវបានចាត់ទុកថាមានលក្ខណៈដាច់ដោយឡែក នៅពេលដែលបំពេញលក្ខខណ្ឌយ៉ាងតិចចំនួន ៣ នៃលក្ខខណ្ឌ ៤ ខាងក្រោម ។ ទី១- អង្គភាពអនុវត្តន៍គម្រោងទទួលខុសត្រូវ ចំពោះដៃគូអភិវឌ្ឍន៍ ឬភ្នាក់ងារផ្តល់មូលនិធិ ជាជាងទទួលខុសត្រូវចំពោះក្រសួង នាយកដ្ឋាន ឬភ្នាក់ងារនៃប្រទេសដៃគូ ។ ទី២- លក្ខខណ្ឌការងារនៃបុគ្គលិក ដែលបានជួលមកពីក្រៅត្រូវបានកំណត់ដោយដៃគូអភិវឌ្ឍន៍ជាជាងដោយស្ថាប័នប្រទេសដៃគូ ។ ទី៣- បុគ្គលិកភាគច្រើនត្រូវបានតែងតាំងដោយដៃគូអភិវឌ្ឍន៍ ជាជាងដោយស្ថាប័នប្រទេសដៃគូ ។ ទី៤- រចនាសម្ព័ន្ធ និងប្រាក់ខែរបស់បុគ្គលិកគម្រោង (រាប់បញ្ចូលទាំងផលលាភ) ខ្ពស់ជាងប្រាក់ខែរបស់មន្ត្រីរាជការ ។ |
| ***Sector***<br>Sectoral classifications organize projects according to their spheres of societal endeavor. For example, "productive" sectors create economic value by generating and distributing goods and services. "Infrastructure" sectors provide the basic installations and facilities on which communities depend. "Social" sectors provide for the mental, physical, and spiritual well-being of individuals and their communities. "Environmental" sectors sustain the earth's physical and biological assets. "Governance" sectors guide and administer the affairs of a state, community, organization or association. Sectoral classifications help provide the social and economic benchmarks used to measure a programme or project's impact. | ***វិស័យ***<br>ការរៀបចំចំណាត់ថ្នាក់តាមវិស័យ គឺសម្រាប់បែងចែងគម្រោងទៅតាមគោលដៅដែលចង់ឱ្យគម្រោងសម្រេច ។ ឧទាហរណ៍ វិស័យផលិតកម្មបង្កើតតម្លៃសេដ្ឋកិច្ច តាមរយៈការផលិត និងការបែងចែកទំនិញ និងសេវាកម្ម ។ វិស័យហេដ្ឋារចនាសម្ព័ន្ធផ្តល់នូវមធ្យោបាយ និងឧបករណ៍គ្រឹះសម្រាប់ប្រើប្រាស់ក្នុងសហគមន៍ ។ វិស័យសង្គមកិច្ចផ្តល់សុខុមាលភាពផ្នែកចិត្តគំនិត កាយសម្បទា ព្រមទាំងស្មារតីដល់បុគ្គល និងសហគមន៍ទាំងមូល ។ វិស័យបរិស្ថានជួយរក្សាផែនដី ទាំងផ្នែករូបសាស្ត្រ និងជីវសាស្ត្រឱ្យបានគង់វង្ស ។ វិស័យអភិបាលកិច្ចជួយណែនាំ និងរៀបចំការងាររដ្ឋបាលរបស់ប្រទេស សហគមន៍ អង្គការ ឬសមាគមផ្សេងៗ ។ ការបែងចែកគម្រោងទៅតាមវិស័យ ជួយផ្តល់នូវលក្ខខណ្ឌវិនិច្ឆ័យសង្គមនិងសេដ្ឋកិច្ច សម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃផលប៉ះពាល់នៃគម្រោង ឬកម្មវិធី ។ |

| English definition | Khmer translation |
|---|---|
| ***Missions***<br>Donor missions to the field are defined as missions that meet all of the following criteria: The mission is undertaken by, or on behalf of, a donor, including by consultants commissioned by a donor. The mission involved international travel typically, but not exclusively, from donor headquarters. The mission made a request to meet with government officials including local government. This definition should exclude missions undertaken by donors to attend events (workshops, conferences, etc.) that do not involve request to meet with government officials.<br><br>***Coordinated missions*** are: (i) missions undertaken by one or more donor jointly, or (ii) missions undertaken by one donor on behalf of another donor (delegated co-operation). | ***បេសកកម្ម***<br>ដើម្បីកំណត់ជាបេសកកម្មដែលបញ្ជូនដោយដៃគូអភិវឌ្ឍន៍ ត្រូវគោរពលក្ខខ័ណ្ឌទាំងអស់ខាងក្រោម ។ បេសកកម្មធ្វើឡើងដោយ ឬក្នុងនាមដៃគូអភិវឌ្ឍន៍ រាប់បញ្ចូលទាំងជំនាញការដែលដៃគូអភិវឌ្ឍន៍ប្រគល់ការងារឱ្យធ្វើ ។ បេសកកម្ម ជាទូទៅ ពាក់ព័ន្ធនឹងការធ្វើដំណើរឆ្លងប្រទេស ដូចជាមកពីស្នាក់ការកណ្ដាលរបស់ដៃគូអភិវឌ្ឍន៍ ។ បេសកកម្មស្នើសុំឱ្យមានកិច្ចប្រជុំជាមួយមន្ត្រីរាជរដ្ឋាភិបាល ដោយរួមទាំងនៅថ្នាក់មូលដ្ឋាន ។ និយមន័យនៃពាក្យបេសកកម្មនេះ មិនរាប់បញ្ចូលដំណើររបស់ដៃគូអភិវឌ្ឍន៍ក្នុងការចូលរួមសិក្ខាសាលា ឬសន្និសីទ ហើយពុំបានស្នើសុំជួបជាមួយមន្ត្រីរាជរដ្ឋាភិបាលឡើយ ។<br><br>***បេសកកម្មដោយមានការសម្របសម្រួល*** គឺជា ÷<br>១- បេសកកម្មដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍មួយ ឬច្រើនរួមគ្នា ឬក៏ជា<br>២- បេសកកម្មធ្វើដោយដៃគូអភិវឌ្ឍន៍មួយ ក្នុងនាមដៃគូអភិវឌ្ឍន៍ផ្សេងទៀត |
| ***Official Development Assistance (ODA)***<br>Grants or Loans to countries and territories on Part I of the DAC List of Aid Recipients (developing countries) which are: (a) undertaken by the official sector; (b) with promotion of economic development and welfare as the main objective; (c) at concessional financial terms [if a loan, having a Grant Element of at least 25 per cent]. In addition to financial flows, Technical Co-operation is included in aid. Grants, Loans and credits for military purposes are excluded. | ***ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ***<br>ជាហិរញ្ញប្បទានឥតសំណង ឬជាកម្ចីសម្បទាន ដែលផ្ដល់ដល់ប្រទេសទាំងឡាយដែលមានឈ្មោះនៅក្នុងផ្នែកទី ១ នៃបញ្ជីឈ្មោះប្រទេសទទួលជំនួយរបស់គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (ប្រទេសកំពុងអភិវឌ្ឍន៍) និងដែល ÷<br>ក- ផ្ដល់ឱ្យវិស័យផ្លូវការ ។<br>ខ- មានគោលដៅចម្បងគឺការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសុខុមាលភាពសង្គម ។<br>គ- ហិរញ្ញប្បទានមានលក្ខណៈសម្បទាន (ប្រសិនបើជាកម្ចី ត្រូវរួមមានសមាសធាតុឥតសំណងយ៉ាងតិចបំផុតស្មើ ២៥% នៃកម្ចី) ។<br>ក្រៅពីលំហូរហិរញ្ញប្បទាន កិច្ចសហប្រតិបត្តិការបច្ចេកទេសក៏ត្រូវរាប់បញ្ចូលជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ដែរ ។ ហិរញ្ញប្បទាន ទាំងឥតសំណងនិងកម្ចីសម្រាប់គោលដៅយោធា មិនត្រូវបានរាប់បញ្ចូលជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ឡើយ។ |
| ***Project/program completion date***<br>Actual, if already completed, or planned completion date of the project/program. | ***កាលបរិច្ឆេទបញ្ចប់គម្រោង/កម្មវិធី***<br>គឺជាកាលបរិច្ឆេទបញ្ចប់ជាក់ស្ដែងនៃគម្រោង/ កម្មវិធី ឬកាលបរិច្ឆេទដែលបានគ្រោងសម្រាប់បញ្ចប់គម្រោង/ កម្មវិធី ។ |
| ***Project/program start date***<br>The actual start date of the implementation of the project/program. Sometimes the same as the project signature/commitment date although usually a few months after signing. | ***កាលបរិច្ឆេទចាប់ផ្ដើមគម្រោង/កម្មវិធី***<br>ជាកាលបរិច្ឆេទជាក់ស្ដែងនៃការចាប់ផ្ដើមអនុវត្តគម្រោង/ កម្មវិធី ។ នៅពេលខ្លះកាលបរិច្ឆេទចាប់ផ្ដើមអនុវត្តគម្រោង/ កម្មវិធី ជាកាលបរិច្ឆេទនៃការចុះហត្ថលេខាលើគម្រោង បើទោះការអនុវត្តន៍ចាប់ផ្ដើមក្រោយកាលបរិច្ឆេទបន្តិចក៏ដោយ ។ |

| English definition | Khmer translation |
|---|---|
| **Public Financial Management terms** | **ពាក្យទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** |
| ***Annual Budget***<br>The expenditure programme originally approved by the legislature. | ***ថវិកាប្រចាំឆ្នាំ***<br>ជាកម្មវិធីចំណាយដែលអនុម័តដោយសភា ។ |
| ***Commitment***<br>A firm written agreement by the donor to provide funds for a particular project or to a Trust Fund. The Commitment Date is the date of that written agreement. Commitments are usually multi-year – i.e., they are designed to fund expenditures for several years – but the total commitment is recorded in the year that the agreement is signed (even though disbursements may be projected to take place over a longer period). | ***ការសន្យាផ្តល់ហិរញ្ញប្បទាន***<br>ជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាក់លាក់មួយរបស់ដៃគូអភិវឌ្ឍន៍ ដោយសន្យាថានឹងផ្តល់ហិរញ្ញប្បទានដល់គម្រោង ឬបញ្ចូលធនធានទៅក្នុងមូលនិធិរក្សាទុកណាមួយ ។ កាលបរិច្ឆេទនៃការសន្យាផ្តល់ហិរញ្ញប្បទានជាកាលបរិច្ឆេទដែលបានធ្វើកិច្ចព្រមព្រៀង ។ ជាទូទៅ ក្នុងការសន្យាផ្តល់ហិរញ្ញប្បទាន ការសន្យាធ្វើសម្រាប់រយៈពេលច្រើនឆ្នាំ មានន័យថាជាកម្មវិធីចំណាយរយៈពេលច្រើនឆ្នាំ ប៉ុន្តែ «ការសន្យាផ្តល់ហិរញ្ញប្បទាន» សរុបត្រូវបានកត់ត្រានៅក្នុងឆ្នាំដែលកិច្ចព្រមព្រៀងបានចុះហត្ថលេខា (ទោះបីជាហិរញ្ញប្បទានអាចគ្រោងសម្រាប់ប្រើប្រាស់ក្នុងកំឡុងពេលវែងក៏ដោយ) ។ |
| ***Concessional Loan***<br>The provision of funds by a donor as a loan which consists of a minimum 25 percent grant element, thus qualifying it as an ODA transaction. It is also commonly referred to as a “soft” loan. | ***កម្ចីសម្បទាន***<br>ការផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ក្នុងទម្រង់ជាកម្ចី ដែលក្នុងនោះ ហិរញ្ញប្បទានឥតសំណងយ៉ាងតិចស្មើនឹង២៥% ។ កម្ចីសម្បទានក៏ជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការដែរ ។ កម្ចីសម្បទានអាចកំណត់ថាជាកម្ចី«ទន់» ផងដែរ ។ |
| ***Disbursement***<br>The release of funds to, or the purchase of goods or services for, a recipient; by extension, the amount thus spent. Disbursements record the actual international transfer of financial resources, or of goods or services valued at the cost of the donor. The Disbursement Date is the date at which those funds were made available – usually this involves the transfer of funds into the implementer’s bank account or the draw down by the implementer of funds held in an account by the donor. | ***ការប្រើប្រាស់ហិរញ្ញប្បទាន***<br>ជាការបញ្ចេញហិរញ្ញប្បទាន ឬការទិញទំនិញ ឬសេវាផ្តល់ឱ្យប្រទេសទទួលហិរញ្ញប្បទាន ។ ដៃគូអភិវឌ្ឍន៍ជាអ្នកទទួលខុសត្រូវក្នុងការផ្ទេរធនធានហិរញ្ញវត្ថុ ឬទំនិញ ឬសេវាកម្ម ។ កាលបរិច្ឆេទនៃការប្រើប្រាស់ហិរញ្ញប្បទាន គឺជាពេលដែលប្រទេសទទួលហិរញ្ញប្បទានទទួលបានហិរញ្ញប្បទានទាំងនោះ (ជាទូទៅ ជាពេលដែលហិរញ្ញប្បទានត្រូវបានផ្ទេរចូលក្នុងគណនីធនាគាររបស់អ្នកអនុវត្តន៍គម្រោង/កម្មវិធី ឬនៅពេលដែលអ្នកអនុវត្តន៍គម្រោងដកហិរញ្ញប្បទានចេញពីគណនីរបស់ដៃគូអភិវឌ្ឍន៍ ។ |
| ***Fiscal Year***<br>Is the fiscal year of the country receiving ODA. The 12 months that covers a single budget cycle. | ***ឆ្នាំសារពើពន្ធ***<br>គឺជាឆ្នាំសារពើពន្ធនៃប្រទេសដែលទទួលហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ ដែលមានរយៈពេល១២ខែ ដែលគ្របដណ្តប់មួយវដ្តនៃដំណើរការថវិកា ។ |
| ***Grant***<br>Transfers made in cash, goods or services for which no repayment is required | ***ហិរញ្ញប្បទានឥតសំណង***<br>ការផ្ទេរហិរញ្ញប្បទានជាសាច់ប្រាក់ ទំនិញ ឬសេវាកម្ម ដោយពុំមានការទាមទារឱ្យសងវិញឡើយ ។ |

| English definition | Khmer translation |
|---|---|
| ***Grant Element***<br>Reflects the financial terms of a commitment: interest rate, MATURITY (q.v.) and grace period (interval to first repayment of capital). It measures the concessionality of a loan, in the form of the present value of an interest rate below the market rate over the life of a loan. Conventionally the market rate is taken as 10 per cent in DAC statistics. Thus, the grant element is nil for a loan carrying an interest rate of 10 percent; it is 100 per cent for a grant; and it lies between these two limits for a soft loan. If the face value of a loan is multiplied by its grant element, the result is referred to as the grant equivalent of that loan. | ***សមាសធាតុឥតសំណង***<br>ឆ្លុះបញ្ចាំងពីល័ក្ខខ័ណ្ឌនៃហិរញ្ញប្បទាន ដូចជា អត្រាការប្រាក់ កាលកំណត់ត្រូវសង និង រយៈពេលអនុគ្រោះ (ចន្លោះពេលរហូតដល់ថ្ងៃកំណត់សងលើកដំបូង) ។ សមាសធាតុឥតសំណងត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃពីកម្រិតសម្បទាននៃកម្ចី ក្នុងរូបភាពជាតម្លៃបច្ចុប្បន្ននៃអត្រាការប្រាក់របស់កម្ចី ដែលត្រូវតែមានកម្រិតទាបជាងអត្រាការប្រាក់នៅលើទីផ្សារ ។ នៅក្នុងស្ថិតិរបស់ OECD/DAC អត្រាការប្រាក់ទីផ្សារត្រូវបានសន្មតស្មើនឹង ១០% ។ ដូចនេះ សមាសធាតុឥតសំណងមានតម្លៃស្មើសូន្យចំពោះកម្ចីដែលមានអត្រាការប្រាក់ ១០% និងស្មើ ១០០% ចំពោះហិរញ្ញប្បទានឥតសំណង ។ សមាសធាតុឥតសំណងត្រូវស្ថិតនៅចន្លោះពី ០ ទៅ ១០០% ។ ផលគុណនៃតម្លៃបច្ចុប្បន្នរបស់កម្ចី និងអត្រាសមាសធាតុឥតសំណង គឺជាឥណទានដែលចាត់ជាហិរញ្ញប្បទានឥតសំណង ។ |
| ***Loans (Credits)***<br>The provision of resources, excluding food or other bulk commodities, for relief or development purposes, including import procurement programmes, which must be repaid according to conditions established at the time of the loan agreement or as subsequently agreed. | ***កម្ចី (ឥណទាន)***<br>ជាការផ្តល់ធនធានទាំងឡាយ (ដោយមិនរាប់បញ្ចូលម្ហូបអាហារ និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) ក្នុងគោលបំណងជួយសង្គ្រោះ ឬសម្រាប់គោលដៅអភិវឌ្ឍន៍ ដោយរួមបញ្ចូលទាំងកម្មវិធីលទ្ធកម្មដែលត្រូវតែសងវិញទៅតាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងកម្ចី ឬតាមការព្រមព្រៀងណាមួយក្រោយទៀត ។ |
| ***National Auditing Procedures***<br>Donors rely on the audit opinions, issued by the country's supreme audit institution, on the government's normal financial reports/statements as defined above. The use of national auditing procedures means that donors do not make additional requirements on governments for auditing.<br><br>For the purpose of the 2008 PD survey, national auditing mechanisms are used when the donor responds "Yes" to BOTH criteria below: 1. Are your funds subject to audit carried out under the responsibility of the Supreme Audit Institution? (Y/N) 2. You do NOT under normal circumstances request additional audit arrangements? (Yes, donors do not require additional audits/No, donors do require additional audits) AND "Yes" to at least one of the criteria below: 3. You do NOT require audit standards different from those adopted by the Supreme Audit Institution? (Yes, donors do not require different audit standards/No, donors do require different audit standards) 4. You do | ***នីតិវិធីសវនកម្មជាតិ***<br>ដៃគូអភិវឌ្ឍន៍ផ្អែកទៅលើជម្រើសអំពីសវនកម្មដែលផ្តល់ដោយស្ថាប័នសវនកម្មជាន់ខ្ពស់របស់ប្រទេស ឬរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ។ ការប្រើប្រាស់ប្រព័ន្ធសវនកម្មជាតិ មានន័យថា ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យរាជរដ្ឋាភិបាលធ្វើសវនកម្មមួយបន្ថែមទៀតឡើយ ។<br><br>ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ដៃគូអភិវឌ្ឍន៍ប្រើប្រាស់យន្តការសវនកម្មជាតិ នៅពេលដែលដៃគូអភិវឌ្ឍន៍ឆ្លើយតបវិជ្ជមានលើចំណុច (១) និង (២) និងឆ្លើយតបវិជ្ជមានយ៉ាងហោចណាស់មួយលើចំណុច (៣) និង (៤) ដូចខាង ក្រោម÷<br>១- តើហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ស្ថិតក្រោមសវនកម្មរបស់ស្ថាប័នសវនកម្មជាន់ខ្ពស់របស់ជាតិឬទេ ?<br>២- តើក្នុងកាលៈទេសៈធម្មតា ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យមានសវនកម្មបន្ថែមឡើយ?<br>៣- ដៃគូអភិវឌ្ឍន៍មិនតម្រូវវឱ្យមានស្តង់ដារសវនកម្ម ដែលខុសគ្នាពីស្តង់ដារដែលកំណត់ដោយស្ថាប័នសវនកម្មជាន់ខ្ពស់ជាតិ ? និង<br>៤- ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យស្ថាប័នសវនកម្មជាន់ខ្ពស់ជាតិ ផ្លាស់ប្តូរកាលបរិច្ឆេទទូទៅ |

| English definition | Khmer translation |
| --- | --- |
| NOT require the SAI to change its audit cycle to audit your funds? (Yes, donors do not require to change the audit cycle/No, donors do require change to the audit cycle) | របស់ស្ថាប័ន ដើម្បីតម្រូវជាមួយនឹងកាលបរិច្ឆេទសវនកម្មមូលនិធិរបស់ដៃគូអភិវឌ្ឍន៍ឡើយ ? |
| ***National Budget Execution Procedures***<br>Donors use national budget execution procedures when the funds they provide are managed according to the national budgeting procedures established in the general legislation and implemented by government. This means that programmes supported by donors are subject to normal country budgetary execution procedures namely procedures for authorisation, approval and payment.<br><br>For the purpose of the 2008 PD survey, national budget execution procedures are used when answers yes to three out of the four criteria below (anything less does not qualify):1. Are your funds included in the annual budget approved by country legislature? (Y/N) 2. Are your funds subject to established country budget execution procedures? (Y/N) 3. Are your funds processed (e.g. deposited & disbursed) through the established country treasury system? (Y/N) 4. You do NOT require the opening of separate bank accounts for your funds? (Y/N) | ***នីតិវិធីសម្រាប់ការគ្រប់គ្រងថវិការដ្ឋ***<br>ដៃគូអភិវឌ្ឍន៍ប្រើប្រាស់នីតិវិធីរដ្ឋសម្រាប់គ្រប់គ្រងថវិការដ្ឋ នៅពេលដែលហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ត្រូវបានចាត់ចែងតាមនីតិវិធីគ្រប់គ្រងថវិការដ្ឋ ដែលមានកំណត់នៅក្នុងច្បាប់ និងអនុវត្តដោយរាជរដ្ឋាភិបាល ។ នេះមានន័យថាកម្មវិធីដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ ត្រូវគោរពតាមនីតិវិធីគ្រប់គ្រងថវិការដ្ឋរបស់រាជរដ្ឋាភិបាល ដូចជាការអនុញ្ញាតចំណាយ ការអនុម័ត និងចំណាយនានា ។<br><br>ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ យើងសន្មតថាដៃគូអភិវឌ្ឍន៍ប្រើប្រាស់នីតិវិធីគ្រប់គ្រងថវិការដ្ឋ ប្រសិនបើបានឆ្លើយជាវិជ្ជមានចំពោះល័ក្ខខ័ណ្ឌបីក្នុងចំណោមល័ក្ខខ័ណ្ឌទាំង ៤ គឺ (១) ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានបញ្ចូលទៅក្នុងថវិការដ្ឋដែលបានអនុមតិដោយរដ្ឋសភា (២) មូលនិធិរបស់ដៃគូអភិវឌ្ឍន៍គោរពតាមនីតិវិធីគ្រប់គ្រងថវិការដ្ឋ (៣) មូលនិធិរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានដំណើរការ (ដូចជាការតំកល់ និងការប្រើប្រាស់) តាមរយៈប្រព័ន្ធរតនាគារជាតិ និង (៤) ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យបើកគណនីធនាគារដោយឡែកសម្រាប់ហិរញ្ញប្បទានឡើយ ។ |
| ***National Financial Reporting Procedures***<br>Legislative frameworks normally provide for specific types of financial reports to be produced as well as periodicity of such reporting. The use of national financial reporting means that donors do not impose additional requirements on governments for financial reporting. In particular donors do NOT require: maintenance of a separate accounting system to satisfy donor reporting requirements. Creation of a separate chart of account to record the use of donor funds.<br><br>For the purpose of the 2008 PD survey, national financial reporting mechanisms are used when the donor responds "Yes" to both criteria below (anything less does not qualify):1. You do NOT require maintenance of a separate accounting system to satisfy your own reporting requirements? (Yes, | ***នីតិវិធីជាតិសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុ***<br>ជាធម្មតា ក្របខ័ណ្ឌច្បាប់ហិរញ្ញវត្ថុតម្រូវឱ្យរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាច្រើនប្រភេទរាប់បញ្ចូលទាំងរបាយការណ៍ក្នុងពេលកំណត់ណាមួយ ។ ការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរដ្ឋមានន័យថា ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុបន្ថែមទៀតទេ ។ ពិសេស ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យរក្សាប្រព័ន្ធគណនេយ្យ ឬប្លង់គណនេយ្យដាច់ដោយឡែក ដើម្បីកត់ត្រាការប្រើប្រាស់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍។<br><br>ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ដៃគូអភិវឌ្ឍន៍ចាត់ទុកថា បានប្រើប្រាស់យន្តការនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុរដ្ឋ នៅពេលដែលបំពេញល័ក្ខខ័ណ្ឌដាច់ខាតទាំង២ គឺ (១)មិនតម្រូវឱ្យរក្សាប្រព័ន្ធគណនេយ្យមួយដាច់ដោយឡែក តាមតម្រូវការនៃនីតិវិធីរបស់ខ្លួន និង (២) តម្រូវឱ្យមានការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយប្រើនូវនីតិវិធីរៀបចំរបាយការណ៍ហិរញ្ញវត្ថុរដ្ឋ ។ |

| English definition | Khmer translation |
|---|---|
| you do not require a separate accounting system/No, you do require a separate accounting system)2. You ONLY require financial reports prepared using country's established financial reporting arrangements? (Y/N) | |
| ***National PFM procedures***<br>Disbursements of ODA for the government sector that use all three components of a country's national public financial management procedures, i.e.: (i) national budget execution procedures; (ii) national financial reporting procedures and (iii) national auditing procedures. | ***នីតិវិធីជាតិសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ***<br>គឺជាការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ តាមវិស័យនានារបស់រាជរដ្ឋាភិបាល ដែលប្រើប្រាស់សមាសធាតុទាំងបីនៃនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ (១) នីតិវិធីនៃការគ្រប់គ្រងថវិការដ្ឋ (២) នីតិវិធីរៀបចំរបាយការណ៍ហិរញ្ញវត្ថុរដ្ឋ និង (៣) នីតិវិធីសវនកម្មជាតិ ។ |
| ***National Procurement Procedures***<br>Donors use national procurement procedures when the funds they provide for the implementation of projects and programmes are managed according to the national procurement procedures as they were established in the general legislation and implemented by government. The use of national procurement procedures means that donors do not make additional, or special, requirements on governments for the procurement of works, goods and services. (Where weaknesses in national procurement systems have been identified, donors may work with partner countries in order to improve the efficiency, economy, and transparency of their implementation). | ***នីតិវិធីជាតិសម្រាប់លទ្ធកម្ម***<br>ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ នៅពេលដែលហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ សម្រាប់អនុវត្តគម្រោងនិងកម្មវិធី ត្រូវបានគ្រប់គ្រងតាមនីតិវិធីនៃប្រព័ន្ធលទ្ធកម្មជាតិ ដែលត្រូវបានអនុមតិដោយរដ្ឋសភា និងអនុវត្តដោយរាជរដ្ឋាភិបាល ។ ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិមានន័យថា ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យរាជរដ្ឋាភិបាលប្រើប្រាស់ប្រព័ន្ធលទ្ធកម្មផ្សេងទៀតឡើយ ក្នុងការងារលទ្ធកម្មទំនិញ ឬសេវានានា (នៅពេលដែលប្រព័ន្ធលទ្ធកម្មជាតិនៅខ្សោយនៅឡើយ ដៃគូអភិវឌ្ឍន៍អាចធ្វើការជាមួយនឹងប្រទេសដៃគូ ដើម្បីបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច និងតម្លាភាពនៃការប្រើប្រាស់ប្រព័ន្ធទាំងនោះ) ។ |
| ***Pledge***<br>The grant or loan resources indicated in a non-binding (often verbal) manner by a donor over one year or a fixed number of years. Often these sums are not associated with any particular project, which must be designed at a later time. A pledge is not equivalent to a commitment and is treated as purely indicative. | ***ការប្រកាសផ្ដល់ហិរញ្ញប្បទាន***<br>ជាការប្រកាសផ្ដល់ធនធាន សម្រាប់រយៈពេលមួយឆ្នាំ ឬច្រើនឆ្នាំ ដែលជាទូទៅមិនភ្ជាប់កាតព្វកិច្ចរបស់ដៃគូអភិវឌ្ឍន៍ (ភាគច្រើនដោយផ្ទាល់មាត់) ។ ការប្រកាសផ្ដល់គ្រាន់តែជាការផ្ដល់ព័ត៌មាន និងពុំមានលក្ខណៈចាប់បង្ខំទេ ។ ហិរញ្ញប្បទានទាំងនេះមិនផ្ដោតលើគម្រោងជាក់លាក់ណាមួយនោះទេ ។ គម្រោងទាំងនោះចាំបាច់ត្រូវរៀបចំនៅពេលក្រោយមកទៀត ។ ការប្រកាសហិរញ្ញប្បទានពុំមានន័យដូចនឹងការសន្យាផ្ដល់ហិរញ្ញប្បទានឡើយ ព្រោះនេះគ្រាន់តែជាការបង្ហាញតួលេខណែនាំប៉ុណ្ណោះ ។ |
| ***Project/program budget***<br>The total resources committed to the project/program from all sources. | ***ថវិការបស់គម្រោង និងកម្មវិធី***<br>ធនធានសរុបរបស់គម្រោង ឬកម្មវិធីដែលបានមកពីគ្រប់ប្រភពទាំងអស់ ។ |
| ***Project/Program Status***<br><br>On-going – once the project document is signed and the project is operationally open. | ***ស្ថានភាពគម្រោង/កម្មវិធី***<br>គម្រោងកំពុងដំណើរការ : នៅពេលដែលឯកសារគម្រោងត្រូវបានចុះហត្ថលេខា ហើយគម្រោងត្រូវបានចាប់ផ្ដើមអនុវត្ត ។ |

| English definition | Khmer translation |
|---|---|
| Completed – the project is operationally closed (financial closure is not necessary)<br><br>Suspended – the activities of the project have been officially suspended at the request of one of the signatory parties.<br><br>Pipeline - donor is identified and a concept paper or project document is being/has been drafted, with funding identified (but not committed). | គម្រោងត្រូវបានបញ្ចប់ ៈ កិច្ចប្រតិបត្តិការរបស់គម្រោងត្រូវបានបញ្ឈប់ (ទោះបីជាមិនទាន់បិទបញ្ជីហិរញ្ញវត្ថុក៏ដោយ) ។<br>គម្រោងបង្អក ៈ សកម្មភាពនានារបស់គម្រោងត្រូវបានបង្អកជាផ្លូវការ តាមសំណើរបស់ភាគីហត្ថលេខីណាមួយ ។<br>គម្រោងអាទិភាពខ្ពស់ ៈ កំណត់ដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រ ហើយឯកសារទស្សនទាន ឬឯកសារគម្រោងត្រូវបានព្រាង ដោយមានការកំណត់ហិរញ្ញប្បទានច្បាស់លាស់ (ប៉ុន្តែពុំមានការសន្យាផ្តល់ហិរញ្ញប្បទាននៅឡើយ) ។ |
| ***Types of ODA*** | ***ប្រភេទហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ*** |
| ***Technical Cooperation***<br>Includes both (a) grants to nationals of aid recipient countries receiving education or training at home or abroad, and (b) payments to consultants, advisers and similar personnel as well as teachers and administrators serving in recipient countries, (including the cost of associated equipment). Assistance of this kind provided specifically to facilitate the implementation of a capital project is included indistinguishably among bilateral project and programme expenditures, and not separately identified as technical co-operation in statistics of aggregate flows.<br><br>***Coordinated Technical Cooperation***<br>Coordinated technical cooperation means free standing and embedded technical cooperation that respects the following principles: Ownership -- Partner countries exercise effective leadership over their capacity development programmes. Alignment – Technical co-operation in support of capacity development is aligned with countries' development objectives and strategies. Harmonisation – Where more than one donor is involved in supporting partner-led capacity development, donors coordinate their activities and contributions.<br><br>For the purpose of the 2008 PD survey, technical cooperation is coordinated when it meets: BOTH criteria below: Criterion 1: Have relevant country authorities (government or non-government) communicated clear capacity development objectives as part of | ***កិច្ចសហប្រតិបត្តិការបច្ចេកទេស*** រួមមាន ÷<br>(ក) ហិរញ្ញប្បទានឥតសំណងដល់ប្រជាជននៃបណ្តា «ប្រទេសទទួលហិរញ្ញប្បទាន» ដូចជាការអប់រំ ឬការបណ្តុះបណ្តាលក្នុងប្រទេសនិងក្រៅប្រទេស និង (ខ) ចំណាយសម្រាប់ទីប្រឹក្សា ជំនាញការ និងបុគ្គលិកប្រហាក់ប្រហែលដទៃទៀត ព្រមទាំងគ្រូបង្រៀន បុគ្គលិករដ្ឋបាលដែលបម្រើការនៅក្នុងប្រទេសទទួលហិរញ្ញប្បទាន (ក្នុងនោះរួមមានការចំណាយលើសំភារៈបរិក្ខារផងដែរ) ។ ហិរញ្ញប្បទានប្រភេទនេះ ត្រូវបានផ្តល់ដើម្បីសម្រួលដល់ការអនុវត្តន៍គម្រោងវិនិយោគ និងត្រូវបានចាត់ទុកជាថវិកាចំណាយរបស់គម្រោង ឬកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ទ្វេភាគី ហើយមិនត្រូវចាត់ជាកិច្ចសហប្រតិ-បត្តិការបច្ចេកទេសនៅក្នុងស្ថិតិអំពីលំហូរធនធានទាំងមូលរបស់គម្រោងឡើយ ។<br><br>***កិច្ចសហប្រតិបត្តិការបច្ចេកទេសដោយមានការសម្របសម្រួល***<br>ជាកិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសដោយភ្ជាប់នឹងគម្រោងវិនិយោគ ដែលគោរពលក្ខខ័ណ្ឌដូចតទៅ÷ភាពជាម្ចាស់ (ប្រទេសដៃគូជាអ្នកដឹកនាំលើកម្មវិធីអភិវឌ្ឍន៍សមត្ថភាព) ការតម្រឹម (កិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់គាំទ្រការអភិវឌ្ឍន៍សមត្ថភាព ត្រូវបានតម្រឹមជាមួយនឹងគោលដៅ និងយុទ្ធសាស្រ្តអភិវឌ្ឍន៍របស់ប្រទេស) សុខដុមនីយកម្ម (នៅពេលដែលមានដៃគូអភិវឌ្ឍន៍ច្រើនចូលរួមគាំទ្រការអភិវឌ្ឍន៍សមត្ថភាព ដៃគូអភិវឌ្ឍន៍ត្រូវសម្របសម្រួលសកម្មភាព និងធនធាន) ។<br><br>ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ត្រូវចាត់ទុកជាកិច្ចសហ-ប្រតិបត្តិការបច្ចេកទេសដោយមានការសម្របសម្រួល នៅពេលដែលបំពេញល័ក្ខខ័ណ្ឌទី១ និងទី២ និងយ៉ាងហោចណាស់ល័ក្ខខ័ណ្ឌមួយនៃល័ក្ខខ័ណ្ឌទី៣ ឬទី៤ ។ |

| English definition | Khmer translation |
| --- | --- |
| broader national or sector strategies? (Y/N) Criterion 2 Is the technical cooperation aligned with the countries' capacity development objectives? (Y/N)AND at least one the criteria below: Criterion 3 Do relevant country authorities (government or non-government) have control over the Technical Cooperation? (Y/N) Criterion 4 If more than one donor is involved in supporting country programmes, are there arrangements involving the country authorities in place for coordinating the technical cooperation provided by different donors? (Y/N).<br><br>***Free-standing Technical Cooperation***<br>The provision of resources aimed at the transfer of technical and managerial skills and know-how or of technology for the purpose of building up national capacity to undertake development activities, without reference to the implementation of any specific investment project(s). FTC includes pre-investment activities, such as feasibility studies, when the investment itself has not yet been approved or funding not yet secured.<br><br>***Investment-related Technical Cooperation***<br>The provision of resources, as a separately identifiable activity, directly aimed at strengthening the capacity to execute specific investment projects (i.e. those that are associated with some material/tangible output). Included under ITC would be pre-investment-type activities directly related to the implementation of an approved investment project. | ១- តើស្ថាប័នពាក់ព័ន្ធ (ទាំងរាជរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល) បានគូសបញ្ជាក់ច្បាស់លាស់អំពីគោលដៅនៃការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងយុទ្ធសាស្ត្រជាតិ ឬវិស័យឬទេ ?<br>២- តើកិច្ចសហប្រតិបត្តិការបច្ចេកទេសត្រូវបានតម្រឹមជាមួយនឹងគោលដៅនៃការអភិវឌ្ឍន៍សមត្ថភាពរបស់រាជរដ្ឋាភិបាល ឬទេ ?<br>៣- តើស្ថាប័នពាក់ព័ន្ធ (ទាំងរាជរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល) ជាអ្នកគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស ឬទេ ?<br>៤- ប្រសិនបើមានដៃគូអភិវឌ្ឍន៍ច្រើនចូលរួមគាំទ្រកម្មវិធី តើមានយន្តការសម្រាប់ស្ថាប័នរបស់រាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលធនធានរបស់ដៃគូអភិវឌ្ឍន៍ ឬទេ ?<br><br>***កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ***<br>ជាការផ្តល់ប្រភពធនធានដែលមានគោលដៅផ្ទេរនូវបច្ចេកទេស បច្ចេកវិទ្យា និងជំនាញខាងការគ្រប់គ្រង និងចំណេះដឹង សំដៅអភិវឌ្ឍសមត្ថភាពជាតិ សម្រាប់ជម្រុញកិច្ចអភិវឌ្ឍន៍ ដោយពុំផ្តោតទៅលើការអនុវត្តន៍គម្រោងវិនិយោគជាក់លាក់ណាមួយឡើយ ។ កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធរួមបញ្ចូលបណ្តាសកម្មភាពមុនពេលវិនិយោគ ដូចជាការសិក្សាសមិទ្ធិលទ្ធភាពទាំងឡាយដែលត្រូវធ្វើមុនពេលអនុមតិគម្រោងវិនិយោគ ឬមុនពេលអនុមតិហិរញ្ញប្បទាន ។<br><br>***កិច្ចសហប្រតិបត្តិការបច្ចេកទេសភ្ជាប់ជាមួយការវិនិយោគ***<br>ជាការផ្តល់ធនធានសំដៅពង្រឹងសមត្ថភាពដើម្បីអនុវត្តគម្រោងវិនិយោគជាក់លាក់ (ដូចជាធនធានសម្រាប់សម្រេចឱ្យបាននូវធាតុចេញជាក់ស្តែង) ។ កិច្ចសហប្រតិបត្តិការបច្ចេកទេសភ្ជាប់ជាមួយការវិនិយោគ ក៏រួមបញ្ចូលផងដែរនូវបណ្តាសកម្មភាពដែលត្រូវអនុវត្តមុនពេលចាប់ផ្តើមគម្រោងវិនិយោគ ។ |
| ***Investment Project /Programme Assistance***<br>The provision of financing, in cash or in kind, for specific capital investment projects, i.e., projects that create productive capital which can generate new goods or services. Also known as capital assistance. Investment project assistance may have a technical co-operation component. | ***ហិរញ្ញប្បទានសម្រាប់គម្រោង/កម្មវិធីវិនិយោគ***<br>ជាការផ្តល់ហិរញ្ញប្បទានជាសាច់ប្រាក់ ឬជាវត្ថុសម្រាប់គម្រោងវិនិយោគមូលធន (គឺជាគម្រោងដែលបង្កើតមូលធនផលិតកម្មដែលអាចបង្កើតទំនិញ ឬសេវាកម្មថ្មី) ។ ជួនកាលគេហៅ «ហិរញ្ញប្បទានសម្រាប់គម្រោង/ កម្មវិធីវិនិយោគ» ថាជាហិរញ្ញប្បទានមូលធន ។ ហិរញ្ញប្បទាននេះអាចមានសមាសធាតុនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសផងដែរ ។ |

| English definition | Khmer translation |
|---|---|
| ***Budget Support or Balance-of-Payments Support***<br>The provision of assistance which is not cast in terms of specific investment or technical co-operation projects but which is instead provided in the context of broader development programme and macro-economic objectives and/or which is provided for the specific purpose of supporting the recipient's balance-of-payments position and making available foreign exchange. This category includes non-food commodity input assistance in kind and financial grants and loans to pay for commodity inputs. It also includes resources ascribed to debt relief. | ***ការគាំទ្រថវិកា ឬការគាំទ្រជញ្ជីងទូទាត់***<br>ជាការផ្តល់ហិរញ្ញប្បទាន ដែលមិនស្ថិតក្នុងបរិការណ៍នៃគម្រោងសហប្រតិបត្តិការបច្ចេកទេស ឬវិនិយោគណាមួយជាក់លាក់ ។ ប៉ុន្តែ គឺជាការផ្តល់ហិរញ្ញប្បទាន ក្នុងបរិការណ៍នៃកម្មវិធីអភិវឌ្ឍន៍ដ៏ទូលំទូលាយ និងមានគោលដៅម៉ាក្រូសេដ្ឋកិច្ច ឬក៏ផ្តល់សម្រាប់គោលដៅជាក់លាក់នៃការគាំទ្រដល់ជញ្ជីងទូទាត់នៃប្រទេសទទួលហិរញ្ញប្បទាន ព្រមទាំងធានាស្ថេរភាពនៃអត្រាប្តូរប្រាក់ ។ ហិរញ្ញប្បទានប្រភេទនេះរួមមានហិរញ្ញប្បទានដែលមិនមែនជាស្បៀងអាហារ តែជាវត្ថុ ឬជាសាច់ប្រាក់ និងកម្ចីដើម្បីទូទាត់ថ្លៃទំនិញ ។ ហិរញ្ញប្បទាននេះក៏រួមមានការលុបចោលបំណុលផងដែរ ។ |
| ***Sector Budget Support***<br>For the purposes of the 2008 PD survey, sector budget support is a sub-category of direct budget support. Sector budget support means that dialogue between donors and partner governments focuses on sector-specific concerns rather than on overall policy and budget priorities. | ***ការគាំទ្រថវិកាតាមវិស័យ***<br>ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ការគាំទ្រថវិកាតាមវិស័យជាប្រភេទមួយនៃការគាំទ្រថវិកាផ្ទាល់ ។ ការគាំទ្រថវិកាតាមវិស័យមានន័យថា កិច្ចពិភាក្សារវាងដៃគូអភិវឌ្ឍន៍និងរាជរដ្ឋាភិបាលផ្តោតលើការគាំទ្រវិស័យជាក់លាក់ ជាជាងការគាំទ្រគោលនយោបាយទូទៅ និងអាទិភាពនៃថវិការដ្ឋ ។ |
| ***Tied Aid***<br>ODA where procurement of the goods or services involved is limited to the donor country or to a group of countries which does not include substantially all developing countries. Tied Aid Credits are subject to certain disciplines concerning their concessionality levels, the countries to which they may be directed, and their developmental relevance so as to avoid using aid funds on projects that would be commercially viable with private finance, and to ensure that recipient countries receive good value. | ***ហិរញ្ញប្បទានសហប្រតិបត្តិការភ្ជាប់ចំណង***<br>ជាហិរញ្ញប្បទាន ដែលការធ្វើលទ្ធកម្មទំនិញ ឬសេវាកម្ម ត្រូវដាក់កំហិតឱ្យទិញ ឬប្រើសេវាកម្មពីប្រទេសដៃគូអភិវឌ្ឍន៍ ឬក្រុមហ៊ុននៃប្រទេសមួយចំនួនប៉ុណ្ណោះ លើកលែងប្រទេសកំពុងអភិវឌ្ឍន៍ ។ ឥណទាននៃ «ហិរញ្ញប្បទានសហប្រតិបត្តិការភ្ជាប់លក្ខខ័ណ្ឌ» ត្រូវមានល័ក្ខខ័ណ្ឌមួយចំនួនពាក់ព័ន្ធនឹងកម្រិតនៃសម្បទាន ប្រទេសដែលត្រូវទិញ ឬប្រើសេវាកម្ម និងការអភិវឌ្ឍន៍ ។ លក្ខខ័ណ្ឌទាំងនេះគឺដើម្បីចៀសវាងការប្រើប្រាស់ហិរញ្ញប្បទានលក្ខណៈពាណិជ្ជកម្ម និងដើម្បីធានាថាប្រទេសទទួលហិរញ្ញប្បទាននឹងទទួលបានផលប្រយោជន៍ខ្ពស់ពីឥណទាននេះ ។ |
| ***Untied Aid***<br>Official Development Assistance for which the associated goods and services may be fully and freely procured in substantially all countries. | ***ហិរញ្ញប្បទានសហប្រតិបត្តិការគ្មានភ្ជាប់ចំណង***<br>ជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ ដែលក្នុងនោះ ទំនិញនិងសេវាកម្មអាចធ្វើលទ្ធកម្មដោយសេរី និងពេញលេញពីប្រទេសណាក៏បាន ។ |
| ***Partially Tied Aid***<br>Official Development Assistance (or Official Aid) for which the associated goods and services must be procured in the donor country or among a restricted group of other countries, which must however include substantially all developing countries. | ***ហិរញ្ញប្បទានសហប្រតិបត្តិការភ្ជាប់ល័ក្ខខ័ណ្ឌខ្លះ***<br>ជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (ឬហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ) ដែលក្នុងនោះ ទំនិញ និងសេវាកម្ម ត្រូវតែធ្វើលទ្ធកម្មនៅក្នុងប្រទេសដៃគូអភិវឌ្ឍន៍ ឬក្នុងចំណោមក្រុមប្រទេសកំណត់ ប៉ុន្តែ ក៏បានរាប់បញ្ចូលប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ផងដែរ ។ |

| English definition | Khmer translation |
| --- | --- |
| ***Emergency and Relief Assistance***<br>The provision of resources aimed at immediately relieving distress and improving the well-being of populations affected by natural or man-made disasters. Food aid for humanitarian and emergency purposes is included in this category. Emergency and relief assistance is usually not related to national development efforts or to enhancing national capacity but is still included in the definition of ODA, although it is sometimes omitted from a narrower definition that relates to "core ODA". | ***ជំនួយមនុស្សធម៌ និងសង្គ្រោះបន្ទាន់***<br>ជាការផ្តល់ហិរញ្ញប្បទាន ក្នុងគោលបំណងសម្រួលការលំបាក និងកែលំអសុខុមាលភាពរបស់ប្រជាពលរដ្ឋដែលទទួលរងគ្រោះពីគ្រោះធម្មជាតិ ឬគ្រោះមហន្តរាយដែលបង្កដោយមនុស្ស ។ ការផ្តល់ស្បៀងអាហារសម្រាប់មនុស្សធម៌ និងសង្គ្រោះបន្ទាន់ ក៏ត្រូវបានរាប់បញ្ចូលក្នុងហិរញ្ញប្បទានប្រភេទនេះដែរ ។ ជាទូទៅ ហិរញ្ញប្បទានសង្គ្រោះបន្ទាន់ និងមនុស្សធម៌មិនពាក់ព័ន្ធទៅនឹងកិច្ចអភិវឌ្ឍន៍ជាតិ ឬការពង្រឹងសមត្ថភាពជាតិឡើយ ។ ទោះបីជាហិរញ្ញប្បទានប្រភេទនេះត្រូវកត់ត្រាថាជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការក៏ដោយ ក៏ហិរញ្ញប្បទាននេះផ្តោតតែលើគោលដៅមនុស្សធម៌ប៉ុណ្ណោះ គឺពុំបានផ្តោតទៅលើកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ឡើយ ។ |
| ***Food Aid (for Development purposes)***<br>The provision of food for human consumption for developmental purposes, including grants and loans for the purchase of food. Associated costs such as transport, storage, distribution, etc., are also included in this category, as well as donor-supplied, food-related items such as animal food and agricultural inputs related to food production, when these are part of a food aid programme. | ***ហិរញ្ញប្បទានជាស្បៀងអាហារ***<br>ជាការផ្តល់ស្បៀងអាហារសម្រាប់ការប្រើប្រាស់របស់ប្រជាជន សំដៅបម្រើការអភិវឌ្ឍន៍ប្រទេស ។ ហិរញ្ញប្បទាននេះមាន ហិរញ្ញប្បទានឥតសំណង និងកម្ចីសម្រាប់ទិញស្បៀងអាហារ ។ ចំណាយរួមផ្សំដូចជាការដឹកជញ្ជូន ថ្លៃស្តុកទុក ការចែកចាយ ក៏រាប់បញ្ចូលក្នុងប្រភេទហិរញ្ញប្បទាននេះដែរ ។ ការឧបត្ថម្ភផ្សេងៗ ដូចជាចំណីសត្វ និងឧបករណ៍កសិកម្មសម្រាប់ផលិតស្បៀង ក៏ត្រូវរាប់បញ្ចូលក្នុងហិរញ្ញប្បទានប្រភេទនេះដែរ ប្រសិនបើកម្មវិធីផ្តល់ហិរញ្ញប្បទានគឺជាផ្នែកមួយនៃកម្មវិធីហិរញ្ញប្បទានស្បៀងអាហារ ។ |

--------------